ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក
# ការពិត



◆ សុំខមាទោសពីអតីតកម្មាភិបាលថ្នាក់ខ្មែរក្រហម

◆ ការកាត់ទោស នួន ជា ពីបទឧក្រិដ្ឋកម្មសង្គ្រាម

[illegible]

លេខ ៨៥ ខែមករា ឆ្នាំ២០០៧

ស្វែងរកការពិត

លេខ៨៥ ខែមករា ឆ្នាំ២០០៧

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ ស្វែងរកយុត្តិធម៌..........១

**ផ្នែកឯកសារ**

◆ អ្នកដឹកនាំសហគមន៍អ៊ីស្លាមសម្ដែងពីចំណាប់អារម្មណ៍..........៤

◆ សុំខមាទោសពីអតីតកម្មាភិបាលថតរូបខ្មែរក្រហម..........៨

◆ សុន្ទរកថារបស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក..........១២

**ផ្នែកប្រវត្តិសាស្រ្តនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម..........១៣

◆ លទ្ធផលនៃការស្ទាបស្ទង់មតិនៅក្នុងដំណើរទស្សនកិច្ច..........២២

◆ មើលខ្សែភាពយន្តឯកសាររំឭកដល់អតីតកាល..........២៧

◆ ជីវិតនៅក្នុងរបស់ កែវ ម៉ៅ..........៣០

◆ វិន ៖ កម្មករក្រសួងពាណិជ្ជកម្ម..........៣២

◆ យុវសិស្សកម្ពុជាយល់ដឹងអំពីអតីតកាលរបស់ឪពុកម្ដាយ..........៣៤

**ផ្នែកច្បាប់**

◆ ការកាត់ទោស នួន ជា ពីបទឧក្រិដ្ឋកម្មសង្រ្គាម..........៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបង្ហាញអំពីការរំលោភច្បាប់របស់ខ្មែរក្រហម..........៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ យុវសិស្សគួរតែទទួលការអប់រំ..........៥៩




ក្រុមសិស្សានុសិស្សទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



ក្រុមសិស្សានុសិស្សនៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ ៖** សូ ហ្វារីណា, ញែម អេន, លីហ្សាប៉ែត ម៉ៃយើ, ផេង ពង្សរ៉ាស៊ី, ទេង ឧត្ដតារា, កែវ ដាស៊ីល, ខេត ហ៊ីល, ដូលា ប្រ៊ូមហូលស៍, លឿង សូភ័ក្ត, ពុធ ធាវី **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុខុល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ស្វែងរកយុត្តិធម៌

## ប្រជាជនកម្ពុជា

ក្នុងរយៈកាលអូសបន្លាយពេលវេលាឆ្ពោះទៅរកកិច្ចព្រមព្រៀងបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ពុំបានពិគ្រោះយោបល់ជាមួយប្រជាជនកម្ពុជាដែលជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានសាកសួរប្រជាជនកម្ពុជាអំពីអារម្មណ៍របស់គាត់ទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងថាតើមេដឹកនាំខ្មែរក្រហមត្រូវកាត់ទោសដែរឬទេ ។ ទាក់ទិននឹងបញ្ហានេះ មានបញ្ហាសំខាន់បីកើតឡើង ÷ ១) ភាពគ្មានយុត្តិធម៌ដែលប្រជាជនកម្ពុជាមានអារម្មណ៍ជាយូរមកហើយ ទាំងក្នុងស្ថានភាពកាត់ទោសមេដឹកនាំខ្មែរក្រហម ទាំងក្នុងសង្គមកម្ពុជាទាំងមូល ២) ការអន្ទះសារចង់បាននូវការដាក់ឲ្យទទួលខុសត្រូវ និង ៣) តម្រូវការចាំបាច់ចូលរួមក្នុងប្រព័ន្ធច្បាប់ជាតិពីប្រជាជនកម្ពុជា ។

## យុត្តិធម៌និងខ្មែរក្រហម

អ្នកខ្លះមានការភ្ញាក់ផ្អើលតិចតួចណាស់ថា ប្រជាជនកម្ពុជាបានសម្តែងនូវការចង់បានការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម (ទោះបីជានៅក្នុងចំណុចនេះ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់ថាខ្លួនបានពិនិត្យឃើញថាគណៈកម្មការស្វែងរកការពិតអាហ្វ្រិកខាងត្បូងអាចធ្វើជាគំរូមួយដែលអាចទទួលយកបានក្នុងប្រទេសកម្ពុជាក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជា ឬ អង្គការសហប្រជាជាតិមិនបានពិចារណាយ៉ាងយកចិត្តទុកដាក់អំពីជម្រើសនេះឡើយ) ។ ការមិនដាក់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋកម្មគឺជាការបន្ថែមទៅលើអារម្មណ៍ស្មុគស្មាញនិងភាពតែលតោលរបស់ប្រជាជនកម្ពុជា ។

អស់រយៈពេលជិត៣០ឆ្នាំហើយ អតីតមេដឹកនាំខ្មែរក្រហមបានរួចផុតពីការដាក់ទោសចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តមកលើប្រជាជនកម្ពុជា ។ មេដឹកនាំទាំងនេះរស់នៅដោយមានសេរីភាពពីការកាត់ទោស ។ ជាឧទាហរណ៍ អៀង សារី ត្រូវបានផ្តល់ការលើកលែងទោស ។ អ្នកស្មោះត្រង់នឹង អៀង សារី ដោយរាប់បញ្ចូលទាំងកូនរបស់អៀង សារី ឈ្មោះ អៀង វុធ គ្រប់គ្រងតំបន់ស្វយ័តដ៏សម្បូរស្តុកស្តម្ភប៉ៃលិន ដែលរាជរដ្ឋាភិបាលបានកាត់ឲ្យអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យជាថ្នូរដោះដូរនឹងសន្តិភាព ។

ដូចគ្នានឹងជនដែលគ្រប់កន្លែងដែរ អៀង សារី និងមេដឹកនាំខ្មែរក្រហមដទៃទៀតបានបដិសេធថាខ្លួនមិនបានពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ។ ជាងនេះទៅទៀត មេដឹកនាំទាំងនេះ បានជ្រកកោនយ៉ាងយូរពីការទទួលខុសត្រូវតាមផ្លូវច្បាប់ដោយលាក់ខ្លួននៅក្រោមការការពារនៃពាក្យថា “ការផ្សះផ្សាជាតិ” ។ អារម្មណ៍ដក់ជាប់នូវឃ្លាថា “កប់រឿងរ៉ាវអតីតកាល” ជាអារម្មណ៍មិនល្អមួយសម្រាប់ប្រជាជន និងធ្វើឲ្យខូចខាតដល់ការកសាងឡើងវិញនូវនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា ។

មេដឹកនាំខ្មែរក្រហមតែមួយគត់ដែលកំពុងតែ ជាប់ឃុំឃាំងពីបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យនោះគឺ ឌុច (កាំង ហ្កេចអៀវ) ។ ក្នុងនាមជាអតីតប្រធានមន្ទីរឃុំឃាំងថ្នាក់មជ្ឈិមដ៏ល្បីល្បាញ(ស-២១) ឌុច ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៩៩ ។ ឌុច ជាប់ឃុំឃាំងដោយគ្មានទទួលបាននូវផលចំណេញពីការជំនុំជម្រះក្តីនេះឡើយ ។

នៅដើមឆ្នាំក្រោយនេះ អង្គជំនុំជម្រះវិសាមញ្ញទំនងជានឹងចេញដីកាចោទប្រកាន់ អៀង សារី និង អៀង ធីរិទ្ធ (ប្រពន្ធរបស់ អៀង សារី នឹងជាអតីតរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការសង្គមនិងការអប់រំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) ខៀវ សំផន និង នួន ជា ដែលអ្នកទាំងនោះស្ថិតក្នុងវ័យ៧០ឆ្នាំ ។ អ្នកវិភាគមកពីសកលវិទ្យាល័យឡុងដុង លោក ស្ទីវ ហេឌ័រ ដែលបច្ចុប្បន្នបំពេញការងារនៅការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានព្យាករណ៍ថា មេដឹកនាំខ្មែរក្រហមពីរនាក់ទៀត ដែលជាប្រធានកងពលយោធាបក្សកុម្មុយនីស្តកម្ពុជា ស៊ូ ម៉េត និង មាស មុត នឹងត្រូវកាត់ទោសដែរ ។ ប៉ុល ពត បានស្លាប់នៅក្នុងព្រៃដោយមិនដឹងពីមូលហេតុនៅក្នុងឆ្នាំ១៩៩៨ ។ កែ ពក សមាជិកគណៈកម្មាធិការមជ្ឈិមបក្សបានស្លាប់ក្នុងឆ្នាំ២០០២ តាម៉ុក បានស្លាប់

នៅក្នុងខែកក្កដា ឆ្នាំ២០០៦ (ទោះបីជាការស្លាប់របស់ តាម៉ុក នឹងប៉ះពាល់ទៅដល់អង្គជំនុំជម្រះវិសាមញ្ញបន្តិចក៏ដោយ ក៏ការស្លាប់នេះបានប៉ះពាល់ខ្លាំងដូចទៅហើយដល់ជនរងគ្រោះដែលចង់ឃើញការវិនិច្ឆ័យទោសជនឃោរឃៅទាំងនេះ ។

បញ្ហាធំមួយដែលកំពុងតែលេចឡើងសម្រាប់ប្រជាជនកម្ពុជាជាច្រើននោះ គឺថាតើជនដែលជាថ្នាក់ទាបណាខ្លះនឹងត្រូវកាត់ទោស (ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា តុលាការ អាចវិនិច្ឆ័យទោសចំពោះតែ“មេដឹកនាំជាន់ខ្ពស់” និង “អ្នកទទួលខុសត្រូវខ្ពស់បំផុត”នៃរបបកម្ពុជាប្រជាធិបតេយ្យ) ។ ទោះបីជារាជរដ្ឋាភិបាលអះអាងថា ឧក្រិដ្ឋជនមួយចំនួនប៉ុណ្ណោះនឹងត្រូវកាត់ទោសយ៉ាងណាក៏ដោយ ក៏ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនដែលរស់នៅជិតខាងរបងជាមួយនិងអ្នកដែលបានប្រព្រឹត្តការសម្លាប់ ចង់ឃើញការផ្តន្ទាទោសឧក្រិដ្ឋកម្ម ហើយជនដែលជាច្រើននៅតែមិនមានការជឿទុកចិត្តថាតុលាការនឹងមិនកាត់ទោសខ្លួនឡើយ ។

មានឧបទ្ទវហេតុមួយបានធ្វើឲ្យប្រជាជនកម្ពុជាមានសេចក្តីជឿទុកចិត្តតិចតួចបំផុតថារាជរដ្ឋាភិបាលប្រាកដជាចង់ស្វែងរកយុត្តិធម៌ដោយអំពើប្រល័យពូជសាសន៍ ។ នៅក្នុងខែមេសា ឆ្នាំ២០០៥ សាលាក្រុងភ្នំពេញបានផ្តល់សិទ្ធិឲ្យទៅក្រុមហ៊ុនជប៉ុនមួយធ្វើការរៀបចំនិងអភិវឌ្ឍវាលពិឃាតបឹងជើងឯក (ដែលស្ថិតនៅចម្ងាយប្រមាណ២៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ និងជាទីកន្លែងដែលអ្នកទោសប្រមាណ១៤.០០០នាក់ ដែលជាប់នៅមន្ទីរគុកទួលស្លែងត្រូវបាននាំយកទៅសម្លាប់ ហើយជាកន្លែងមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ប្រជាជនកម្ពុជា) ។ ការព្រមព្រៀងនេះ បានអនុញ្ញាតឲ្យក្រុមហ៊ុនអភិវឌ្ឍបូជនីយដ្ឋានប្រល័យពូជសាសន៍ ក្នុងទិសដៅបម្រើឲ្យវិស័យទេសចរណ៍សម្រាប់រយៈពេល៣០ឆ្នាំ ដោយជាថ្នូរនឹងថវិកាចំនួន១៥.០០០ដុល្លារ ក្នុងមួយឆ្នាំៗ ។ បន្ទាប់ពីរឿងរ៉ាវនេះបានចុះផ្សាយក្នុងកាសែតក្នុងស្រុក ការព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយការតវ៉ាយ៉ាងខ្លាំងក្លាពីសំណាក់ប្រជាជនកម្ពុជា ។

### ***ការចង់បានការទទួលខុសត្រូវ***

អស់រយៈពេលជាងដប់ឆ្នាំមកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា បានសម្ភាសជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនពាន់នាក់ ។ ក្នុងចំណោមនោះ ជនរងគ្រោះមួយចំនួនតូចដែលបានសម្តែងការទាមទារនូវសំណងជំងឺចិត្តជាទឹកប្រាក់ចំពោះអ្វីដែលខ្មែរក្រហមបានប្រព្រឹត្តមកលើគាត់និងក្រុមគ្រួសាររបស់គាត់ ។ ការទាមទារសំណងជំងឺចិត្តចេះតែផ្លាស់ប្តូរ ប៉ុន្តែជនរងគ្រោះជាច្រើនអះអាងថា ទោះបីជាខ្លួនទទួលបាននូវសំណងជំងឺចិត្តក៏ដោយ ក៏គាត់ដឹងថា ការសងជំងឺចិត្តនេះមិនអាចគ្រប់គ្រាន់ទៅនឹងការឈឺចាប់របស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដែរ ។ ផ្ទុយទៅវិញ ការសុំឲ្យសងជំងឺចិត្តរបស់ជនរងគ្រោះមានលក្ខណៈទន់ភ្លន់ ហើយជនរងគ្រោះចង់បញ្ចប់ត្រឹមតែការដាក់ឲ្យទទួលខុសត្រូវតាមផ្លូវច្បាប់តែប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្ទាបស្ទង់មតិប្រជាជនកម្ពុជា ៧ពាន់នាក់ទៅលើចំណាប់អារម្មណ៍របស់គាត់អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម និងការផ្សះផ្សាជាតិ ។ មានប្រជាជនកម្ពុជាជាង៨៩ភាគរយក្នុងចំណោមប្រជាជនកម្ពុជា៧០០នាក់ដែលបានឆ្លើយសំណួរនោះបានបាត់បង់ញាតិសន្តាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាការសុំខមាទោសជាគោលគំនិតសំខាន់មួយនៅក្នុងទ្រឹស្តីព្រះពុទ្ធក៏ដោយ (ប្រជាជនកម្ពុជាជិត៩៥ភាគរយជាពុទ្ធសាសនិក) ក៏ជាងពីរភាគបីនៃអ្នកឆ្លើយសំណួរបានឆ្លើយថា ទោះបីជាខ្លួនមិនបានទាមទារឲ្យសងសឹកក៏ដោយ ក៏អ្នកទាំងនោះមិនអាចអត់ឱនឲ្យកម្មាភិបាលខ្មែរក្រហមដែលបានធ្វើឲ្យគាត់មានការឈឺចាប់បានដែរ ។ អ្នកឆ្លើយសំណួរជាង១៦ភាគរយចង់ឲ្យជនដែលស្ម័គ្រចិត្តចូលមកសុំទោស បើទោះបីជាអ្នកឆ្លើយសំណួរ៩៧ភាគរយចង់ឲ្យមានការដាក់ឲ្យទទួលខុសត្រូវដោយតុលាការក៏ដោយ ។ ទាក់ទិននឹងអង្គជំនុំជម្រះវិសាមញ្ញនេះ វាគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ប្រជាជនកម្ពុជាជាង៧០ភាគរយចង់បានតុលាការមួយដែលមានការចូលរួមពីអង្គការសហប្រជាជាតិ ទោះបីជាប្រជាជនកម្ពុជាប្រហែល២០ភាគរយចង់ឲ្យប្រទេសកម្ពុជាដំណើរការតុលាការនេះតែឯង ។

នៅពេលដែលសួរសំណួរទាក់ទិននឹងអត្ថន័យនៃពាក្យថា ការផ្សះផ្សាជាតិនិងការបង្រួបបង្រួម និងថាតើធ្វើយ៉ាងដូចម្តេច ដើម្បី

សម្រេចបាននូវការផ្សះផ្សាជាតិនិងការបង្រួបបង្រួមនោះ ប្រជាជនបានសម្តែងមតិរបស់ខ្លួនអំពីអត្ថន័យនៃពាក្យថា ការផ្សះផ្សាជាតិ និងការបង្រួបបង្រួមដោយប៉ិនប្រសប់ ។ អ្នកឆ្លើយសំណួរភាគច្រើនបានចាត់ទុកកិច្ចការនេះជាដំណើរការដែលសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមនៃប្រជាជនកម្ពុជាទាំងអស់ ÷

ប្រទេសជាតិមួយត្រូវមានភាពឯករាជ្យ ការបង្រួបបង្រួមភាពថ្មីថ្មោង និងការអភិវឌ្ឍន៍ ជាមួយការស្តារឡើងវិញនូវទំនាក់ទំនងនិងសាមគ្គីភាពគ្នារវាងប្រជាពលរដ្ឋរបស់ខ្លួន និងការបែករំលែកទស្សនៈគ្នាទៅវិញទៅមកដើម្បីអនាគតរុងរឿង ។

សេចក្តីជៀសផុតពីអំពើហិង្សានិងជម្លោះ ការទទួលបាននូវសន្តិភាព ភាពរុងរឿងការអភិវឌ្ឍន៍ និងយុត្តិធម៌សង្គម ។

សង្គមមួយត្រូវផ្លាស់ប្តូរនិងមានតម្លាភាពដោយផ្អែកលើនីតិរដ្ឋ ។ ប្រជាជនកម្ពុជាទាំងថ្នាក់ បុគ្គលក្នុងសហគមន៍ អន្តរសហគមន៍ និងជាតិ បាននិងកំពុងកែលម្អលក្ខណៈដែលធ្វើខូចខាតបុរេវិជ្ជមានរបស់ខ្លួន និងកំពុងធ្វើឲ្យទំនាក់ទំនងធំធេងរបស់ខ្លួនមានភាពល្អប្រសើរជាងមុន ។ ប្រជាជនកម្ពុជាអាចបញ្ចប់កំហឹងផ្ទាល់ខ្លួន និងរឿងរ៉ាវអាក្រក់នៅក្នុងអតីតកាលដើម្បីសម្រេចបាននូវទស្សនវិស័យនយោបាយនៃកម្ពុជាដ៏ថ្មីថ្មោង ។ ថ្នាក់ដឹកនាំត្រូវគិតផលប្រយោជន៍ជាតិជាមុន ។

## តម្រូវការចាំបាច់ចូលរួមជាសាធារណៈ

ទោះបីជាគ្មានការពិគ្រោះយោបល់ដ៏ត្រឹមត្រូវជាមួយនឹងជនរងគ្រោះក្នុងពេលដែលកំពុងពិភាក្សាការបង្កើតអង្គជំនុំជម្រះមេដឹកនាំខ្មែរក្រហម ក៏ដំណើរការនេះផ្ទាល់ គឺជាដំណើរការអប់រំដល់ប្រជាជនកម្ពុជា និងត្រូវបានពិភាក្សាយ៉ាងទូលំទូលាយដោយមានការចុះផ្សាយក្នុងសារព័ត៌មាន ។ បច្ចុប្បន្ននេះ ប្រជាជនត្រូវបានផ្តល់ឱកាសច្រើនក្នុងការបង្ហាញនូវចំណាប់អារម្មណ៍និងទស្សនៈរបស់ខ្លួនអំពីតុលាការនេះ ។ បញ្ហាដែលជនរងគ្រោះបានលើកឡើងធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ការប្រជុំ និងឯកសារស្រាវជ្រាវនានា ។ ការពិភាក្សាជាសាធារណៈដ៏ល្អនេះ ផ្តល់ឱកាសដល់ជនរងគ្រោះ និងជនដៃដល់ត្រៀមខ្លួនចូលរួមការជំនុំជម្រះក្តីនាពេលខាងមុខនេះ ។

នៅក្នុងប្រទេសមួយដែលអត្រានៃអ្នកចេះអាននិងសរសេរមានការកើនឡើងរហូតដល់៦៥ភាគរយ រួមនឹងប្រសិទ្ធភាពក្នុងការទទួលបានព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ មិនអាចផ្សព្វផ្សាយទៅដល់តំបន់ជនបទជាច្រើននោះ ការអប់រំត្រូវតែអប់រំអំពីដំណើរការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម និងអត្ថន័យនៃការជំនុំជម្រះនេះសម្រាប់ប្រទេសនិងប្រជាជនកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បាននិងកំពុងតែចាប់ផ្តើមធ្វើការផ្សព្វផ្សាយព័ត៌មានទាំងនេះទូទាំងប្រទេស ដើម្បីផ្តល់ប្រឹក្សាស្វែងយល់អំពីគោលការណ៍ច្បាប់សំខាន់ៗដល់ប្រជាពលរដ្ឋខ្មែរ ព្រមទាំងពន្យល់អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ។

អង្គការក្រៅរដ្ឋាភិបាលជាច្រើនក្នុងចំណោមអង្គការសិទ្ធិពលរដ្ឋនិងសិទ្ធិមនុស្សរបស់កម្ពុជាជាង២០អង្គការ បាននិងកំពុងធ្វើការបញ្ជាក់យ៉ាងច្បាស់ថា សំឡេងរបស់ប្រជាជនកម្ពុជាកំពុងតែត្រូវបានដឹងឮ និងថាសំណួររបស់ប្រជាជនកម្ពុជាកំពុងតែត្រូវបានឆ្លើយផងដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានអញ្ជើញអ្នកស្រុកអ្នកភូមិជាង៥ពាន់នាក់ទូទាំងប្រទេសកម្ពុជាមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង វាលពិឃាតបឹងជើងឯក និងអគារអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងបន្ទប់សវនាការ អ្នកស្រុកអ្នកភូមិជួបសំណេះសំណាលជាមួយមន្ត្រីតុលាការ និងសួរសំណួរដោយសេរីអំពីទម្រង់និងខ្លឹមសារសំខាន់ៗនៃការជំនុំជម្រះក្តីនាពេលខាងមុខនេះ ។ អ្នកទាំងនេះចង់ដឹងណាស់ថាតើជនណាខ្លះនឹងត្រូវកាត់ទោស ថាតើនៅពេលណាទើបសវនាការនឹងចាប់ផ្តើម ថាតើអង្គជំនុំជម្រះវិសាមញ្ញនឹងប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ ថាតើជនរងគ្រោះនឹងទទួលបានអ្វីខ្លះពីការកាត់ទោសនេះ និងថាតើជនរងគ្រោះអាចដាក់ពាក្យប្តឹងមេដឹកនាំខ្មែរក្រហមដោយរបៀបណាដែរ ក្នុងការបង្ហាញឈ្មោះមេដឹកនាំមួយចំនួន ។ ជនរងគ្រោះពិតជានឹងទទួលបាននូវចម្លើយទាំងនេះ និងចម្លើយនៃសំណួរផ្សេងៗទៀត ដូចដែលសវនាការលាតត្រដាងឲ្យឃើញ ។ ក្នុងរយៈកាលនេះ អ្នកស្រុកអ្នកភូមិដែលបានចូលរួមនឹងត្រឡប់មកកាន់ទីក្រុងភ្នំពេញម្តងទៀតដើម្បីចូលរួមក្នុងសវនាការរយៈពេលមួយសប្តាហ៍ ។ បន្ទាប់មក អ្នកទាំងនេះនឹងវិលត្រឡប់

ទៅកាន់ភូមិដ្ឋានរបស់ខ្លួនវិញ និងរៀបចំវេទិកាពិភាក្សាអំពីអ្វីដែលខ្លួនបានយល់ដឹង ។

នៅពេលដែលការជំនុំជម្រះនេះបានបញ្ចប់ ការទទួលបានយុត្តិធម៌នឹងធ្វើឲ្យធូរស្បើយយ៉ាងច្រើនដល់អារម្មណ៍ឈឺចាប់របស់ជនរងគ្រោះ ។ ជាងនេះទៅទៀត ជនដែលដល់ថ្នាក់ទាបដែលរស់នៅក្នុងស្ថានភាពដ៏លំបាកក្បែរខាងជាមួយនឹងជនរងគ្រោះប្រហែលជាអាចស្នើសុំខមាទោសពីជនរងគ្រោះ ហើយប្រទេសកម្ពុជាអាចនឹងចាប់ផ្តើមការផ្សះផ្សាជាតិនិងការធូរស្បើយពីការឈឺចាប់ ។

ក៏ប៉ុន្តែ សំណួរជាច្រើនទៀត ដែលប្រជាជនកម្ពុជាចែករំលែកជាមួយប្រជាជននៅលើពិភពលោក នឹងទំនងជាមិនទទួលនូវចម្លើយដ៏ត្រឹមត្រូវពីតុលាការនៃច្បាប់ទេ ។ ពុំមានអ្នកណាម្នាក់យល់ច្បាស់អំពីមូលហេតុដែលប្រជាជនកម្ពុជាសម្លាប់ប្រជាជនខ្លួនឯង ហើយប្រជាជនកម្ពុជាជាច្រើននៅតែមានជំនឿថា ជនបរទេសបានបញ្ជាឲ្យខ្មែរសម្លាប់ខ្មែរ ។ ប្រជាជនកម្ពុជាឆ្ងល់អំពីតួនាទីនយោបាយនៃប្រទេសលោកខាងលិចផ្សេងៗទៀត និងមានចម្ងល់ថាតើប្រទេសទាំងនោះនឹងត្រូវធ្វើការកាត់ទោសដែរឬទេ? ជាងនេះទៅទៀត ប្រជាជនកម្ពុជាសួរថា តើហេតុអ្វីបានជាអង្គការសហប្រជាជាតិនិងប្រទេសដទៃទៀតមិនបានជួយអន្តរាគមន៍បញ្ឈប់អំពើប្រល័យពូជសាសន៍ដូច្នេះ?

ភាគច្រើននៃអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិប-តេយ្យជាជនរងគ្រោះ ឬជាសាក្សីនៃឧក្រិដ្ឋកម្មដែលបង្កើតដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះជាក់ស្តែងណាស់ខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ចម្លើយរបស់តុលាការចំពោះបញ្ហានេះ គឺការវិនិច្ឆ័យទោសចំពោះបទឧក្រិដ្ឋកម្មទាំងនេះ ។ ក៏ប៉ុន្តែ អង្គជំនុំជម្រះវិសាមញ្ញនឹងមិនអាចឆ្លើយបាននូវសំណួរមួយដែលប្រហែលជាសំណួរដ៏សំខាន់បំផុតមួយក្នុងចំណោមសំណួរទាំងនេះគឺ «តើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់គ្រួសាររបស់យើង?» ។

សំណួរនេះនិងសំណួរផ្សេងៗទៀត នៅតែជាបញ្ហាសម្រាប់កូនខ្មែរជំនាន់ក្រោយ ក៏ប៉ុន្តែ មានតែសាលាក្តីខ្មែរក្រហមទេដែលអាចជួយយើងឲ្យស្វែងរកចម្លើយតាមរយៈការស្វែងរកយុត្តិធម៌និងការពិតសម្រាប់យើងទាំងអស់គ្នា ។ ខ្មែរក្រហមជាចោរប្រវត្តិសាស្ត្ររបស់យើង ហើយនេះជាពេលវេលាដ៏សំខាន់ដែលយើងទទួលបានត្រឡប់វិញនូវប្រវត្តិសាស្ត្ររបស់យើង សិក្សាប្រវត្តិសាស្ត្ររបស់យើង និងផ្សះផ្សាខ្លួនយើងផ្ទាល់ និងជាមួយអ្នកដទៃទៀត ។ **ឆាំង យុ**

# អ្នកដឹកនាំសហគមន៍អ៊ីស្លាមសម្តែងពីចំណាប់អារម្មណ៍ និងការសង្ឃឹមទុកចំពោះតុលាការខ្មែរក្រហម

រថយន្តក្រុងមួយឈប់នៅមុខអគារធំពីរទើបនឹងស្ថាបនារួចថ្មីៗលាតសន្ធឹងលើផ្ទៃដីដ៏ធំទូលាយ ។

ក្រោមកម្តៅថ្ងៃពេលព្រឹក បុរស៣៣នាក់ក្នុងឯកសណ្ឋានអាវឃឺតនិងកូហៀស (មួកកាតីប) បានចុះពីរថយន្តម្តងម្នាក់ៗ និងអមដោយស្ត្រីស្លៀកពាក់បែបបុរាណមានកន្សែងទទូរក្បាល ។ បុរសទាំងនោះសុទ្ធសឹងជាមេដឹកនាំសមាគមន៍ខ្មែរអ៊ីស្លាមមកពីតាមបណ្តាខេត្តក្រុងទាំង១២ ដែលត្រូវធ្វើដំណើរលើផ្លូវដែលមានចម្ងាយពី៣០ទៅ៣០០គីឡូម៉ែត្រមុននឹងមកដល់ទីក្រុងភ្នំពេញ ។

ការជួបជុំនេះគឺជាកិច្ចខំប្រឹងប្រែងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីនាំប្រជាជនទៅកាន់ទីតាំងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តាមរយៈដំណើរទស្សនកិច្ចនេះ ប្រជាជនមានឱកាសមើលឃើញផ្ទាល់ភ្នែកនូវតុលាការ ដែលនឹងត្រូវនាំមេដឹកនាំនៃរបបខ្មែរក្រហមមកកាត់ទោស បន្ទាប់ពីអំពើប្រល័យពូជសាសន៍កើតមានអស់រយៈពេលជិត៣០ឆ្នាំកន្លងមកនេះ ។

អ៊ីមុាំស្រុក (អ្នកដឹកនាំសាសនាអ៊ីស្លាមប្រចាំស្រុក) មកពីខេត្តក្រចេះ មានការរំជួលចិត្តនឹងរឿងរ៉ាវឆ្លងកាត់កន្លងមក ហើយគាត់ទាំងអស់គ្នាបានសម្តែងនូវក្តីដឹងគុណចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសឲ្យគាត់បានមកឃើញស្ថាន

ភាពតុលាការជាក់ស្តែង ។ អ៊ីម៉ាំម្នាក់មានប្រសាសន៍ថា "ខ្ញុំរីករាយណាស់ដែលបានមកចូលរួមដំណើរទស្សនកិច្ចនេះ ។ ខ្ញុំនឹងពាំនាំអ្វីដែលខ្ញុំបានដឹងពុត្រឡប់ទៅប្រាប់អ្នកភូមិឯទៀត ។ ឥឡូវនេះខ្ញុំបានយល់ដឹងពីដំណើរការនេះហើយ ។"

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងមជ្ឈមណ្ឌលឯកសារកម្ពុជា


សូ ហ្វារីណា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកើតចេញពីកិច្ចខំប្រឹងប្រែងរវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ដោយមានការចូលរួមពីចៅក្រមកម្ពុជា ចៅក្រមអន្តរជាតិ និងបុគ្គលិកសំខាន់ៗជាច្រើនរូបទៀត ។ តុលាការចាប់ផ្តើមដំណើរការជាផ្លូវការកាលពីដើមខែកុម្ភៈ ឆ្នាំ២០០៦ ក្នុងអណត្តិស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តិក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តុលាការនេះដើរតួនាទីជាតុលាការគំរូមួយសម្រាប់នីតិវិធីតុលាការនៅកម្ពុជា ។ សម្រាប់សាលាដំបូងមានចៅក្រមចំនួន៥រូបគឺ ចៅក្រមកម្ពុជា៣រូប និងចៅក្រមអន្តរជាតិ២រូប ។ សម្រាប់តុលាការកំពូលមានចៅក្រមកម្ពុជា៤រូប និងចៅក្រមអន្តរជាតិ៣រូប ។

កាលពីឆ្នាំមុន មជ្ឈមណ្ឌលឯកសារកម្ពុជា បាននាំប្រជាជនកម្ពុជារាប់ពាន់នាក់មកមើលទីតាំងអគារតុលាការ និងទីតាំងប្រវត្តិសាស្ត្រចំនួន២កន្លែងទៀតគឺ សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង និងវាលពិឃាតបឹងជើងឯក ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានរៀបចំឲ្យប្រជាជនចូលរួមប្រជុំស្តាប់ការស្រាយបំភ្លឺរបស់សមាជិករដ្ឋសភា ឯកឧត្តម ម៉ោញ សាផាន អំពីបញ្ហាច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ មជ្ឈមណ្ឌល-ឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនដែលមកទស្សនាបន្ទប់សវនាការនឹងផ្សព្វផ្សាយពត៌មានទៅសហគមន៍ទាំងមូលតាមរយៈនេះប្រទេសជាតិទាំងមូលនឹងចូលរួមក្នុងដំណើរការនេះ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាយល់ឃើញថា ដំណើរទស្សនកិច្ចនេះ មានសារសំខាន់ណាស់ក្នុងការគាំទ្រឲ្យប្រជាជនកម្ពុជាចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ និងផ្តល់នូវវេទិកាពិភាក្សាឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យប្រជាជនបានបញ្ចេញមតិយោបល់ ។ លោកនាយកជឿជាក់ថា តាមរយៈការផ្តល់ឳកាសឲ្យប្រជាជនចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ តុលាការនឹងរឹតតែមានតម្លាភាព ។

ដំណើរទស្សនកិច្ចនេះជាផ្នែកមួយនៃគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំសម្រាប់សហគមន៍ចាមមូស្លីម ។ ក្នុងគម្រោងនេះមជ្ឈមណ្ឌលឯកសារកម្ពុជាស្វះស្វែងរកកំណត់ត្រាស្តីពីបទពិសោធន៍ជនជាតិចាមក្នុងរបបប្រល័យពូជសាសន៍ ។ កិច្ចការនេះដំបូងឡើងជាផ្នែកមួយនៃគម្រោងឯកសាររស់ ហើយក៏ក្លាយទៅជាគម្រោងមួយដាច់ដោយឡែកក្នុងឆ្នាំ២០០៧ ។ ដោយមានកំណត់ត្រាតិចតួចស្តីពីការសម្លាប់ជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការប្រមែប្រមូលឯកសារ និងសក្ខីភាពរបស់សមាគមន៍នេះផ្ទាល់អាចមានប្រយោជន៍សម្រាប់តុលាការ ។

នៅចុងឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាពិភាក្សាសាធារណៈចំនួន២ ស្តីពី"យុត្តិធម៌និងការផ្សះផ្សាក្នុងសហគមន៍ចាមមូស្លីម"នៅខេត្តកំពតនិងខេត្តពោធិ៍សាត់ ។ ប្រជាជនប្រមាណ២០០នាក់ ត្រូវបានអញ្ជើញឲ្យមកចូលរួម ដែលក្នុងនោះ មានមេដឹកនាំសាសនាលំដាប់ខេត្ត ហាកិម តួន និង


អ្នកដឹកនាំសហគមន៍អ៊ីស្លាមជួបសំណេះសំណាលជាមួយសហព្រះរាជអាជ្ញា

អ្នកភូមិមួយចំនួនទៀត ។ តាមរយៈវេទិកាពិភាក្សានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា អាចវាស់ស្ទង់គំនិតពីសំណុំរឿងកាត់ក្តីរបស់តុលាការ ។ ប្រជាជនមកចូលរួមមានចំណាប់អារម្មណ៍ចង់បញ្ចេញគំនិតយោបល់របស់ខ្លួន និងស្នើសុំឲ្យមានគណៈកម្មការស្វែងរកការពិត ដើម្បីផ្សះផ្សាជាមួយនឹងជនដែលជាអតីតកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ។

គម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំផ្សាភ្ជាប់កិច្ចការជាច្រើនជាមួយស្ត្រីជនជាតិចាមមូស្លីមដើម្បីបង្កើនទស្សនវិស័យស្ត្រីជារួមមួយលើរបបប្រល័យពូជសាសន៍ ។ គម្រោងនាពេលអនាគតនេះរួមមានការបោះពុម្ពផ្សាយទស្សនាវដ្តីចាមប្រចាំត្រីមាស ការបង្កើតគេហទំព័រ និងការចែកតារាងស្ទង់មតិដើម្បីស្រាវជ្រាវរកចំនួនជនជាតិចាមដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។

ប្រជាជនកម្ពុជាទាំងអស់ ទាំងជនរងគ្រោះនិងជនដែលសុទ្ធតែរងទុក្ខវេទនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនគិតពីជនជាតិ សាសនា និងសង្គមឡើយ ។ យ៉ាងណាមិញ មានភ័ស្តុតាងបង្ហាញថា ខ្មែរក្រហមពិតជាបានធ្វើទុក្ខបុកម្នេញជនជាតិចាមមូស្លីមដោយហេតុផលជនជាតិភាគតិចនិងសាសនា ។ អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោក អ៊ីសា ឧស្មាន បានគូសបញ្ជាក់ឲ្យឃើញថា អត្រាជនជាតិចាមបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម គឺប្រហែល២ ឬ៣ដង បើប្រៀបធៀបទៅនឹងអត្រាស្លាប់របស់ប្រជាជនកម្ពុជា (យោងតាមសៀវភៅ អ៊ីតូបាស "យុត្តិធម៌សម្រាប់ជនជាតិចាមមូស្លីមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ២០០២") ។

**ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

មេដឹកនាំសាសនាអ៊ីស្លាមទាំងអស់មកដល់ភ្នំពេញនៅរសៀលថ្ងៃច័ន្ទ ទី១៥ ខែមករា និងស្នាក់នៅផ្ទះសំណាក់ក្បែរវិហារអ៊ីស្លាមអន្តរជាតិ ។ គាត់ទាំងអស់គ្នាទទួលបានទស្សនាវដ្តីស្វែងរកការពិត និងអាវយឺតមានរំលេចពាក្យស្លោកស្តីពីតុលាការខ្មែរក្រហមដែលចូលរួមសរសេរដោយបុគ្គលិកមជ្ឈមណ្ឌល ។

ព្រឹកថ្ងៃបន្ទាប់ មេដឹកនាំសាសនាអ៊ីស្លាមទាំងអស់ ធ្វើដំណើររយៈពេល១ម៉ោងទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ដែលមានទីតាំងស្ថិតនៅជាយក្រុងភ្នំពេញ ។ ដំណើរទស្សនកិច្ចនេះ មានអមដំណើរដោយអ្នកសារព័ត៌មាននិងអ្នកថតរូបជាច្រើននាក់ ។

នៅអាគារអង្គជំនុំជម្រះវិសាមញ្ញ មេដឹកនាំសាសនាអ៊ីស្លាមទាំងអស់ទទួលកញ្ចប់ឯកសារ និងផ្ទាំងរូបភាពស្តីអំពីតុលាការ ។ គាត់ទាំងអស់គ្នាត្រូវបាននាំទៅទស្សនាអគារ ហើយចូលរួមអង្គុយនៅក្នុងអនាគតបន្ទប់សវនាការដើម្បីស្វែងយល់ពីតុលាការ និងលើកសំណួរទៅលោក រាជ សម្បត្តិ មន្ត្រីព័ត៌មានសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ គាត់ទាំងអស់គ្នាត្រូវបាននាំទៅមើលរូបសំណាកអ្នកតាដំបងដែកនៅក្នុងបរិវេណអគារតុលាការ ។



អ្នកដឹកនាំសហគមន៍អ៊ីស្លាមជួបសំណេះសំណាលជាមួយនាយកមជ្ឈមណ្ឌលឯកស

បន្ទាប់ពីដំណើរទស្សនកិច្ចនេះមេដឹកនាំសាសនាអ៊ីស្លាមត្រូវបាននាំទៅជួបសហព្រះរាជអាជ្ញា ដែលនេះជាឱកាសដ៏កម្រនិងមិនដែលកើតមានចំពោះដំណើរទស្សនកិច្ចមុនៗ ។ គាត់ទាំងអស់គ្នាអង្គុយជុំវិញតុប្រជុំវែងមួយ ដើម្បីស្តាប់ការណែនាំខ្លួនរបស់សហព្រះរាជអាជ្ញា ជា លាង និង រ៉ូបើត ភីទី មកពីប្រទេសកាណាដា ។ ទន្ទឹមនឹងនោះ សហព្រះរាជអាជ្ញាទាំងពីរក៏បានធ្វើការឆ្លើយតបនឹងសំណួរមួយចំនួនផងដែរ ។ បន្ទាប់ពីការប្រជុំគ្នានេះ គាត់ទាំងអស់ឈរជុំគ្នាថតរូបមុននឹងឡើងរថយន្តក្រុង ។

ពេលត្រឡប់មកដល់ភ្នំពេញ មេដឹកនាំសាសនាអ៊ីស្លាមបាន

ជួបជាមួយលោក ឆាំង យុ និង សូ ហ្វារីណា ប្រធានគម្រោងប្រវត្តិសាស្ត្រតាមរយៈការសួរនាំ ។ សូ ហ្វារីណា បានបង្ហាញអ្នកមកចូលរួមទាំងអស់នូវតារាងស្ទង់មតិដើម្បីសុំយោបល់ពីអ្នកចូលរួមមុននឹងតារាងនេះត្រូវបានចែកចាយ ។ លោកនាយកបានសាកសួរអ្នកចូលរួមដើម្បីសុំឲ្យមានការបញ្ជូនបុគ្គលណាមានសមត្ថភាពខ្ពស់បំផុតក្នុងការចែករំលែកព័ត៌មានស្តីពីតុលាការដល់សហគមន៍ទាំងមូល ។ តំណាងម្នាក់នេះនឹងត្រូវផ្តល់ទំនួលខុសត្រូវនិងឱកាសចូលរួមស្តាប់សវនាការឆ្នាំនេះ ដើម្បីធានានូវការផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីដំណើរការតុលាការដល់សហគមន៍ចាម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រកាសនូវគោលបំណងរបស់ខ្លួនក្នុងការរៀបចំការប្រជុំពីរទៀតសម្រាប់មេដឹកនាំសាសនាអ៊ីស្លាមដែលមិនទាន់បានមកចូលរួមដំណើរទស្សនកិច្ចលើកនេះ ។


…បារកម្ពុជា

លោក រាជ សម្បត្តិ មានប្រសាសន៍ថា «នេះបង្ហាញពីកម្លាំងជំរុញកាន់តែខ្លាំងឲ្យអង្គជំនុំជម្រះវិសាមញ្ញដំណើរការទៅមុខ ។ សហគមន៍ចាម ក៏ដូចជាក្រុមជនជាតិដទៃទៀត តែងតែទទួលការស្វាគមន៍ឲ្យមកទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញជានិច្ច ។ ខ្ញុំសង្ឃឹមថាអ្នកទាំងអស់គ្នានឹងជួយផ្សព្វផ្សាយអ្វីដែលបានដឹងឮដល់អ្នកជិតខាងឯទៀត» ។

## ចំណាប់អារម្មណ៍និងប្រតិកម្ម

ក្នុងខណៈពេលជួបប្រជុំជាមួយមន្ត្រីព័ត៌មានសាធារណៈនិងសហព្រះរាជអាជ្ញា មេដឹកនាំសាសនាអ៊ីស្លាមឆ្លៀតឱកាសនេះ ដើម្បីបង្ហាញចំណាប់អារម្មណ៍ផ្សេងៗគ្នា ។ សំណួរជាច្រើនត្រូវបានចោទឡើងទាក់ទិនទៅនឹងការអូសបន្លាយពេលវេលានៃសវនាការ ការការពារសាក្សី និងជនរងគ្រោះ ។ យ៉ាងណាមិញ ចំណាប់អារម្មណ៍ចម្បងរបស់គាត់ទាំងអស់គ្នាគឺបុគ្គលដែលនឹងត្រូវនាំយកមកកាត់ទោស ។ នៅក្នុងច្បាប់តុលាការខ្មែរក្រហមបញ្ជាក់ថា មានតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតទេដែលត្រូវយកទៅកាត់ទោស ។ មេដឹកនាំសាសនាអ៊ីស្លាមទាំងអស់បារម្ភថា កម្មាភិបាលថ្នាក់កណ្តាលនិងថ្នាក់ក្រោមអាចគេចផុតពីការដាក់ទោសលើឧក្រិដ្ឋកម្មផ្ទាល់ខ្លួនជាច្រើន រួមមានការសម្លាប់មនុស្សជាដើម ។

«យោងតាមមាត្រា២ (នៅក្នុងកូនសៀវភៅផ្តល់ព័ត៌មានពីតុលាការ) ប៉ុន្តែប្រសិនបើមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងអស់ស្លាប់ដោយចាស់ជរា តើកម្មាភិបាលថ្នាក់កណ្តាលនឹងត្រូវយកមកកាត់ទោសជំនួសដែរឬទេ?» ។ នេះជាសំណួររបស់ ហាជី សូហ៊ុយ៉ាន មកពីខេត្តបាត់ដំបង ។

អាលី ខស្មាន មកពីខេត្តតាកែវ បានសួរនូវសំណួរប្រហាក់ប្រហែលគ្នានេះដែរ ។ «ក្នុងមាត្រា២នៃច្បាប់ខ្មែរក្រហមចែងថាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនឹងត្រូវយកមកកាត់ទោស ។ ប៉ុន្តែមានកម្មាភិបាលខ្មែរក្រហមខ្លះបានប្រព្រឹត្តបទល្មើសដើម្បីតែមុខមាត់ខ្លួនឯង ។ តើតុលាការសម្រេចករណីនេះដូចម្តេចដែរ?» អាលី ខស្មាន បន្ថែមពីក្តីបារម្ភរបស់គាត់ក្នុងការរស់នៅក្នុងភូមិជាមួយជនដៃដល់ទាំងនោះ ។

ខណៈដែលមានការស្នើសុំយោបល់ពីបញ្ហានេះ បុគ្គលិកទទួលបន្ទុកកិច្ចការសាធារណៈនៃមជ្ឈមណ្ឌលឯកសារកម្ពុជា កែវ ដាស៊ីល លើកឡើងថា «បញ្ហានេះសំខាន់ខ្លាំង ព្រោះនេះបង្ហាញឲ្យឃើញថាយុត្តិធម៌តាមផ្លូវច្បាប់ដែលបានមកពីការកាត់ទោសមេដឹកនាំកំពូលគឺមិនគ្រប់គ្រាន់ឡើយ ។ យើងចាំបាច់ត្រូវធ្វើអ្វីមួយនៅតាមភូមិឃុំដើម្បីបន្ធូរបន្ថយភាពតានតឹងរវាងជនរងគ្រោះពីរបបប្រល័យពូជសាសន៍និងជនដៃដល់ដែលរស់នៅក្បែរៗគ្នា ។

ក្រៅពីក្តីបារម្ភនេះ អ្នកដឹកនាំសាសនាអ៊ីស្លាមមានប្រតិកម្មវិជ្ជមាន និងរីករាយពេលបានទទួលដំណឹងពីតុលាការដែលបម្រុងនឹងកើតឡើង ។ គាត់ទាំងអស់គ្នាសង្ឃឹមថាដំណើរការសវនាការនឹងកើតមានឆាប់ៗនេះ ។ ខកញ៉ា ខ្នូរ កែទាំ មេដឹកនាំម្នាក់មកពីខេត្តកំពង់ឆ្នាំងមិនបានលើកឡើងនូវសំណួរអ្វីទេព្រោះសំណួរដែលអ្នកចូលរួមផ្សេងទៀតលើកឡើងដូចជាសំណួរនិងការបារម្ភរបស់គាត់ដែរ ។ គាត់មានប្រសាសន៍ថា «ខ្ញុំលែងមានចម្ងល់ឬសំណួរអ្វីទៀតហើយ ខ្ញុំយល់បានច្រើនជាងមុន ប៉ុន្តែអ្នកជិតខាងខ្ញុំចង់ឃើញយុត្តិធម៌កើតមានក្នុងពេលឆាប់ៗនេះ ។»

**សូ ហ្វារីណា និង លីហ្សាប៊ែត ម៉ៃយើ**

# សុំខមាទោសពីអតីតកម្មាភិបាលថតរូបខ្មែរក្រហម

ខ្ញុំបាទ ញ៉ែម អេន អតីតអ្នក ថតរូបនៅមន្ទីរស-២១ (គុកទួលស្លែង) ក្នុងសម្បជញ្ញៈផ្ទាល់ ដោយពុំមានការពាក់ព័ន្ធជាមួយបុគ្គលណាម្នាក់ ឬឥទ្ធិពលណាមួយ សូមជម្រាបជាសង្ខេបនូវប្រវត្តិពិតផ្ទាល់ខ្លួនអំពីការចូលរួមជាមួយអង្គការបដិវត្តន៍ នៃរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅឆ្នាំ១៩៧១ ពេលខ្ញុំ អាយុបាន១១ឆ្នាំ បន្ទាប់ពីព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទម្លាក់រាជ្យសម្តេច ព្រះនរោត្តម សីហនុ នៅស្រុកកំណើតខ្ញុំមានចលនាឃោសនាអំពាវនាវ ដោយ លោក ហ៊ូ នឹម, ហ៊ូ យន់, និង ខៀវ សំផន ឲ្យប្រជាជនចូលព្រៃ ដើម្បីតស៊ូរំដោះប្រទេសពីបរទេសឈ្លានពាន ។ បងប្រុសបង្កើតរបស់ខ្ញុំប្អូនរូបបានចូលបម្រើក្នុងជួរកងឈ្លបនៃចលនាតស៊ូ នេះ ចំណែករូបខ្ញុំបានចូលបម្រើនៅក្នុងក្រុមសិល្បៈបដិវត្តជំនាញវាយស្គរឃីកេ ។ នៅឆ្នាំ១៩៧៣ ដោយអង្គការបដិវត្តន៍បានពិនិត្យឃើញសកម្មភាពបម្រើការងារ



ញ៉ែម អេន ឆ្នាំ១៩៧៧



ញ៉ែម អេន ឆ្នាំ២០០៧

និងសីលធម៌ល្អរបស់ខ្ញុំ អង្គការបានសម្រេចឲ្យខ្ញុំចូលបម្រើការងារក្នុងកងកុមារដឹកជញ្ជូនស្បៀងនិងគ្រាប់សម្រាប់យុទ្ធជនសមរភូមិមុខ ។

ក្រោយការរំដោះទឹកដីពីរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយ លន់ នល់ ខ្ញុំបាទត្រូវបានអង្គការជ្រើសរើសឲ្យចូលក្នុងកងកុមារឈានមុខ ហើយបានបញ្ជូនមកអប់រំបំពាក់បំប៉នសតិអារម្មណ៍ និងគោលជំហរនៅតំបន់ព្រែកហូរ តាខ្មៅ ខេត្តកណ្តាល ។ ជីវិតក្នុងអាយុ១៦ឆ្នាំ ជាជីវិតកំពុងពេញមោទនភាព តែមានចំណេះដឹងតិចតួចត្រូវបានអង្គការបណ្តុះមនោគមវិជ្ជាក្រហមឲ្យស្រលាញ់ជាតិមាតុភូមិឲ្យស្អប់ខ្មាំងបរទេស ។ ខ្ញុំត្រូវបានអង្គការលើកសរសើរចំពោះស្នាដៃបំពេញភារកិច្ចជូនបដិវត្ត ហើយជាមោទនបំផុត ដែលខ្ញុំត្រូវអង្គការបញ្ជូនឲ្យទៅរៀនបច្ចេកទេសថតភាពយន្ត បញ្ចាំងភាពយន្ត ថតរូបភាព ផ្តិតរូបភាព និងគូរផែនទីនៅប្រទេសចិន ។ ការដឹកនាំដោយមានការបំពាក់បំប៉នគោលជំហរជាប្រចាំ និងការផ្តល់ឱកាសដល់ខ្ញុំឲ្យបានទទួលជំនាញមួយជាទីស្រលាញ់ ធ្វើឲ្យខ្ញុំមានឆន្ទៈមោះមុតបំផុត ក្នុងការបំពេញភារកិច្ចជូនអង្គការ ។

បន្ទាប់ពីត្រឡប់មកពីសិក្សានៅប្រទេសចិនវិញ រូបខ្ញុំត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅក្នុងកងថតខ្សែភាពយន្ត និងថតរូបអនុស្សាវរីយ៍របស់ថ្នាក់ដឹកនាំ និងគណៈប្រតិភូបរទេសដែលបានអញ្ជើញមកទស្សនកិច្ចនៅក្នុងប្រទេសខ្មែរនាសម័យនោះ ។ ជាមួយគ្នានេះដែរ អង្គការក៏បានចាត់តាំងឲ្យរូបខ្ញុំថតរូបអ្នកទោសនៅមន្ទីរស-២១“គុកទួលស្លែង” ដែលក្រុមរបស់ខ្ញុំមានសមាជិកប្រាំមួយនាក់ ក្នុងនោះមានតែខ្ញុំម្នាក់គត់ដែលបានទៅរៀននៅប្រទេសចិន ហើយការងារបច្ចេកទេសភាគច្រើនត្រូវបានអង្គការបញ្ជាឲ្យរូបខ្ញុំជាអ្នកជួយដល់ក្រុមបច្ចេកទេស ។ ខ្ញុំសូមជម្រាបជូនជនរួមជាតិឲ្យបានជ្រាបច្បាស់ថា អ្វីៗនាសម័យនោះសុទ្ធតែជារបស់អង្គការទាំងអស់ សូម្បីតែអាយុជីវិតក៏ជារបស់អង្គការដែរ ប៉ុន្តែអង្គការបានកំណត់សកម្មភាពនិងគោលជំហររបស់កម្មាភិបាល និងយុទ្ធជន ដោយឈរលើសីលធម៌ដប់ពីរប្រការរបស់អង្គការ ។ កម្មាភិបាល និងយុទ្ធជននៅក្នុងរបបនោះត្រូវបានសម្លាប់ក្រោមមូលហេតុនៃការប្រព្រឹត្តផ្ទុយទៅនឹងប្រការណាមួយនៃសីលធម៌របស់អង្គការនេះឯង ។

ជានិច្ចកាលក្នុងការបំពេញភារកិច្ច អង្គការបានពង្រឹងគោលជំហរច្បាស់ថា “ការងារយើង យើងដឹង, ការងារគេ គេដឹង, សក់អ្នកណាក្បាលអ្នកហ្នឹង” ។ រូបខ្ញុំក្នុងពេលថតរូបប្រៀបបាន

ទៅនឹងមនុស្សយន្ត មានសិទ្ធិត្រឹមតែថតគ្មានសិទ្ធិសួរនាំអ្វីទាំងអស់ ទោះបីដឹងថាអ្នកទាំងនោះនឹងត្រូវប្រហារជីវិតនាពេលបន្តិចទៀតក៏ដោយ ។ ទិសដៅអង្គការគឺត្រូវកសាងប្រទេសជាតិឆ្ពោះទៅកាន់ភាពរុងរឿង មហាលោតផ្លោះ មហាអស្ចារ្យ អ្នកណាមិនគោរពអង្គការវិន័យ ឬប្រឆាំងនឹងអង្គការ អង្គការត្រូវតែកម្ទេចកង់ប្រវត្តិសាស្ត្ររបស់អង្គការកំពុងវិលទៅមុខ អ្នកណាភាដៃដាច់ដៃ អ្នកណាភាជើងដាច់ជើង ត្រូវតែមានជំនឿលើអង្គការនិងគោរពអង្គការ ។ ក្រោមមនោគមវិជ្ជាស្នេហាជាតិ ស្អប់បរទេស និងក្រោមការបំពាក់បំប៉នគោលជំហររបស់អង្គការធ្វើឲ្យរូបខ្ញុំយល់ថាការដឹកនាំរបស់អង្គការនាអំឡុងពេលនោះ ពិតជាមហាអស្ចារ្យមហាលោតផ្លោះប្រាកដមែន ។ មានពេលមួយ រូបខ្ញុំបានឃើញបងប្អូនរបស់ខ្ញុំពីរនាក់ត្រូវបានអង្គការបញ្ជូនមកដាក់ក្នុងមន្ទីរស-២១នេះ ពេលនោះរូបខ្ញុំមានការរន្ធត់ជាខ្លាំង ហើយចាប់ផ្តើមមានការប្រុងប្រយ័ត្នគ្រប់ជំហាននៃសកម្មភាពការងារ និងមានការព្រួយបារម្ភជានិច្ច ។ ក្នុងឱកាសនេះ ខ្ញុំបាទសុំធ្វើជាសាក្សីម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យប្រសិនបើតុលាការត្រូវការ ។

គោលបំណងសំខាន់ៗក្នុងពេលនេះសម្រាប់រូបខ្ញុំ មានឆន្ទៈពីរគឺ : ១) ការសុំខមាទោសបញ្ចេញនូវមនោសញ្ចេតនានៃការសោកស្តាយជាពន់ពេក ចំពោះព្រឹត្តិការណ៍មួយដ៏ឃោរឃៅដែលមិនគួរកើតមាន ហើយរូបខ្ញុំបាទមានចំណែកមួយនៃម៉ាស៊ីនសម្លាប់របស់ខ្មែរក្រហម និងបានរួមសកម្មភាពជាមួយដោយភាពឈ្លក់វង្វេងនឹងមនោគមអង្គការ បម្រើការជូនអង្គការ ។ ខ្ញុំមានបងប្អូនបង្កើតនិងសាច់ញាតិឆ្ងាយមួយចំនួនក៏ត្រូវបានអង្គការសម្លាប់ដូចបងប្អូនទាំងអស់ដែរ ដើម្បីឲ្យដួងវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅក្នុងសម័យនោះ និងអារម្មណ៍ខ្ញុំផ្ទាល់បានស្ងប់ចំពោះហេតុការណ៍នោះ ខ្ញុំសូមសម្តែងនូវទឹកចិត្តផ្ទាល់ដោយស្មោះសបំផុត លើកហត្ថប្រណមសុំខមាទោសចំពោះដួងវិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ដែលបានស្លាប់និងត្រូវបានសម្លាប់ដោយរបបកម្ពុជាប្រជាធិបតេយ្យ សូមឲ្យដួងវិញ្ញាណក្ខន្ធរបស់លោកទាំងអស់ទៅកាន់សុគតិភព ។ សក្ខីភាពនៃការសុំខមាទោសនេះគឺជាសមានចិត្តដ៏ជ្រះថ្លាយ៉ាងពិតប្រាកដរបស់ខ្ញុំ ព្រោះថាជនរងគ្រោះមួយចំនួនដែលរូបខ្ញុំបានថតនៅមន្ទីរស-២១ ហើយរូបខ្ញុំដឹងថាអ្នកទាំងនោះនឹងត្រូវគេប្រហារជីវិត ប៉ុន្តែរូបខ្ញុំមិនអាចជួយអ្វីបានទាល់តែសោះ "គ្មានការរន្ធត់ណាជាងដែលយើងឃើញជនរងគ្រោះម្នាក់ដែលត្រូវគេប្រុងសម្លាប់ តែយើងមិនអាចជួយសង្គ្រោះបាននោះទេ" ។ ខ្ញុំបាទសូមជម្រាបជូនជនរងគ្រោះថា នាសម័យនោះខ្ញុំបាទគ្រាន់តែដឹងថា ជនរងគ្រោះនឹងត្រូវអង្គការប្រហារជីវិត ប៉ុន្តែវិធីធ្វើទារុណកម្មនិងវិធីសម្លាប់រូបខ្ញុំពុំបានឃើញនិងដឹងឡើយ ហើយរូបខ្ញុំក៏ស្មានមិនដល់ថា មានភាពព្រៃផ្សៃដូចពេលដែលរូបខ្ញុំចូលមកដល់មន្ទីរស-២១ជាលើកដំបូងនៅឆ្នាំ១៩៩៥ ។ ការសុំខមាទោសចំពោះជនរងគ្រោះដោយរបបខ្មែរក្រហមនេះ រូបខ្ញុំធ្វើឡើងដោយខ្លួនឯងផ្ទាល់ ហើយក៏ជាបំណងប្រាថ្នារបស់ខ្ញុំជាយូរមកហើយដែរ ប៉ុន្តែពុំមានឱកាសសមស្រប ទើបតែពេលនេះ ស្រប



ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ មូសូមេលី និង ញ៉ែម អេន

ពេលដែលរដ្ឋាភិបាលទើបបង្កើតបាននូវតុលាការកាត់ទោសមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ រូបខ្ញុំយល់ថា ការសុំខមាទោសក៏អាចជាសភាវៈមួយសម្រាប់ចៅក្រមកាត់ក្តីធ្វើការពិចារណាដើម្បីជំនុំជម្រះក្តីនាពេលខាងមុខនេះ ។ ការសុំខមាទោសរបស់រូបខ្ញុំផ្ទាល់នេះ ប្រសិនបើអាចជានិមិត្តរូបនៃការសុំខមាទោសជួសឲ្យកម្មាភិបាលនិងយុទ្ធជនដែលបានបម្រើរបបកម្ពុជាប្រជាធិបតេយ្យរូបខ្ញុំ ព្រមទទួលដោយសុទ្ធចិត្តនិងប្រកបដោយកិត្តយស ហើយខ្ញុំសូមប្រកាសថា នៅក្នុងសវនាការកាត់ទោសមេដឹកនាំនៃរបបខ្មែរក្រហមខាងមុខ បើតុលាការត្រូវការរូបខ្ញុំស្មាគន៍ ។ និង២) ក្រោមដំបូលនៃព្រះពុទ្ធសាសនា ខ្ញុំបាទក៏សូមលំឱនកាយគោរព និងអំពាវនាវចំពោះគ្រួសារនៃជនរងគ្រោះទាំងអស់ មេត្តាតម្កល់ចិត្តសន្តោសដល់រូបខ្ញុំ ក៏ដូចជាអ្នកដែលដើរតាមរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់ផង សូមមេត្តាឲ្យអហោសិកម្មនិងគ្នា ។ កាលៈទេសៈនៃបរិយាកាសសង្គមជាអ្នកកំណត់វាសនាប្រទេសជាតិ និងប្រជាជនខ្មែរឲ្យទទួលរងនូវវិប្បយោគដ៏រន្ធត់របៀបនេះ ហើយ ប៉ុល ពត បានអនុវត្តនូវលទ្ធិមួយដ៏ឆ្កួតលីលា ប្រៀបដូចជាអង្គុលីមាតាមប្រហារជីវិតមនុស្សកាត់យកម្រាមដៃមួយពាន់ដើម្បីឲ្យខ្លួនក្លាយជាអាទិទេពដូច្នេះដែរ ។ ក្នុងន័យនេះខ្ញុំបាទសូមឲ្យគ្រួសារដែលបានទទួលរងគ្រោះនៅក្នុងរបបខ្មៅងងឹតនោះ មេត្តាផ្តល់នូវការយោគយល់ និងអធ្យាស្រ័យធំធេងបំផុត ដោយធម៌ខន្តីសម្រួលអារម្មណ៍ឲ្យជ្រះថ្លា លុបបំបាត់ភាពរើសអើងនិន្នាការរវាងអ្នកដែលបានដើរតាមរបបខ្មែរក្រហម និងអ្នកដែលបានទទួលរងគ្រោះ ដើម្បីរួមចំណែកពង្រឹងមាគ៌ាផ្សះផ្សាជាតិរបស់រដ្ឋាភិបាលឲ្យទទួលបានជោគជ័យត្រចះត្រចង់ ក្នុងការអភិវឌ្ឍន៍ប្រទេសឆ្ពោះទៅកាន់ភាពសម្បូររុងរឿងនិងសុខក្សេមក្សាន្ត ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមជម្រាបជូនបងប្អូនជនរួមជាតិមេត្តាជ្រាបផងដែរ អ្នកដើរតាមអង្គការបដិវត្តន៍ក៏ជាជន-រងគ្រោះដ៏ធ្ងន់ធ្ងរផងដែរ ព្រោះថាបងប្អូនទាំងនោះត្រូវអង្គការពន្លក់សតិអារម្មណ៍ឲ្យជឿជាក់លើអង្គការ ដើរតាមអង្គការ បម្រើអង្គការ ហើយទីបំផុតក៏ត្រូវអង្គការសម្លាប់ចោល ។ បច្ចុប្បន្នបងប្អូនមួយចំនួនកំពុងមានវិប្បដិសារីយ៉ាងខ្លាំង ដោយទឹកចិត្តស្នេហាជាតិ ស្រលាញ់មាតុភូមិដ៏ឧត្តុង្គឧត្តម ហើយមួយជីវិតរបស់គាត់បានបូជាជីវិតដោយឈ្លក់វង្វេងនឹងអង្គការ ប៉ុន្តែទីបំផុតមិនបានផលប្រយោជន៍ជូនជាតិ បែរជាផ្តល់ផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ប្រទេសជាតិទៅវិញ ។

បច្ចុប្បន្នខ្ញុំបាទបានទទួលតួនាទីពីរាជរដ្ឋាភិបាលជាអភិបាលរងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលជាទីតាំងធំចុងក្រោយបំផុតនៃរបបខ្មែរក្រហម ហើយក៏ជាទីកន្លែងដែលមេដឹកនាំកំពូលនៃរបបនោះ បានស្លាប់នៅទីនោះដែរ ។ ការរំពុកអំពីចលនាដឹកនាំរបស់របបខ្មែរក្រហមមិនមែនមានន័យថា រូបខ្ញុំគាំទ្ររបបនោះទេ


ញ៉ែម អេន អតីតអ្នកថតរូបអ្នកទោសនៅទួលស្លែង (ស-២១)

ប៉ុន្តែព្រឹត្តិការណ៍ដ៏ខ្មៅងងឹតនេះវាគឺជាដំណាលប្រវត្តិសាស្ត្រដ៏ពិតប្រាកដមួយ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ហើយកូនខ្មែរជំនាន់ក្រោយនិងប្រជាជាតិនៃសាកលលោកស្ទើរតែមិនជឿថានឹងមានកើតឡើង ។ ជាមួយនេះផងដែរ ខ្ញុំបាទក៏សូមឲ្យមតិជាតិនិងអន្តរជាតិជួយពិចារណាអំពីសកម្មភាពដ៏លីលារបស់ ប៉ុល ពត ដែលបានប្រើនយោបាយដ៏ឃោរឃៅនិងល្ងង់ខ្លៅ

ដើម្បីដឹកនាំប្រទេសជាតិរបៀបនេះ ។ រូបខ្ញុំសង្កេតឃើញថា ប៉ុល ពត មានប្រពន្ធ មានកូន ចេះស្រលាញ់ប្រពន្ធកូន មានមនោសញ្ចេតនា ចេះចេញទៅលំហែកាយនៅបរទេស ប៉ុន្តែបែរជាបង្កើតគោលនយោបាយសម្លាប់គ្រួសារ ប្តីប្រពន្ធ អ្នកដទៃទៅវិញ ។

អនុស្សាវរីយ៍ដ៏ជូរចត់ប្រកបដោយវិប្បដិសារីរបស់ខ្មែរនេះ រូបខ្ញុំបានប្រមែប្រមូលនូវរូបថតមេដឹកនាំខ្មែរក្រហមនិង


គម្រោងសារមន្ទីរនៅខេត្តឧត្តមានជ័យ គូរដោយស្ថាបត្យករ លឹម ទ្រី មើលចំពីមុខ

រូបថតដែលទាក់ទងជាមួយរបបខ្មែរក្រហមជាច្រើនរក្សាទុកតាំងពីរបបនេះរលំរលាយ គួបផ្សំនិងការដឹងច្បាស់អំពីប្រវត្តិនៃរបបនោះ រូបខ្ញុំមានបំណងរៀបចំបើកសារមន្ទីរមួយនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដើម្បីតាំងរូបថតមួយចំនួន និងការពណ៌នាអំពីប្រវត្តិសាស្ត្រត្រួសៗអំពីសកម្មភាពដែលបានកើតមាននៅក្នុងសម័យខ្មែរក្រហមនោះ ។

ការរៀបចំសារមន្ទីរសុំខមាទោសនិងការផ្សះផ្សាជាតិមានគោលបំណងដូចខាងក្រោម ៖

១) តាំងពិពណ៌រូបថតនៃរបបខ្មែរក្រហមទុកឲ្យកូនខ្មែរជំនាន់ក្រោយនិងអន្តរជាតិបានស្គាល់ ។

២) ជាកន្លែងប្រវត្តិសាស្ត្រជាតិមួយដែលបានរំឭកដល់ភាពវិនាសកម្មរបស់ប្រទេសជាតិនិងប្រជាជនខ្មែរ ក្រោមការដឹកនាំនៃរបបខ្មែរក្រហមក្នុងអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ និងចង់ឲ្យទិដ្ឋភាពនេះក្លាយទៅជាការយោគយល់គ្នាទៅវិញទៅមក ដើម្បីបញ្ចៀសឲ្យបាននូវបាតុភូតអាក្រក់នេះកើតមានឡើងម្តងទៀត ។

៣) ជាទីកន្លែងសម្រាប់និស្សិត ឬបញ្ញវន្តជាតិនិងអន្តរជាតិ ធ្វើកម្មសិក្សាអំពីប្រវត្តិសាស្ត្ររបស់ប្រទេសក្រោមការដឹកនាំរបស់របបខ្មែរក្រហម និងបង្កើនឆន្ទៈដល់មេដឹកនាំនិងយុទ្ធជនខ្មែរក្រហមដែលមានជីវិតរស់នៅឲ្យក្លាហានចេញមុខមកសុំខមាទោសចំពោះជនរងគ្រោះដែលបានស្លាប់ ដើម្បីឲ្យដួងវិញ្ញាណក្ខន្ធអ្នកទាំងនោះបានស្ងប់ ហើយក៏ជាទីកន្លែងសម្រាប់ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាតិនិងអន្តរជាតិផងដែរ ។

គម្រោងរៀបចំសារមន្ទីរនេះបានត្រូវរដ្ឋាភិបាលអនុញ្ញាតតាមរយៈក្រសួងវប្បធម៌និងវិចិត្រសិល្បៈរួចហើយ នៅរង់ចាំតែការស្វែងរកមូលនិធិនិងការប្រឹក្សារៀបចំ ដែលបច្ចុប្បន្នមជ្ឈមណ្ឌលឯកសារកម្ពុជាបានសន្យានឹងផ្តល់ការប្រឹក្សាបច្ចេកទេសក្នុងការរៀបចំសារមន្ទីរនេះ ។

ជាទីបញ្ចប់ ខ្ញុំបាទសូមធ្វើការសុំអភ័យទោសគ្រប់យ៉ាងចំពោះឥស្សរជនជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា និងជនរួមជាតិទាំងអស់ក្នុងការរៀបរាប់ប្រវត្តិខាងលើក្រែងមានការប៉ះពាល់ដល់កិត្តិយស ដោយប្រការណាមួយជាអចេតនា ។ ខ្ញុំបាទសូមបួងសួងចំពោះព្រះបារមីនៃវត្ថុស័ក្តិសិទ្ធិក្នុងលោក ព្រះមេត្តាប្រោះព្រំដល់ប្រទេសកម្ពុជានិងប្រជារាស្ត្រខ្មែរឲ្យបានជួបតែសេចក្តីសុខ សេចក្តីចម្រើន និងភាពសម្បូរសប្បាយរុងរឿងតរៀងទៅ ។

**អន្លង់វែង, ថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧**

**ញ៉ែម អេន**

# សុន្ទរកថារបស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងអ្នកថតរូបខ្មែរក្រហមឈ្មោះ ញ៉ែម អេន

ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៧

សូមជម្រាបសួរ! ខ្ញុំមានសេចក្តីរីករាយសូមស្វាគមន៍អស់លោក លោកស្រីទាំងអស់ដែលបានមកកាន់ស្ថានទូតអាមេរិក នៅថ្ងៃនេះ ដើម្បីជួបជាមួយលោក ញ៉ែម អេន ដែលជាអ្នកថតរូបនៃរបបខ្មែរក្រហម ដែលបានថតរូបជាច្រើនសន្លឹកនៅក្នុងបន្ទប់គុកទួលស្លែង ។ រូបថតទាំងនោះត្រូវបានដាក់បង្ហាញពេញនៅក្នុងបន្ទប់ទំនេរនៅឯគុកទួលស្លែង ។ រូបថតទាំងនោះធ្វើឲ្យអ្នកទស្សនាគ្រប់គ្នាមានការរន្ធត់ចិត្តជាខ្លាំង ។ ភ្នែករបស់ជនរងគ្រោះម្នាក់ៗសម្លឹងមករកយើង លងយើង ស្រែកមកកាន់យើង បន្ទាប់ពីរូបថតទាំងនេះស្ថិតក្នុងភាពស្ងប់ស្ងាត់អស់រយៈពេលបីទសវត្សរ៍មកហើយនោះ ។ ពុំមាននរណាម្នាក់ដែលបានទៅទស្សនាគុកទួលស្លែងអាចបំភ្លេចរូបថតទាំងនោះទេ ។

ទោះបីជាមានការចោទប្រកាន់និងការនិយាយបញ្ចិតបញ្ចៀងអំពីអ្នកដែលបានថតរូបទាំងនេះយ៉ាងណាក្តី ក៏រូបថតទាំងនេះគឺជាតឹកតាងដែលមិនអាចប្រកែកបាននៃភាពយង់ឃ្នងរបស់របបខ្មែរក្រហមបានដែរ ។ យើងទាំងអស់គ្នាបានដឹងហើយតាមរយៈការសិក្សាអង្កេតនៅពេលថ្មីៗនេះថា មានប្រជាជនខ្មែរវ័យក្មេងជាច្រើនមិនជឿថា មានអំពើប្រល័យពូជសាសន៍បានកើតឡើង និងជឿថាឪពុកម្តាយរបស់ពួកគេពិតជាបាននិយាយបំភ្លើសនូវអំពើដែលគួរឲ្យរន្ធត់នោះ ដូចនេះ មានតែរូបថតទាំងនេះទេដែលជួយរំឭកដល់មនុស្សគ្រប់ៗគ្នាអំពីទំហំធំធេងពិតប្រាកដនៃឧក្រិដ្ឋកម្មនោះ ។ យើងស្ទើរតែគ្មានអារម្មណ៍ចម្លែកចំពោះអំពើឃោរឃៅដែលកើតមានរាល់ថ្ងៃ ដែលយើងអាននៅលើទំព័រកាសែតរបស់យើងរាល់ព្រឹក ប៉ុន្តែខ្ញុំគិតថា យើងមានអារម្មណ៍ចម្លែកចំពោះរូបថតទាំងនោះ ពីព្រោះរូបថតទាំងនេះតែងតែធ្វើឲ្យយើងមានអារម្មណ៍មិនស្ងប់និងមិនស្រួលក្នុងចិត្តជានិច្ច ។ យើងតែងតែឮពាក្យដែលគេច្រើននិយាយថា រូបថតមួយមានតម្លៃស្មើនឹងមួយពាន់ពាក្យ ។ រូបនីមួយៗមានតម្លៃស្មើនឹងទឹកភ្នែកមួយពាន់តំណក់ ។

ទន្ទឹមនឹងការរួមចំណែកមួយយ៉ាងសំខាន់នៃរូបថតទាំងនេះ ក្នុងការថែរក្សានិងចងក្រងទុកជាឯកសារស្តីពីអំពើឃោរឃៅនៃរបបខ្មែរក្រហម ខ្ញុំគិតថា លោក ញ៉ែម អេន ជាឧទាហរណ៍គំរូដ៏ល្អមួយដោយលោកបានសុំខមាទោសចំពោះការមានចំណែករបស់លោកនៅក្នុងអំពើឃោរឃៅនោះ ។ បើប្រៀបធៀបទៅនឹងអ្វីដែលលោកបាននឹងកំពុងធ្វើនៅពេលនេះ គឺផ្ទុយពីអ្វីដែលពុំមានមេដឹកនាំខ្មែរក្រហមណាម្នាក់បានចេញមុខសារភាពកំហុស ឬទទួលយកការស្តីបន្ទោសចំពោះឧក្រិដ្ឋកម្មដ៏ឃោរឃៅនៃរបបនោះ ។ ដើម្បីឲ្យមានការផ្សះផ្សាជាតិពិតប្រាកដនៅកម្ពុជា អ្នកដែលបានជួយប្រព្រឹត្តអំពើឃោរឃៅទាំងនេះ ត្រូវហ៊ានចេញមុខទទួលស្គាល់អំពើឧក្រិដ្ឋរបស់ខ្លួន ។

ពិតមែនហើយថា ការបើកសារមន្ទីរនេះនឹងមិនធានាដល់ការផ្សះផ្សាជាតិ ឬសង្គដឹងចិត្តចំពោះការឈឺចាប់របស់ជនរងគ្រោះនោះទេ ។ នេះគ្រាន់តែជាជំហានតូចដ៏មានសារសំខាន់មួយប៉ុណ្ណោះ ។

យើងមានមោទនភាពផងដែរនៅថ្ងៃនេះ យើងមានមិត្ត និងសហការីរបស់យើងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសលោក ឆាំង យុ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកសហការយ៉ាងជិតស្និទជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងជួយផ្តល់ថវិកាដល់សកម្មភាពរបស់មជ្ឈមណ្ឌលនេះអស់រយៈពេលមួយទសវត្សរ៍មកហើយ ។ យើងមានមោទកភាពចំពោះការខិតខំប្រឹងប្រែងរួមគ្នារបស់យើងក្នុងការរក្សាទុកប្រវត្តិអតីតកាល និងនាំជនមានទោសមកកាត់ទោស ។ អស់រយៈកាលយូរពេកមកហើយដែលប្រទេសកម្ពុជាមិនបានទទួលយុត្តិធម៌ ។ មិនមានគ្រួសារណាមួយនៅកម្ពុជាដែលថាមិនបានទទួលរងការឈឺចាប់ដោយអំពើប្រល័យពូជសាសន៍នោះទេ តែអ្នកដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នេះ នៅតែរស់នៅក្នុងជីវិតមួយប្រកបដោយសុវត្ថិភាព សេរីភាព និងសម្បូរសប្បាយនៅក្នុងចំណោមអ្នកដែលបានប្រព្រឹត្តអំពើយង់ឃ្នង ។ សូមអរគុណ ។ **ចូរសេហ្វ មូស្សូមេលី**

# គុកខ្មែរក្រហម

## ខេត្តកណ្តាល

## ស្រុកកណ្តាលស្ទឹង

### ១) មន្ទីរសន្តិសុខសាលាត្រពាំងស្វា ហៅ គុកសង់

នៅឆ្នាំ១៩៦៣ “ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍” បានសាងសង់សាលាអប់រំមូលដ្ឋានមួយ នៅជិតភូមិត្រពាំងស្វា ឃុំទ្រា ក្បែរមាត់ទន្លេបាទី ស្រុកបាទី ខេត្តតាកែវ ។ សាលារៀននេះ ជាគ្រឹះស្ថានអប់រំមួយសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនឲ្យមានចំណេះដឹងផ្នែកគរុកោសល្យ ។

នៅឆ្នាំ១៩៧៧ ក្រោមបញ្ជារបស់ ឈិត ជឿន ហៅ ម៉ុក កន្លែងនេះបានប្រែក្លាយទៅជាកន្លែងកាប់សម្លាប់មនុស្សយ៉ាងសាហាវបំផុត ។ គ្រឹះស្ថាននេះត្រូវអង្គការដាក់ឈ្មោះថ្មីថា គុកសង់ ។ អ្នកជាប់ឃុំឃាំងនៅគុកសង់មានពីរផ្នែកគឺ ផ្នែកនារីនិងផ្នែកបុរស ។ អ្នកទោសទាំងអស់ត្រូវកងឈ្លបចងដៃនៅខាងមុខ ទីធ្លា រួចបណ្តើរឲ្យធ្វើការសិនមុននឹងបញ្ជូនទៅកាន់មន្ទីរឃុំឃាំង ។ ការដឹកជញ្ជូនអ្នកទោសពីសហករណ៍នានាមកកាន់គុកសង់គឺ ច្រើនដឹកមកនៅពេលយប់ តាមរថយន្តធំៗដែលមានដំបូលបិទជិតឈឹង ។ ក្នុងចំណោមអ្នកទោសទាំងនោះ មានអ្នកខ្លះជាប្រពន្ធកម្មាភិបាលខ្មែរក្រហមដែលត្រូវចោទប្រកាន់ពីបទក្បត់បដិវត្តន៍ទៀតផង ។ ចំណែកអ្នកទោសមួយចំនួនទៀត ជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញនិងអ្នកមានសាច់ញាតិឬក្រុមគ្រួសារប្រធានភូមិប្រធានឃុំ ដែលត្រូវអង្គការចាប់ខ្លួនរួចជាស្រេច ។ អ្នកទោសទាំងអស់ត្រូវកងឈ្លបដាក់ខ្នោះដែកជាប់ជើងទាំងខ្សែៗ ដោយអង្គុយរបៀបដេកផ្អែកនឹងជញ្ជាំងគុក ។ បើជើងអ្នកទោសណាធំជាងរន្ធខ្នោះ ខ្មែរក្រហមនឹងដំជើងអ្នកទោសបញ្ចូលក្នុងរន្ធខ្នោះដោយគ្មានអាណិតអាសូរឡើយ ។


គុកសង់ ភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

មន្ទីរសន្តិសុខ“សង់” ស្ថិតនៅក្នុងភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចម្ងាយប្រមាណ៦០ម៉ែត្រពីព្រំប្រទល់ខេត្តតាកែវ ។ សាក្សីសំខាន់ៗមួយចំនួនបានដឹងរឿងរ៉ាវផ្សេងៗដែលកើតឡើងនៅក្នុងគុកសង់ ហើយជាមនុស្សធ្លាប់រស់នៅក្បែរមន្ទីរសន្តិសុខនេះទៀតផង ។

ឡុង ម៉េងគ្រី ហៅ តាខ្មៅចលង អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិក្រាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ បានរៀបរាប់ប្រាប់ថា គាត់ធ្លាប់ធ្វើជាប្រធានភូមិ ក្នុងចន្លោះឆ្នាំ១៩៧០ និង ១៩៧៣ ហើយបានលាលែងពីតំណែងនៅក្នុងឆ្នាំ ១៩៧៣ ។ ក្រោយមកអង្គការដឹងពីប្រវត្តិរបស់គាត់ហើយក៏ត្រូវខ្មែរ-ក្រហមកាត់ទោស ដែលនៅក្នុងពេលនោះ មានមនុស្សប្រហែល១០នាក់ផ្សេងទៀតត្រូវខ្មែរក្រហមកម្ទេចចោល ។ ដើម្បីបំភ័ន្តភ្នែកប្រជាជនក្នុងការសម្លាប់មនុស្សប្រមាណ ១០នាក់នេះ ខ្មែរក្រហមបានឲ្យក្រុមសិល្បៈមកសម្តែងជូនប្រជាជនកម្សាន្តក្នុងភូមិ ។ គ្រី បានរួចខ្លួនពីការកាត់ទោសព្រោះគាត់មានគោច្រើននឹមសម្រាប់ធ្វើស្រែ ព្រមទាំងបានបញ្ជូនកូនប្រុសម្នាក់ឲ្យចូលបម្រើកងទ័ពខ្មែរក្រហមផង ។ ម៉េងគ្រី អះអាងថា នៅចុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់មនុស្សជាបណ្តើរៗ ។ មានពេលខ្លះគាត់បានឃើញហេតុការណ៍នេះផ្ទាល់ភ្នែក ។ ក្នុងបរិវេណគុកសង់ប្រមាណមួយគីឡូម៉ែត្របួនជ្រុង គឺជាទីកន្លែងសម្លាប់មនុស្សរបស់ខ្មែរក្រហម ។ នៅក្នុងឆ្នាំ១៩៧៥

កូនរបស់ ម៉េងគ្រី ម្នាក់ត្រូវខ្មែរក្រហមសម្លាប់ដោយចាក់ថ្នាំពុល ។

រឿង ជាអ្នកកាន់កាប់បញ្ជីឈ្មោះអ្នកទោសចូលនិងអ្នកទោសយកទៅសម្លាប់ ។ សព្វថ្ងៃ រឿង រស់នៅភូមិត្រពាំងស្វាយ ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ក្រៅពីឈ្មោះនេះ ម៉េងគ្រី បានប្រាប់ឈ្មោះសន្តិសុខមួយចំនួនទៀតដូចជា ម៉ៅ, ឈុន, តាំ និង ហ៊ឹម ជាដើម ដែលអ្នកទាំងអស់នេះរស់នៅក្នុងភូមិត្រពាំងស្វាយ ឃុំទ្រាដែរ ។ សា សំ អាយុ២៩ឆ្នាំ ជាអនុប្រធានភូមិត្រពាំងស្វាយ បាននិយាយប្រាប់ពីឈ្មោះ ពេញ (នាមត្រកូលនិងនាមខ្លួន) របស់កងសន្តិសុខទាំងប្រាំនាក់ថា តូច រឿង ភេទប្រុស ជួន ឈុន ភេទប្រុស ។ តាំ មានឈ្មោះពេញថា សាក់ តាំ ភេទប្រុស សួស ម៉ៅ ភេទប្រុស និងឈ្មោះ ងិន ហ៊ឹម ។ ទីបំផុត ហេង បានប្រាប់ឈ្មោះជនរងគ្រោះដែលធ្លាប់ជាប់ឃុំឃាំងក្នុងគុកសង់ ហើយនៅរស់រហូតមកដល់សព្វថ្ងៃគឺ ១) សិរិត កុំ ភេទស្រី ជាអ្នកលក់នំត្នោតនៅផ្សារដើមអម្ពិល ភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ២) សំអឿន ភេទស្រី សព្វថ្ងៃជាឧបាសិកាសុំសីលនៅវត្តកោះប៉ុនលី ភូមិបឹងខ្យាង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រពន្ធរបស់ ម៉េងគ្រី ឈ្មោះ លី ឡាយហេង ភេទស្រី អាយុ៦២ឆ្នាំ បានប្រាប់ថាមានរណ្តៅធំៗពីរដែលអ្នកទោសជីកតាមបញ្ជារបស់ប្រធានគុក ប៉ុន្តែគ្មាននរណាដឹងថាជីកដើម្បីគោលបំណងអ្វីឡើយ ។ ប៉ុន្តែតាមប្រជាជនដឹង រណ្តៅទាំងពីរនេះសម្រាប់កប់សាកសពជនរងគ្រោះដែលខ្មែរក្រហមសម្លាប់ ។ នៅពេលសួរចម្លើយម្តងៗ អ្នកទោសត្រូវកងឈ្លបដាក់ខ្នោះកជើង ហើយអង្គុយទល់មុខជញ្ជាំងគុក ។

ជួន ឈន់ ភេទប្រុស អាយុ៣០ឆ្នាំ សព្វថ្ងៃជាប្រជាជនរស់នៅភូមិជាមួយ សួស ម៉ៅ បានប្រាប់ថា គាត់មានមុខងារជាអ្នកយាមអ្នកទោសនៅគុកសង់អស់រយៈពេល៨ខែ ។ ក្នុងរយៈពេលនេះ ឈន់ បានទទួលបញ្ជាពីមេគុកឲ្យកាន់កាំភ្លើងអាកាបណ្តើរអ្នកទោសទៅធ្វើការនិងយកមកដាក់គុកវិញ ។ ក្រុមឃ្លាំអ្នកទោសដូចរូបគាត់ (ជួន ឈន់) ត្រូវបែងចែកជាពីរក្រុម គឺក្រុមយាមនិងក្រុមសម្លាប់ ។ ការងាររបស់ក្រុមទាំងពីរនេះគឺដាច់ស្រឡះពីគ្នា ។ ឈន់ និយាយថា អ្នកទោសត្រូវយកចេញទៅធ្វើការនៅម៉ោង៧ព្រឹករហូតដល់ម៉ោង១១និងចេញធ្វើការម្តងទៀតនៅម៉ោង១រសៀលរហូតដល់ម៉ោង៥ល្ងាចទើបត្រឡប់មកវិញ ។

វ៉ាន ថុន ភេទប្រុស អាយុ៤៩ឆ្នាំ ជាប្រជាជនសាមញ្ញរស់នៅភូមិត្រពាំងស្វាយក្បែរគុកសង់ ។ កាលពីជំនាន់ខ្មែរក្រហម វ៉ាន ថុន រស់នៅភូមិមាត់បឹង ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ថុន បាននិយាយពីប្រភេទអ្នកទោសថា អ្នកទោសជាកម្មាភិបាលខ្មែរក្រហមបានត្រូវកងឈ្លបសម្លាប់ផ្តាច់ពូជតែម្តង ។ ប៉ុន្តែបើអ្នកទោសដែលជាប្រជាជន១៧មេសាវិញ គឺគ្រាន់តែសម្លាប់អ្នកណាដែលមានកំហុសប៉ុណ្ណោះ ។

សិរិទ្ធ កុំ និងកូនរបស់គាត់ត្រូវកងឈ្លបចាប់ដាក់គុកសង់អស់រយៈពេល៦ខែ ប៉ុន្តែគាត់នៅរស់រានមានជីវិតពេលដែលកងទ័ពវៀតណាមចូលមកដល់ក្នុងខែមករា ឆ្នាំ១៩៧៩ ។ កំហុសរបស់គាត់គ្មានអ្វីធំដុំទេ គឺគ្រាន់តែគាត់រៀបការជាមួយបុរសម្នាក់ដែលខ្មែរក្រហមចោទថាជាខ្មាំងរបស់បដិវត្តន៍ប៉ុណ្ណោះ ព្រោះប្តីរបស់គាត់បានចែកខសឲ្យអ្នកជិតខាងប្រើប្រាស់ចម្អិនអាហារ ។ ដោយសារកំហុសនេះ ប្រធានភូមិឈ្មោះ ពេជ្រ ឆុច បានផ្តន្ទាទោសគាត់ឲ្យជាប់គុកអស់មួយជីវិតនៅក្នុងគុកសង់ ។ សព្វថ្ងៃនេះមេភូមិ ឆុច នៅរស់នៅឡើយ ហើយមានផ្ទះនៅជិតភូមិបឹងខ្យាង ។ កុំ និយាយថា នៅពេលឃើញ ឆុច ជិះម៉ូតូឆ្លងកាត់មុខផ្ទះគាត់ម្តងៗ ធ្វើឲ្យ «ខ្ញុំនឹកឃើញដល់រឿងរ៉ាវចាស់ដែលកន្លងផុតទៅ» ។

តាមអ្នកស្រុកនៅភូមិត្រពាំងស្វាយបានឲ្យដឹងថា ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់មនុស្សក្នុងឃុំទ្រានៅចុងឆ្នាំ១៩៧៥ ។ ជនរងគ្រោះភាគច្រើនសុទ្ធតែជាប្រជាជនថ្មី ដូចជាអតីតយុទ្ធជន អ្នករដ្ឋការ និងគ្រូបង្រៀនជាដើម ។ នៅដើមឆ្នាំ១៩៧៧ ខ្មែរក្រហមបានបញ្ជូនមនុស្សកាន់តែច្រើនឡើងៗទៅកាន់មន្ទីរគុកសង់ ។ នៅខែមេសា ឆ្នាំ១៩៧៧ លេខាតំបន់២៥របស់ខ្មែរក្រហមឈ្មោះ ស៊ុំ ជា ត្រូវបានចាប់ខ្លួន ហើយលេខាភូមិភាគនិរតីឈ្មោះ ម៉ុក បានប្រគល់មុខតំណែងនេះឲ្យឈ្មោះ ប្រាក់ ដែលជាសមាជិកគណៈកម្មាធិការតំបន់កាន់កាប់វិញ ។ នៅពេលជាមួយគ្នានោះដែរ គណៈសន្តិសុខនៅតំបន់នេះឈ្មោះ កាសេស បានដឹងថាខ្លួនពិតជាត្រូវពួកខ្មែរក្រហមបោសសម្អាតមិនខាន ដោយហេតុនេះ

គាត់និងប្រពន្ធក៏សម្រេចចិត្តធ្វើអត្តឃាតទៅ ។

មុ៉ក បានបង្កើតមូលដ្ឋានរបស់ខ្លួនក្នុងគុកសង់នៅឆ្នាំ១៩៧៧ ។ ប្រជាជនមូលដ្ឋានម្នាក់ដែលកាលនោះរស់នៅក្នុងឃុំទ្រាបានឲ្យដឹងថា ខ្មែរក្រហមបានជួសជុលនិងពង្រីកគុកសង់ថែមទៀត ។ តាំងពីពេលនោះមកការសម្លាប់មនុស្សនៅក្នុងតំបន់កាន់តែកើនឡើងជាលំដាប់ ហើយប្រជាជនមូលដ្ឋាននិងប្រជាជនថ្មីក៏ត្រូវខ្មែរក្រហមបញ្ចូលឈ្មោះទៅក្នុងបញ្ជីជនរងគ្រោះជាបណ្តើរៗដែរ ។ ក្នុងពេលនោះគុកសង់បានចាប់ផ្តើមធ្វើសកម្មភាពយ៉ាងពេញទំហឹង ។ មជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន បានក្លាយទៅជាកន្លែងសម្លាប់មនុស្សយ៉ាងសាហាវរបស់ខ្មែរក្រហម ។

ជនរងគ្រោះម្នាក់ដែលត្រូវឈ្លបខ្មែរក្រហមចាប់ដាក់គុកនៅទីនោះបានប៉ាន់ប្រមាណថា នៅក្នុងគុកសង់មានបុគ្គលិក២២នាក់សម្រាប់ត្រួតពិនិត្យការស្លាប់រស់របស់អ្នកទោសទាំងអស់ ។ សាក់ តាំ បានប្រកែកថាខ្លួនមិនបានសម្លាប់នរណាម្នាក់ទេនៅក្នុងគុកសង់នេះ ទោះបីជាអ្នកស្រុកអ្នកភូមិនិយាយថាគាត់ជាឆ្មាំសន្តិសុខកំណាចឃោរឃៅក៏ដោយ ។ តាំ តួញត្អែរថា ការចោទប្រកាន់ទាំងនេះមិនត្រឹមត្រូវទេ ។ គាត់ប្រាប់ថា គាត់គ្រាន់តែជាអ្នកដាំស្លនិងអ្នករៀបចំបាយទឹកឲ្យមនុស្សនៅក្នុងគុកដែលមានចំនួនដល់ទៅ៥០០នាក់ប៉ុណ្ណោះ ។ ពេលដាំស្លគាត់បានដាក់អង្ករមួយក្តាប់ចូលក្នុងឆ្នាំងដើម្បីបបរឲ្យមានសភាពរាវកក្អក ។ មួយវែកៗសុទ្ធតែទឹកមានតែអង្ករពីរបីគ្រាប់ ហើយតម្រូវឲ្យអ្នកទោសហូបពីរនាក់ ។ តាំ និយាយថា ក្នុងមួយថ្ងៃៗមានមនុស្សយ៉ាងហោចណាស់១៥នាក់ត្រូវស្លាប់ដោយសារហូបមិនគ្រប់គ្រាន់ ។

អ្នករួចខ្លួនពីគុកសង់នៅចាំបានថា អ្នកសម្លាប់មនុស្សហាក់ដូចជាមានមោទនភាពចំពោះការងាររបស់ខ្លួនណាស់ ក្នុងការបម្រើបដិវត្តន៍ ហើយអ្នកទាំងនោះមានការងារជាច្រើនទៀតដែលត្រូវធ្វើ ។ ជនដៃដល់សម្លាប់មនុស្សម្នាក់នៅក្នុងគុកសង់ឈ្មោះ ផាន បានអួតអាងថា «ទោះបីជាត្រូវសម្លាប់មនុស្ស៥០០នាក់ក៏ដោយ ក៏មកដល់សព្វថ្ងៃនេះ ដៃរបស់ខ្ញុំគ្មានចុករោយស្រពន់ដែរ» ។ ទំហំនៃការពិឃាតមនុស្សនៅជិតគុកសង់បង្ហាញថាមានប្រជាជនច្រើនណាស់ដែលត្រូវសម្លាប់នៅទីនោះ ។ បុគ្គលិកផ្នែករដ្ឋបាលម្នាក់ទៀតដែលធ្វើការនៅគុកសង់ ឈ្មោះ ទូច រឿង បាននិយាយប្រាប់អំពីការនាំអ្នកទោសចូលនិងចេញពីគុកសង់ថារៀងរាល់១សប្តាហ៍ ឬ១០ថ្ងៃម្តង មានអ្នកទោសមួយចំនួនធំត្រូវឈ្លបនាំមកដាក់គុក ជួនកាលមានរហូតដល់ទៅ៨០នាក់ ឬ១០០នាក់ ជួនកាលលើសពីនេះទៀតក៏មាន ។ រឿង ជាអ្នកទទួលខុសត្រូវខាងចុះឈ្មោះនិងតាមដានប្រវត្តិរូបអ្នកទោស ។ ប្រជាជនមូលដ្ឋានត្រូវអង្គការបែកដាច់មិនឲ្យឡុកឡំជាមួយប្រជាជន១៧មេសាទេ ហើយរៀបចំឲ្យបុរសនិងស្ត្រីនៅកន្លែងផ្សេងពីគ្នា ។ ជួនកាលអ្នកទោសខ្លះត្រូវផ្ទេរទៅកាន់មន្ទីរសន្តិសុខផ្សេងៗទៀតដូចជា«មន្ទីរ១៥» នៅស្រុកកោះធំជាដើម ។ អ្នកទោសខ្លះត្រូវស្លាប់ដោយការអត់អាហារ ខ្លះទៀតត្រូវសម្លាប់នៅក្នុងគុកសង់តែម្តង ។ គ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឡើយ ។ ដោយសារមានអ្នកទោសចូលជាប្រចាំ បានធ្វើឲ្យចំនួនអ្នកទោសនៅគុកសង់កើនឡើងជាលំដាប់ ។

រឿង ប្រកែកថា គាត់មិនដែលបានសម្លាប់មនុស្សឡើយ គាត់គ្រាន់តែជាស្មៀនកត់ត្រាប៉ុណ្ណោះ ។ រឿង និយាយដូច្នេះថា «បញ្ជីដែលខ្ញុំធ្វើគឺធ្វើតែបញ្ជីអ្នកទោសប៉ុណ្ណោះ» ។ រឿង បានចង្អុលបង្ហាញគ្រឹះរបស់គុកដែលជាកន្លែងដាក់ប្រជាជនថ្មីថាអ្នកទោសរាប់រយនាក់ត្រូវបានឃុំឃាំងនៅទីនេះ ។ រៀងរាល់យប់យាមគករតែងតែមកនាំអ្នកទោសម្តងពី១៥ទៅ២០នាក់ ហើយបណ្តើរទៅកាន់កន្លែងសម្លាប់ចម្ងាយ១គីឡូម៉ែត្រពីគុកនេះ ហើយជនដៃដល់សុទ្ធតែមានបញ្ជីសម្លាប់នៅក្នុងដៃគ្រប់គ្នា ។ រឿង បានប្រកែកដាច់ខាត ព្រមទាំងឆ្លើយប្រាប់ពីការធ្វើបញ្ជីឈ្មោះនេះថា «ជារឿងសម្ងាត់»ទៅវិញ ។ ទោះជាយ៉ាងនេះក្តីក៏នៅមានប្រជាជនមួយចំនួនក្នុងភូមិត្រពាំងស្វាមួយចំនួនដែលមានគំនុំនឹង រឿង បានប្រាប់ថា រឿង ជាអ្នកធ្វើបញ្ជីឈ្មោះអ្នកទោស ។ ចំពោះការសម្លាប់មនុស្សយ៉ាងច្រើននៅគុកសង់អ្នកខ្លះបានទម្លាក់រឿងនេះទៅលើ តាម៉ុក លេខាភូមិភាគនិរតីថាបានបង្គាប់បញ្ជាឲ្យធ្វើការកាប់សម្លាប់នេះ ។ អតីតអ្នកទោសនៅគុកសង់ ដែលរួចខ្លួនពីសេចក្តីស្លាប់បាននិយាយពី តាម៉ុក ថាខស្សរាហ៍ចេញចូលគុកសង់ជាញឹកញយ ។ ចំណែកអតីតអ្នកយាមគុកសង់ម្នាក់និយាយថា «តាម៉ុក តែងតែចុះមកត្រួតពិនិត្យមើលគុកជានិច្ច ហើយពេលដែលគាត់ចុះមកមើលម្តងៗ ច្បាស់ជាមាន

យកមនុស្សទៅសម្លាប់មិនខាន» ។ ឆ្មាំគុកបន្តថា «តាំងពីឆ្នាំ ១៩៧៧ តាម៉ុក តែងមកគុកសង់រាល់សប្តាហ៍» ។ សាក្សីជាច្រើនបាននិយាយឲ្យដឹងពីការបោសសម្អាតរបស់ តាម៉ុក លើប្រធានគុកឈ្មោះ ម៉ុង និង ម៉េង ។ អតីតអ្នកទោសម្នាក់នៅគុកសង់ម្នាក់ឈ្មោះ ស៊ុម រីម បាននិយាយប្រាប់ពីការផ្លាស់ប្តូរមេគុកថា «ក្រោយពីអង្គការផ្លាស់ប្តូរ អាម៉ុង និង អាម៉េង ដែលជាអ្នកមើលការខុសត្រូវពីមុន តាសែម បានចូលមកកាន់កាប់ជំនួសវិញ» ។ អតីតឆ្មាំគុកសង់ និន ហ៊ឹម ក៏បានបញ្ជាក់អំពីវិធីសាហាវព្រៃផ្សៃក្នុងការគ្រប់គ្រងកម្មាភិបាលក្រោមបញ្ជារបស់ តាម៉ុក ។ ហ៊ឹម និយាយថា ពេលដែល តាម៉ុក កាន់កាប់តំបន់នេះក្នុងឆ្នាំ ១៩៧៧ ប្រធានគុកសង់ឈ្មោះ កាសេស ត្រូវបានសម្លាប់ដោយក្រុមមនុស្សថ្មីផ្សេងទៀត ។ ហេតុនេះហើយបានជា ម៉ុង ក្លាយជាប្រធានគុកសង់ ។ តាមសម្តីរបស់ និន ហ៊ឹម ឲ្យដឹងថា នៅពេលដែល តាម៉ុក សម្រេចចិត្តផ្លាស់ ម៉ុង ឃើញ «កូនចៅរបស់គាត់ក៏សម្លាប់ ម៉ុង ចោលភ្លាម» ។ ហ៊ឹម ត្រូវខ្មែរក្រហមហៅឲ្យមកធ្វើជាអ្នកយាមអ្នកទោសនៅគុកសង់ ប៉ុន្តែ ហ៊ឹម និយាយប្រាប់ថា «តាមពិតខ្មែរក្រហមតាមដានខ្ញុំទៅវិញទេ ព្រោះខ្ញុំត្រូវបានចោទប្រកាន់ថា ជាខ្មាំងដោយសារតែលួចគាស់ដំឡូងមីយកទៅដុតឲ្យអ្នកទោសស្ត្រីបួនប្រាំនាក់ដែលជាអ្នកទោសកម្រិតស្រាលហូប ។

ស៊ុម រីម ត្រូវចាប់ខ្លួនហើយបញ្ជូនមកដាក់គុកសង់នៅខែកក្កដា ឆ្នាំ១៩៧៧ ជាមួយនឹងកូនពីរនាក់ ។ ក្នុងអំឡុងពេលជាប់ឃុំ រីម មានផ្ទៃពោះជិតគ្រប់ខែទៅហើយ ។ ប្តីរបស់គាត់ត្រូវចាប់ខ្លួននៅខែមករា ឆ្នាំ១៩៧៧ ដោយចោទប្រកាន់ថា គាត់ធ្លាប់ធ្វើជាសមាជិកគណៈកម្មាធិការឃុំ ។ ក្រោមការធ្វើទារុណកម្មនៅគុកសង់រួមនឹងបទល្មើសជាច្រើនទៀតរបស់ប្តីគាត់ ទើបធ្វើឲ្យខ្មែរក្រហមចោទប្រកាន់ប្តីគាត់ថា ជាភ្នាក់ងារសម្ងាត់សូវៀត កា.ហ្សេ.បេ ទៀតផង ។ ឆ្មាំគុកស្រីម្នាក់ឈ្មោះ ប៊ុន ដែលមើលការខុសត្រូវផ្នែកអ្នកទោសនារីបានប្រាប់ រីម ថាប្តីរបស់គាត់ត្រូវឈ្លបវាយធ្វើបាបយ៉ាងដំណំរហូតដល់ទ្រាំលែងបានក៏ធ្វើអត្តឃាត ។ ចំណែក តៅ សំអឿន មិនមានសំណាងដូច ស៊ុម រីម ឡើយ ។ នៅដើមឆ្នាំ១៩៧៨ សំអឿន ត្រូវកងឈ្លបចាប់ខ្លួន ។ ប្តីរបស់គាត់បាត់ខ្លួនក្រោយពីជាប់គុករយៈពេលដ៏ខ្លី ។ ដូចជាស្ត្រីដទៃៗទៀតដែរ ទោសរបស់ សំអឿន បណ្តាលមកពីគាត់រៀបការជាមួយបុរសម្នាក់ដែលអង្គការចោទថាជា«ខ្មាំង» ។ ព្រមជាមួយនេះ កូនស្រីម្នាក់និងកូនប្រុសពីរនាក់ទៀតរបស់គាត់ក៏ត្រូវកងឈ្លបសម្លាប់នៅក្នុងគុកសង់ដែរ ។ ទោះបីជា សំអឿន ត្រូវខ្មែរក្រហមទុកជីវិតឲ្យក៏ដោយ ក៏ សំអឿន ត្រូវបង្ខំឲ្យធ្វើការងារជាទម្ងន់ដូចជា គាស់គល់ឈើនៅក្នុងភក់ជាដើម ។ បច្ចុប្បន្នស្ត្រីមេម៉ាយរូបនេះបានបួសជាដូនជីនៅវត្តកោះប៊ុនលី ។ បាន សុខឃឹន ត្រូវចាប់ខ្លួននិងដាក់ឃុំឃាំងនៅគុកសង់ក្រោយពេលខ្មែរក្រហមចាប់ប្តីរបស់គាត់យកទៅកាលពី២-៣ខែមុន ។ នៅក្នុងគុក សុខឃឹន ត្រូវកងឈ្លបបង្អត់អាហារជាច្រើនថ្ងៃ ព្រមទាំងវាយដំដោយដំបងឫស្សីផង ។ សុខឃឹន និយាយថា «ពេលពួកវាសួរចម្លើយ បើយើងឆ្លើយវាមិនវាយទេ ប៉ុន្តែបើយើងមិនឆ្លើយ ពួកវាច្បាស់ជាវាយមិនខាន» ។ អ្នកទោសត្រូវបង្ខំឲ្យដេកផ្ទាល់ឥដ្ឋដោយគ្មានអ្វីដណ្តប់ខ្លួនប្រាណឡើយ ។

នៅខែកញ្ញា ឆ្នាំ១៩៧៧ ឈឹម សូម៉ាលី ត្រូវខ្មែរក្រហមចាប់ខ្លួនយកទៅជាមួយមនុស្ស៨៥នាក់ផ្សេងទៀត ។ «ខ្មែរក្រហមបានយកខ្ញុំទៅគុកសង់ទន្លេបាទី ។ ពួកវាបាននាំខ្ញុំយកទៅសម្លាប់ជាមួយមនុស្សទាំង៨៥នាក់ ហើយស្លាប់ទាំងអស់នៅសល់តែរូបខ្ញុំម្នាក់...» ។ សូម៉ាលី បានរៀបរាប់អំពីស្ថានភាពនៅគុកសង់ថា «យើងត្រូវធ្វើកិច្ចការទាំងអស់តាំងពីវែកដីរហូតដល់ដឹកដីដកស្ទូង ពេលយើងវែកដី កងឈ្លបបានដាក់ច្រវាក់ជាប់ជើងទាំងពីរ ។ ពួកវាតែងតែដាក់ច្រវាក់ជានិច្ចមិនមែនចាំតែពេលចូលគុកទើបវាដាក់ច្រវាក់ទេ... ។ ខ្នោះនោះធ្វើអំពីដែក ទំហំប្រហែលប៉ុនចម្រឹងបង្អួច ដោយពត់ឲ្យជារង្វង់ត្រឹមភ្នែកគោ រួចហើយធ្វើប្រហោងដើម្បីស៊កដែកវែងមួយដែលដាក់បានមនុស្សប្រហែល ១០នាក់ក្នុងមួយជួរៗ ។ ក្នុងមួយបន្ទប់មាន១០ជួរ ក្នុងមួយជួរៗមាន១០នាក់ ។ ខ្មែរក្រហមមិនដោះលែងអ្នកណាម្នាក់ទេ» ។ ស្ត្រីអ្នកភូមិម្នាក់ទៀតបានក្លាយជាអ្នកទោសនៅគុកសង់តាមរបៀបផ្សេងពីគេ ។ ឈឹម ស៊ិន ឆ្ងល់ថាហេតុអីបានជាប្តីគាត់មិនមកជួបគាត់រៀងរាល់១០ថ្ងៃម្តងតាមការអនុញ្ញាតរបស់អង្គការដូច្នេះ? ។ ក្រោយមកមានមនុស្សម្នាក់មកប្រាប់ថា ប្តីរបស់គាត់

ត្រូវខ្មែរក្រហមចាប់យកទៅដាក់នៅគុកសង់ហើយ ។ ពេលដឹងភ្លាមគាត់ក៏ធ្វើដំណើរទៅរកប្តីភ្លាម ។ ពេលទៅដល់គុក កម្មាភិបាលខ្មែរក្រហមវ័យក្មេងៗជាច្រើននាក់បានឃាត់គាត់មិនឲ្យទៅរកប្តីទេ ហើយថែមទាំងប្រើពាក្យសម្តីមិនសមរម្យផ្សេងៗ ។ ក្រោយមកកម្មាភិបាលខ្មែរក្រហមវ័យក្មេងៗទាំងនោះក៏ចាប់គាត់ដាក់គុកតែម្តង ។ ស៊ិន បានក្លាយជាអ្នកទោសរហូតដល់ខែមករា ឆ្នាំ១៩៧៩ ។ ពេល ស៊ិន ជាប់គុកសង់គាត់បានឃើញព្រឹត្តិការណ៍ជាច្រើន ។ "ក្នុងមួយលើកៗមានប្រជាជន៧០ ឬ ៨០នាក់ ត្រូវបាននាំចេញពីភូមិ ។ អ្នកដែលត្រូវនាំយកទៅនោះ ត្រូវស្លាប់ទាំងអស់គ្មានអ្នកណាម្នាក់រួចខ្លួនឡើយ" ។

ពេលរបបខ្មែរក្រហមដួលរលំភ្លាម អ្នកស្រុកអ្នកភូមិក៏ក្រោកឈរឡើង ហើយចាប់កម្មាភិបាលខ្មែរក្រហមដែលនៅសេសសល់ទុកមួយកន្លែង ។ អាជ្ញាធរថ្មីនិងប្រជាជនបាននាំខ្លួនអតីតខ្មែរក្រហមនិងកម្មាភិបាលដែលធ្វើការនៅក្នុងគុកសង់ជាច្រើននាក់នាំយកទៅវាលពិឃាតនៅជិតគុកសង់ បន្ទាប់មកបង្ខំឲ្យជីករណ្តៅសាកសពរួមនៅទីនោះ ។ សួស ម៉ៅ ភេទប្រុស អាយុ៥១ឆ្នាំ នៅភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បាននិយាយរឿងរ៉ាវដែលកើតមាននៅក្នុងគុកសង់ទាំងមានជំងឺប្រចាំកាយថា គាត់ជាឆ្មាំគុកមួយរូបដែលមានតួនាទីឈរយាមអ្នកទោសនៅគុកសង់ក្នុងឆ្នាំ១៩៧៧ ។ អ្នកទោសទាំងអស់ដែលស្លាប់ដោយសារការសម្លាប់នៅក្នុងគុកសង់គឺគាត់ (សួស ម៉ៅ) មិនបានដឹងឡើយ ព្រោះគាត់គ្រាន់តែជាអ្នកបណ្តើរអ្នកទោសយកទៅធ្វើការនិងយកមកដាក់នៅក្នុងគុកវិញប៉ុណ្ណោះ ។ ម៉ៅ បន្តថា កងឈ្លបច្រើនដឹកអ្នកទោសយកទៅសម្លាប់នៅពេលយប់ ។ ពេលដឹកចេញម្តងៗ ខ្មែរក្រហមឲ្យអ្នកយាមឈប់សម្រាក ហើយឲ្យចេញពីកន្លែងយាមសិន ។ ម៉ៅ មិនដឹងថាមានការសម្លាប់មនុស្សនៅគុកសង់ឡើយ ក្នុងរយៈពេលដែលគាត់បំពេញការងារនៅក្នុងទីនោះ ។ ម៉ៅ ទើបតែបានដឹងច្បាស់ក្រោយពេលគាត់ត្រឡប់មកភូមិវិញនៅឆ្នាំ១៩៧៩ប៉ុណ្ណោះ គឺនៅពេលរដ្ឋអំណាចឲ្យគាត់ទៅគាស់រណ្តៅសាកសពនៅក្នុងបរិវេណគុកសង់ដែលធ្វើឲ្យគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ម៉ៅ មិនបានទទួលរងការធ្វើបាបមកលើរូបរាងកាយពីសំណាក់ប្រជាជននៅក្នុងភូមិឡើយ ប៉ុន្តែ ម៉ៅ បាននិយាយថា មានការសងសឹកភ្លាមៗដែរទៅលើជនដៃដល់ជាច្រើននាក់ដែលប្រជាជនកំណត់មុខសញ្ញាយ៉ាងច្បាស់លាស់ថា ពិតជាបានសម្លាប់អ្នកទោសអស់យ៉ាងច្រើននៅគុកសង់នេះ ដូចជាប្រធានគុកសង់ឈ្មោះ ម៉ុង និងអនុប្រធានឈ្មោះ ម៉េង ជាដើម ។ នៅចុងឆ្នាំ១៩៧៨ ម៉ុង ត្រូវខ្មែរក្រហមគ្នាឯងតាមរកចាប់ខ្លួនមកសម្លាប់ចោល ដោយសារស៊ើបដឹងថាមានជាប់ទាក់ទងនឹងខ្មែរយួន ។ ប្រពន្ធរបស់ ម៉ុង ជាខ្មែរកម្ពុជាក្រោម ដែលមានឪពុកមិនចេះនិយាយខ្មែរសោះ ។ អ្នកនៅរស់មួយចំនួនបានទៅរកមើលភស្តុតាងក្រែងមាននៅសេសសល់របស់របរអ្នកជាទីស្រឡាញ់របស់ខ្លួនដែលបាត់បង់ជីវិតទៅ ។ ព្រះចៅអធិការវត្តក្រូចសើច ព្រះនាម ពេញ សាម៉ន បានមានសង្ឃដីកាថា នៅឆ្នាំ១៩៧៩ ប្រជាជនបានជីករណ្តៅសាកសពរួមនៅទន្ទេបាទីដែលមានចំនួនប្រហែលពី៣០ទៅ៦០រណ្តៅ ។ អដ្ឋិធាតុជនរងគ្រោះត្រូវបានជីកយកមកដាក់នៅក្នុងអតីតអគារគុក ។ ប៉ុន្តែ រយៈពេលជាច្រើនឆ្នាំក្រោយមកមានអ្នកស្រុកអ្នកភូមិខ្លះបាននាំគ្នាទៅរុះរើដំបូលគុកសង់យកមកធ្វើផ្ទះសម្បែងរៀងៗខ្លួន ។ ២០ឆ្នាំក្រោយមក អដ្ឋិធាតុជនរងគ្រោះរាប់ពាន់នាក់ដែលស្ថិតនៅទីនោះបានចាប់ផ្តើមពុកផុយ ។ ព្រះចៅអធិការវត្តក្រូចសើចបានសម្រេចព្រះទ័យថា ត្រូវតែជួយថែរក្សាអដ្ឋិធាតុនេះដើម្បីឲ្យប្រជាជនចងចាំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ហើយព្រះអង្គបានដឹកនាំកសាងស្តូបមួយនៅក្បែរអគារគុកនោះដើម្បីតម្កល់អដ្ឋិធាតុ ។ "អាត្មាសង្កេតឃើញថា អដ្ឋិធាតុគ្មានអ្នកណាថែរក្សាឲ្យបានត្រឹមត្រូវឡើយ គឺនៅហាលថ្ងៃ ហាលភ្លៀងហាលខ្យល់ទៅជាពុកផុយអស់ ថែមទាំងត្រូវសត្វគោស៊ីទៀតផង ។ ដោយហេតុនេះអាត្មាគិតថា ប្រសិនបើអដ្ឋិធាតុស្ថិតនៅក្នុងសភាពបែបនេះវានឹងបាត់បង់អស់ជាមិនខាន ហើយភស្តុតាងនឹងត្រូវរលាយបាត់" ។

ដូច្នេះហើយបានជានៅចុងឆ្នាំ១៩៩៩ ព្រះសង្ឃបានបិណ្ឌបាត្រចរិកាពីសប្បុរសជននានាយកមកសង់បូជនីយដ្ឋានថ្មីមួយជាប់នឹងទីតាំងគុកសង់និងរៀបពិធីធំមួយដើម្បីដង្ហែអដ្ឋិធាតុជនរងគ្រោះដែលជាស្នាដៃរបស់ តាម៉ុក ពីគុកសង់មកតម្កល់ក្នុងបូជនីយដ្ឋានថ្មីនេះ ។ ព្រះចៅអធិការវត្តមានដីកាថា រដ្ឋាភិបាលមានផែនការរុះរើសំណង់គុកចាស់ ហើយសង់ជាសាលារដ្ឋបាលជំនួសវិញ ។

បើផែនការនេះត្រូវសម្រេចមែននោះ ភស្តុតាងនៃគុក ព្រមទាំងរណ្តៅសាកសពរួមដែលមិនទាន់ជីកនឹងត្រូវបាត់បង់ ហើយនៅសល់តែការចងចាំប៉ុណ្ណោះ ។ អ្នកនៅរស់រានមានជីវិតម្នាក់ឈ្មោះ ស៊ុម រីម មានអនុស្សាវរីយ៍ឈឺចាប់ជាច្រើនដោយគាត់បានរំឭកថា ក្រោយឆ្នាំ១៩៧៩ ពេលប្រជាជនជីករណ្តៅរួមនៅគុកសង់ អ្នកស្រុកបានប្រទះឃើញមានទារកតូចៗដែលខ្មែរក្រហមសម្លាប់ដោយរុំខ្ចប់នឹងថង់ផ្លាស្ទិក ហើយបោះចូលក្នុងរណ្តៅពីលើសាកសពឪពុកម្តាយ ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ គុកសង់ ស្ថិតនៅក្នុងភូមិត្រពាំងស្វា ឃុំទ្រា ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

**ស្ថិតិ** ៖ គុកសង់ ជាអតីតសាលាបណ្តុះបណ្តាលគរុកោសល្យ និងវិក្រឹត្យការចំពោះគរុនិស្សិតទាំងឡាយដែលមានបំណងក្លាយខ្លួនជាគ្រូបង្រៀនដ៏ល្អម្នាក់ទៅអនាគត ។ នៅឆ្នាំ១៩៧៧ សាលារៀននេះបានប្រែឈ្មោះទៅជា"គុកសង់" បន្ទាប់ពីខ្មែរក្រហមជួសជុលរួច ។ អ្នកទោសជាច្រើនត្រូវឈ្លបខ្មែរក្រហមសម្លាប់តាមវិធីបង្អត់បាយ យកទៅសម្លាប់ និងធ្វើទារុណកម្មយ៉ាងសាហាវ ។ ការឃុំឃាំងអ្នកទោសត្រូវបែងចែកផ្សេងពីគ្នា គឺបុរសមួយផ្នែក និងនារីមួយផ្នែក ។ រហូតមកដល់សព្វថ្ងៃជនដៃដល់និងជនរងគ្រោះមួយចំនួននៅរស់រានមានជីវិតនៅឡើយ ហើយស្ថិតនៅក្នុងភូមិជាមួយគ្នា និងក្បែរៗគ្នាទៀតផង ។

## ស្រុកកៀនស្វាយ

### ៧) មន្ទីរសន្តិសុខវត្តចំពុះក្អែក

វត្តចំពុះក្អែក ជាវត្តចំណាស់មួយស្ថិតនៅក្នុងឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ នៅឆ្នាំ១៩៧៦ ព្រះវិហារវត្តចំពុះក្អែកទាំងមូលត្រូវអង្គការខ្មែរក្រហមយកធ្វើជាកន្លែងឃុំឃាំង និងសម្លាប់មនុស្សយ៉ាងសាហាវនិងបណ្តេញព្រះសង្ឃ ព្រមទាំងឧបាសកឧបាសិកាចេញពីវត្ត ។ អ្នកទោសរាប់ពាន់នាក់ ដែលជាប់ឃុំឃាំងក្នុងវត្តចំពុះក្អែក គឺមានទាំងប្រជាជនថ្មីនិងប្រជាជនមូលដ្ឋាន ក្រៅពីនេះសុទ្ធតែជាកងទ័ពភូមិភាគបូព៌ា ។

សាយ អ៊ឹម ភេទប្រុស អាយុ៦៨ឆ្នាំ ជាប្រជាជនមូលដ្ឋានដែលជាប់គុកនៅមន្ទីរសន្តិសុខវត្តចំពុះក្អែកពីបទចោទប្រកាន់គាត់ថាបានលួច(អាហារបន្ថែម)ពីវត្តចំពុះក្អែក និងពីសហករណ៍ទៅឲ្យខ្មាំងដែលលាក់ខ្លួននៅទួលប្រទាង ជាកន្លែងដែល អ៊ឹម ធ្លាប់បានចូលទៅកាប់ឫស្សីនៅទីនោះដើម្បីយកមកធ្វើជាកញ្ច្រែងចិញ្ចឹមដង្កូវនាង ។ អ៊ឹម ត្រូវកងឈ្លបចងស្លាបបណ្តើរទៅកាន់មន្ទីរសន្តិសុខវត្តចំពុះក្អែក ។ ថ្វាង ប្រធានមន្ទីរសន្តិសុខវត្តចំពុះក្អែក ជាអ្នកបញ្ជាផ្ទាល់ឲ្យកងសន្តិសុខនាំ អ៊ឹម ទៅកាន់កន្លែងសួរចម្លើយដែលស្ថិតនៅខាងជើងព្រះវិហារ ។ ថ្វាង មានស្រុកកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ពេលទៅដល់មន្ទីរសួរចម្លើយ កងឈ្លបបានអានពីទោសកំហុសឲ្យ អ៊ឹម ស្តាប់តាមរយៈពាក្យ បណ្តឹងពីភូមិថា "អ៊ឹមបានសេពគប់ជាមួយខ្មាំងដែលជាចោរលួច" ។ អ៊ឹម ត្រូវកងឈ្លបយកកៅអីឈើនិងដំបងឫស្សីដែលទើបតែកាប់ថ្មីៗវាយធ្វើបាប ដោយសារ អ៊ឹម មិនបានឆ្លើយតាមអ្វីដែលកងសន្តិសុខចង់បាន ។ បន្តិចក្រោយមក អ៊ឹម ត្រូវកងឈ្លបនាំចេញពីកន្លែងសួរចម្លើយដោយដាក់ច្រវាក់ឃុំឃាំងជាមួយអ្នកទោសបុរសផ្សេងទៀតដែលជាប់នៅក្នុងកុដិនិងសាលាបាលីប៉ែកខាងត្បូងព្រះវិហារ ។ ការឃុំឃាំងត្រូវបែងចែកជាពីរផ្នែកគឺមួយផ្នែកជាប្រភេទអ្នកទោសស្ត្រីដែលកងឈ្លបដាក់ឃុំឃាំងនៅក្នុងសាលា-



វត្តចំពុះក្អែក ភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល

រៀន ។ ចំណែកអ្នកទោសបុរសត្រូវកងសន្តិសុខដាក់ឃុំឃាំងក្នុងព្រះវិហារ សាលាបាលី និងកុដិមួយចំនួន ។ ប៊ុន សឿន ភេទស្រី និយាយថា អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងសាលាបាលីត្រូវកងឈ្លបចាប់សម្រាតខោអាវទាំងអស់ ទើបដាក់ខ្នោះជាក្រោយ ។ អ៊ុម និយាយពីពេលបន្ទោរបង់តូច-ធំម្តងៗថា ខ្មែរក្រហមបានប្រគល់កេសគ្រាប់អាមេរិកាំងមួយឲ្យអ្នកទោសដែលជាប់ខ្នោះ ។ ប្រសិនបើនរណាចង់បន្ទោរបង់ត្រូវហុចកេសគ្រាប់បន្តគ្នាទៅឲ្យអ្នកបន្ទាប់ទៀត ។ ពេលលាមកពេញកេស កងឈ្លបបញ្ជាឲ្យអ្នកទោសយកទៅចាក់នៅលើបល្ល័ង្កព្រះដែលធំជាងគេក្នុងព្រះវិហារ ឬនៅសាលាបាលី ។ ក្រៅពីធ្វើពលកម្មយ៉ាងហួសកម្រិត អ្នកទោសម្នាក់ៗបានទទួលរបបអាហារតែបបររាវកក្កូកមួយកាដឹកទឹកប៉ុណ្ណោះ ។ អ៊ុម បន្ថែមថា ជួនកាលកងសន្តិសុខបានឲ្យអ្នកទោសហូបបបរពោតក្រហមដែលរាវកក្កូកជំនួសបបរអង្ករ ។ អ្នកទោសខ្លះត្រូវស្លាប់ដោយដាច់ពោះនិងខ្លះទៀតស្លាប់ដោយសារកងសន្តិសុខសម្លាប់បន្ទាប់ពីសួរចម្លើយ ។ ការសម្លាប់នេះ ជួនកាលកងសន្តិសុខធ្វើឡើងនៅក្នុងបរិវេណវត្តចំពុះក្អែក និងជួនកាលដឹកទៅតាមទូកយកទៅសម្លាប់នៅកោះគរ ស្រុកកោះធំ និងកោះថ្មី ស្រុកស្អាង ខេត្តកណ្តាល ឬសម្លាប់នៅកណ្តាលទន្លេក៏មាន ។ ប៊ុន សឿន ភេទស្រី អាយុ៤០ឆ្នាំ ជាអតីតអ្នកទោសម្នាក់នៅវត្តចំពុះក្អែក ត្រូវបានចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៧៦ ពីបទដើរហើរសេរី គ្មានការអនុញ្ញាត ហើយត្រូវកងឈ្លបនាំយកទៅដាក់ឃុំឃាំងជាមួយនារីបីនាក់ផ្សេងទៀតនៅក្នុងសាលារៀនមួយខ្នងដែលមានចាក់សោពីក្រៅ និងមានឈ្លបបីនាក់ឈរយាមផង ។ កងឈ្លបមិនបានដាក់ខ្នោះ សឿន ភ្លាមៗទេ ។ នៅពេលថ្ងៃ សឿន ត្រូវខ្មែរក្រហមបណ្តើរឲ្យធ្វើការនិងនៅពេលខ្លះគាត់ត្រូវអង្គការសួរនាំពីសតិអារម្មណ៍ចំពោះបដិវត្តន៍ទៀតផង ។ ក្រោយមក សឿន ត្រូវបានដោះលែងឲ្យធ្វើការនៅក្នុងមន្ទីរសន្តិសុខដោយគ្មានដាក់ខ្នោះ ។ សឿន និយាយថា ពេលគាត់នៅក្រៅឃុំ គាត់សង្កេតឃើញព្រឹត្តិការណ៍សម្លាប់មនុស្សរៀងរាល់ថ្ងៃ ។ អ្នកទោសខ្លះត្រូវជាប់ឃុំឃាំងនៅវត្តចំពុះក្អែករយៈពេលយូរ ហើយខ្លះទៀតជាប់មិនបានមួយថ្ងៃផងក៏ត្រូវនាំយកទៅសម្លាប់ ។ កងទ័ពខាងភូមិភាគបូព៌ា២៥នាក់ត្រូវខ្មែរក្រហមដឹកតាមរថយន្តកាំមីញ៉ុងមកឃុំទុកនៅសាលាមួយខ្នងផ្សេងទៀតក្នុងអំឡុងឆ្នាំ១៩៧៨ ។ មួយរយៈខ្លីក្រោយមក កងទ័ពទាំងនោះត្រូវកងឈ្លបយកទៅសម្លាប់ដោយបន្សល់ទុកតែឯកសណ្ឋាន២៥កំប្លេនៅក្រោមដើមខ្វិត និងដើមចំប៉ាប៉ែកខាងជើងព្រះវិហារប៉ុណ្ណោះ ។ សឿន រៀបរាប់ប្រាប់ពីការសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខវត្តចំពុះក្អែកថា កងឈ្លបបានចាប់បញ្ជូនអ្នកទោសតាមរថយន្តធំៗទៅដាក់ត្រឹមមាត់ទន្លេត្រង់កោះក្របី ហើយផ្ទេរអ្នកទោសដាក់កាណូតដឹកយកទៅសម្លាប់នៅទីតាំងពិឃាតកោះគរ កោះថ្មី និងកណ្តាលទន្លេបាសាក់ ។ អ្នកទោសប្រភេទនេះ ជាទាហានលន់នល់ មានឋានៈចាប់ពីស័ក្តិមួយឡើងទៅ ឬអ្នកជាប់និន្នាការនយោបាយពីសង្គម ។ ចំណែកអ្នកទោសជាប្រជាជនធម្មតាត្រូវកងឈ្លបសម្លាប់នៅក្នុងបរិវេណវត្តចំពុះក្អែកតែម្តង ។ អ្នកទោសទាំងពីប្រភេទនេះត្រូវកងឈ្លបសម្លាប់ដោយវះពោះនិងកាត់ប្រមាត់ប្រកថង់ ។ ប៊ុន សឿន ជាអ្នកធ្លាប់ព្យួរហាលប្រមាត់មនុស្សទាំងអស់ដោយផ្ទាល់ដៃ ។ នៅពេល សឿន ឈឺគាត់ត្រូវអង្គការផ្តល់ប្រមាត់មនុស្សឲ្យផឹកដើម្បីព្យាបាលជំងឺ ។ ក្នុងពេលជាមួយគ្នា សាយ អ៊ុម ត្រូវបានដោះលែងឲ្យមកធ្វើជាចុងភៅប្រចាំមន្ទីរសន្តិសុខវិញ ។ ពេលនោះហើយដែលគាត់ប្រទះឃើញប្រមាត់ជាច្រើនដែលទើបតែកាត់ថ្មីៗដាក់ហាលនៅលើចេតិយ ។

ក្រោយថ្ងៃរំដោះខែមករា ឆ្នាំ១៩៧៩ ប្រមាត់ខ្លះត្រូវក្រៀមស្វិត ហើយខ្លះទៀតនៅសើមៗនៅឡើយ ។ សឿន បានប្រាប់ថា គាត់ជាអ្នកប្រមូលប្រមាត់ទាំងនោះដាក់ក្នុងទៃចំនួនបីដែលក្នុងទៃនីមួយៗមានចំណុះប្រហែលមួយតៅ ។ សព្វថ្ងៃនេះ វត្តចំពុះក្អែក ជាវត្តមួយមានលក្ខណៈ និងរូបរាងល្អផ្តាច់គេនៅក្នុងស្រុកកៀនស្វាយ ។

## ទិន្នន័យសង្ខេប

**ទីតាំង** : វត្តចំពុះក្អែកស្ថិតនៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**ស្ថិតិ** : វត្តចំពុះក្អែកត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខនៅឆ្នាំ១៩៧៦ ។ មន្ទីរសន្តិសុខនេះមានឃុំឃាំងជនរងគ្រោះជាប្រជាជនថ្មីនិងប្រជាជនចាស់ ព្រមទាំងកងទ័ពភូមិភាគបូព៌ាផង ។ អ្នកទោសត្រូវបានសម្លាប់យ៉ាងឃោរឃៅនៅ

ក្នុងបរិវេណវត្តចំពុះក្អែក នៅកណ្តាលទន្លេបាសាក់ និងនៅទីតាំងសម្លាប់កោះថ្មី និងកោះគរ ក្នុងស្រុកកោះធំ ។

## ស្រុកខ្សាច់កណ្តាល

### ៣) មន្ទីរសន្តិសុខសាលាសន្ទុង

សាលារៀនសន្ទុង ជាមូលដ្ឋានរបស់កងទ័ពខ្មែរក្រហមតាំងពីប្រទេសធ្លាក់ក្នុងភ្នក់ភ្លើងសង្គ្រាមម៉េះ ។ បន្ទាប់ពីថ្ងៃរំដោះ១៧ ខែមេសា ឆ្នាំ១៩៧៥ ទីតាំងនេះបានប្រែក្លាយទៅជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់អ្នកទោសវិញ ។ នៅឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីបានចូលកាន់កាប់មុខតំណែងជំនួសកម្មាភិបាលដែលធ្លាប់គ្រប់គ្រងពីមុន ។ កម្មាភិបាលថ្មីនេះបានអនុវត្តផែនការកម្ទេចកម្មាភិបាលខ្មែរក្រហមខាងភូមិភាគបូព៌ាទាំងអស់តាំងពីគណៈភូមិរហូតដល់គណៈស្រុក ព្រោះអង្គការចោទប្រកាន់ថាបានរួមគំនិតក្បត់បដិវត្តន៍ជាមួយមេកោយរបស់ខ្លួន ។ ការធ្វើទារុណកម្មយ៉ាងសាហាវចំពោះអ្នកទោសទាំងនោះបានកើតមាននៅក្នុងមន្ទីរសន្តិសុខសាលាសន្ទុង ហើយបន្ទាប់មកត្រូវកងឈ្លបយកទៅសម្លាប់ចោលទាំងអស់ ។ ចំណែកអ្នកទោសដែលជាប់ពីមុនមកគឺដោយសាររឿងរ៉ាវផ្សេងៗក្រៅពីអំពើក្បត់ដូចជាករណី ឡូញ ឡូញ ជាដើម អាចទទួលបានការបន្ធូរបន្ថយទោសខ្លះ ។ ឡូញ ប្រាប់ថា គាត់ជាកម្មាភិបាលថ្នាក់ទាបម្នាក់នៅក្នុងភូមិភាគបូព៌ា ដែលមានតួនាទីដឹកនាំប្រជាជនធ្វើស្រែ ប៉ុន្តែគាត់ត្រូវបានចាប់ខ្លួនមកដាក់ក្នុងមន្ទីរឃុំឃាំងអស់រយៈពេល៧ខែនិង៣ថ្ងៃ ដោយសារបានប្រព្រឹត្តខុសសីលធម៌ជាមួយនារីម្នាក់រហូតបែកការណ៍ ។ អ្នកទោសស្ទើរទាំងអស់ត្រូវបាននាំយកទៅសម្លាប់នៅក្នុងបិរវេណវត្តសន្ទុង និងនៅក្នុងស្រះចាស់មួយខាងក្រោយសាលារៀន ។ ឡូញ បានរួចខ្លួនពីការសម្លាប់នេះ ។ នង សុជាត ជាអ្នកធ្លាប់ជាប់ឃុំឃាំងជាមួយ ឡូញ នៅមន្ទីរឃុំឃាំងសាលារៀនសន្ទុងដែរ ហើយសព្វថ្ងៃរស់នៅកោះខកញ៉ាតី ។

### ទិន្នន័យសង្ខេប

**ទីតាំង** ៖ សាលារៀនសន្ទុងស្ថិតនៅភូមិវិហារសួគ៌ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

**ស្ថិតិ** ៖ សាលារៀនសន្ទុងបានក្លាយទៅជាមន្ទីរសន្តិសុខកាលពីជំនាន់ខ្មែរក្រហម ។ នៅឆ្នាំ១៩៧៧ អ្នកទោសដែលជាប់នៅក្នុងនោះមានលាយចម្រុះគ្នារួមទាំងកម្មាភិបាលខ្មែរក្រហមដែលមានឋានៈចាប់ពីជាគណៈឃុំឡើងទៅ ត្រូវបាននាំយកទៅសម្លាប់ចោលទាំងអស់ ។

### ៤) មន្ទីរសន្តិសុខចម្ការស៊ីវ

ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខមួយប្រចាំស្រុកខ្សាច់កណ្តាលនៅលើផ្ទះចំនួនពីរខ្នង ដែលមានឈ្មោះថា មន្ទីរសន្តិសុខចម្ការស៊ីវ ដែលមួយខ្នងជាកម្មសិទ្ធិរបស់ឈ្មោះ ហ៊ុន ឡេង និងមួយខ្នងទៀតជាកម្មសិទ្ធិរបស់ឈ្មោះ ប៉ាន់ បេងហ៊ុន ។ ចំណែកផ្ទះរបស់ ម៉ឹង ម៉ៅចំរើន គឺជាកន្លែងស្នាក់នៅរបស់ប្រធានសន្តិសុខឈ្មោះ សូនី ។

ជនរងគ្រោះដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះភាគច្រើនជាប្រជាជនចាស់ អ្នកទោសត្រូវកងឈ្លបដាក់ខ្នោះជាប់គ្នាជាជួរៗ ដែលក្នុងមួយជួរៗមានអ្នកទោស៩នាក់ ។ ការសួរចម្លើយបានធ្វើឡើងស្ទើរតែរៀងរាល់ថ្ងៃ ។ អ្នកទោសខ្លះត្រូវកងសន្តិសុខធ្វើទារុណកម្មតាមវិធីរុកដែកក្តៅចូលក្នុងខ្លួន និងខ្លះទៀតត្រូវវាយបំបាក់កដៃកជើង ។

មឿង ហ៊ីល ជាអតីតអ្នកទោសម្នាក់នៅក្នុងមន្ទីរសន្តិសុខចម្ការស៊ីវដែលនៅមានជីវិតរហូតមកដល់បច្ចុប្បន្ននេះ ។ សព្វថ្ងៃ ហ៊ីល មានអាយុ៧២ឆ្នាំ រស់នៅក្នុងភូមិព្រែកតាមាក់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ។ ក្នុងពេលជាប់ឃុំឃាំង ហ៊ីល បានឃើញកងឈ្លបធ្វើទារុណកម្មអ្នកទោសសព្វបែបយ៉ាង ។ ដោយសារ ហ៊ីល ជាអតីតទាហានលន់នល់ គាត់ត្រូវខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៦ ។ ហ៊ីល ត្រូវកងសន្តិសុខនាំយកទៅសួរចម្លើយ ព្រមទាំងឲ្យផ្តិតមេដៃលើចម្លើយសារភាពរបស់គាត់គ្រប់សន្លឹកទៀតផង ។ កុសល ក៏ជាអ្នកទោសនៅមន្ទីរសន្តិសុខចម្ការស៊ីវម្នាក់ដែរ ដោយសារបានលួចហូបចេកខ្ចីរបស់កម្មាភិបាលបម្រើការនៅក្នុងមន្ទីរឃុំឃាំងម្នាក់ដែលគ្រប់ទុក ។

ហុងគី បាននិយាយប្រាប់តាមពាក្យរបស់ តាសាំង ជាអ្នកធ្វើខ្នោះនៅមន្ទីរសន្តិសុខចម្ការស៊ីវថា កម្មាភិបាលធ្វើការនៅក្នុងគុកចម្ការស៊ីវម្នាក់បានសម្លាប់ឪពុកបង្កើតរបស់ខ្លួនឯងនៅឆ្នាំ១៩៧៨ ព្រោះចាត់ទុកគាត់ជាខ្មាំងរបស់អង្គការ ។ កម្មាភិបាល

វ័យក្មេងម្នាក់នោះបានស្តីបន្ទោសឪពុករបស់ខ្លួន ហើយត្រូវ តាសាំង លើកយកមកនិយាយប្រាប់ថា "អាកូនវាថា វាវ៉ៃខ្លាំងទេ មិនមែនវ៉ៃឪវាឯណា" ។ ឪពុកនោះត្រូវកូនបង្កើតធ្វើទារុណកម្មរហូតដល់ស្លាប់ ហើយក៏សែងយកទៅកប់ចោលនៅប៉ែកខាងក្រោយមន្ទីរឃុំឃាំង ។ តាសាំង សព្វថ្ងៃរស់នៅភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ។ ចំណែកកម្មាភិបាលខ្មែរក្រហមវ័យក្មេងម្នាក់ទៀត ត្រូវកម្មាភិបាលខ្មែរក្រហមឯទៀតបញ្ឆោតឲ្យទៅធ្វើការនៅប៉ែកខាងត្បូងមន្ទីរពេញមួយថ្ងៃ ព្រោះឪពុករបស់កម្មាភិបាលវ័យក្មេងនោះត្រូវឈ្លបនាំទៅសម្លាប់នៅប៉ែកខាងក្រោយមន្ទីរឃុំឃាំងនេះដែរ ។ នៅពេលត្រឡប់មកកាន់មន្ទីរសន្តិសុខវិញ គ្មានអ្នកណាម្នាក់បង្ហើបប្រាប់កម្មាភិបាលរូបនោះឲ្យដឹងពីការសម្លាប់ឪពុករបស់ខ្លួនឡើយ ប៉ុន្តែគាត់បានដឹងរឿងនេះ ដោយសារម្តាយរបស់គាត់និយាយប្រាប់ពេលដែលគាត់ទៅលេងផ្ទះ ។

ម៉ុយ ហុងគី អាយុ៦៩ឆ្នាំ បច្ចុប្បន្នរស់នៅភូមិអន្លង់ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ធ្លាប់រស់នៅក្បែរមន្ទីរសន្តិសុខចម្ការស៊ីវកាលពីជំនាន់ខ្មែរក្រហម ។ ហុងគី បានស្តាប់ឮសំឡេងអ្នកទោសស្រែកឲ្យជួយនៅពេលកងឈ្លបសួរចម្លើយម្តងៗ ។ រៀងរាល់ខែនៅថ្ងៃទី២៩ មានអ្នកទោសប្រមាណពី៥ ទៅ១០នាក់ត្រូវកងឈ្លបនាំយកទៅសម្លាប់នៅប៉ែកខាងកើតមន្ទីរសន្តិសុខចម្ងាយប្រហែល២០០ម៉ែត្រ ហើយបញ្ចូលអ្នកទោសថ្មីជំនួសវិញ ដែលជួនកាលក្នុងមួយខែមានចំនួនលើសពីអ្នកទោសដែលកងឈ្លបសម្លាប់ទៅទៀត ។ ហុងគី បញ្ជាក់ថា អ្នកទោសទាំងនោះច្រើនបញ្ជូនមកពី (ជន្លឹងជ្រៃធំ) ភូមិវិហារសួគ៌ ភូមិសន្ទុង និងឃុំកោះចូរ៉ាម ។ មឿង ហ៊ល ប្រាប់ថានៅពេលសម្លាប់អ្នកទោសម្តងៗ ខ្មែរក្រហមបានចាក់មេក្រូបន្លឺសំឡេងកងរំពង ដើម្បីបន្ទប់កុំឲ្យប្រជាជនដែលកំពុងបំពេញការងារឮសម្រែកជនរងគ្រោះ ។ ចំណែកនៅមន្ទីរសន្តិសុខវិញ ក៏ហាមឃាត់មិនឲ្យប្រជាជនធ្វើដំណើរឆ្លងកាត់ដែរ ។

នៅឆ្នាំ១៩៧៩ រណ្តៅសាកសពយ៉ាងច្រើននៅជុំវិញបរិវេណមន្ទីរសន្តិសុខចម្ការស៊ីវ បានបង្ហាញឲ្យឃើញភ័ស្តុតាងយ៉ាងច្បាស់ក្រឡែត ។ ហុងគី បានដើរជុំរណ្តៅសាកសពនៅពេលគាត់ដើររកគោដែលបាត់ ។ គាត់បានដើរជាន់ក្បាលខ្មោចដែលកប់ក្នុងដី និងឃើញផ្នូរនីមួយៗប្រេះបែកដោយសារសាកសពហើម ។ បច្ចុប្បន្នរណ្តៅទាំងនោះ ត្រូវរលុបអស់ដោយសារទឹកជំនន់ ។ ក្រៅពីរណ្តៅដែលប្រជាជនលប់ អតីតមន្ទីរសន្តិសុខនេះបានបន្សល់ទុកនូវផ្ទះមួយខ្នងរបស់មេសន្តិសុខចម្ការស៊ីវឈ្មោះសូនី ដែលបច្ចុប្បន្ន ម៉ឹង ម៉ៅចំរើន កំពុងរស់នៅ ។

## ទិន្នន័យសង្ខេប

**ទីតាំង** : ចម្ការស៊ីវស្ថិតនៅក្នុងភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

**ស្ថិតិ** : មន្ទីរសន្តិសុខប្រចាំស្រុកខ្សាច់កណ្តាលមួយត្រូវខ្មែរក្រហមបង្កើតឡើងដោយឲ្យឈ្មោះថា មន្ទីរសន្តិសុខចម្ការស៊ីវ ។ ជនរងគ្រោះដែលជាប់នៅក្នុងមន្ទីរសន្តិសុខចម្ការស៊ីវភាគច្រើនជាប្រជាជនមូលដ្ឋាន ហើយមានភាគតិចជាប្រជាជនជម្លៀស ។ នៅថ្ងៃទី២៩ រៀងរាល់ខែ ខ្មែរក្រហមបាននាំអ្នកទោសពី៥ ទៅ១០នាក់យកទៅសម្លាប់នៅប៉ែកខាងកើតមន្ទីរ សន្តិសុខចម្ងាយប្រហែល២០០ម៉ែត្រ ហើយចាប់ផ្តើមបញ្ជូនអ្នកទោសថ្មីចូលមកវិញ ។ ក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខចម្ការស៊ីវ បានបន្សល់ទុកផ្ទះមួយខ្នងដែលជាកម្មសិទ្ធរបស់ ម៉ឹង ម៉ៅចំរើន ។



ចម្ការស៊ីវ ភូមិកំពង់ដំរី ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

**ផេង ពងរ៉ាស៊ី**

# លទ្ធផលនៃការស្ទាបស្ទង់មតិនៅក្នុងដំណើរទស្សនកិច្ចអគារ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

***សំណួរទី១ ៖ តើលោក-អ្នកគិតថា ដំណើរទស្សនកិច្ចបែបនេះ មានសារប្រយោជន៍សម្រាប់លោក-អ្នកដែរឬទេ?***

***លទ្ធផល*** ៖ ប្រជាជន៤០៦ ក្នុងចំណោម៤០៩នាក់ ផ្តល់ចម្លើយថាដំណើរទស្សនកិច្ចនេះមានសារសំខាន់និងអត្ថប្រយោជន៍ចំពោះគាត់ ។

ក្រៅពីចម្លើយដូចខាងលើ ប្រជាជនបានចូលរួមផ្តល់មតិចំនួនបី ដែលមិនមានបញ្ជាក់ថាដំណើរទស្សនកិច្ចនេះមានសារប្រយោជន៍យ៉ាងណា ÷ ◆ ខ្ញុំគិតថាសវនាការមានសារប្រយោជន៍ខ្លាំងណាស់ ព្រោះសវនាការអាចបន្ធូរបន្ថយកំហឹង ភាពតានតឹងរបស់ប្រជាជន និងអ្នកដែលបានបាត់បង់ជីវិតក្នុងសម័យខ្មែរក្រហម ។ ◆ ក្នុងដំណើរទស្សនកិច្ចនេះ ខ្ញុំឃើញរូបភាពដ៏គួរឲ្យរន្ធត់ និងធ្វើឲ្យខ្ញុំកើតកំហឹងចងសងសឹកម្តងទៀត ◆ តាមរយៈដំណើរទស្សនកិច្ចនេះ ខ្ញុំបានទទួលព័ត៌មានទាក់ទិនទៅនឹងរបបខ្មែរក្រហមដ៏សាហាវឃោរឃៅ និងយល់ដឹងពីឧក្រិដ្ឋកម្មនានាដែលខ្មែរក្រហមបានប្រព្រឹត្តក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩ ។

**មតិប្រជាជនឆ្លើយតបទៅនឹងសំណួរទី១**

ការផ្សព្វផ្សាយព័ត៌មានស្តីពីរបបខ្មែរក្រហមគឺជាការសំខាន់ ។ របបខ្មែរក្រហមបានសម្លាប់ប្រជាជនរាប់លាននាក់និងធ្វើឲ្យប្រជាជនជាច្រើនចងកំហឹង ។

ដំណើរទស្សនកិច្ចមានភាពសំខាន់ ៖

- ព្រោះជនរងគ្រោះបានទទួលព័ត៌មានពិតស្តីពីតុលាការ ។
- បានមកឃើញអ្វីៗផ្ទាល់ភ្នែក ។
- បង្ហាញពីរបបនេះជារបបផ្តាច់ការសម្លាប់មនុស្សយ៉ាងឃោរឃៅ ។
- អាចឲ្យយើងចងចាំនូវរបបប្រល័យពូជសាសន៍ដ៏ឃោរឃៅដែលមិនធ្លាប់មានពីមុនមកនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ។
- សម្រាប់យើងក្នុងការណែនាំក្មេងជំនាន់ក្រោយឲ្យស្គាល់មុខឧក្រិដ្ឋជនពិតប្រាកដដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។
- ក្នុងនាមខ្ញុំជាមេឃុំមួយរូប ខ្ញុំគិតថា ដំណើរទស្សនកិច្ចមានសារសំខាន់ដល់ប្រយោជន៍ជាតិ និងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។
- ធ្វើឲ្យខ្ញុំកើតចិត្តអាណិតអាសូរដល់ជនរងគ្រោះពីសម័យខ្មែរក្រហមនិងធ្វើឲ្យខ្ញុំចងចាំជារៀងរហូត ។
- កាន់តែច្បាស់ក្នុងចិត្តថាអំពើប្រល័យពូជសាសន៍ បែបនេះពិតជាកើតមាននៅកម្ពុជាប្រាកដមែន ។ កាលពីមុនខ្ញុំមិនបានដឹងរឿងនេះឲ្យច្បាស់ទេ ។
- រំឭកឡើងវិញនូវការចងចាំដ៏ជូរចត់របស់ខ្ញុំ ព្រោះខ្ញុំផ្ទាល់បានទៅដល់កន្លែងប្រល័យពូជសាសន៍ ។
- ខ្ញុំសង្ឃឹមថាខ្ញុំនឹងអាចឆ្លើយបំភ្លឺនៅចំពោះមុខតុលាការ ។
- ខ្ញុំគិតថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានតួនាទីយ៉ាងសំខាន់ក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ ខ្ញុំសប្បាយចិត្តដែលមជ្ឈមណ្ឌលឯកសារកម្ពុជាជួយឧបត្ថម្ភដំណើរទស្សនកិច្ចនេះ ។
- បើគ្មានដំណើរទស្សនកិច្ចនេះ ខ្ញុំមុខជាមិនបានមកឃើញឧទាហរណ៍ជាក់ស្តែងពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ។
- ជួយការស្វែងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជាទាំងមូល ។

***សំណួរទីពីរ ៖ តើលោក-អ្នកគិតថា បានយល់ដឹងអ្វីខ្លះបន្ទាប់ពីបានចូលរួមដំណើរទស្សនកិច្ចនេះ ហើយដែលលោក-អ្នកអាចចែករំលែកការយល់ដឹងនោះទៅអ្នកស្រុក អ្នកភូមិផ្សេងទៀតបានទេ?***

***លទ្ធផល*** ៖ ទទួលបាន៤០៤ចម្លើយ ។ ចម្លើយមានបញ្ជាក់ ÷

- យល់ដឹងពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមចំនួន៦៥ចម្លើយ
- បានឃើញភស្តុតាងនិងទីកន្លែងជាក់ស្តែងចំនួន ២២០ចម្លើយ
- យល់កាន់តែច្បាស់ពីរបបប្រល័យពូជសាសន៍ចំនួន១៧៧

ចម្លើយ ◆ បានជួបជាមួយជនរងគ្រោះមកពីកន្លែងផ្សេងៗចំនួន ១១ចម្លើយ ។

**មតិប្រជាជនឆ្លើយតបទៅនឹងសំណួរទី២ ៖**

- បន្ទាប់ពីបានចូលរួមដំណើរទស្សនកិច្ចនេះ ខ្ញុំយល់ដឹងពីច្បាប់សម្រាប់តុលាការក្នុងការចោទប្រកាន់មេដឹកនាំខ្មែរក្រហម ។
- មានការឈឺចាប់ច្រើនពេករហូតមិនអាចបំភ្លេចបាន ។
- ពេលធ្វើដំណើរទស្សនកិច្ច ខ្ញុំឃើញកន្លែងខ្មែរក្រហមធ្វើទារុណកម្មមនុស្ស ហើយខ្ញុំរន្ធត់យ៉ាងខ្លាំងពេលខ្ញុំបានអានវិន័យសន្តិបាល១០ចំណុចរបស់ទួលស្លែង ។
- ពេលធ្វើដំណើរទស្សនកិច្ច ខ្ញុំយល់ដឹងពីសកម្មភាពនិងវិធីសម្លាប់មនុស្សដ៏ឃោរឃៅរបស់ខ្មែរក្រហមមកលើប្រជាជនខ្លួនឯង ។
- ខ្ញុំបានឃើញភ័ស្តុតាងជាទីកន្លែងនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ។
- ខ្ញុំរន្ធត់ចិត្តពេលដែលឃើញភ័ស្តុតាងជាក់ស្តែងនិងឧបករណ៍ធ្វើទារុណកម្មរបស់ខ្មែរក្រហម ។
- ខ្ញុំកាន់តែច្បាស់ក្នុងចិត្តថាអំពើប្រល័យពូជសាសន៍ពិតជាកើតឡើងមែនមិនមែនជារឿងប្រឌិតឡើយ ។
- ខ្ញុំបានសិក្សាអំពីដំណើរការក្នុងការបង្កើតតុលាការ ហើយខ្ញុំបានឃើញផ្ទាល់ភ្នែកនូវទីកន្លែងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។
- ខ្ញុំយល់កាន់តែច្បាស់នូវភាពសាហាវឃោរឃៅ យង់ឃ្នង់របស់ខ្មែរក្រហម និងអំពីវិធីដែលខ្មែរក្រហមប្រើក្នុងការសម្លាប់ប្រជាជនជាតិសាសន៍ដូចគ្នា ។
- ខ្ញុំមានការរន្ធត់ និងអាណិតអាសូរយ៉ាងខ្លាំងចំពោះជនរងគ្រោះដែលបានបាត់បង់ជីវិត ។
- ខ្ញុំគិតថាយើងមិនគួរផ្តល់ការលើកលែងទោសចំពោះឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ ត្រូវតែបញ្ជូនមេដឹកនាំទៅកាន់តុលាការខ្មែរក្រហមតុលាការ ។

***សំណួរទី៣៖ តើការយល់ដឹងនោះមានអ្វីខ្លះ? ចូលរៀបរាប់ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន?***

***លទ្ធផល ៖*** ទទួលបាន៤០៦ចម្លើយ ។ ប្រជាជនមកចូលរួមសុទ្ធតែបញ្ជាក់ថាគាត់នឹងចែកចាយព័ត៌មានដែលគាត់ទទួលបានតាមរយៈដំណើរទស្សនកិច្ចនេះ ។

ប្រជាជនមកចូលរួមនឹងផ្សព្វផ្សាយព័ត៌មានជូន ÷ ◆ អ្នកភូមិឬសមាជិករស់នៅក្នុងសហគមន៍ជាមួយគ្នាចំនួន៣០៦ចម្លើយ ◆ អ្នកជិតខាងចំនួន៦៣ចម្លើយ ◆ ក្រុមគ្រួសារនិងមិត្តភក្តិចំនួន ១០២ចម្លើយ ◆ និងក្មេងជំនាន់ក្រោយចំនួន២៣ចម្លើយ ។

ទីកន្លែងដែលប្រជាជនមកចូលរួមនិងធ្វើការផ្សព្វផ្សាយព័ត៌មាន ÷ ទីវត្តអារាមនិងបុណ្យទានផ្សេងៗ ការប្រជុំតាមភូមិ និងសាលារៀន ។

**មតិប្រជាជនឆ្លើយតបទៅនឹងសំណួរទី៣**

- ខ្ញុំនឹងបង្រៀនក្មេងជំនាន់ក្រោយឲ្យចងចាំពីច្បាប់នេះ ដើម្បីកុំឲ្យមានការរំលោភសិទ្ធិមនុស្សនាថ្ងៃអនាគត ។ ទាំងប្រជាជននៅទីក្រុងនិងជនបទសុទ្ធតែចង់រស់នៅដោយសុខសន្តិភាព ។
- ខ្ញុំនឹងចែករំលែកចំណេះដឹងដែលទទួលបានពីដំណើរទស្សន-កិច្ច ដូចជាអ្វីដែលខ្ញុំបានឃើញនៅគុកទួលស្លែង និងវាលពិឃាតជើងឯក ។ ខ្ញុំនឹងប្រាប់អ្នកភូមិខ្ញុំតាមរយៈការប្រជុំតាមភូមិ និងជួយអប់រំក្មេងប្រុសស្រីជំនាន់ក្រោយ ។
- ក្នុងនាមខ្ញុំជាជនរងគ្រោះមួយរូប ខ្ញុំនឹងចែកចាយបទពិសោធន៍របស់ខ្ញុំជាមួយនឹងអ្នកភូមិឯទៀត ។
- ខ្ញុំនឹងចែករំលែកអ្វីដែលខ្ញុំបានស្តាប់ឮនិងមើលឃើញផ្ទាល់ភ្នែកដល់អ្នកភូមិខ្ញុំ ហើយកាន់តែប្រសើរប្រសិនបើខ្ញុំមានឯកសារសម្រាប់ចែកចាយ ។
- ខ្ញុំនឹងរៀបរាប់ប្រាប់អ្នកភូមិខ្ញុំពីស្ថានភាពដ៏គួរឲ្យអាណោចអាធ័ម និងទីកន្លែងភ័ស្តុតាងជាក់ស្តែងដែលខ្ញុំបានមើលឃើញផ្ទាល់នឹងភ្នែក ។
- ខ្ញុំនឹងចែកចាយការយល់ដឹងរបស់ខ្ញុំជាមួយនឹងអ្នកភូមិ ដើម្បីរួមចំណែកក្នុងការថែរក្សាប្រវត្តិសាស្ត្រ ។
- ខ្ញុំនឹងប្រាប់អ្នកភូមិគ្រប់គ្នាពីគម្រោងនេះ ។
- ពេលខ្ញុំត្រឡប់ទៅភូមិវិញ ខ្ញុំនឹងប្រាប់អ្នកភូមិឲ្យលម្អិតពីដំណើរទស្សនកិច្ច និងដំណើរការកាត់ទោសខ្មែរក្រហមនាពេលឆាប់ៗខាងមុខនេះ ។
- ខ្ញុំនឹងពន្យល់ប្រាប់បងប្អូន មិត្តភ័ក្តិខ្ញុំ ដើម្បីឲ្យទាំងអស់គ្នាបាន

យល់កាន់តែច្បាស់ពីដំណើរការតុលាការនិងច្បាប់កាត់ទោស មេដឹកនាំខ្មែរក្រហម ។

◆ ដំណើរទស្សនកិច្ចផ្តល់ឲ្យខ្ញុំនូវគំនិតនិងព័ត៌មានថ្មីៗជាច្រើន ហើយខ្ញុំនឹងចែករំលែកការយល់ដឹងនេះជាមួយអ្នកភូមិនិងសហគមន៍ ។

◆ សភាពដែលខ្ញុំឃើញនូវគុកទួលស្លែង និងវាលពិឃាតជើងឯក ធ្វើឲ្យខ្ញុំមានការឈឺចាប់យ៉ាងខ្លាំង ។ ខ្ញុំនឹងចែកចាយការឈឺចាប់នេះជាមួយនឹងអ្នកភូមិឯទៀត ។

◆ ខ្ញុំអាចចែករំលែកការយល់ដឹងពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយនឹងអ្នកភូមិ តាមរយៈការចែកចាយព័ត៌មានផ្ទាល់ ការជជែកពិភាក្សាគ្នា ពេលមានកម្មវិធីបុណ្យទានផ្សេងៗ នៅក្នុងភូមិ ។

◆ ដោយប្រើប្រាស់ព័ត៌មានដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំអាចចែករំលែកការយល់ដឹងពីដំណើរទស្សនកិច្ចនេះជាមួយនឹងអ្នកភូមិខ្ញុំ តាមរយៈការជជែកគ្នាលេង ។

**សំណួរទី៤ ៖ តើមានកន្លែងណា ឬបញ្ហាអ្វីមួយដែរឬទេ ដែលលោក-អ្នកមិនទាន់យល់ច្បាស់ ហើយត្រូវការពន្យល់បន្ថែមទៀត?**

**លទ្ធផល** ៖ ទទួលបាន៣១០ចម្លើយ ។ ប្រជាជនមកចូលរួមសុទ្ធតែបញ្ជាក់ថាគាត់នឹងចែកចាយព័ត៌មានដែលគាត់ទទួលបានតាមរយៈដំណើរទស្សនកិច្ចនេះ ។

ចម្លើយទទួលបានរួមមាន ÷ ◆ យល់គ្រប់ចំណុចចំនួន៧៣ចម្លើយ ◆ ត្រូវការការពន្យល់បន្ថែមផ្នែកច្បាប់ចំនួន៥៩ចម្លើយ ◆ ត្រូវការឯកសារបន្ថែមដើម្បីជួយឲ្យយល់កាន់តែច្បាស់ចំនួន១៨ចម្លើយ ◆ ចង់យល់ដឹងបន្ថែមពីការប្រល័យពូជសាសន៍ឲ្យបានទូលំទូលាយជាងនេះចំនួន១៦ចម្លើយ ◆ ចង់ដឹងពីថ្ងៃកំណត់ពិតប្រាកដនៃការបើកសវនាការចំនួន១០ចម្លើយ ◆ ចង់ដឹងពីតួនាទីអង្គការសហប្រជាជាតិចំនួន១១ចម្លើយ ◆ ចង់ដឹងពីការចូលដៃរបស់សហគមន៍អន្តរជាតិនិងតួនាទីរបស់សហគមន៍នេះចំនួន២០ចម្លើយ ◆ អ្នកណាខ្លះនឹងត្រូវបញ្ជូនទៅកាត់ទោស? មូលហេតុអ្វី? ចំនួន៤៦ចម្លើយ ◆ ការបញ្ចេញមតិផ្ទាល់ខ្លួន ឬមិនយល់សំណួរចំនួន២២ចម្លើយ ◆ ចង់ឃើញទីកន្លែងប្រល័យពូជសាសន៍ផ្សេងទៀត ឬយល់ថា ដំណើរទស្សនកិច្ចមានពេលខ្លីពេកចំនួន៩ចម្លើយ ◆ ហេតុអ្វីមានការពន្យារពេលក្នុងការកាត់ទោសខ្មែរក្រហម? ចំនួន២០ចម្លើយ ◆ តើមានការដាក់ទោសចំពោះឧក្រិដ្ឋជនយ៉ាងណាដែរ? ហេតុអ្វីបានជាគ្មានទោសប្រហារជីវិត? ចំនួន១០ចម្លើយ ◆ តើជនរងគ្រោះនឹងទទួលបានសំណងអ្វីខ្លះ? ចំនួន៣០ចម្លើយ ។

**មតិប្រជាជនឆ្លើយតបនឹងសំណួរទី៤**

◆ ខ្ញុំនៅមិនទាន់យល់ថាតើតុលាការនឹងកាត់ទោសតែមេដឹកនាំកំពូល ឬក៏កាត់ទោសទាំងជនដៃដល់ដែលនៅក្រោមបង្គាប់ ។



◆ ខ្ញុំសំណូមពរឲ្យផ្សព្វផ្សាយឲ្យបានច្បាស់នូវច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម (ធ្វើយ៉ាងណាឲ្យទូលំទូលាយ និងងាយស្រួលយល់)

◆ យើងមានច្បាប់កាត់ទោសខ្មែរក្រហម១៩៧៥-៧៩ ចុះចំណែករបប លន់ នល់ វិញ ។ របបនេះបានសម្លាប់មនុស្សជាច្រើននាក់ ។ តើយើងបញ្ជូនអ្នកទាំងនោះទៅតុលាការទេ?

◆ ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហម គ្រប់ដណ្តប់តែចំពោះ

ជនណាដែលប្រព្រឹត្តបទឧក្រិដ្ឋក្នុងរវាងឆ្នាំ១៩៧៥-៧៩ ។ ប៉ុន្តែខ្ញុំសូមឲ្យច្បាប់ដាក់ទោសក្នុងរបប លន់ នល់ ជាពិសេសសកម្មភាពចក្រពត្តិនិយមរបស់សហរដ្ឋអាមេរិក ។ ហេតុអ្វីបានជាច្បាប់មានសមត្ថកិច្ចចំពោះតែរបបខ្មែរក្រហម?

- ប្រសិនបើមានបញ្ជីឈ្មោះជនរងគ្រោះ បញ្ជីនេះគួរតែថតចម្លងចែកចាយជូនសាច់ញាតិរបស់ជនរងគ្រោះ ។
- តើនរណាខ្លះនឹងត្រូវបញ្ជូនទៅសវនាការកាត់ក្តី? តើមានទោសប្រហារជីវិតឬទេ? តើមេដឹកនាំខ្មែរក្រហមថ្នាក់ទាបដែលកំពុងរស់នៅជាមួយយើងនឹងត្រូវនាំយកទៅកាត់ទោសទេ? សព្វថ្ងៃនេះ យើងមានច្បាប់និងថវិការគ្រប់គ្រាន់សម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ចុះហេតុអ្វីបានជាសវនាការនៅតែមានការពន្យារពេល?



ប្រជាជននៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- មេដឹកនាំខ្មែរក្រហមខ្លះបានស្លាប់ទៅហើយ ខ្លះទៀតបានទទួលការលើកលែងទោស ហើយខ្ញុំឆ្ងល់ថាតើជនដែលប្រភេទនេះនឹងយកមកកាត់ទោសបានដែរទេ?
- ខ្ញុំគិតថាប្រសិនបើមានខ្សែភាពយន្តឯកសារចាក់បញ្ចាំងជូនប្រជាជននៅតាមជនបទដាច់ស្រយាលនោះជាការប្រសើរ ។
- ខ្ញុំមិនយល់ថាហេតុអ្វីបានជាមានរបបប្រល័យពូជសាសន៍កើតឡើង និងតើអ្នកណាជាអ្នកនៅក្រោយខ្នងរឿងនេះ?
- ខ្ញុំចង់ដឹងថាតើប្រទេសណាខ្លះដែលមានជាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅកម្ពុជា ។
- ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាមានការអូសបន្លាយពេលវេលាយ៉ាងនេះ ធ្វើឲ្យមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ស្លាប់ម្នាក់ហើយម្នាក់ទៀតជាបណ្តើរៗ ។
- ខ្ញុំចង់ដឹងថាតើមានសំណងជំងឺចិត្តជាសាច់ប្រាក់ដែរឬទេ?
- ខ្ញុំនៅមានចម្ងល់អំពីការជាប់ទាក់ទិនរបស់សហគមន៍អន្តរជាតិជាមួយតុលាការនេះ ។
- ខ្ញុំគិតថាពេលវេលាសម្រាប់ដំណើរទស្សនកិច្ចនេះខ្លីពេកមិនអាចឲ្យយើងយល់ច្បាស់អស់ពីរបបប្រល័យពូជសាសន៍ ។
- ខ្ញុំចង់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសិក្សា ដើម្បីអប់រំក្មេងជំនាន់ក្រោយឲ្យដឹងពីព្រឹត្តិការណ៍ដែលប្រវត្តិសាស្ត្រ ។ ដូចខ្ញុំនេះ ខ្ញុំក៏មិនសូវច្បាស់ពីរឿងរ៉ាវដែលបានកើតឡើងដែរ ។
- ខ្ញុំនៅឆ្ងល់ថាហេតុអ្វីបានជាតុលាការមិនកាត់ទោសប្រហារជីវិតដល់មេដឹកនាំខ្មែរក្រហម ដែលបានសម្លាប់ប្រជាជនអស់ជាច្រើននាក់ ។

**សំណួរទី៩ ៖ តើមានអ្វីផ្សេងទៀតដែលលោក-អ្នកចង់ឃើញ ឬមើលនៅក្នុងដំណើរទស្សនកិច្ចបែបនេះ?**

**លទ្ធផល** ៖ ទទួលបាន៣២៦ចម្លើយ ។

ចម្លើយទទួលបានរួមមាន ÷ ◆ ចង់ឃើញសវនាការផ្ទាល់ ឬចង់ស្តាប់ការផ្សាយតាមវិទ្យុចំនួន៩៦ចម្លើយ ◆ សំណូមពរឲ្យមានជាខ្សែភាពយន្តឯកសារច្បាប់និងឯកសារផ្សេងៗទៀតចំនួន៣២ចម្លើយ ◆ ស្នើឲ្យសវនាការកើតឡើងឲ្យឆាប់ៗតាមដែលអាចធ្វើទៅបានចំនួន៩៦ចម្លើយ ◆ មានចម្ងល់ថាតើនឹងមានអ្វីបន្សល់ទុកបន្ទាប់ពីការកាត់ក្តីត្រូវបានចប់សព្វគ្រប់ចំនួន៣ចម្លើយ ◆ សំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយផ្តល់ព័ត៌មាននិងសេវាកម្មផ្សេងៗចំនួន៣ចម្លើយ ◆ ចង់ឃើញទីកន្លែងបូជនីយដ្ឋានផ្សេងៗទៀតចំនួន៤ចម្លើយ ◆ ការពិភាក្សាជាក្រុមចំនួន១ចម្លើយ ◆ មិនយល់សំណួរចំនួន៣៧ចម្លើយ ◆ សុំឲ្យមានការកាត់

ទោសដោយសុក្រិតនិងយុត្តិធម៌ចំនួន១៣ចម្លើយ ◆ ចង់ឃើញទីកន្លែងភ័ស្តុតាងវាលពិឃាតរណ្តៅសាកសពនិងចង់ឲ្យមានដំណើរទស្សនកិច្ចបែបនេះទៀតចំនួន៤៣ចម្លើយ ◆ ចង់ប្រឈមមុខផ្ទាល់ជាមួយជនដៃដល់ចំនួន៨ចម្លើយ ◆ ចង់ឲ្យដំណើរទស្សនកិច្ចមានរយៈយូរជាងនេះទៀតចំនួន៧ចម្លើយ (ជាពិសេសនៅទួលស្លែង) ◆ ត្រូវការការពន្យល់បន្ថែមលម្អិតលើផ្នែកនយោបាយប្រវត្តិសាស្ត្រចំនួន៣ចម្លើយ ◆ ចង់ឲ្យប្រជាជនផ្សេងទៀតបានចូលរួមដំណើរទស្សនកិច្ចនេះចំនួន១៥ចម្លើយ ◆ សុំឲ្យមានថវិកាច្រើនជាងនេះសម្រាប់ប្រជាជនធ្វើដំណើរមកភ្នំពេញចំនួន២ចម្លើយ ។

**មតិប្រជាជនឆ្លើយតបទៅសំណួរទី៥ ៖**

- ខ្ញុំចង់ឃើញការកាត់ទោសខ្មែរក្រហម និងចង់ឃើញរូបភាពពីអំពើប្រល័យពូជសាសន៍បែបនេះនៅប្រទេសដទៃទៀត ។
- ខ្ញុំគិតថាដំណើរទស្សនកិច្ចនេះគួរតែមានកម្មវិធីពិភាក្សាជាក្រុម ។
- ខ្ញុំចង់ឃើញវាលពិឃាតដទៃទៀត និងចង់មើលខ្សែភាពយន្តឯកសារ ។ ខ្ញុំគិតថាការធ្វើបែបនេះជាវិធីដ៏ល្អមួយក្នុងការផ្សព្វផ្សាយព័ត៌មាន ។
- មុនពេលមានសវនាការ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញផ្សព្វផ្សាយច្បាប់ទាក់ទងទៅនឹងការកាត់ទោសមេដឹកនាំខ្មែរក្រហម ជូនដល់ប្រជាជនទូទាំងប្រទេស ។
- ខ្ញុំចង់ដឹងពីបទឧក្រិដ្ឋដែលខ្មែរក្រហមប្រព្រឹត្តមកលើប្រជាជនកម្ពុជាទាំងមូល ។ ទន្ទឹមនឹងនេះខ្ញុំចង់ឲ្យមានកំណត់ត្រាសវនាការ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង ។
- ខ្ញុំចង់ឲ្យមានការកត់ត្រានូវបទឧក្រិដ្ឋដែលខ្មែរក្រហមប្រព្រឹត្តដើម្បីឲ្យក្មេងជំនាន់ក្រោយចងចាំអតីតកាល ។
- ខ្ញុំចង់ឲ្យមានសវនាការដ៏សុក្រិតនិងយុត្តិធម៌ ។
- ខ្ញុំសំណូមពរឲ្យមានការចែកចាយដោយឥតគិតថ្លៃនូវកាស្សែតវីដេអូជូនប្រជាជនដែលបានមកចូលរួម ។
- ដំណើរទស្សនកិច្ចគួរតែបង្ហាញពីស្ថានភាពនយោបាយនៅកម្ពុជា ។
- ខ្ញុំមិនចង់ឃើញដំណើរទស្សនកិច្ចនេះតែនៅកម្ពុជាទេ ខ្ញុំគ្រាន់តែចង់បានការអភិវឌ្ឍន៍នៅប្រទេសយើងប៉ុណ្ណោះ ។
- ចង់ឃើញតុលាការនិងសវនាការកាត់ទោសប្រទេសមហាអំណាចដែលគាំទ្រខ្មែរក្រហម ដូចជា មន្ត្រីអង្គការសហប្រជាជាតិដែលផ្តល់កៅអីអង្គុយឲ្យខ្មែរក្រហម ។
- ខ្ញុំចង់ទៅទស្សនាកន្លែងដែល ប៉ុល ពត ស្លាប់ ដើម្បីឲ្យអស់ចិត្តថា ប៉ុល ពត ពិតជាស្លាប់ប្រាកដមែន ។
- ខ្ញុំចង់ឃើញមេដឹកនាំខ្មែរក្រហមផ្ទាល់ ។
- ខ្ញុំចង់ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានផ្តល់ឱកាសដល់ខ្ញុំចូលរួមដំណើរទស្សនកិច្ចនេះ ។
- ខ្ញុំចង់បានឯកសារច្បាប់ខ្មែរក្រហមមួយចំនួន ។
- ខ្ញុំចង់ទៅទស្សនារណ្តៅសាកសពរួមនៅកន្លែងផ្សេងៗទៀត ។
- ខ្ញុំចង់មើលខ្សែភាពយន្តឯកសារនិងរូបថត ។
- ដំណើរទស្សនកិច្ចនេះមានរយៈពេលខ្លី ហើយខ្ញុំសំណូមពរឲ្យរៀបចំកម្មវិធីវែងជាងនេះ ដើម្បីឲ្យប្រជាជនបានទៅទស្សនាកន្លែងផ្សេងៗទៀត ។

**ក្រុមការងារមូលដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា**

**កំណាព្យ ៖ បទភាគគតិ**
**យើងខ្ញុំជាក្រុមកុមារបដិវត្តន៍ឈានមុខ**

**យើងខ្ញុំកុមារ ក្មួយចៅអង្គការ បដិវត្តន៍កម្ពុជា**
**ជាក្រុមឈានមុខ ដឹកនាំចលនា អនុវត្តមាគ៌ា**
**ការពារកសាង។**
**យើងខ្ញុំកុមារ ព្យាយាមឧស្សាហ៍ រៀនសូត្រសព្វយ៉ាង**
**នយោបាយបច្ចេកទេស វប្បធម៌ជាគាង**
**សតិអារម្មណ៍ភ្លឺស្វាង ឈានមុខជានិច្ច។**
**ឈានមុខបំផុស ចលនាដាំដុះ ពលកម្មប្តូរផ្តាច់**
**ឈានមុខការពារ កម្ពុជាជានិច្ច ឈានមុខកម្ទេច**
**កម្មសិទ្ធឯកជន។**
**យើងខ្ញុំកុមារ តាំងចិត្តប្តេជ្ញា បំពាក់បំប៉ន**
**ជំហរបដិវត្តន៍ វណ្ណៈអធន ដើម្បីជាធុន**
**បន្តវេនបដិវត្តន៍។**

*(សៀវភៅកំណត់ហេតុលេខ១០ ៧/៧)*

# មើលខ្សែភាពយន្តឯកសាររំឭកដល់អតីតកាល

នៅក្នុងដំណើរការចុះបញ្ចាំងខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងខេត្តមណ្ឌលគិរី ក្នុងគោលបំណងឲ្យប្រជាជនចូលរួមការពិភាក្សាឲ្យបានច្រើនអំពីបទពិសោធន៍ទាំងឡាយដែលគាត់បានឆ្លងកាត់ផ្ទាល់និងជួបប្រទះក្នុងសម័យនោះ ពិសេសគឺករណីការរំលោភផ្លូវភេទលើស្ត្រីភេទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាលទ្ធផល មានប្រជាជនទាំងចាស់ក្មេងបានចូលរួមទស្សនានិងមួយចំនួនបានឡើងរ៉ាយរាប់អំពីទុក្ខលំបាកនិងការនិរាស្ត្រព្រាត់ប្រាសបងប្អូនរបស់គាត់ ។ មួយអ៊ាន គឺជាស្ត្រីរងគ្រោះម្នាក់ដែលបានតស៊ូរស់ពីរបបនេះក្រោយពីប្អូនៗនិងឪពុកបានស្លាប់ ។ មួយអ៊ាន ពេញចិត្តយ៉ាងខ្លាំងចំពោះកម្មវិធីបញ្ចាំងខ្សែភាពយន្តនេះ ពី-ព្រោះថា ប្រជាជនក៏ដូចជាក្មេងជំនាន់ក្រោយ ដែលនៅក្នុងស្រុករបស់គាត់ បានដឹងកាន់តែច្បាស់និងជឿថា មានរបបនេះមែន ពិសេសទៅទៀតកូនៗរបស់គាត់តែម្ដង ។



ប្រជាជនកំពុងទស្សនាខ្សែភាពយន្តឯកសារនៅខេត្តមណ្ឌលគិរី

ក្នុងខណៈពេលដែលក្រុមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ចាំងខ្សែភាពយន្តមួយ“វាលស្រែខ្មែរក្រហម”និង“ហួតបុប្ផាណា” នៅទីធ្លាវាលស្មៅមួយនាពេលព្រលប់ មួយអ៊ាន បានឈរសន្ទនាជាមួយខ្ញុំអំពីសារប្រយោជន៍របស់ខ្សែភាពយន្តនេះ ហើយថែមទាំងបានរៀបរាប់អំពីជីវិតតស៊ូរបស់គាត់នៅក្នុងសម័យនោះទៀតផង និងមកដល់ជីវិតជោគជ័យក្នុងពេលបច្ចុប្បន្ននេះ ។

មួយអ៊ាន មានបងប្អូន១៨នាក់ ។ មុនឆ្នាំ១៩៧៥ គាត់ធ្លាប់រស់នៅក្រោយរោងកុនចេនឡា ។ ឪពុកឈ្មោះ ហ៊ូ សួន ជាជាងកាត់សក់ ។ ម្ដាយស្លាប់នៅឆ្នាំ១៩៧០ ដោយជំងឺទាស់សរសៃ ។ បងៗរបស់ មួយអ៊ាន បានរស់នៅបែកផ្ទះរៀងៗខ្លួនបន្ទាប់ពីរៀបការហើយ ។ ដូច្នេះ មួយអ៊ាន មានភារកិច្ចមើលថែប្អូនៗទាំងបួននាក់ជាមួយឪពុកចាស់ជរា ។ មួយអ៊ាន ធ្លាប់ធ្វើការនៅមន្ទីរពិសោធន៍ថ្នាំនៅទីក្រុងភ្នំពេញ ។

នៅពេលដែលកងទ័ពខ្មែរក្រហមបណ្ដេញប្រជាជនចេញពីទីក្រុងមួយអ៊ាននិងក្រុមគ្រួសារបានជម្លៀសទៅដល់ស្ពានព្រែកត្នោតខេត្តកណ្ដាលមួយរយៈនិងបន្ទាប់មកជម្លៀសទៅនៅខេត្តបាត់ដំបង ។

មួយអ៊ាន ត្រូវអង្គការបញ្ជូនទៅលើកទំនប់នៅសហករណ៍កំពតពលក្នុងខេត្តកណ្ដាលអស់រយៈពេលជាងមួយខែ ហើយក៏ធ្លាក់ខ្លួនឈឺរហូតដល់វិកលចរិតអស់រយៈពេលប្រហែលបួនខែនៅសហករណ៍កំពតពល ។ នៅទីនោះ អង្គការបានចាត់តាំងឲ្យក្រុមរបស់គាត់ដែលមានសមាជិកស្រី១០នាក់លើកដីឲ្យបាន១០ម៉ែត្រក្នុងរយៈពេល២ថ្ងៃ ។ មួយអ៊ាន និងក្រុមការងារបានទទួលរងនូវការទិតៀនយ៉ាងធ្ងន់ធ្ងរពីក្រុមផ្សេងៗដោយសារធ្វើការមិនសម្រេចតាមផែនការរហូតដល់មានទំនាស់ពាក្យសម្ដី ។ មួយអ៊ាន រំឭកថា ៈ “ខ្ញុំឆ្កួតដោយសារតែឈ្លោះប្រកែកជាមួយគេ ។ គេឡើងទិតៀនខ្ញុំថា ធ្វើមិនហើយ មិនដាច់ខាត នៅសួនតួ នៅទុកក្របក ទុកសក់វែង ។ ពេលខ្ញុំឈ្លោះគ្នាទៅគេធ្វើខ្ញុំ ខ្ញុំឈឺឆ្កួតមិនដឹងអ៊ីទាំងអស់ ដឹងពីតែសប្បាយ” ។

មួយអ៊ាន បានជាសះស្បើយឡើងវិញបន្ទាប់ពីឆ្លងថ្នាំខ្មែរ

របស់ពេទ្យសង្គមកិច្ច ។ ប៉ុន្តែរហូតមកដល់សព្វថ្ងៃ មួយអ៊ាន នៅតែជឿថាគាត់បានជាសះស្បើយដោយខ្មោចម្តាយមកជួយ ពីព្រោះនៅក្នុងអំឡុងពេលគាត់វង្វេងស្មារតីនោះគាត់ឃើញរូបភាពប្លែកៗដែលអ្នកដទៃមើលមិនឃើញ ហើយឃើញខ្មោចម្តាយមកជួយទៀតផង ។ មួយអ៊ាន និយាយថា ៖ ខ្ញុំមិនមែនវង្វេងវង្វាយនិយាយតែម្នាក់ឯងទេ ពេលកំពុងឆ្កួត ខ្ញុំស្រែកហៅម៉ែពីព្រោះក្តៅពេក ខ្ញុំឃើញខ្មោចម្តាយមកជួយ ។ ឃើញម្រេញគង្វាលមកលេងជាមួយខ្ញុំ ។ ខ្ញុំឆ្កួតថ្នាំនោះបីដងស្រាប់តែជា ។

ក្រោយជាសះស្បើយបានបីថ្ងៃអង្គការបញ្ជូនក្រុមគ្រួសាររបស់ មួយអ៊ាន ទៅកន្លែងផ្សេង ។ អង្គការប្រកាសថាអ្នកធ្លាប់រស់នៅស្រុកណាឲ្យទៅស្រុកនោះវិញ ។ ប្រជាជនភាគច្រើននាំគ្នាត្រេកអរពេលឮថាអង្គការឲ្យទៅស្រុកវិញ ប៉ុន្តែជាក់ស្តែងអង្គការបានបញ្ជូនទៅកន្លែងផ្សេងៗ ។ គ្រួសាររបស់ មួយអ៊ាន និងគ្រួសារដទៃទៀតត្រូវអង្គការបញ្ជូនតាមកប៉ាល់ឆ្ពោះទៅខេត្តបាត់ដំបង ។ "មកដល់ខេត្តបាត់ដំបង ប្រហែលពាក់កណ្តាលអាធ្រាត្រ រថភ្លើងក៏ឈប់ដាក់ឲ្យប្រជាជនមួយចំនួនចុះ ។ ម៉ោងប្រហែលមួយរំលងអាធ្រាត្រខ្មែរក្រហមឲ្យប្រជាជនចុះមួយចំនួនទៀតចំក្រុមខ្ញុំតែម្តង ។ ខ្ញុំប្រកែកមិនបានទេ ។ ខ្មែរក្រហមគំរាមថា បើអ្នកណាមិនចុះបាញ់ចោល ។ ខ្ញុំមិនដឹងទៅទិសខាងណាទេ ព្រោះមេឃងងឹតឈឹង ។ ខ្ញុំសម្រាកនៅក្បែរផ្លូវរថភ្លើងរហូតដល់ភ្លឺ ។ ព្រលឹមឡើងទើបដឹងថាពួកខ្ញុំកំពុងស្ថិតនៅមាត់ជ្រោះ" ។

ប្រជាជនជម្លៀសទាំងអស់មិនអនុញ្ញាតឲ្យរស់នៅក្បែរផ្លូវរថភ្លើងឡើយ ។ ខ្មែរក្រហមបានដេញអ្នកទាំងអស់នោះឲ្យចូលទៅក្នុងព្រៃដើម្បីរានព្រៃធ្វើជាភូមិ ។ ដោយសារប្រជាជនជម្លៀសភាគច្រើនជាជនជាតិចិន ភូមិនោះត្រូវបានឲ្យឈ្មោះថាជាភូមិចិន ។ នៅភូមិនោះមានប្រជាជនស្លាប់ច្រើនដោយសារហូបស្ល្វែងនិងកង្វះអាហារ ។ ឪពុករបស់ មួយអ៊ាន បានស្លាប់ដោយដាច់ពេលនិងទ័លនោមក្រោយពេលទៅដល់ទីនោះរយៈពេលបួនថ្ងៃ ។ "ខ្ញុំស្រណោះឪពុកខ្ញុំណាស់ ពេលគាត់ស្លាប់មានតែភួយមួយរុំគាត់ទេ ។ ខ្ញុំគ្មានអង្ករហូបទេ ហូបតែស្លឹកឈើជួនកាលដាច់ពេលមួយសប្តាហ៍នៅសល់តែកន្ទក់ ខ្មែរក្រហមបានយកមកចំហុយឲ្យរឹកទៅបាយ រួចពូតជាដុំៗចែកឲ្យយើងមួយដុំម្នាក់ៗហូប រួចហៅយើងទៅធ្វើការមួយពេលទៀត ។

មួយអ៊ាន ត្រូវបង្ខំឲ្យធ្វើការគ្មានពេលសម្រាកឡើយ ។ ប្អូនស្រីម្នាក់របស់គាត់ត្រូវអង្គការបញ្ជូនទៅសមរភូមិ ចំណែកគាត់និងប្អូនបីនាក់ធ្វើការនៅសមរភូមិក្រោយ ។ អង្គការចេះតែឃោសនាថាបើចង់ស៊ីឆ្អែត លុះត្រាតែទៅសមរភូមិមុខទើបមានបាយមានអង្ករហូប ។ មួយអ៊ាន បាននាំប្អូនៗទៅសមរភូមិមុខសង្ឃឹមថា បានហូបឆ្អែតនឹងគេ ក៏ប៉ុន្តែនៅពេលទៅដល់ទីនោះប្អូនស្រីរបស់គាត់បានស្លាប់ដោយសារហូបមិនឆ្អែត ។ "ខ្ញុំធ្វើការដើម្បីក្រពះប្រសិនបើអត់ហូប ធ្វើម៉េចខ្ញុំមានកម្លាំងធ្វើការ ។ ម៉ោងប្រហែលពីររសៀលខ្ញុំសម្រេចចិត្តនាំប្អូនៗចេញទៅសមរភូមិជាមួយគេ ។ ខ្ញុំចងប្អូនតូចអាយុ៥ឆ្នាំដាក់ពីក្រោយខ្នង ហើយធ្វើដំណើរទៅជាមួយប្អូនពីរនាក់ទៀត ខ្ញុំបានទៅដល់កន្លែងនោះម៉ោង១រំលងអាធ្រាត្រ ។ នៅយប់នោះម៉ោងប្រហែលបី ទៀបភ្លឺទើបខ្ញុំទទួលបានបបរដើមចេកហូប ។ ប្អូនស្រីទី៣របស់ខ្ញុំដែលមានអាយុ១៥ឆ្នាំបានស្លាប់ដោយដាច់បាយ វាឃ្លានពេក" ។ ប្អូនរបស់ មួយអ៊ាន ស្លាប់នៅក្នុងរដូវវស្សាភ្លៀងធ្លាក់ជោកជាំនិងជាពេលដែលអង្គការរើការដ្ឋានទៅនៅភូមិសាយ ហើយប្រជាជនបាននាំគ្នាចាកចេញស្ទើរស្ងាត់ភូមិ ។ មួយអ៊ាន បានយកសាកសពប្អូនជាទីស្រឡាញ់ដាក់ដេកក្នុងមុងជាមួយ ដើម្បីកុំឲ្យត្រូវទឹកភ្លៀង ។ "ខ្ញុំយកខ្មោចប្អូនខ្ញុំដាក់ក្នុងមុងដេក ជាមួយខ្ញុំនិងប្អូនពីរនាក់ទៀត ។ បានរយៈពេលប្រាំថ្ងៃ ដង្កូវចោះក្បាលប្អូនខ្ញុំ ។ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េច ព្រោះថាខ្ញុំនិងប្អូនពីរនាក់គ្មានកម្លាំងកំហែងដូចគ្នា ខ្ញុំនិងប្អូនបានអូសខ្មោចប្អូនទៅកប់នៅក្បែរដំបូកមួយឆ្ងាយពីស្រែ ។ ខ្ញុំជីករណ្តៅកប់សាកសពប្អូនតាំងពីព្រឹករហូតដល់ម៉ោងបីរសៀលនៅតែមិនអាចកប់សាកសពប្អូនជិត ។ បីថ្ងៃក្រោយមកខ្ញុំបានទៅមើលផ្នូរប្អូនខ្ញុំម្តងទៀត ស្រាប់តែបាត់សាកសពវា" ។

អង្គការបានចាត់តាំង មួយអ៊ាន ទៅធ្វើការជាមួយមិត្តនារីចាស់ៗនៅការដ្ឋានឈ្វាវ ចំណែកប្អូនពីរនាក់ អង្គការចាត់តាំងឲ្យទៅធ្វើជី ។ ប្អូនទាំងពីររបស់ មួយអ៊ាន បានស្លាប់បន្តបន្ទាប់ដោយដាច់ពេលដែរ ។ ប្អូនម្នាក់ស្លាប់នៅភូមិសាយនិងម្នាក់ទៀតស្លាប់នៅការដ្ឋានចាស់បន្ទាប់ពីអង្គការរើភូមិទៅវិញ ។ "ខ្ញុំស្រណោះ

ប្អូនពៅរបស់ខ្ញុំណាស់ វាហៅខ្ញុំម៉ាក់ៗពីព្រោះខ្ញុំចិញ្ចឹមវាតាំងពីតូច ។ វាថាបើវាមានបាយក្តាំងក៏កូនហូបរស់ដែរ ។ អ្នកជុំវិញក៏អាណិតវាគ្រប់គ្នា ។ ថ្ងៃនោះខ្ញុំរត់ទៅបើកបបរមួយវែកមកឲ្យប្អូន ប៉ុន្តែពេលខ្ញុំមកដល់ប្អូនខ្ញុំដាច់ខ្យល់ស្លាប់ទៅហើយ ។ ការរស់នៅទីនោះលំបាកណាស់ ។ ពេលខ្លះម៉ោងពីរឬម៉ោងបីខ្ញុំមិនទាន់បានរបបពេលព្រឹកហូបផង ។ ពេលបើករបបបានម្តងៗមិនហ៊ានឲ្យកំពប់ទេ ពេលខ្លះខ្ញុំហូបបបរមិនទាន់រួចផងអង្គការដេញឲ្យទៅធ្វើការទៀត» ។

របបអាហារដែលអង្គការចែកឲ្យមិនអាចបង្គ្រប់សេចក្តីស្រេកបានឡើយ មួយអ៊ាន ត្រូវធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឲ្យខ្លួនបានហូបឆ្អែត ទោះបីជាអង្គការប្រមាថនិងទិតៀន ឬដឹងថាទង្វើដែលខ្លួនធ្វើជាបទល្មើសរបស់អង្គការក៏ដោយ ។ «ខ្យងក្តាមដែលរកបានខ្ញុំហូបឆៅ ។ ពេលឡើងពីស្ទូងមកខ្ញុំត្រូវប្រញាប់ឡើងមកមុនគេដើម្បីដើរបេះផ្លែឈើនិងស្លឹកឈើដែលអាចហូបបាន ដូចជាអំពិល គ្រឡាញ់ ស្លុកស្តៅ បេង និងយកសំបកដំឡូងឈើមកស្ងោរហូប ។ ជួនពេលខ្លះខ្ញុំចាប់ស៊ីទាំងឆៅ ។ ខ្មែរក្រហមពួកខ្ញុំថាពួកអា១៧មេសា អត់មានដាច់ខាតទេ កម្មសិទ្ធិក្រាស់ណាស់ កម្មសិទ្ធិសួនតូច ។ ក្រោយមកទៀតវានិយាយថា សក់អាណាក្បាលអាហ្នឹង អាណាខូចយកអ្នែងទៅ» ។

ប្រជាជនជម្លៀសក្រៅពីស្លាប់ដោយអត់អាហារក៏មានស្លាប់ដោយសម្លាប់ដែរ ខ្មែរក្រហមចាប់ប្រជាជនសម្លាប់ស្ទើររាល់ថ្ងៃដោយចោទថាខុសនេះខុសនោះ ជាពិសេសនៅមានប្រជុំ ឬចូលរួមមិទ្ទីងម្តងៗតែងមានចាប់មនុស្សយកទៅសម្លាប់ ។ «កំពុងតែធ្វើមិទ្ទីងលើកផែនការធ្វើស្រែ៣តោនមួយហិកតាស្រាប់តែវាថា អានោះខ្មាំង វានាំគ្នារត់ស្រមកចាប់ម្នាក់នោះចេញផុតពីមិទ្ទីងបន្តិចឮស្នូរកាំភ្លើងផ្ទុះ ។ ពេលប្រជុំរួច យើងនាំគ្នាទៅមើលឃើញស្លាប់បាត់ទៅហើយ ។ មួយភូមិខ្ញុំមានរាប់ពាន់នាក់ ប៉ុន្តែនៅទីបញ្ចប់មួយក្រុមៗសល់ពីរនាក់ បីនាក់ប៉ុណ្ណោះ» ។

នៅក្នុងឆ្នាំ១៩៧៨ កម្មាភិបាលភូមិភាគនិរតីបានឡើងកាន់អំណាច ឯការសម្លាប់កាន់តែសាហាវជាងមុនដែរ ទាំងប្រជាជនកម្មាភិបាលខាងបូព៌ានិងកម្មាភិបាលពាយ័ព្យដែលជាសមាជិករបស់អង្គការ ក៏ត្រូវកម្មាភិបាលភូមិភាគនិរតីចាប់យកទៅសម្លាប់មិនរើសមុខ ។ មួយអ៊ាន បានឃើញទាហានខ្មែរក្រហមចងមនុស្សយកសម្លាប់ទាំងខ្សែៗ ។ ពីមុនខ្មែរក្រហមប្រើតែពាក្យថា សក់អាណា ក្បាលអាហ្នឹង បើនៅក្រុមគ្រួសារមាន នរណាម្នាក់ធ្វើខុសយកតែអ្នកនោះទៅទេ ផុតពីនោះខ្មែរក្រហមចាប់ផ្តើមប្រើពាក្យថា ជីកស្មៅជីកទាំងឫស សូម្បីតែកូនតូចក៏មិនទុកដែរ ។ «ថ្ងៃមួយពេលខ្ញុំកំពុងច្រូតស្រូវខ្ញុំក្រឡេកឃើញសន្តិសុខបណ្តើរមនុស្សទាំងខ្សែៗតាមផ្លូវរទេះភ្លើងយកទៅសម្លាប់» ។

បន្ទាប់ពីប្អូនៗស្លាប់អស់ មួយអ៊ាន ក្លាយជាមនុស្សឯកោ ។ មួយអ៊ាន ដើរធ្វើការចល័តពីកន្លែងមួយ ទៅកន្លែងមួយជាមួយក្រុមបុរសៗដោយគ្មានគោលដៅដោយក៏មិននឹកស្មានថាខ្លួនជីវិតរស់បានដល់សព្វថ្ងៃនេះដែរ ។ «ខ្ញុំអស់សង្ឃឹមក្នុងជីវិត ខ្ញុំមិននឹកស្មានថាមានថ្ងៃនេះទេ ខ្ញុំចេះតែទៅតាមគេ ស្ពាយអង្រឹងកញ្ចាស់មួយតាមខ្លួនជានិច្ច ។ ខ្ញុំទៅគ្រប់សមរភូមិតាំងពីសមរភូមិឆាយ បាល័ង្ក, ហប់, សូភី, និងសមរភូមិកោះក្រឡ ។ រាងកាយខ្ញុំស្គមស្គាំងដូចមនុស្សប្រុសសុទ្ធសាធ សក់ក្បាលជ្រុះអស់ សូម្បីតែឈាមរដូវក៏គ្មានដែរ ។ ខ្ញុំចូលទៅធ្វើការជាក្រុមបុរសៗរហូតដល់គេថា ខ្ញុំប្រុស» ។

នៅពេលដែលកងទ័ពរណសិរ្សចូលរំដោះប្រទេសនៅថ្ងៃទី៧មករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានកៀរប្រជាជនឡើងភ្នំចុះភ្នំ ដើម្បីគេចពីកងទ័ពវៀតណាម ។ មួយអ៊ាន បន្តរស់នៅជាមួយខ្មែរក្រហមរយៈពេល៩ខែទៀត ។ ពេលទៅដល់ការដ្ឋានមួយមានសភាពការណ៍ស្ងប់ស្ងាត់ ខ្មែរក្រហមបានរៀបការគាត់ជាមួយបុរសម្នាក់ឈ្មោះ អែម ហែម ដែលជាប្រជាជនជម្លៀសដូចគ្នា ។ មួយអ៊ាន រំឭកថា «នៅក្នុងថ្ងៃរៀបការនោះមានរហូតដល់៧០គូ ។ ប្តីខ្ញុំអាយុលើសខ្ញុំ១១ឆ្នាំ រូបរាងគាត់អាក្រក់ ប៉ុន្តែគាត់ល្អរកគ្មានទេ» ។

ក្រោយពេលដឹងថាកងទ័ពវៀតណាមរំដោះប្រទេស ខ្មែរក្រហមបញ្ជាឲ្យប្រជាជនធ្វើឃ្លាំងនៅក្រោមដីដើម្បីស្តុបស្បៀង ហើយអ្នកទាំងនោះត្រូវខ្មែរក្រហមសម្លាប់បំបិទមាត់ក្រោយពេលធ្វើឃ្លាំងរួច ។ បន្ទាប់មក ឲ្យអ្នកផ្សេងជញ្ជូនស្បៀងយកទៅលាក់ ។ មួយអ៊ាន បានចូលរួមជញ្ជូនស្បៀងដែរ ប៉ុន្តែជញ្ជូនមិនទាន់រួចរាល់ផង កងទ័ពវៀតណាមបានចូលមកដល់ ។ អ្នកខ្លះដឹងសភាពការណ៍មុននាំគ្នាក្រាបទៅនឹងដី មួយអ៊ាន ដែលក្តាប់សភាពការណ៍មិនបានៗរត់ទៅជាមួយខ្មែរក្រហម បណ្តាលឲ្យកងទ័ពវៀតណាម

បាញ់ត្រូវមួយគ្រាប់បន្សល់ទុកស្លាកស្នាមមកដល់សព្វថ្ងៃ ។

នៅខែកញ្ញា ឆ្នាំ១៩៧៩ មួយអ៊ាន និងស្វាមីបានមករស់នៅខេត្តបាត់ដំបងបានមួយរយៈពេលខ្លី ហើយក៏សម្រេចចិត្តវិលត្រឡប់ទៅស្រុកកំណើតវិញក្រោយពីឮដំណឹងថាប្អូននិងម្តាយមីងនៅរស់ ។ មួយអ៊ាន បានជួបប្អូនប្រុសម្នាក់ ហ៊ូ គីមស្រេន ហៅ ហុង ហឿន និងប្អូនស្រី ហ៊ូ ណារ៉េត ម្នាក់ទៀតដែលបានបែកគ្នាកាលពីទៅចល័ត និងបន្ទាប់មកទៀតបានជួបបងប្រុសម្នាក់ដែលរស់នៅភ្នំពេញ ។ ក្រៅពីមុខរបរធ្វើចម្ការ ប្តីរបស់គាត់ធ្វើជាប៉ូលិសភូមិ ហើយគាត់ធ្វើជាមេភូមិ ។ ប៉ុន្តែដោយសារស្ថានភាពអសន្តិសុខនិងពិបាករស់នៅ មួយអ៊ាន បានផ្លាស់ទៅរស់ជាមួយបងប្រុសនៅព្រៃកីហ្គួសពោធិ៍ចិនតុងរយៈពេល៦ខែ ។ នៅឆ្នាំ១៩៩១ មួយអ៊ាន បានមករស់នៅខេត្តមណ្ឌលគិរីវិញ ដោយឮថាខេត្តនេះងាយស្រួលរកស៊ី ។ រស់នៅបានប្រហែលមួយឆ្នាំ ប្រជាជនសំណូមពរឲ្យមីងធ្វើជាប្រធានភូមិ ។ នៅឆ្នាំ១៩៩៣ ប្តីរបស់មីងស្លាប់ដោយជំងឺគ្រុនចាញ់និងឈឺក្រពះបន្សល់ទុកនូវកូនស្រី៥នាក់និងកូនប្រុស៣នាក់ ។ សព្វថ្ងៃ មួយអ៊ាន រស់នៅជាមួយកូនៗនិងស្វាមីទី២ធ្វើជាមេជាងផ្ទះ ។ រហូតដល់ឆ្នាំ២០០២មានការបោះឆ្នោតមេឃុំសង្កាត់ មួយអ៊ាន បានជាប់ជាជំទប់ទី២ ឃុំស្ពានមានជ័យ ខេត្តមណ្ឌលគិរី ។

ក្រោយពីរបបខ្មែរក្រហម មួយអ៊ាន នៅសល់តែបងប្អូនបួននាក់ បងប្រុសច្បង ហ៊ូ លីមហួត និងប្អូនពីរនាក់ទៀតដែលជួបនៅកំពង់ចាម ។ ក្រៅពីនោះត្រូវខ្មែរក្រហមសម្លាប់អស់៦នាក់ បីនាក់ស្លាប់ដោយអត់បាយនិងបាត់ខ្លួនម្នាក់ឈ្មោះ ហ៊ូ គីមស្រ៊ី និងក្រុមគ្រួសាររបស់គាត់ដែលបានផ្លាស់ទៅធ្វើការនៅខេត្តកំពង់ឆ្នាំងមួយសប្តាហ៍មុនខ្មែរក្រហមកាន់កាប់ប្រទេស ។ ក្រោយពីបញ្ចប់សាច់រឿង មួយអ៊ាន បានសំណូមពរឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាជួយចុះផ្សាយរកបងប្រុសរបស់គាត់ឈ្មោះ ហ៊ូ គីមស្រ៊ី និងក្រុមគ្រួសារដែលបាត់ខ្លួននៅខេត្តកំពង់ឆ្នាំង ។

**លី សុផល**

# ជីវិតនៅក្នុងគុករបស់ កែវ ម៉ៅ

កែវ ម៉ៅ ជាអតីតអ្នកទោសរបស់អង្គការបដិវត្តន៍ខ្មែរក្រហម ដែលត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៦ ស្ទើរមួយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយ ម៉ៅ បានទទួលនូវទារុណកម្មនិងឃើញទិដ្ឋភាពគ្រប់បែបយ៉ាង ។ ម៉ៅ បានរំឭកថា ៖

ខ្ញុំចូលបម្រើកងទ័ពនៅអំឡុងឆ្នាំ១៩៧១-១៩៧២ ។ គោលដៅតែមួយគត់របស់ខ្ញុំគឺដើម្បីបម្រើសម្តេចព្រះនរោត្តម សីហនុ ។ ខ្ញុំបម្រើកងទ័ពយ៉ាងស្វិតស្វាញ ហើយត្រូវរបួសគ្រប់កន្លែងនៅក្នុងឆ្នាំ១៩៧៤ ។ ផ្ទុយទៅវិញ ជីវិតរបស់ខ្ញុំហាក់បីដូចជាជាប់អន្ទាក់ទៅវិញ ព្រោះនៅឆ្នាំដដែលនេះពួកកងទ័ពខ្មែរក្រហមចាប់ខ្ញុំទៅដាក់គុកបន្ទាប់ពីមេៗរបស់ខ្ញុំត្រូវបានចាប់ខ្លួន ។ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ខ្ញុំចំណាយពេលវេលានៅតែក្នុងគុកប៉ុណ្ណោះ ។

ពីដំបូងខ្ញុំត្រូវបានបញ្ជូនទៅធ្វើទ័ពនៅខេត្តកំពង់ស្ពឺ ។ បម្រើទ័ពមិនបានយូរប៉ុន្មានផង មេៗរបស់ខ្ញុំត្រូវកងទ័ពខ្មែរក្រហមចាប់ខ្លួន ។ នៅខែមិថុនា ឆ្នាំ១៩៧៤ អង្គការបានចាប់ខ្លួនខ្ញុំនៅខេត្តកំពង់ស្ពឺដោយចោទប្រកាន់ថា "ខ្ញុំជាខ្មាំង" ខ្ញុំមិនអាចប្រកែកពីការចោទប្រកាន់នេះឡើយ ។ ខ្ញុំនិងអ្នកភូមិពីរនាក់ទៀតឈ្មោះ ឈួន ឈាវ និង ង៉ែត ភឿន ត្រូវបានចាប់ខ្លួនរួចបញ្ជូនទៅដាក់គុកនៅព្រៃក្តួចនៅជើងភ្នំដីរមាល ។ ខ្ញុំជាប់នៅទីនោះអស់រយៈពេលពីរខែគត់ ។ ខ្មែរក្រហមដែលមកចាប់ខ្ញុំនៅពេលនោះមានបីនាក់ ឈ្មោះ ចេង, ដាំ និង ឈៀង ។ អ្នកទាំងបីនាក់នេះឋិតនៅក្រោមបញ្ជារបស់ ហាន់ និង ឆេន ដែលសព្វថ្ងៃកំពុងរស់នៅអន្លង់វែង ។

បន្ទាប់ពីជាប់គុកនៅព្រៃក្តួចអស់រយៈពេលពីរខែ ខ្ញុំត្រូវបានបញ្ជូនទៅគុកក្រាំងតាចាន់(ក្នុងខេត្តតាកែវ)បន្ត ។ នៅទីនោះមានអ្នកទោសចំនួន២០នាក់ដែលជាប់ខ្នោះជាមួយខ្ញុំ ។ ខ្ញុំត្រូវបានដាក់ខ្នោះដៃនិងខ្នោះជើងទាំងពីរ ។ អ្នកជាប់ខ្នោះបែបនេះត្រូវបានចាត់ទុកថាជាអ្នកទោសកម្រិតធ្ងន់ ព្រោះថាពេលនោះគឺជាពេលដែលអង្គការខ្មែរក្រហមចាត់វិធានការចាប់ជនជាតិវៀតណាមដែលមកពីទីក្រុងហាណូយ ។ អ្នកទោសវៀតណាមដែលមានកម្រិតធ្ងន់ ខ្មែរក្រហមមិនងាយនឹងទុកឲ្យមានជីវិត

រស់នៅបានយូរឡើយ ។ ចំណែកអ្នកទោសដែលពួកខ្មែរក្រហមចោទថាជាខ្មាំងក៏ត្រូវបញ្ជូនទៅសម្លាប់ជារឿយៗដែរ ។ នៅក្នុងចំណោមអ្នកទោស២០នាក់ដែលកំពុងតែជាប់ទោសជាមួយខ្ញុំ មានពេលខ្លះសន្តិសុខគុកបានហៅឈ្មោះអ្នកទោស៤-៥នាក់ទៅសម្លាប់ចោល ។ បន្ទាប់មកអង្គការបញ្ជូនអ្នកទោសថ្មីមកបំពេញចន្លោះអ្នកដែលត្រូវបានយកទៅសម្លាប់ ។ ដូច្នេះអ្នកទោសដែលជាប់ជាមួយខ្ញុំមានចំនួនថេរជានិច្ច ។ អ្នកទោសមួយចំនួនទៀតអង្គការមិនចាំបាច់យកទៅសម្លាប់ឡើយ ។ វិធីសម្លាប់ក្រៅពីយកទៅសម្លាប់ដោយផ្ទាល់ដៃគឺ ធ្វើឲ្យអ្នកទោសទ្រុឌទ្រោមទាំងកម្លាំងចិត្តនិងកម្លាំងកាយ ដោយផ្តល់របបអាហារឲ្យមិនគ្រប់គ្រាន់ ធ្វើឲ្យរាងកាយរបស់អ្នកទោសមិនអាចទ្រាំទ្រនឹងការវាយដំប្រំធាក់របស់សន្តិសុខខ្មែរក្រហមក្នុងពេលសួរចម្លើយម្តងៗ ។ ម្យ៉ាងទៀត យើងគ្មានកម្លាំងកំហែងឯណានឹងដើរអួសទៅមុខជាមួយនឹងច្រវ៉ាក់ដែលកំពុងតែជាប់ជើងរបស់ទាំងពីរទេ ។

“ខ្មែរក្រហមដាក់ទោសឲ្យខ្ញុំស្លាប់ តែខ្ញុំហួសពេលកំណត់ត្រូវស្លាប់” ដូចនេះខ្ញុំត្រូវមានជីវិតរស់វិញ ។ ខ្មែរក្រហមយល់ថាទោសកម្រិតធ្ងន់ដូចខ្ញុំ ជាមួយនឹងការបង្អត់អាហារបែបនេះ ខ្ញុំនឹងស្លាប់នៅក្នុងអំឡុងពេលណាមួយជាមិនខាន ។ ប៉ុន្តែ ពេលវេលាកំណត់បានមកដល់ ខ្ញុំបែរជាមិនស្លាប់ ។ បែបនេះអង្គការទុកផ្លូវឲ្យខ្ញុំរស់ដោយសម្រាលទោសខ្ញុំឲ្យស្រាលជាងមុន ។ សន្តិសុខបានដកខ្នោះចេញពីជើងរបស់ខ្ញុំម្ខាង ។ នៅក្នុងគុក ខ្ញុំបានលបមើលតាមប្រហោងជញ្ជាំងបន្ទប់របស់ខ្ញុំ ខ្ញុំឃើញកងសន្តិសុខខ្មែរក្រហមសម្លាប់អ្នកទោសយ៉ាងសាហាវ រួចបោះសាកសពគរលើគ្នាដូចជាសត្វធាតុ ។ ការសម្លាប់កើតមានជាហូរហែរហូតដល់ម៉ោង៦ល្ងាច ។ អ្នកទោសនៅជិតខ្ញុំម្នាក់បានត្អូញត្អែរថា គាត់មិនអាចរស់បានយូរឡើយ ពីព្រោះសន្តិសុខវាយសួរចម្លើយគាត់រហូតដល់ធ្លាក់ឈាម ។ ពីរថ្ងៃក្រោយមកគាត់ក៏បានស្លាប់ ឃើញទិដ្ឋភាពបែបនេះខ្ញុំពិតជាមានការរន្ធត់ចិត្តខ្លាំងណាស់ ព្រោះមិនដឹងថាវាសនារបស់ខ្ញុំដូចគាត់ដែរឬអត់ ។ ឈ្មោះអ្នកទោសដែលនៅក្បែរខ្ញុំតែងតែត្រូវបាននាំចេញជាហូរហែ ។

នៅពេលសន្តិសុខចូលមកហៅឈ្មោះអ្នកទោសម្តងៗ ខ្ញុំតែងបន់ស្រន់កុំឲ្យហៅចំឈ្មោះរបស់ខ្ញុំ ។ ពេលសន្តិសុខហៅរំលងឈ្មោះខ្ញុំម្តងៗ ខ្ញុំមានអារម្មណ៍ត្រេកអរណាស់ព្រោះខ្ញុំដឹងថា ខ្ញុំនៅមានសង្ឃឹមសម្រាប់ថ្ងៃស្អែកទៀត ។ ខ្ញុំរស់នៅក្នុងគុកនេះអស់រយៈពេល៩ខែទើបអង្គការដោះលែងពីគុកក្រាំងតាចាន់វិញ ។ ខ្ញុំត្រេកអរណាស់ ប៉ុន្តែ ខ្ញុំមិនអាចឈានជើងដើរចេញពីគុកបានឡើយ ដោយសារកជើងរបស់ខ្ញុំរលេះរលួយសល់តែឆ្អឹង ។ ខ្ញុំព្យាយាមដើរចេញពីកន្លែងដ៏ខ្មៅងងឹតនេះ ប៉ុន្តែនៅពេលខ្ញុំបោះជំហានទៅមុខ រាងកាយខ្ញុំទាំងមូលដួលជាច្រើនសា ។ ខ្ញុំគិតថាប្រហែលជាគ្មានឱកាសរួចផុតពីរណ្តៅមរណៈនេះឡើយ ។ តាមស្ថានភាពនៅក្នុងបរិវេណគុកនិងរបៀបចាត់ចែងការពារកុំឲ្យអ្នកទោសរត់ ខ្ញុំសន្និដ្ឋានថាគ្មានអ្នកទោសណាម្នាក់អាចលួចរត់ចេញពីគុកនោះបានឡើយ ។

សភាពដែលខ្ញុំមិនដើរចេញផុតពីបរិវេណគុកនេះ ហាក់ដូចជាប្រផ្នូលអាក្រក់មួយសម្រាប់ខ្ញុំ ដែលនៅតែមិនអាចគេចផុតពីជីវិតរស់នៅក្នុងគុកនេះបាន ។

ជាអកុសល សន្តិសុខគុកក្រាំងតាចាន់ បែរជាបញ្ជូនខ្ញុំទៅដាក់គុកមន្ទីរ២០៤ ។ ខ្ញុំជាប់គុកនៅមន្ទីរនេះអស់រយៈពេលជាងមួយឆ្នាំទៀត ។ នៅទីនោះ អ្នកទោសស្ត្រីនិងអ្នកទោសបុរស ត្រូវបានបែងចែកឲ្យនៅផ្សេងគ្នា ។ យប់ឡើងសន្តិសុខខ្មែរក្រហមហៅអ្នកទោសស្ត្រីចេញក្រៅ ខ្ញុំមិនដឹងថា ខ្មែរក្រហមធ្វើអ្វីចំពោះអ្នកទោសស្ត្រីឡើយ ។ ប៉ុន្តែទោះជាខ្ញុំដឹង ក៏ខ្ញុំមិនហ៊ាននិយាយដែរ ខ្ញុំស៊ូទ្រាំធ្វើគ-ថ្លង់មិនឮអ្វីទាំងអស់ ដើម្បីកុំឲ្យគ្រោះថ្នាក់ដល់ខ្លួន ។ អ្នកទោសស្ត្រីម្នាក់បានលួចប្រាប់ខ្ញុំថា រយៈពេលដែលគាត់ជាប់ខ្នោះ ពួកសន្តិសុខបានលូកស្ទាបអាវៈយវៈភេទរបស់គាត់ ប៉ុន្តែគាត់មិនអាចធ្វើអ្វីពួកនោះបានឡើយ ។

ទីបំផុតខ្ញុំត្រូវខ្មែរក្រហមដោះលែងពីគុកនៅឆ្នាំ១៩៧៨ ប៉ុន្តែសកម្មភាពខ្ញុំនៅតែស្ថិតក្នុងការតាមដានពីឈ្លបខ្មែរក្រហមជានិច្ច ។៦ខែក្រោយមកអង្គការបានរៀបចំផ្សំផ្គុំខ្ញុំជាមួយនារីម្នាក់ដែលជាប្រពន្ធរបស់ខ្ញុំសព្វថ្ងៃ ។

បន្ទាប់មកទៀតខ្មែរក្រហមបានបំបែកខ្ញុំនិងប្រពន្ធឲ្យរស់នៅដាច់ដោយឡែកពីគ្នា ។ ដោយសារខ្ញុំមានប្រវត្តិជាអ្នកទោស គ្រប់សកម្មភាពរបស់ខ្ញុំត្រូវពួកខ្មែរក្រហមតាមដានជាប់រហូត ។ ជីវិតរបស់ខ្ញុំប្រៀបដូចជារស់នៅក្នុងគុកឥតជញ្ជាំងដែរ ប៉ុន្តែខ្ញុំ

មិនអស់សង្ឃឹមឡើយ ព្រោះខ្ញុំមានបំណងជួបប្រពន្ធរបស់ខ្ញុំដែលទើបតែរៀបការថ្មីថ្មោងនាពេលអនាគត ។

ថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ គឺជាថ្ងៃដែលរបបខ្មែរក្រហមបានដួលរលំ ។ ខ្ញុំបានវិលត្រឡប់មករស់នៅតាមបែបជីវិតធម្មតានៅក្នុងភូមិរបស់ខ្ញុំ ។ សព្វថ្ងៃខ្ញុំមានកូនបីនាក់ ខ្ញុំនិងក្រុមគ្រួសាររស់នៅជួបជុំគ្នា ។ ជីវភាពរស់នៅរបស់ខ្ញុំកាន់តែប្រសើរជាងមុន ប៉ុន្តែអតីតកាលរបស់ខ្ញុំនៅតែដិតដាមក្នុងអារម្មណ៍ខ្ញុំជានិច្ច ។ ពេលខ្លះខ្ញុំយល់សុបិនឃើញខ្ញុំកំពុងតែទទួលរងទារុណកម្មនៅក្នុងគុក ។ ពេលខ្ញុំភ្ញាក់ពីដំណេកទើបខ្ញុំដឹងថា នេះជាបច្ចុប្បន្នកាល មិនមែនជាអតីតកាលឡើយ ខ្ញុំមានប្រពន្ធនិងកូន ពេលនោះអារម្មណ៍របស់ខ្ញុំក៏រសាយទៅវិញ ។ ប៉ុន្តែនៅពេលដែលខ្ញុំឃើញជនដៃដល់ខ្មែរក្រហមម្នាក់នៅក្នុងភូមិ អារម្មណ៍របស់ខ្ញុំចាប់ផ្តើមពុះកញ្ជ្រោលឡើងវិញ ។ ទោះជាយ៉ាងណាក្តី ក៏ខ្ញុំមិនអាចធ្វើអ្វីអ្នកនោះបានឡើយ ព្រោះប្រទេសមានច្បាប់ ។ **ឆង ឧត្តតារា**

# វន់ : កម្មករក្រសួងពាណិជ្ជកម្ម

បន្ទាប់ពីរដ្ឋប្រហារឆ្នាំ១៩៧០ ឃុំអំពិល ក្នុងខេត្តសៀមរាបត្រូវកាន់កាប់ដោយកងទ័ពរំដោះ ហើយយុវជនយុវនារីនិងក្មេងៗជំទង់ត្រូវបានកេណ្ឌឲ្យធ្វើជាកងឈ្លបដើរយាមល្បាតនិងតាមចាប់គិញនៅក្នុងភូមិ ។ មិនខុសពីក្មេងៗដែលមានវ័យស្របាលគ្នាដែលនៅក្នុងភូមិ ហ៊ិន វន់ ដែលកាលនោះមានអាយុទើបតែ១៣ឆ្នាំ ត្រូវប្រធានភូមិឈ្មោះ រ៉ឹក ចាត់តាំងឲ្យចូលធ្វើជាឈ្លបនៅភូមិអញ្ចាញ ។

វន់ បានឲ្យដឹងថា កាលពីកុមារភាព វន់ បានបោះបង់ចោលការសិក្សាមកបម្រើបដិវត្តន៍ ។ វន់ មានឈ្មោះដើមថា វួន ។ ក្រោយមក វន់ ត្រូវបានបំពាក់អាវុធ និងត្រូវបានបញ្ជូនឲ្យទៅហ្វឹកហាត់ក្បួនយោធានៅឃុំខ្នារពោធិ៍ក្នុងស្រុកសូទ្រនិគមរយៈពេល៨ខែ ។ នៅឆ្នាំ១៩៧៣ ក្រោយពីបានបញ្ចប់វគ្គ វន់ និងកងទ័ពដែលមានវ័យស្របាលគ្នាត្រូវបានចាត់តាំងឲ្យទៅវាយឆ្មក់តំបន់ខាងក្នុងដែលកាន់កាប់ ដោយទាហាន លន់ នល់ ។ កងទ័ពរំដោះបានធ្វើការវាយប្រហារជាច្រើនលើកទើបដណ្តើមបានមូលដ្ឋានខេត្តសៀមរាប ។ រយៈពេលពីរបីថ្ងៃបន្ទាប់ពីវាយដណ្តើមបានខេត្តសៀមរាប កងរបស់ វន់ ត្រូវបានហៅឲ្យទៅប្រជុំជាមួយកងដទៃទៀតនៅវត្តខ្វាច់ដើម្បីជប់លៀងអបអរពីជ័យជម្នះនេះ ។ ក្នុងឱកាសជុំគ្នានោះ ប្រធានវរៈរបស់ វន់ ឈ្មោះ ហ័ស បានប្រាប់កងទ័ពរំដោះឲ្យត្រៀមលក្ខណៈទៅជួយរំដោះទីក្រុងភ្នំពេញតាមសេចក្តីអំពាវនាវរបស់សម្តេចឪ ។

នៅថ្ងៃបន្ទាប់ វន់ និងកងទ័ពរំដោះទាំងយុទ្ធជននិងយុទ្ធនារីប្រមាណ៦០០នាក់ដែលមកពីកងផ្សេងៗបានធ្វើដំណើរដោយកាណូតតាមបឹងទន្លេសាបឆ្ពោះទៅទីក្រុងភ្នំពេញ ។ មកដល់ខេត្តកំពង់ឆ្នាំង ទូករបស់ វន់ បានលិច ហើយត្រូវបានជួយសង្គ្រោះដោយទូកកងទ័ពរំដោះដែលធ្វើដំណើរទៅជាមួយគ្នា ។ ការធ្វើដំណើរនេះមានរយៈពេលពីរសប្តាហ៍ទើបធ្វើដំណើរដល់ក្រុងភ្នំពេញ ។

ពេលទៅដល់ក្រុងភ្នំពេញ ទីក្រុងទាំងមូលត្រូវបានរំដោះរួចរាល់ ហើយប្រជាជនត្រូវបានជម្លៀសចេញអស់ដែរ ។ ពេលនោះទើប វន់ ដឹងថា នេះជានយោបាយរបស់អង្គការដើម្បីអូសទាញយុទ្ធជនឲ្យទៅធ្វើជាកម្មករតែប៉ុណ្ណោះ ។ កងរបស់ វន់ ត្រូវបានចាត់តាំងឲ្យទៅឈរជើងនៅវត្តទួលទំពូង ដើម្បីរង់ចាំទទួលផែនការថ្មី ។ អង្គការចាប់ផ្តើមធ្វើប្រវត្តិរូបកងទ័ពដែលមកដល់ថ្មី ហើយ វន់ ក៏បានធ្វើប្រវត្តិរូបដែរ ។ ក្រៅពីនេះ វន់ ត្រូវបានចាត់តាំងឲ្យដាំដើមដូងនៅជុំវិញផ្សារចាស់និងគាស់ថ្មនៅម្តុំនោះ ។ វន់ និយាយថា «យើងទៅក្រោយគេ ពេលទៅដល់ភ្នំពេញគ្មានឃើញមនុស្សម្នាទេ ស្ងាត់ជ្រាប ។ យើងចេះតែដាំដូង ហើយកាប់គាស់ថ្មតាមអ៊ីចឹង ...នយោបាយវាគេចេះតែប្រើយើង ។ គេកុហកថាភ្នំពេញមិនទាន់ដាច់ ...តាមពិតគំនិតគេនោះគេឲ្យយើងទៅធ្វើកម្មករ» ។

ប្រហែលជា៨ខែក្រោយមក អង្គការចាត់តាំងយុទ្ធជនទាំងអស់ឲ្យទៅជួយរំដោះក្រុងកំពង់សោម ដែលនេះក៏ជាលេសមួយដើម្បីដកយុទ្ធជនឲ្យចេញពីទីក្រុងដែរ ។ នៅក្រុងកំពង់សោម វន់

ត្រូវបានដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ដែលមាន វិទ្ធ ជាប្រធានប្រចាំការនៅកំពង់ផែកំពង់សោម ។ វន់ មានភារកិច្ចដញ្ជូនផ្លែដូងនិងកៅស៊ូឡើងកប៉ាល់ចិន និងការពារសម្ភារដែលកប៉ាល់ចិនដឹកទម្លាក់នៅកំពង់ផែដូចជាអង្ករ គ្រឿងបរិភោគនិងរថយន្ត ។ ថ្វីដ្បិតតែកំពង់ផែជាកន្លែងដោះដូរស្បៀងអាហារនិងទំនិញរវាងកម្ពុជានិងចិនក៏ដោយ ក៏ វន់ និងកម្មករដទៃទៀតមិនបានទទួលរបបអាហារបរិបូណ៌ដែរ ។ វន់ និយាយទាំងហួសចិត្តថា "...ដូរ(អង្ករ) បានហើយមិនដឹងគំនិតគេ(អង្គការ) គិតដូចម្ដេច មិនដឹងយកអង្ករទៅណា ឲ្យប្រជាជនហូបឬយកទៅទុកចោល?" ។ វន់ បានលួចអង្ករយកមកដាំហូបពេលយប់ម្ដងម្កាលដែរ ដើម្បីបំប៉នកម្លាំងឲ្យធន់នឹងការងារធ្ងន់ ។

ពីរឆ្នាំក្រោយមក វន់ ត្រូវបញ្ជូនឲ្យទៅធ្វើជាកម្មករលីសែងនៅសាខាពាណិជ្ជកម្មក្នុងខេត្តកំពង់ចាម (កំពង់ផែពាណិជ្ជកម្មទន្លេបិទ) ។ វន់ ដឹកជញ្ជូនជ័រកៅស៊ូពីឡានដាក់ផែនិងពីផែដាក់ឡានវិញ ទុកឲ្យក្រុមដឹកជញ្ជូនដឹកពីខេត្តកំពង់ចាមទៅខេត្តស្វាយរៀង ។ ពេលខ្លះ វន់ ក៏ត្រូវធ្វើដំណើរតាមរថយន្តដឹកជញ្ជូនដែរ ដើម្បីជញ្ជូនកៅស៊ូទម្លាក់នៅកំពង់ចម្លងអ្នកលឿងនិងបញ្ជូនបន្តទៅក្រុងកំពង់សោម ។

នៅចុងឆ្នាំ១៩៧៨ វន់ បានផ្លាស់ឲ្យមកបកផ្លែគយកសំឡីនៅវត្តទួលទំពូង ។ ក្រោយពីបកបានចំនួនគ្រប់គ្រាន់ហើយ វន់ ត្រូវបញ្ជូនសំឡីទាំងនោះទៅគ្រីបនៅតាខ្មៅមុននឹងនាំចេញទៅក្រៅ ។ ការងារនៅកន្លែងបកផ្លែគមិនសូវពិបាកដូចការងារកម្មករលីសែងដូចនៅកំពង់ផែទេ ក៏ប៉ុន្តែ វន់ តែងព្រួយបារម្ភអំពីសុវត្ថិ-ភាពរបស់ខ្លួនជាងកន្លែងមុនៗ ដោយសារថាសមាជិកនៅក្នុងក្រុមរបស់គាត់បានបាត់ខ្លួនជាបន្តបន្ទាប់ អ្នកខ្លះត្រូវអង្គការផ្លាស់ឲ្យទៅធ្វើការនៅខេត្តបាត់ដំបង ហើយអ្នកខ្លះទៀតក៏បាត់ខ្លួនដោយមិនដឹងមូលហេតុ ។ វន់ បញ្ជាក់ថា "នៅយូរទៅបាត់សមា-ជិក ខ្លះគេផ្លាស់ឲ្យទៅអ៊ីណេះទៅអ៊ីណោះ ។ ច្រើនតែផ្លាស់ចេញពីទួលទំពូងឲ្យទៅនៅបាត់ដំបង ហើយមិនដឹងគេផ្លាស់យកទៅណា? អត់ដែលឃើញត្រឡប់មកវិញទេ ទៅក៏បាត់សូន្យៗ ។ នឹកឃើញថា គេដកយើងទៅពិតជាយកទៅសម្លាប់ហើយ ម៉្លោះហើយយើងចេះតែទុកក្នុងចិត្ត" ។

នៅគ្រប់កន្លែងធ្វើការ វន់ តែងនឹករឭកដល់ឪពុកម្ដាយនិងបងប្អូនដែលរស់នៅឯស្រុកកំណើត ក៏ប៉ុន្តែ វន់ មិនដែលមានឱកាសទៅលេងឬក៏សរសេរសំបុត្រប្រាប់ដល់ក្រុមគ្រួសារពីសុខទុក្ខរបស់ខ្លួនទេ ហើយ វន់ ក៏មិនបានដឹងថាឪពុកម្ដាយដែលរស់នៅតាមសហករណ៍មានសុខទុក្ខយ៉ាងណាដែរ ។

រហូតដល់ដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមរំដោះបានទីក្រុងភ្នំពេញ អង្គការបានជម្លៀសប្រជាជនទៅភាគខាងលិច ។ វន់ មិនបានធ្វើដំណើរទៅតាមខ្មែរក្រហមទេ ។ វន់ ធ្វើដំណើរត្រឡប់ទៅភូមិកំណើតវិញដើម្បីស៊ើបសួរដំណឹងឪពុកម្ដាយ ។ វន់ ចំណាំឪពុកម្ដាយរបស់ខ្លួនមិនច្បាស់ទេ ព្រោះពេលចាកចេញពីផ្ទះគាត់មានអាយុ១៣ប៉ុណ្ណោះ ។ ឪពុកម្ដាយរបស់ វន់ សប្បាយចិត្តណាស់ គាត់ទាំងពីរនឹកស្មានថាកូនរបស់គាត់ស្លាប់បាត់បង់ជីវិតនៅក្នុងរបបនោះបាត់ទៅហើយ ។

បច្ចុប្បន្ន វន់ មានអាយុ៥០ឆ្នាំនិងមានកូន៨នាក់ហើយ ។ ក៏ប៉ុន្តែគាត់នៅតែមិនយល់អំពីនយោបាយនិងការគ្រប់គ្រងរបស់ខ្មែរក្រហមឡើយ គាត់ជឿងឆ្ងល់ចំពោះនយោបាយខ្មែរក្រហមក្នុងកសាងសង្គមមួយដែលបរិសុទ្ធ គ្មានការចាយលុយ និងគ្មានសេរីភាពក្នុងការរស់នៅ ។ វន់ និយាយថា "របបហ្នឹងវាប្រុងសម្លាប់យើងចោលអស់ក៏មិនដឹង ។ បើសង្គ្រាមចប់ហើយគេមិនឲ្យមកផ្ទះ នឹកឃើញក្នុងចិត្តខ្លួនឯង ប៉ុន្តែមិនឲ្យគេដឹងខ្លាចគេសម្លាប់យើងចោលទៀត" ។

វន់ សង្ឃឹមថា តុលាការខ្មែរក្រហមនឹងលាតត្រដាងឲ្យប្រជាជនបានដឹងពីមូលហេតុពិតនៃការដឹកនាំរបស់ខ្មែរក្រហមទៅរកការសម្លាប់មនុស្ស និងដើម្បីឲ្យប្រជាជនអស់មន្ទិលសង្ស័យចំពោះអតីតកាលរបស់ខ្លួន និងចាប់ផ្ដើមជីវិតថ្មី ។ វន់ បានបញ្ជាក់ពីចម្ងល់របស់ខ្លួនថា "ខ្ញុំចង់ដឹងថាតើខ្មែរក្រហមសម្លាប់ប្រជាពលរដ្ឋហ្នឹងវាបៀបម៉េច? ហេតុដូម្ដេចបានជាសម្លាប់ប្រជាពលរដ្ឋ"?

វន់ ក៏មានការព្រួយបារម្ភអំពីការស្លាប់បាត់បង់ជីវិតរបស់មេដឹកនាំខ្មែរក្រហមបន្តបន្ទាប់ទៀត មុនពេលឡើងឆ្លើយបំភ្លឺពីការពិតនៅក្នុងតុលាការករណីដូចជា តាម៉ុក ជាដើម ។

**ណាយ សុផារី**

# យុវសិស្សកម្ពុជាយល់ដឹងអំពីអតីតកាលរបស់ឪពុកម្តាយ និងសាលាក្តីខ្មែរក្រហម

នៅថ្ងៃអង្គារ៍ទី១៩ ខែធ្នូ ឆ្នាំ២០០៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចមួយសម្រាប់ក្រុមសិស្សវិទ្យាល័យប្រមាណជាង៣០០នាក់ទៅកាន់ទីតាំងបូជនីយដ្ឋានប្រល័យពូជសាសន៍សំខាន់ៗមួយចំនួនព្រមទាំងអគារសវនាការនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ដំណើរទស្សនកិច្ចនេះ ត្រូវបានធ្វើឡើងក្នុងទ្រង់ទ្រាយធំជាលើកដំបូងបង្អស់ ដែលវិទ្យាល័យនានានៅក្នុងប្រទេសកម្ពុជាមិនធ្លាប់បានធ្វើពីមុនមក



ចាប់តាំងពីអំពើប្រល័យពូជសាសន៍បានបញ្ចប់ នៅក្នុងឆ្នាំ១៩៧៩ ។

ដោយសារឆ្នាំ២០០៦នេះគឺជាឆ្នាំដែលតុលាការចោទប្រកាន់បទឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យបានលេចរូបរាងច្បាស់នោះ វាហាក់ដូចជាមានលក្ខណៈសមហេតុផលដែលលោក ហង់ ឈុំ នាយកវិទ្យាល័យហ៊ុនសែន អង្គស្នួល បានធ្វើសំណើសុំនាំសិស្សានុសិស្សរបស់លោកមកទស្សនកិច្ចសិក្សានៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលជាកន្លែងបញ្ជាក់ច្បាស់ពីអំពើឧក្រិដ្ឋកម្មដ៏ឃោរឃៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីទទួលបានសំបុត្រមួយច្បាប់ពីលោក ហង់ ឈុំ ដែលស្នើសុំឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំដំណើរទស្សនកិច្ចសម្រាប់សិស្សរបស់លោក មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំដំណើរទស្សនកិច្ចនេះដោយដឹកនាំក្រុមសិស្សទៅទស្សនាមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសាន៍ទួលស្លែង បូជនីយដ្ឋានវាលពិឃាដជើងឯក និងជួបជាមួយមន្ត្រីនានានៅក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទើបសាងសង់រួច ។

ក្រុមសិស្សចំនួន៣៨៣នាក់និងលោកគ្រូអ្នកគ្រូចំនួន៣៨នាក់ បានមកចូលរួមដើម្បីរំពុកឡើងវិញនិងរៀនសូត្រអំពីព្រឹត្តិការណ៍មួយក្នុងប្រវត្តិសាស្ត្រកម្ពុជាដែលមានលក្ខណៈឃោរឃៅរហូតដល់ឪពុកម្តាយភាគច្រើនអាចត្រឹមតែនិយាយបានបន្តិចបន្តួចតែប៉ុណ្ណោះ ។ ភាគច្រើននៃសិស្សថ្នាក់ទី១២ទាំងអស់ដែលមានអាយុចាប់ពី១៧ឆ្នាំទៅដល់២០ឆ្នាំ ដំណើរទស្សនកិច្ចនេះ

គឺជាលើកដំបូងហើយដែលនាំពួកគេទៅកាន់កន្លែងទាំងបីនោះ ។ នេះមិនមែនជាដំណើរទស្សនកិច្ចសិក្សាពិសេសជាងគេនោះទេ ប៉ុន្តែជាដំណើរទស្សនកិច្ចមួយដែលនាំយុវជនកម្ពុជាទាំងអស់ បោះជំហានទៅមុខឲ្យកាន់តែជិតថែមទៀតដើម្បីស្វែងយល់អំពីអតីតកាលឪពុកម្តាយរបស់ខ្លួន ។

អ្វីដែលពិបាកដឹងអំពីរឿងរ៉ាវនៃការរស់រានមានជីវិតប្តីក៏ការនិយាយអំពីអំពើឃោរឃៅនៃរបបខ្មែរក្រហមនៅពេលជួបជុំគ្នាហូបបាយល្ងាចនោះត្រូវបង្ហាញច្បាស់នៅថ្ងៃអង្គារ៍នេះ ។ តាំងពីព្រឹកព្រលឹមរហូតដល់ពាក់កណ្តាលរសៀលនៃដំណើរទស្សនកិច្ច ក្រុមសិស្សបានបង្ហាញចេញនូវអារម្មណ៍ផ្សេងៗពីគ្នា រាប់ចាប់តាំងពីអារម្មណ៍ភ័យរន្ធត់រហូតដល់អារម្មណ៍ទុក្ខព្រួយនិងខឹងសម្បា ។ ក៏ប៉ុន្តែក្រុមសិស្សសម្តែងនូវសេចក្តីសង្ឃឹមនិងសុទិដ្ឋិនិយមនៅក្នុងដំណើរទស្សនកិច្ចនេះ ។ យោងទៅតាមបទសម្ភាសន៍មួយចំនួនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើឡើងជាមួយក្រុមសិស្សនោះ សិស្សភាគច្រើនបានសម្តែងនូវសេចក្តីប្រាថ្នាចង់ឲ្យមានការកាត់សេចក្តីមួយដ៏ឆាប់រហ័សនិងអព្យាក្រិត្យ ហើយបន្ថែមទៀតថា តុលាការនេះនឹងមានសមត្ថភាពរកយុត្តិធម៌បាន ។ ជារួមនេះដំណើរទស្សនកិច្ចនេះផ្តល់នូវការចងចាំទុកក្នុងចិត្តជនជាប្រយោជន៍សម្រាប់ការសិក្សារបស់សិស្សផង ។

ក្នុងសម្លៀកបំពាក់ឯកសណ្ឋានសិស្ស សិស្សថ្នាក់ទី១២ បានជួបជុំគ្នានៅក្នុងបរិវេណវិទ្យាល័យនៅម៉ោង៧ព្រឹក ឈរតម្រង់ជួររង់ចាំដោយអន្ទះសារដើម្បីឡើងរថយន្ត ។ មុនឡើងរថយន្ត បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកឯកសារសំខាន់ៗពីរប្រភេទ គឺកូនសៀវភៅដែលនិយាយអំពីច្បាប់ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជានិងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ព្រមទាំងទស្សនាវដ្តី«ស្វែងរកការពិត»លេខថ្មីៗ ។ សិស្សភាគច្រើនបានបើកឯកសារទាំងនោះអានភ្លាម ។ នេះប្រហែលជាលើកដំបូងហើយដែលសិស្សទាំងនោះបានទទួលឯកសារទាក់ទងនឹងអំពើប្រល័យពូជសាសន៍និងតុលាការនេះ ។

នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង សិស្សថ្នាក់ទី១២ទាំងអស់បានដើរពិនិត្យមើលដោយផ្ចិតផ្ចង់នូវផ្ទាំងរូបថតដែលដាក់តាំងនៅក្នុងអគារនីមួយៗ ព្រមទាំងថតរូបទាំងនោះទុកដោយប្រើទូរស័ព្ទដៃ កាមេរ៉ា និងកាមេរ៉ាឌីជីថល ។ ជាមួយគ្នានោះក៏មានពិភាក្សាគ្នារវាងលោកគ្រូអ្នកគ្រូអំពីអ្វីដែលពួកគេបានឃើញនៅពេលនោះដែរ ។ វាច្បាស់ណាស់ថា សិស្សានុសិស្សនៃវិទ្យាល័យ ហ៊ុនសែន អង្គស្នួល ប្រាកដជានឹងធ្វើការប្រៀបធៀបរវាងអតីតសិស្សវិទ្យាល័យនោះ(ទួលស្លែងអតីតវិទ្យាល័យ)ជាមួយនឹងវិទ្យាល័យរបស់ខ្លួន ។ នៅលើផ្ទាំងដ៏ធំដែលសរសេរជាភាសាខ្មែរ បារាំង និងអង់គ្លេស អំពីបទបញ្ជាសន្តិសុខ សិស្សប្រហែល១០០នាក់បានផ្តុំគ្នាកត់ត្រាអំពីបទបញ្ជាសន្តិសុខរបស់គុកសម្ងាត់ស-២១ ។ អ្នកខ្លះឈរសរសេរ អ្នកខ្លះអង្គុយសរសេរ ហើយអ្នកខ្លះវិញទៀតឈរអានឮៗឲ្យមិត្តភក្តិរបស់ខ្លួនស្តាប់ និងសរសេរតាម ។ អ្នកផ្សេងទៀតចម្លងបទបញ្ជានោះទាំងភាសាខ្មែរនិងភាសាអង់គ្លេស ។ នៅពេលខ្ញុំសួរលោកគ្រូម្នាក់ថា តើហេតុអ្វីបានសិស្សចេះតែបន្តកត់ត្រាស្ទើរតែគ្រប់អ្វីៗទាំងអស់បែបនេះ លោកគ្រូបានឆ្លើយថា សិស្សទាំងអស់នឹងត្រូវសួរសំណួរនៅពេលត្រឡប់ទៅថ្នាក់រៀនវិញអំពីអ្វីដែលពួកគេបានរៀនសូត្រអំពីដំណើរទស្សនកិច្ចនេះ ។


ក្រុមសិស្សានុសិស្សដើរទស្សនាអគារគុកនៅមន្ទីរស-២១

បទសម្ភាសន៍មួយចំនួនត្រូវបានធ្វើឡើងដោយក្រុមថតខ្សែភាពយន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រព័ន្ធឃោសនាផ្សេងៗ...ដោយផ្តល់ឲ្យយើងនូវគំនិតនិងទស្សនៈផ្ទាល់របស់មនុស្សជំនាន់ថ្មីអំពីអំពើប្រល័យ

ពូជសាសន៍នេះ ។ គីម ធារិទ្ធ ជា យុវជនកម្ពុជាម្នាក់ដែលមានការសង្ស័យមិនចង់ជឿថា មានអំពើប្រល័យពូជសាសន៍កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងទ្រង់ទ្រាយធំបែបនេះទេ ។ ក្នុងវ័យ១៩ឆ្នាំ ធារិទ្ធ បាននិយាយថា បន្ទាប់ពីបានធ្វើដំណើរមកកាន់សារមន្ទីរប្រល័យពូជសាសន៍ ឥឡូវនេះខ្លួនជឿរឿងរ៉ាវដែលជីដូនជីតារបស់ខ្លួនបានប្រាប់ហើយ ។ នៅពេលសួរថាតើគួរមានតុលាការដែរឬទេ ធារិទ្ធ បាននិយាយថា មិនគួរមានទេ ព្រោះអ្វីដែលបានកើតឡើងគឺជារឿងអតីតកាលទៅហើយ ។ ទោះជាយ៉ាងណាក៏ដោយ សិស្សផ្សេងទៀតយល់ថា តុលាការជារឿងចាំបាច់ ។ យុវសិស្ស អួន ឌីម៉ង់ អាយុ១៩ឆ្នាំ បញ្ជាក់ថា ខ្លួនគាំទ្រឲ្យមានតុលាការពីព្រោះថា អ្នកដែលប្រព្រឹត្តអំពើឃោរឃៅបែបនេះគួរតែត្រូវបាននាំយកទៅជំនុំជម្រះទោសចំពោះមុខច្បាប់ ។ បន្ទាប់ពីធំដឹងក្តី ឌីម៉ង់ ពិតជាជឿថាអំពើប្រល័យពូជសាសន៍បានកើតឡើងតាមរយៈស្តាប់ការរៀបរាប់អំពីការលំបាករបស់ឪពុកម្តាយខ្លួនដែលបានឆ្លងកាត់នៅក្នុងរបបនោះ ។ ការយល់ដឹងរបស់ ឌីម៉ង់ ពីអំពើប្រល័ពូជសាសន៍កើតឡើងតាមរយៈការផ្សព្វផ្សាយតាមទូរទស្សន៍ ការបង្ហាត់បង្រៀនរបស់លោកគ្រូអ្នកគ្រូ និងអានទស្សនាវដ្តី *ស្វែងរកការពិត* របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឌីម៉ង់ សង្ឃឹមថាតុលាការនេះនឹងធ្វើជាមេរៀនដើម្បីទប់ស្កាត់កុំឲ្យអ្នកគ្រប់គ្រងរបបក្រោយៗយកគំរូតាមរបបខ្មែរក្រហមទៀត ហើយអំពើប្រល័យពូជសាសន៍នឹងមិនកើតមានជាលើកទីពីរ នៅក្នុងប្រទេសកម្ពុជា ។ ស្រដៀងគ្នានេះដែរ នៅ សូគ្រីដា ក៏បានចាត់ទុកតុលាការនេះជាវិធីមួយដើម្បីជួយទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគត ។ ក្នុងវ័យ១៨ឆ្នាំ សូគ្រីដា ជឿថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបប្រល័យពូជសាសន៍នោះ មិនត្រូវទុកឲ្យកន្លងផុតទៅដោយគ្មានការដាក់ទោសទេ ។ សូគ្រីដា សង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញនឹងរកយុត្តិធម៌ឲ្យព្រលឹងប្រជាជនកម្ពុជាដែលបានស្លាប់ក្នុងអំឡុងរបបខ្មែរក្រហម ។ សិស្សដែលត្រូវបានសម្ភាសន៍និយាយថា ពួកគេគុកកួលរន្ធត់ក្នុងចិត្តចំពោះអ្វីដែលគេបានឃើញនៅក្នុងសារមន្ទីរគុកទួលស្លែង ។ សិស្សម្នាក់បាននិយាយថាខ្លួនមានអារម្មណ៍ខ្លាចផងនិងខឹងសម្បាផងនៅពេលឃើញរូបដែលដាក់តាំងនៅក្នុងអតីតគុកនោះ ។ សិស្សម្នាក់ទៀតនិយាយថា ខ្លួនមានអារម្មណ៍អាណិតអាសូរយ៉ាងខ្លាំងចំពោះអ្នកដែលបានស្លាប់ ។

បន្ទាប់មក សិស្សវិទ្យាល័យទាំងអស់បានធ្វើដំណើរឆ្ពោះ


ក្រុមសិស្សានុសិស្ស ធ្វើទស្សនកិច្ចនៅវាលពិឃាតបឹងជើងឯក

ទៅកាន់បូជនីយដ្ឋានវាលពិឃាដជើងឯក ដែលពួកគេអាចទស្សនាទីតាំងវាលពិឃាតមួយរបស់របបខ្មែរក្រហម ។ ជាថ្មីម្តងទៀត សិស្សចាប់ផ្តើមកត់ត្រានិងថតរូបដោយប្រើទូរស័ព្ទដៃនិងកាមេរ៉ាឌីជីថល ។ សិស្សទាំងអស់ដំណើរយ៉ាងយឺតៗជុំវិញបូជនីយដ្ឋាន និងពិភាក្សាគ្នាអំពីអ្វីដែលបានឃើញ ។ សិស្សស្រីម្នាក់មានភាពក្លាហានក្នុងការឆ្លើយទៅនឹងសំណួរ យុវសិស្ស ឈួយ ជ្រូវី មានអាយុ១៨ឆ្នាំ ហាក់ដូចជាមានការយល់ដឹងច្រើនពីអំពើប្រល័យពូជសាសន៍និងតុលាការ ។ ជ្រូវី និយាយថា ចំណាប់អារម្មណ៍របស់ខ្លួនខាងនយោបាយនិងបញ្ហាសង្គមគឺផុសចេញពីឪពុករបស់ខ្លួន ។ ពេលដែលឪពុករបស់នាងនិយាយប្រាប់ពីការធ្វើការងារធ្ងន់ៗដែលគាត់បានស៊ូទ្រាំក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្លួន យល់ឃើញថាវាពិបាកនឹងជឿណាស់ ។ ក៏ប៉ុន្តែបន្ទាប់ពីបានទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងបូជនីយដ្ឋានវាលពិឃាដជើងឯក ជ្រូវី លែងមានការសង្ស័យទៀតដែលថាតើអំពើប្រល័យពូជសាសន៍មានពិតប្រាកដឬក៏អត់នោះ ។ ជ្រូវី បញ្ជាក់ថា ពេលឃើញភ័ស្តុតាងជាក់ស្តែង នៅចំពោះមុខបែបនេះធ្វើឲ្យខ្លួនរកនិយាយអ្វីមិនចេញ ហើយខ្លួនមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំង ។

ទាក់ទងទៅនឹងបញ្ហាអង្គជំនុំជម្រះវិសាមញ្ញ ជ្រូវី មាន

យោបល់ថា ទី១ ការកាត់ទោសត្រូវតែធ្វើជាសាធារណៈនិងមានតម្លាភាព មិនមែនត្រឹមតែដោយសារសាធារណជនមានសិទ្ធិស្គាល់អ្នកដែលមានគំនិតក្នុងការសម្លាប់ជីវិតមនុស្សស្លូតត្រង់អស់យ៉ាងច្រើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអព្យាក្រិតភាពរបស់តុលាការក៏ត្រូវតែរក្សាឲ្យបានដែរ ។ ទី២ សមាសភាពចម្រុះកម្ពុជានិងអន្តរជាតិថា មានភាពវិជ្ជមានដែលភាគីកម្ពុជាអាចទទួលបានចំណេះដឹងនិងបទពិសោធន៍ដ៏មានតម្លៃពីភាគីអន្តរជាតិនិងគោលដៅអាចសម្រេចបានយ៉ាងងាយស្រួល ។ ជ្រូវី បន្ថែមទៀតថា ខ្ញុំនអនុះសារក្នុងការចូលរួមសវនាការនិងស្នើសុំឲ្យមានថ្ងៃឈប់សម្រាករយៈពេលមួយថ្ងៃនៅថ្ងៃបើកសវនាការដើម្បីឲ្យសិស្សបានចូលរួមនៅក្នុងឱកាសពិសេសនេះ ។ ដោយមិនស្ទាក់ស្ទើរ ជ្រូវី ក៏បានឆ្លើយនូវសំណួរដែលសិស្សផ្សេងទៀតមានការលំបាកក្នុងការឆ្លើយ នៅពេលសួរអំពីទស្សនៈយ៉ាងម៉េចដែរដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតមានឡើងម្តងប្រជាជនត្រូវតែចេះស្រលាញ់និងគោរពគ្នាទៅវិញទៅមក ។

ទីកន្លែងចុងក្រោយនៃដំណើរទស្សនកិច្ចនេះចាប់ផ្តើមនៅម៉ោង២រសៀល ដោយបានជួបប្រជុំជាមួយលោក រាជ សម្បត្តិ មន្ត្រីអ្នកនាំពាក្យរបស់អង្គជំនុំជម្រះវិសាមញ្ញ និងលោក ភីតធ័រ ហ្វូសស៊័រ មន្ត្រីទទួលបន្ទុកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ សិស្សទាំងពីរត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់ពីមន្ត្រីតុលាការទាំងពីររូបនេះ និងការស្រាយបំភ្លឺអំពីព័ត៌មានស្តីអំពីសមាសភាពចម្រុះរបស់តុលាការ រចនាសម្ព័ន្ធអគារតុលាការចំណុចមួយចំនួនស្តីអំពីច្បាប់ខ្មែរក្រហម (ដូចជាក្រុមអ្នកដែលនឹងត្រូវនាំយកមកកាត់ទោស) បទបញ្ជាផ្ទៃក្នុងរបស់សាលាក្តី និងទីកន្លែងឃុំឃាំងដែលស្ថិតនៅខាងក្រោយសាលសវនាការ ។

បន្ទាប់មកទាំងលោកគ្រូអ្នកគ្រូនិងកូនសិស្សមានឱកាសសួរសំណួរ ។ សំណួរដែលបានសួររួមមាន តើអ្នកណាខ្លះនឹងត្រូវនាំយកទៅកាត់ទោស ហេតុអ្វីបានជាមានការចូលរួមពីអន្តរជាតិនៅ



ក្រុមសិស្សានុសិស្សស្តាប់ការបកស្រាយរបស់លោក រាជ សម្បត្តិ នៅអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា

ទៀតនៅក្នុងប្រទេសកម្ពុជា? ជ្រូវី បានឆ្លើយតបយ៉ាងរហ័សថា “វាសាមញ្ញបំផុត” ។ វាទាក់ទងទៅនឹងនយោបាយប្រកបដោយភាពស្មើភាពគ្នានិងទ្វេភាគីរវាងមេដឹកនាំប្រទេសយើង ។ យើងត្រូវតែធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យប្រាកដមួយនៅក្នុងប្រទេសកម្ពុជា ។ មានសារសំខាន់ប្រហាក់ប្រហែលគ្នានេះដែរក្នុងតុលាការនេះ ប្រសិនបើសហគមន៍អន្តរជាតិបានដឹងពីអំពើប្រល័យពូជសាសន៍នៅខណៈពេលដែលអំពើនេះកំពុងកើតឡើងនោះហេតុអ្វីក៏អន្តរជាតិមិនធ្វើអ្វីសោះដើម្បីទប់ស្កាត់ តើដំណើរការវិវត្តន៍របស់អង្គជំនុំជម្រះវិសាមញ្ញត្រូវផ្សព្វផ្សាយយ៉ាងដូម្តេចតាមរយៈទូរទស្សន៍ វិទ្យុ និងកាសែត តើនៅពេលណាទើបមាន

សវនាការដំបូង តើនឹងមានការស៊ើបអង្កេតប្រទេសនានាដែលជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហមដែរឬទេ តើពាក្យ"អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតនិងមេដឹកនាំជាន់ខ្ពស់" មានន័យដូចម្តេច តើការលើកលែងទោសត្រូវដោះស្រាយយ៉ាងដូចម្តេច ហេតុអ្វីបានជាខ្មែរក្រហមមានអាសនៈនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ តើអ្វីទៅជាគោលដៅរបស់របបកម្ពុជាប្រជាធិបតេយ្យដែលនាំឲ្យមនុស្សជាច្រើនបាត់បង់ជីវិត តើនឹងមានការកាត់ទោសជនជាតិបរទេសដែរឬទេ តើជនជាប់ចោទត្រូវឃុំឃាំងយូរប៉ុនណា មុនពេលមានការកាត់ទោស តើអ្នកដែលត្រូវកាត់ឲ្យជាប់ទោសនឹងមានទោសយ៉ាងណាខ្លះ និងការសម្លាប់ក្រុមគ្រួសារដោយពួកខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៨ តើតុលាការត្រូវបានដោះស្រាយយ៉ាងដូម្តេចដែរ?

ក្រៅពីឆ្លើយនឹងសំណួរខាងលើនេះ លោក សម្បត្តិ ក៏បាននិយាយប្រាប់អំពីប្រភេទជំងឺបាក់ស្បាតនិងវិធីទប់ទល់នឹងប្រភេទជំងឺនេះ ។ អារម្មណ៍នៅក្នុងបន្ទប់សវនការនោះពេលខ្លះមានភាពហ្មត់ចត់ និងពេលខ្លះមានភាពរស់រវើក ។ លោក សម្បត្តិ បានប្រើពាក្យសាមញ្ញៗជំនួសពាក្យបច្ចេកទេសមកពន្យល់បកស្រាយពីចំណុចផ្សេងដើម្បីឲ្យសិស្សងាយយល់ ។ ដោយសារពេលវេលាមានកំណត់ការសំណេះសំណាលជាមួយមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញបានបញ្ចប់ទៅនៅម៉ោង៣និង៣០នាទី ។ នៅពេលប្រជុំចប់ លោក ភីតធ័រ ហ្វូសធ័រ និងលោក រាជ សម្បត្តិ បានប្រគល់កូនសៀវភៅស្តីពីការណែនាំបំភ្លឺអំពីសាលាក្តីខ្មែរក្រហមចំនួន៣កញ្ចប់ដល់នាយកសាលានិងលោកគ្រូអ្នកគ្រូ ដើម្បីទុកចែកជូនសិស្សានុសិស្ស និងតម្កល់ទុកនៅក្នុងបណ្ណាល័យរបស់ខ្លួន ។ បន្ទាប់មកលោក សម្បត្តិ បាននាំសិស្សានុសិស្សដើរទស្សនាបរិវេណអង្គជំនុំជម្រះវិសាមញ្ញនិងពន្យល់ប្រាប់អំពីសារសំខាន់នៃរូបសំណាកដែលស្ថិតនៅក្បែរអគារសវនាការនោះ ។

ជារួមដំណើរទស្សនកិច្ចនេះបានទទួលជោគជ័យដ៏ត្រចះត្រចង់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងរៀបចំជាដំណើរទស្សនកិច្ចស្រដៀងគ្នាទៀតឲ្យដល់សិស្សានុសិស្សនៅពេលខាងមុខទៀត ក្នុងបំណងជួយអប់រំយុវជនកម្ពុជាស្វែងយល់ពីអំពើប្រល័យពូជសាសន៍ ។ ដំណើរទស្សនកិច្ចនេះបានផ្តល់ដល់សិស្សានុសិស្សនូវចំណេះដឹងបន្ថែមក្រៅពីមុខវិជ្ជានៅក្នុងថ្នាក់រៀន ដែលនេះជាកត្តាជម្រុញនិងលើកទឹកចិត្តសិស្សឲ្យចូលរួមយ៉ាងសកម្ម ។ ម្យ៉ាងទៀតដំណើរទស្សនកិច្ចនេះនឹងនាំឲ្យពួកគេឲ្យឃើញជាក់ស្តែងនូវរឿងរ៉ាវជូរចត់របស់ឪពុកម្តាយនិងអតីតកាលប្រទេសជាតិរបស់ពួកគេ ហើយនឹងនាំពួកគេឆ្ពោះទៅរកយុត្តិធម៌តាមផ្លូវតុលាការស្របទៅតាមបទដ្ឋានអន្តរជាតិ និងលើកទឹកចិត្តពួកគេឲ្យគិតគូរអំពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាលប្រទេសរបស់ខ្លួន ។ **កែវ ដាស៊ីល**

**ប្រសិនបើលោកនាយកវិទ្យាល័យមានបំណងចង់ឲ្យសិស្សរបស់ខ្លួនធ្វើទស្សនកិច្ចស្វែងយល់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន សូមអញ្ជើញទាក់ទងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុFM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុFM១០៣.២៥MHz ខេត្តបាត់ដំបងរៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ប៉ាង ពីរ័ន**

# ការកាត់ទោស នួន ជា ពីបទឧក្រិដ្ឋកម្មសង្គ្រាម

## សេចក្តីផ្តើម

នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ពិភពលោកមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើប្រទេសអាស៊ីអាគ្នេយ៍ដែលទទួលបានឯករាជ្យថ្មីៗ និងជាប់ពាក់ព័ន្ធក្នុងសង្គ្រាមជាមួយនឹងប្រទេសមហាអំណាចខាងសេដ្ឋកិច្ចនិងយោធា ។ កាសែតជាច្រើនបានចុះផ្សាយពីជ័យជម្នះរបស់វៀតណាមខាងជើងមកលើសហរដ្ឋអាមេរិក ជម្លោះក្នុងតំបន់រវាងចិននិងរុស្ស៊ី និងការទម្លាក់គ្រាប់ដោយសម្ងាត់របស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជា ។ ដោយបិទបាំងដោយស្រមោលនៃការតស៊ូខាងនយោបាយនៅលើពិភពលោកនេះ ជម្លោះដ៏ល្វីងជូចត់ក្នុងតំបន់បានពុះកញ្ជ្រោលឡើងរវាងប្រទេសពីរដែលជាប្រទេសសម្ព័ន្ធមិត្តនឹងគ្នា ។ ចាប់តាំងពីដើមសតវត្សរ៍ទី២០ មេដឹកនាំបក្សកុម្មុយនីស្តរបស់កម្ពុជា និងវៀតណាមជំនាន់នោះបានខិតខំប្រឹងប្រែងផ្តួលរលំរបបអាណានិគមនិយមបារាំងនិងចក្រពត្តិអាមេរិក ។ មេដឹកនាំនៃប្រទេសទាំងពីរបានធំធាត់ឡើងនៅក្រោមការកៀបសង្កត់របស់អាណានិគមនិយមបារាំង និងបានចាកចេញពីទឹកដីកំណើតរបស់ខ្លួនដើម្បីទៅសិក្សាឯក្រៅប្រទេស ។ នៅពេលដែលអ្នកទាំងនោះ បានវិលត្រឡប់មកកាន់ប្រទេសកំណើតរបស់ខ្លួនវិញ ការមិនពេញចិត្តនឹងស្ថានភាពនយោបាយនិងសេដ្ឋកិច្ចពួកគេបានដឹកនាំប្រទេសធ្លាក់ចូលទៅក្នុងសង្គ្រាមវាយឆ្មក់ដែលផ្តើមចេញពីតំបន់ដាច់ស្រយាល ។ នៅក្នុងឆ្នាំ១៩៣០ មេដឹកនាំទាំងនោះបានចងសម្ព័ន្ធមិត្តនឹងគ្នាដើម្បីបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន ។



នួន ជា

ភាពជាដៃគូរវាងកម្ពុជានិងវៀតណាម បានផ្តល់ផលប្រយោជន៍គ្នាទៅវិញរវាងប្រទេសទាំងពីរ ។

ផ្ទុយទៅវិញ សង្គ្រាមបានផ្ទុះឡើងរវាងប្រទេសកម្ពុជានិងវៀតណាម ។ របបខ្មែរក្រហមដែលជារបបមួយដែលធ្វើឲ្យប្រជាជនរបស់ខ្លួនមានការភ័យខ្លាចនិងមិនជឿទុកចិត្តគ្នា បានចោទប្រកាន់វៀតណាមខាងជើងថាបានស៊ើបការណ៍ និងបានប៉ុនប៉ងគ្រប់គ្រងតំបន់ឥណ្ឌូចិន ។ ការភ័យខ្លាចនេះទំនងជាមានការទាក់ទងទៅនឹងអំពើក្បត់របស់វៀតណាមខាងជើងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ ។ ជាងនេះទៅទៀត វៀតណាមបានបង្ហាញពីអារម្មណ៍ព្រហ្មវិហារធម៌របស់ខ្លួនចំពោះប្រជាជនកម្ពុជា ដោយសំដៅលើការទំនាក់ទំនងគ្នាជា"អាន់អែម" ជាវៀតណាមដែលមានន័យថា "បងប្អូន" ។ ដោយហេតុនេះ ក្នុងខណៈដែលខ្មែរក្រហមបង្ខំឲ្យប្រជាជនរបស់ខ្លួនជឿជាក់លើរបបដ៏គួរភ័យខ្លាចនេះ ខ្មែរក្រហមក៏បានវាយលុកចូលភូមិជាច្រើនរបស់វៀតណាមនៅក្នុងខេត្តហាទៀង និង តាយនិញ ។ ភាគច្រើននៃប្រជាជនវៀតណាមដែលរស់នៅក្នុងទីក្រុងភ្នំពេញត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥ ។ បុរសខ្មែរត្រូវបានបង្ខំឲ្យនាំប្រពន្ធរបស់ខ្លួនដែលជាជនជាតិវៀតណាមយកទៅសម្លាប់ចោល ។ ជាដំបូង ការប្រយុទ្ធគ្នារវាងប្រទេសទាំងពីរ ត្រូវបានរក្សាការសម្ងាត់ពីសហគមន៍អន្តរជាតិ ។ ជម្លោះនេះបានកើតឡើងនៅក្នុងឆ្នាំ១៩៧៧ ដែលនាំឲ្យមានការវាយតបតយ៉ាងខ្លាំងពីប្រទេសវៀតណាមចូលក្នុងប្រទេសកម្ពុជា

ហើយ នៅចុងបញ្ចប់វៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញ ។

វៀតណាមត្រូវខ្មែរក្រហមចាត់ទុកថាជា«សត្រូវស្នូលពូជ» ហើយអ្នកភូមិ សូម្បីអ្នកដែលរស់នៅក្នុងភូមិភាគបូព៌ា ក៏បានដើរតាមមាគ៌ារបស់បក្សដោយលះបង់ជីវិតផ្ទាល់របស់ខ្លួនដែរ ។ ការសម្លាប់ដ៏ធំធេង ត្រូវបានរាយការណ៍ឲ្យដឹងពេញទូទាំងតំបន់ ហើយការស្រែកប្រឆាំងវៀតណាម បានចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៧ ។ ដូចដែល ប៉ែន យៀវនិន ចង្អុលបង្ហាញភាពប្រទូស្ត-រាយគ្នាដែលកើនឡើងជាមួយប្រទេសវៀតណាមដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ផ្លូវការរបស់បក្ស បានឆ្លុះបញ្ចាំងអំពី «ទំនាក់ទំនងគ្នារវាងជម្លោះផ្ទៃក្នុងនិងការវាយប្រហាររបស់ខ្មែរក្រហមចូលក្នុងទឹកដីប្រទេសវៀតណាម» ។

ឧក្រិដ្ឋកម្មដែលប្រព្រឹត្តមកលើអ្នកទោសវៀតណាមនៅមន្ទីរឃុំឃាំងស-២១ អាចនឹងត្រូវដាក់ទោសជាបទឧក្រិដ្ឋកម្មសង្គ្រាមដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ ការចោទប្រកាន់ឧក្រិដ្ឋកម្មសង្គ្រាម ចំពោះការរំលោភបំពានមកលើកងទ័ពវៀតណាម អាចសម្រេចបានជាលទ្ធផលច្រើនជាងការទាមទារជីវិតកងទ័ពខ្មែរដោយសារតែវាបាំងជម្លោះមិនមែនអន្តរជាតិ ។ ធាតុគំរូភ័ស្តុតាងនៃច្បាប់រដ្ឋប្បវេណីមានលក្ខណៈទន់ភ្លន់ ហើយចៅក្រមត្រូវពិនិត្យស្ទើរតែគ្រប់ភ័ស្តុតាងដែលពាក់ព័ន្ធទាំងអស់ ។ បណ្តឹងចោទប្រកាន់ នួន ជា អាចជាបណ្តឹងដែលអាចទទួលយកបានដោយសារតែភ័ស្តុតាងចោទប្រកាន់ នួន ជា មានប្រសិទ្ធភាពច្រើនជាងបើប្រៀបធៀបទៅនឹងភ័ស្តុតាងចោទប្រកាន់ចុងចោទដទៃទៀត ។

អនុសញ្ញាទីក្រុងហ្សឺណែវទី៣ ដែលការពារឈ្លើសសឹកមានចែងនូវ«ជម្លោះប្រដាប់អាវុធអន្តរជាតិ» និងជនរងគ្រោះដែលត្រូវបានចាត់ទុកជា«ជនដែលត្រូវការពារ»ដោយអនុសញ្ញានេះ ។ បន្ថែមពីនេះទៀត មាត្រា៦នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក៏មានចែងនូវឧក្រិដ្ឋកម្មដែលមានកម្រិត «រំលោភបំពានយ៉ាងធ្ងន់ធ្ងរ» ដើម្បីកំណត់លក្ខណៈជាឧក្រិដ្ឋកម្មសង្គ្រាម ។

## ចម្លើយសារភាព

ប្រជាជនវៀតណាមប្រហែល៤៨៨នាក់ ត្រូវខ្មែរក្រហមចាប់ខ្លួននិងបានបញ្ជូនមកកាន់មន្ទីរឃុំឃាំងទួលស្លែងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមានអ្នកទោសប្រុស ៣៨១នាក់ អ្នកទោសស្ត្រី៥៩នាក់ និងអ្នកទោសជាកុមារ៤៧នាក់ ។ អ្នកទោសទាំងនោះ ត្រូវបានចាប់ខ្លួននៅក្នុងប្រទេសវៀត-ណាម ក្នុងទឹកដីដែលមានជម្លោះក្បែរព្រំដែន និងនៅក្នុងប្រទេសកម្ពុជា ។ ភាគច្រើនអ្នកទោសទាំងនោះ ជាជនស៊ីវិល និងអ្នកទោសជាច្រើននាក់ទៀតជាទាហាន ព្រមទាំងទាហាននៃកងទ័ពវៀតណាមខាងត្បូងដែលជា«ទាហានដែលបម្រើឲ្យរបប ធីវ គី ដ៏គួរឲ្យស្អប់ខ្ពើម» ។

ចម្លើយសារភាព និងប្រវត្តិរូបអ្នកទោសវៀតណាមប្រហែល ៥០នាក់ ព្រមទាំងបញ្ជីឈ្មោះសម្លាប់អ្នកទោសទាំងនោះ ត្រូវបានរក្សាទុកនៅក្នុងបណ្ណសារដ្ឋានទួលស្លែង ដែលជាមន្ទីរឃុំឃាំងដ៏ល្បីល្បាញរបស់ខ្មែរក្រហមដែលបានឃុំឃាំងអ្នកទោសប្រហែល ២ម៉ឺននាក់នៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ចម្លើយសារភាពទាំងនេះ ត្រូវបានសរសេរតែក្នុងរយៈពេលប៉ុន្មានម៉ោង ឬប៉ុន្មានថ្ងៃប៉ុណ្ណោះមុននឹងយកទៅសម្លាប់ចោល ។ អតីតយុទ្ធជនមន្ទីរឃុំឃាំងទួលស្លែង ឬ ស-២១ អះអាងបញ្ជាក់ថា អ្នកទោសជនជាតិវៀតណាមទាំងនេះ ត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់ចោល ។ ម្យ៉ាងទៀត ទូរលេខដែលចេញពីកម្មាភិបាលខ្មែរក្រហមនៅភូមិភាគបូព៌ាបង្ហាញឲ្យដឹងអំពីការរំលោភបំពាន និងការធ្វើទារុណកម្មអ្នកទោសវៀតណាមផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ចម្លើយសារភាពនៅទួលស្លែងផ្តល់ជាភ័ស្តុតាងដ៏សុក្រិតបំផុតទាក់ទិននឹងបទឧក្រិដ្ឋកម្មសង្គ្រាម ពីព្រោះចម្លើយទាំងនេះមានអត្តសញ្ញាណសម្គាល់ជនរងគ្រោះមួយចំនួន ដែលមានពេលវេលាច្បាស់លាស់បញ្ជាក់អំពីការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់ ។ អនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មរបស់អង្គការសហប្រជាជាតិកំណត់ឲ្យប្រើប្រាស់ចម្លើយសារភាពដែលធ្វើឡើងដោយការធ្វើទារុណកម្មតាមនីតិវិធី ។ ក៏ប៉ុន្តែ អនុសញ្ញានេះ អនុញ្ញាតឲ្យប្រើប្រាស់ចម្លើយសារភាពដែលជាភ័ស្តុតាងបង្ហាញអំពីការធ្វើទារុណកម្ម ។ ការប្រើប្រាស់ចម្លើយសារភាពនៅក្នុងបរិបទនេះ ជាក់ស្តែង មិនបានបង្កបញ្ហាខាងនយោបាយដូចគ្នាទៅនឹងការប្រើប្រាស់ចម្លើយសារភាពទាំងនេះទៅតាមខ្លឹមសារសំខាន់ៗនៃចម្លើយសារភាពឡើយ ។

យុទ្ធជនគុកទួលស្លែង បានបកប្រែនិងចម្លងចម្លើយសារភាព

ជាភាសាវៀតណាម ក្នុងខណៈពេលដែលពួកគេកំពុងសួរចម្លើយអ្នកទោស ក៏ប៉ុន្តែ ចម្លើយសារភាពភាគច្រើនត្រូវបានកត់ត្រាជាភាសាខ្មែរ ។ ម៉ម ណៃ អនុប្រធានសួរចម្លើយ និង ចាន់ អ្នកទាំងពីរជាអ្នកចាត់ចែងការសួរចម្លើយអ្នកទោសវៀតណាម ពីព្រោះអ្នកទាំងពីរនេះចេះភាសាវៀតណាមយ៉ាងស្ទាត់ ។ បន្ទាប់មក ម៉ម ណៃ បានបកប្រែនិងចម្លងចម្លើយសារភាពទាំងនោះជាភាសាវៀតណាម ។ អ្នកទោសភាគច្រើនត្រូវបានចាប់ខ្លួននៅភូមិភាគបូព៌ា តាមបណ្តោយព្រំដែនវៀតណាម ដោយកងពលលេខ៧០៣នៃកងទ័ពខ្មែរក្រហម ។ នៅពេលខ្លះ កងទ័ពរបស់កងពល៧០៣ បានដឹកជញ្ជូនអ្នកទោសទាំងនោះមកកាន់គុកទួលស្លែងផ្ទាល់តែម្តង ។ នៅពេលខ្លះទៀត សន្តិសុខគុក និងពេជ្ឈ-ឃាត ត្រូវបានបញ្ជូនទៅកាន់ខេត្តស្វាយរៀង ដើម្បីនាំអ្នកទោសត្រឡប់មកទីក្រុងភ្នំពេញវិញ ។

ក្នុងចំណោមចម្លើយសារភាពដែលត្រូវបានរកឃើញ មានអ្នកទោសស្ត្រី៨នាក់និងអ្នកទោសប្រុស៤០នាក់ ។ អ្នកទោសទាំងនោះមានអាយុចាប់ពី២០ទៅ៣៥ឆ្នាំ ។ ការជួបពិភាក្សាជាមួយនឹងអតីតយុទ្ធជន ស-២១ បង្ហាញឲ្យឃើញថាប្រហែលជាមានអ្នកទោសស្ត្រីច្រើនជាងនេះ ប៉ុន្តែចម្លើយសារភាពរបស់អ្នកទោសទាំងនោះមិនត្រូវបានកត់ត្រា ឬត្រូវបានខូចខាតអស់ក៏មិនដឹង ។ មានភស្តុតាងរូបថតអ្នកទោសស្ត្រីជនជាតិវៀតណាមម្នាក់ ដែលបានធ្វើអត្តឃាតដោយលោតទម្លាក់ខ្លួនពីអគារជាន់ទី៣ ។ បញ្ជីឈ្មោះសម្លាប់ជាច្រើនទៀត ក៏មានឈ្មោះអ្នកទោសស្ត្រីវៀតណាមផ្សេងៗទៀតដែរ ដែលគេមិនទាន់រកឃើញចម្លើយសារភាពនៅឡើយ ។ អ្នកទោសស្ត្រីទាំងនោះ ត្រូវខ្មែរក្រហមចាប់ខ្លួននៅក្នុងអំឡុងពេលមានជម្លោះនៅតាមព្រំដែនរវាងប្រទេសទាំងពីរ ។ ស្ត្រីខ្លះមានប្តីជាជនជាតិខ្មែរដែលរស់នៅក្នុងភូមិខ្មែរ ។ អ្នកទោសខ្លះទៀតបានសារភាពថា ខ្លួនជាគិញស៊ើបការណ៍ឲ្យរដ្ឋាភិបាលវៀតណាម ។ អ្នកទោសស្ត្រីម្នាក់ឈ្មោះ ង្វៀន ធី បាច វើ ជាអតីតអ្នកចម្រៀងប្រចាំសណ្ឋាគារ រ៉េកស៍ នៅក្នុងទីក្រុងសាយហ្គន ។ អ្នកទោសស្ត្រីម្នាក់នោះត្រូវខ្មែរក្រហមចាប់ខ្លួននៅជិតព្រំដែនខ្មែរនៅពេលដែលគាត់កំពុងតែធ្វើដំណើរទៅលេងសាច់ញាតិគាត់ និងបានឆ្លើយសារភាពថាខ្លួនជាគិញស៊ើបការណ៍ឲ្យរដ្ឋាភិបាលវៀតណាម ។

ភាគច្រើនអ្នកទោសបុរសជនជាតិវៀតណាម ជាទាហាន និងជាមន្ត្រីដែលបម្រើក្នុងជួរកងទ័ពវៀតណាម ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលមានជម្លោះ ឬក្នុងពេលកំពុងតែបំពេញបេសក-កម្មស៊ើបការណ៍ ។ ទាហានទាំងនោះតែងតែផ្តល់ព័ត៌មានយ៉ាងលម្អិតអំពីមុខនាទី សកម្មភាព និងទីតាំងកងវរសេនាតូចរបស់ខ្លួនព្រមទាំងការហ៊ឹកហ៊ឺនយោធារបស់ខ្លួនថែមទៀត ។ អ្នកទោសចំនួន៣នាក់ក្នុងចំណោមអ្នកទោសទាំងនោះ បានសារភាពថា ខ្លួនជាសមាជិកនៃកងពលផ្កាយមាស ដែលមកពីកងពល សុង ប៊ែ ដែលជាកងពលពិសេសគ្រប់គ្រងមន្ទីរឃុំឃាំង ។ អ្នកទោសជាច្រើនត្រូវបានចាប់ខ្លួននៅលើទូកក្នុងដែនសមុទ្រខ្មែរ ហើយបានសារភាពថាជានាវិកនៃកងទ័ពជើងទឹកវៀតណាម ។ អ្នកខ្លះទៀត ជាមន្ត្រីមូលដ្ឋាន ជាអ្នកភូមិ និងជាជនជាតិភាគតិច ដែលត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថាជាគិញជួយកងទ័ពជើងទឹកវៀតណាម ។ ភាគច្រើនអ្នកទោសទាំងនោះ មានអាយុពី២៤ទៅ២៦ឆ្នាំ ។ អ្នកទោសជាច្រើននិយាយថា ត្រូវខ្មែរក្រហមចាប់ខ្លួននៅក្នុងប្រទេសកម្ពុជា បើទោះបីជាពួកគេរស់នៅក្បែរព្រំដែនក៏ដោយ ។ មានអ្នកទោស១២នាក់បានសារភាពថា ខ្លួនត្រូវខ្មែរក្រហមចាប់បាននៅក្នុងប្រទេសវៀតណាមនៅក្នុងខេត្តតាយនិញ, ហាទៀង និង ដុងថាប់ ដែលនៅជាប់ព្រំដែនខ្មែរក្នុងពេលដែលការប្រយុទ្ធគ្នាមានសភាពខ្លាំងក្លានោះ ។

## ការដាក់ទោសឧក្រិដ្ឋកម្មសង្គ្រាមដោយច្បាប់ស្តីពីការបង្កើតអង្គ-ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

មាត្រា៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្តល់អំណាចឲ្យតុលាការវិនិច្ឆ័យទោសជនសង្ស័យពីបទរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវដែលត្រូវបានប្រព្រឹត្តប្រឆាំងជនដែលត្រូវការពារក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ តាមអនុសញ្ញាទីក្រុងហ្សឺណែវ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទាំងនេះ ពិតជាត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលសង្គ្រាមដែលត្រូវបានប្រកាស ឬអំឡុងពេលមាន“ជម្លោះប្រដាប់អាវុធ”រវាងប្រទេសទាំងពីរ ។ ដើម្បីធ្វើការដាក់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមពីបទឧក្រិដ្ឋកម្ម

សង្គ្រាមដោយច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រះរាជអាជ្ញា ត្រូវបង្ហាញថា ឧក្រិដ្ឋកម្មទាំងនោះបានកើតឡើងនៅក្នុងអំឡុងពេលមានជម្លោះប្រដាប់អាវុធ និងបង្ហាញថាឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងជនដែលត្រូវការពារ ដូចដែលត្រូវបានកំណត់ដោយអនុសញ្ញាទីក្រុងហ្សឺណែវ ព្រមទាំងបង្ហាញថា អំពើទាំងនោះគឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ដូចដែលមានចែងនៅក្នុងអនុសញ្ញានេះ និងមាត្រា៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ១) ជម្លោះប្រដាប់អាវុធ

មាត្រា២នៃអនុសញ្ញាទីក្រុងហ្សឺណែវចែងថា អនុសញ្ញានេះអនុវត្តបានចំពោះគ្រប់ករណីទាំងអស់ ដែលទាក់ទិននឹងសង្គ្រាមដែលត្រូវបានប្រកាស ឬ“ជម្លោះប្រដាប់អាវុធណាមួយ” ដែលកើតឡើងរវាងរដ្ឋពីរឬច្រើន ។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានកំណត់និយមន័យ “ជម្លោះប្រដាប់អាវុធ” ក្នុងអនុសញ្ញានេះថា ជា“ការងាកមកប្រើប្រាស់កម្លាំងប្រដាប់អាវុធរវាងរដ្ឋនិងរដ្ឋ ឬអំពើឃោរឃៅអូសបន្លាយប្រដាប់ដោយអាវុធរវាងអាជ្ញាធរ រដ្ឋាភិបាល និងក្រុមអង្គការចាត់តាំងប្រដាប់ដោយអាវុធ ឬរវាងក្រុមទាំងនេះជាមួយនឹងរដ្ឋ” ។ និយមន័យមិនច្បាស់នេះ បង្ហាញពីការលំបាកក្នុងការសម្គាល់ “ជម្លោះប្រដាប់អាវុធ” នៅក្នុងសម័យទំនើប ដែលជាបញ្ហាដែលអ្នកធ្វើសេចក្តីព្រាងច្បាប់នៃអនុសញ្ញាទីក្រុងហ្សឺណែវ ដែលឆ្លងកាត់ក្នុងសម័យសង្គ្រាមលោកធំៗ មិនបានគិតទុកជាមុននោះ ។ អនុសញ្ញានេះ ដែលខុសពីពាក់កណ្តាលចុងក្រោយនៃសតវត្សរ៍ទី២០ បានសន្មតថាវានឹងមានភាពងាយស្រួលក្នុងការកំណត់ពេលវេលា និងទីតាំងដែលជម្លោះប្រដាប់អាវុធបានកើតឡើង ។ សង្គ្រាម៥០ឆ្នាំដែលកន្លងបំផុតទៅ និងដែលខុសពីការសម្លាប់រង្គាលក្នុងសម័យសង្គ្រាមលោកទាំងពីរ មិនមែនងាយស្រួលក្នុងការកំណត់និយមន័យដូចនឹងភាពខុសគ្នារវាងសង្គ្រាមនិងសន្តិភាព បច្ចាមិត្តនិងសម្ព័ន្ធមិត្ត ដែលមានភាពស្រពិចស្រពិលនោះទេ ។ អ្នកស្រាវជ្រាវផ្នែកច្បាប់នៅតែមានការខ្វែងគំនិតគ្នាអំពីកម្រិតពិតប្រាកដនៃជម្លោះប្រដាប់អាវុធ និងកម្រិតនៃការប្រយុទ្ធគ្នា ក្នុងគោលបំណងធ្វើឲ្យការអនុវត្តអនុសញ្ញានេះ មានភាពត្រឹមត្រូវ ។

អាថ៌កំបាំងនៃសង្គ្រាម និងប្រការដែលប្រទេសទាំងពីរមិនបានប្រកាសសង្គ្រាមប្រឆាំងគ្នាទៅវិញទៅមកធ្វើឲ្យមានភាពស្មុគស្មាញយ៉ាងខ្លាំងក្នុងការកំណត់កាលបរិច្ឆេទពិតប្រាកដនៃជម្លោះប្រដាប់អាវុធរវាងប្រទេសវៀតណាមនិងកម្ពុជា ។ រដ្ឋាភិបាលខ្មែរក្រហមបានផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាមជាផ្លូវការនៅក្នុងខែធ្នូ ឆ្នាំ១៩៧៧ មុនសេចក្តីប្រកាសដែលពិភពលោកខាងក្រៅបានដឹងតិចតួចបំផុតអំពីជម្លោះព្រំដែនដែលបង្កឡើងរវាងរដ្ឋទាំងពីរ ។

មន្ទីរឃុំឃាំងទួលស្លែង មានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ហើយអ្នកទោសត្រូវបានធ្វើទារុណកម្មនិងយកទៅសម្លាប់ចោលនៅឆ្ងាយពីតំបន់ដែលមានជម្លោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយ យោងតាមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង និងជម្លោះប្រដាប់អាវុធមានទំនាក់ទំនងគ្នា បើទោះបីជាជម្លោះប្រដាប់អាវុធនិងឧក្រិដ្ឋកម្មទាំងនោះកើតឡើងនៅទីកន្លែងផ្សេងគ្នាក៏ដោយ ។ សាលាឧទ្ធរណ៍នៅក្នុងរឿងក្តី ក័រឌិក អះអាងថា ខ្លួនមានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលទាក់ទិននឹង “ជម្លោះដែលកើតឡើងនៅលើទឹកដីផ្សេងៗទៀត ដែលគ្រប់គ្រងដោយភាគីជម្លោះ” ។ ក្នុងករណីនេះ ជនស៊ីវិលនិងកងទ័ពវៀត-ណាមដែលមកពីព្រំដែន ត្រូវបានចាប់ខ្លួនដោយសង្ស័យថាមានជាប់ពាក់ព័ន្ធនៅក្នុងជម្លោះប្រដាប់អាវុធដែលកំពុងតែកើតឡើងរវាងប្រទេសទាំងពីរ ។ ការដែលបញ្ជូនអ្នកទាំងនោះទៅកាន់មន្ទីរឃុំឃាំងទួលស្លែងមិនមែនជាការដកហូតសិទ្ធិរបស់អ្នកទាំងនោះដែលជាឈ្លើយសឹកនិងជនស៊ីវិលនោះទេ ។

ព្រះរាជអាជ្ញាត្រូវព្យាយាមបង្ហាញនូវកាលបរិច្ឆេទចាប់ផ្តើមជម្លោះប្រដាប់អាវុធមុនគេបំផុតដែលអាចធ្វើទៅបាន ដើម្បីប្រើប្រាស់ជាភ័ស្តុតាងបង្ហាញពីការសម្លាប់និងការធ្វើទារុណកម្ម ។ ការចែកព្រឹត្តិការណ៍តាមឆ្នាំ បង្ហាញពីកាលបរិច្ឆេទមានសក្តានុពលភាពនៃការចាប់ផ្តើមជម្លោះប្រដាប់អាវុធ ។

**ឆ្នាំ១៩៧៥** : ជម្លោះរវាងវៀតណាមនិងកម្ពុជាបានចាប់ផ្តើមយូរមកហើយ មុនពេលដែលប្រទេសទាំងពីរនេះ បានបែកបាក់គ្នានៅក្នុងឆ្នាំ១៩៧៧ ។ ទោះបីជាប្រទេសទាំងពីរ ធ្លាប់បាន

ចងសម្ព័ន្ធ ភាពគ្នាប្រឆាំងនឹងបារាំងនិងអាមេរិកក៏ដោយ ក៏ខ្មែរក្រហមមិនពេញចិត្តនឹងការលេបទឹកដីខ្មែរពីបុរាណរបស់វៀតណាមដែលកើតមានយូរមកហើយដែរ មុនពេលដែលអំណាចបស្ចិមប្រទេសមកដល់នោះ ។ ការប្រយុទ្ធគ្នានៅតាមព្រំដែនដើម្បីទាមទារទឹកដីត្រឡប់មកវិញ បានចាប់ផ្ដើមនៅដើមឆ្នាំ ១៩៧៤ និងមានភាពតានតឹងខ្លាំងឡើងនៅក្នុងឆ្នាំ១៩៧៥ ។ ប្រវត្តិវិទូខ្លះកំណត់យកការប្រយុទ្ធគ្នាដំបូងនេះថាជាកាលបរិច្ឆេទចាប់ផ្ដើមជម្លោះប្រដាប់អាវុធក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។ ជម្លោះមួយក្នុងចំណោមជម្លោះដំបូងបំផុត គឺឧបទ្ទវហេតុនៅកោះប៉ូលូវៃ ដែលបានកើតឡើងនៅក្នុងខែមិថុនា ឆ្នាំ ១៩៧៥ ។ ខ្មែរក្រហមបានបាញ់ផ្លោងមកលើកោះភូគួក(កោះត្រល់) នៅថ្ងៃទី១៩ ខែមេសា ហើយវៀតណាមបានកាន់កាប់កោះវៃនៅក្នុងខែមិថុនា ។ ព្រឹត្តិការណ៍នេះមានភាពមិនច្បាស់លាស់ក៏ពិតមែន ក៏ប៉ុន្តែព្រឹត្តិការណ៍នេះត្រូវបានភាគីជម្លោះទាំងពីរពិភាក្សាគ្នា ដោយឥតឈប់ឈរដែលជាការប៉ះទង្គិចគ្នាយ៉ាងធ្ងន់ធ្ងរមួយ ។ នៅក្នុងឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានតស៊ូប្រយុទ្ធ ដោយហេតុថា កម្ពុជាមិនទាន់បានប្រគល់ប្រជាជនវៀតណាមប្រហែល៥១៥នាក់ដែលខ្មែរក្រហមបានចាប់ខ្លួននៅក្នុងព្រឹត្តការណ៍នោះមកឲ្យវៀតណាមវិញឡើយ ។ គោលបំណងនៃជម្លោះនេះគឺ ការទាមទារទឹកដីខ្មែរត្រឡប់មកវិញ ដែលបានបង្កើតវៀតណាមខាងត្បូង ។ យោងតាម ប៉ែន យៀនិន បានឲ្យដឹងថា ការប្រយុទ្ធគ្នានេះ បានបញ្ចប់នៅពេលដែលវៀតណាមខាងត្បូងចាប់ផ្ដើមចុះខ្សោយ និងនៅពេលដែលខ្មែរក្រហមបានឡើងកាន់អំណាច ។ ប៉ុល ពត បានពន្យារការប្រយុទ្ធគ្នានេះ ដោយហេតុថា មានការយល់ច្រឡំគ្នានៅក្នុងជួរកម្មាភិបាលថ្នាក់ទាបមួយផ្នែក និងបានព្យាយាមបញ្ចប់ជម្លោះជាមួយវៀតណាមឲ្យបានឆាប់រហ័ស ។ ព្រឹត្តិការណ៍នេះ អាចជាសញ្ញាបង្ហាញពីការចាប់ផ្ដើមជម្លោះប្រដាប់អាវុធ និងទំនងជាបង្ហាញដែរថា ក្នុងចំណោមប្រជាជនវៀតណាមដែលបាត់ខ្លួន៥១៥នាក់ ខ្លះជាជនរងគ្រោះនៃឧក្រិដ្ឋកម្មសង្គ្រាមដំបូងបំផុត ។ ទូរលេខដែលទាក់ទិននឹងការព្រួយបារម្ភរបស់វៀតណាមអំពីប្រជាជនវៀតណាមបាត់ខ្លួនចំនួន៥១៥នាក់នេះ ត្រូវបានរាយការណ៍ជូន នួន ជា ដែលជាអ្នកទទួលខុសត្រូវចំពោះសកម្មភាពនេះ ។

**ឆ្នាំ១៩៧៦** ៖ ការប្រយុទ្ធគ្នាបានកើតឡើងនាដើមឆ្នាំ ១៩៧៦ ចន្លោះខែធ្នូនិងខែមករា និងរហូតដល់ខែមីនា ។ ការប្រយុទ្ធគ្នានេះ បានបន្តរហូតពេញមួយខែកុម្ភៈ ។ មានការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់នៅតាមបណ្ដោយព្រំដែន មានការវាយប្រហារមកលើភូមិដ្ឋាននិងការចាប់ពង្រត់ និងមានការឈ្លានពាន ប៉ុនប៉ងកាន់កាប់ដែនសមុទ្រទៀតផង ។ ត្រង់ចំណុចនេះវៀតណាមបានប្រាប់ឲ្យគូបដិបក្ខរបស់ខ្លួន(ប្រជាជនកម្ពុជា) ថាប្រជាជនវៀតណាមឆ្ងល់ថាតើហេតុអ្វីនៅតែមានការប្រយុទ្ធគ្នាដដែល បើសង្គ្រាមចប់ទៅហើយនោះ ។ ភាគីទាំងពីរបានបន្តចរចានិងពិភាក្សាគ្នាលើចំណុចនេះ ដែល ប៉ុល ពត បាននិយាយថា ខ្លួនចង់រក្សាសាមគ្គីភាព ហើយបានទម្លាក់កំហុសការប៉ះទង្គិចបង្ហូរឈាមគ្នាទៅលើភាពដែលមិនអាចអត់ធ្មត់បានរបស់កម្មាភិបាលថ្នាក់ទាប ។ ក៏ប៉ុន្តែ បើពិនិត្យផ្ទុយទៅវិញប្រជាជនវៀតណាមនិងកម្ពុជាបានចាត់ទុកគ្នាជាសត្រូវទៅវិញទៅមករួចទៅហើយ ។

ការប្រយុទ្ធគ្នាបានបន្តពេញដើមឆ្នាំ១៩៧៦ ហើយបានបន្តជាដំណាក់ៗពេញមួយឆ្នាំ ។ មានភ័ស្តុតាងបង្ហាញភូមិដែលដុតនិងចាប់ពង្រត់ទាហាននិងជនស៊ីវិល ដែលបានកើតឡើងពេញអំឡុងឆ្នាំ១៩៧៦ ហើយបទសម្ភាសន៍បន្ថែមទៀតនៅភូមិភាគបូព៌ានិងក្នុងខេត្តមណ្ឌលគិរី អាចបង្ហាញសាក្សីដែលបានឃើញការប្រយុទ្ធគ្នានេះ និងការរំលោភបំពានលើទាហាននិងជនស៊ីវិលវៀតណាម ។

**ឆ្នាំ១៩៧៧** ៖ ជម្លោះប្រដាប់អាវុធពិតជាបានកើតឡើងនៅក្នុងខែមេសា ឆ្នាំ១៩៧៧ ដូចនេះឧក្រិដ្ឋកម្មដែល នួន ជា បានប្រព្រឹត្តក្រោយពេលនោះ ត្រូវបានបិទបាំងដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ មានកើនឡើងយ៉ាងខ្លាំងនូវចំនួនទាហានតាមបណ្ដោយព្រំដែននៅក្នុងខែមេសា រហូតដល់មានការប្រយុទ្ធដ៏ធំធេងនៅក្នុងខែកញ្ញា ។ បន្ទាប់មក មេដឹកនាំខ្មែរក្រហមបានទទួលព័ត៌មានស្ដីអំពីសង្គ្រាមជាមួយកងទ័ពវៀតណាម និងការឃោសនានយោបាយក្រោយខែមេសា ឆ្នាំ១៩៧៧ បានដៅប្រជាជនវៀតណាមថាជាសត្រូវ ។ នៅពេលដែលសង្គ្រាមទាំងមូលបានចាប់ផ្ដើមប្រវត្តិវិទូនិងប្រជាជនកម្ពុជា ខ្មែរក្នុងស្រុកក៏បានដឹងអំពី

បញ្ហានោះដែរ ។ ទំនាក់ទំនងរបស់ខ្មែរក្រហមបានបង្ហាញឲ្យឃើញជម្លោះជាច្រើនក្រោយរយៈពេលនោះ គឺទាក់ទិនជាមួយនឹងការកើនឡើងយ៉ាងខ្លាំងនូវចំនួនអ្នកទោសវៀតណាមនៅមន្ទីរឃុំឃាំងទួលស្លែង ។

ជាការពិតណាស់ បើទោះបីជាតុលាការកំណត់ច្បាប់ថាកាលបរិច្ឆេទជាផ្លូវការនៃការចាប់ផ្ដើមជម្លោះប្រដាប់អាវុធជាអន្តរជាតិ បានចាប់ផ្ដើមនៅក្នុងខែមករា ឆ្នាំ១៩៧៨ នៅពេលដែលទំនាក់ទំនងរវាងប្រទេសទាំងពីរត្រូវបានបញ្ចប់ជាផ្លូវការយ៉ាងណាក៏ដោយ ក៏នៅតែមានការរំលោភបំពាន និងការសម្លាប់អ្នកទោសជាច្រើននៅមន្ទីរឃុំឃាំងទួលស្លែងក្រោយពេលនោះ ។ យោងតាមការស្រាវជ្រាវនិងសៀវភៅដែលនឹងបោះពុម្ពផ្សាយនៅពេលខាងមុខនេះរបស់ ស៊ីម សុរិយា មានប្រជាជនវៀត-ណាមចំនួន៤១៨នាក់ ត្រូវខ្មែរក្រហមចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៨ និងប្រជាជនវៀតណាមចំនួន១៧១នាក់ត្រូវបានសម្លាប់នៅគុកទួលស្លែង ។ ការចាប់ខ្លួនប្រជាជនវៀតណាម បានកើនឡើងខ្ពស់នៅក្នុងខែមេសាក្នុងឆ្នាំដដែល និងបានចាប់ផ្ដើមកើនឡើងជាថ្មីម្ដងទៀតនៅក្នុងខែកញ្ញា ខែតុលា និងខែវិច្ឆិកា ព្រមទាំងប៉ុន្មានខែក្រោយទៀត ដែលនាំឲ្យមានការឈ្លានពានដ៏ធំធេងរបស់កងទ័ពវៀតណាមចូលក្នុងប្រទេសកម្ពុជា ។


ផ្ទះដែល នួន ជា រស់នៅសព្វថ្ងៃនៅក្រុងប៉ៃលិន

## ៧) ជនដែលត្រូវការពារ

អនុសញ្ញាទីក្រុងហ្សឺណែវ ការពារសិទ្ធិជនរងគ្រោះក្រោមឈ្មោះថា “ជនដែលត្រូវការពារ” ។ តាមអនុសញ្ញាទីក្រុងហ្សឺណែវទី៣ “ជនដែលត្រូវការពារ” រាប់បញ្ចូលទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ព្រមទាំងសមាជិកកងឈ្លប ឬទាហានស្ម័គ្រចិត្តដែលបង្កើតកម្លាំងប្រដាប់អាវុធបែបនេះមួយផ្នែក ដែលជាភាគីជម្លោះនិងដែលធ្លាក់ចូលទៅក្នុងអំណាចរបស់សត្រូវ ។ អនុសញ្ញាទីក្រុងហ្សឺណែវទី៤ ផ្ដល់ការការពារដ៏ធំធេងចំពោះជនដែលកំណត់ក្នុងពេលណាមួយជាក់លាក់ និងក្នុងចរិកលក្ខណៈណាមួយ ដែលបានរកឃើញខ្លួនឯងផ្ទាល់ក្នុងករណីមានជម្លោះ ឬការកាន់កាប់ទឹកដីដែលស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ភាគីមួយនៅក្នុងជម្លោះ ឬអាជ្ញាធរដែលចូលមកកាន់កាប់ ដែលមិនមែនជាជនជាតិនៃទឹកដីដែលត្រូវបានកាន់កាប់ ។

ជាក់ស្ដែង អ្នកទោសវៀតណាមទាំងអស់នៅទួលស្លែង ដោយយោងតាមព័ត៌មានដែលមាននៅក្នុងប្រវត្តិរូប គឺជាជនដែលត្រូវការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៣ឬទី៤ ។ ទាហានវៀតណាមទាំងនោះត្រូវបានការពារក្នុងនាមជាឈ្លើយសឹកដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៣ ។ ប្រជាជនវៀតណាម ភាគច្រើនដែលរស់នៅក្រោមរបបកម្ពុជាប្រជាធិប-តេយ្យ ត្រូវខ្មែរក្រហមចាត់ទុកជាជនតាំងទីលំនៅក្នុងប្រទេសកម្ពុជា ជំនួសពាក្យប្រជាជនខ្មែរ ដូចនេះសូម្បីតែជនស៊ីវិលដែលត្រូវបានចាប់ខ្លួននៅព្រំដែន ក៏ត្រូវបានការពារដោយអនុសញ្ញានេះផងដែរ ។ ជាការពិតណាស់ ជនស៊ីវិលវៀតណាមដែលត្រូវ

ខ្មែរក្រហមចាប់ពង្រត់ពីប្រទេសវៀតណាមក៏ត្រូវបានការពារផងដែរ ។

ចំពោះហេតុផលនយោបាយផ្ទាល់ខ្លួន រដ្ឋាភិបាលវៀតណាមអះអាងថា ខ្មែរក្រហមពិតជាមិនបានចាប់ទាហានវៀតណាមទេ ។ មន្ត្រីរដ្ឋាភិបាលវៀតណាមអះអាងថា ខ្មែរក្រហមបានឲ្យប្រជាជនខ្មែរស្លៀកសំលៀកបំពាក់ឯកសណ្ឋានយោធា ដើម្បីឲ្យខ្លួនទទួលបានជ័យជម្នះនៅក្នុងសមរភូមិ ។ នៅក្នុងចម្លើយសារភាពមួយចំនួន ជាពិសេសចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានចោទប្រកាន់ថាជាសមាជិកនៃកងទ័ពជើងទឹកវៀតណាម ការអះអាងនេះ អាចពិតជាត្រឹមត្រូវ ។ អ្នកទោសទាំងនោះឆ្លើយថាខ្លួនជាសមាជិកនៃកងទ័ពជើងទឹកវៀតណាម ក៏ប៉ុន្តែ ពួកគេបានផ្តល់ព័ត៌មានមិនច្បាស់អំពីតួនាទីបេសកកម្ម និងមេបញ្ជាការរបស់ខ្លួន ។ ម្យ៉ាងទៀត អ្នកទោសទាំងនោះបានឆ្លើយថាខ្លួនបានបោះកាំភ្លើងនិងផែនទីចោលមុនត្រូវបានគេចាប់ខ្លួន ដែលខ្មែរក្រហមប្រហែលជាបានបង្ខំអ្នកទោសឲ្យប្រឌិតរឿងរ៉ាវដើម្បីបិតបាំងនូវកង្វះភ័ស្តុតាងប្រឆាំងនឹងខ្លួនឯង ។ នួន ជា ប្រហែលជាប្រើប្រាស់ភ័ស្តុតាងនេះការពារខ្លួន ដោយលើកហេតុផលថាអ្នកទោសទាំងនោះមិនមែនជាទាហានពិតប្រាកដ ដូចនេះអ្នកទោសទាំងនោះមិនត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៣ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ភាគច្រើនទាហានវៀតណាមបានរៀបរាប់រឿងរ៉ាវយ៉ាងលម្អិត ដែលពិបាកនឹងគិតថាពួកគេមិនមែនជាជនដូចដែលពួកគេអះអាងនោះទេ ។ ហ៊ឹម ហ៊ុយ ដែលជាប្រធានពេជ្ឈឃាតម្នាក់ក្នុងចំណោមពេជ្ឈឃាតសំខាន់ៗនៅគុកទួលស្លែង ក៏បដិសេធចំពោះការអះអាងនេះដែរ ដោយបានបញ្ជាក់ថា ទាហានវៀតណាមបានស្ថិតក្នុងឯកសណ្ឋានយោធារួចទៅហើយ មុនពេលដែលទាហានវៀតណាមត្រូវបានបញ្ជូនទៅកាន់គុកទួលស្លែង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏អ្នកទោសវៀតណាមទាំងនោះមិនមែនជាទាហាន ពួកគេនៅតែជាជនជាតិវៀតណាមដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៤ ដូចគ្នានឹងជនស៊ីវិលដែលស្ថិតក្នុងដៃរបស់សត្រូវដែរ ។

ជាងនេះទៅទៀត នួន ជា អាចមានចេតនាទាញហេតុផលថាជនស៊ីវិលមួយចំនួន (ឬទាំងអស់) ដែលជាប់ឃុំឃាំងក្នុងគុកទួលស្លែង ត្រូវបានដកសិទ្ធិដោយអនុសញ្ញាទីក្រុងហ្សឺណែវទី៤ ពីព្រោះពួកគេបានសារភាពថាខ្លួនជាគិញស៊ើបការណ៍ឲ្យរដ្ឋាភិបាលវៀតណាម ។ [មាត្រា៥នៃអនុសញ្ញាទីក្រុងហ្សឺណែវទី៤ បានចែងថា ជនបែបនេះមិនត្រូវបានផ្តល់សិទ្ធិទាមទារនូវសិទ្ធិនិងអភ័យឯកសិទ្ធិបែបនេះដោយអនុសញ្ញានេះទេ ក៏ដូចជាការរើសអើងចំពោះការធានារបស់ភាគីរដ្ឋ ប្រសិនបើត្រូវបានអនុវត្តដោយយល់ស្របបុគ្គលបែបនេះ ។] មាត្រានេះបានចែងទៀតថា ជនស៊ីវិលដែលត្រូវបានចោទថាជាគិញ ត្រូវបានដកសិទ្ធិទទួលបានព័ត៌មានផ្សេងៗ ។

ទឡ្ហីករណ៍នេះមិនអាចសម្រេចនូវហេតុផលពីរយ៉ាង ។ ហេតុផលទីមួយ មាត្រា៥នៃអនុសញ្ញាទីក្រុងហ្សឺណែវ ចែងថា “ទោះយ៉ាងណាក៏ដោយ ជនបែបនេះត្រូវប្រព្រឹត្តក្នុងលក្ខណៈជាមនុស្សធម៌” និងទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ ។ ស្ថានភាពអ្នកទោសនៅគុកទួលស្លែងមានលក្ខណៈគ្មានមេត្តា ហើយការសម្លាប់អ្នកទោសក៏មានភាពសាហាវព្រៃផ្សៃថែមទៀត ។ ហេតុផលទីពីរ ការប្រើប្រាស់ចម្លើយសារភាពបែបបង្ខំក្នុងការបង្ហាញថាអ្នកទោសទាំងនេះជាគិញនោះ នឹងរំលោភបំពានលើគោលការណ៍អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មរបស់អង្គការសហប្រជាជាតិ ។ អ្នកទោសជាច្រើនត្រូវបានធ្វើទារុណកម្មយ៉ាងឃោរឃៅ រហូតដល់ពួកគេឆ្លើយកុហកថា ខ្លួនជាគិញដើម្បីសង្គ្រោះជីវិតរបស់ពួកគេ ។

### ៣) ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ

តាមមាត្រា៦នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការមានយុត្តាធិការកាត់សេចក្តីលើឧក្រិដ្ឋកម្មសង្គ្រាមទាំងនេះដែល“រំលោភបំពានយ៉ាងធ្ងន់ធ្ងរ” លើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ នេះជាភ័ស្តុតាងដែលបង្ហាញយ៉ាងច្បាស់ថា ខ្មែរក្រហមបានប្រព្រឹត្តយ៉ាងហោចណាស់នូវការរំលោភបំពានចំនួន៣ក្នុងចំណោមការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះអ្នកទោសវៀតណាមនៅក្នុងគុកទួលស្លែង គឺការសម្លាប់ដោយចេតនា ការធ្វើទារុណកម្មឬការធ្វើបាបដោយអមនុស្សធម៌ និងការបង្កឲ្យមានរបួសយ៉ាងធ្ងន់ធ្ងរដល់រាងកាយឬសុខភាព ។

បញ្ជីឈ្មោះសម្លាប់នៅទួលស្លែង ជាភ័ស្តុតាងដែលបង្ហាញអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដោយការសម្លាប់ដោយចេតនា ។ បញ្ជីឈ្មោះទាំងនេះមាន ឈ្មោះ អាយុ ភេទ ជនជាតិ និងតួនាទីរបស់អ្នកទោស ដោយភ្ជាប់ជាមួយនឹងថ្ងៃដែលអ្នកទោសត្រូវបានយកទៅសម្លាប់ចោល ។ បញ្ជីឈ្មោះនេះ មានសេចក្តីបញ្ជាក់ពីឈ្មោះពេជ្ឈឃាត និងយុទ្ធជនមន្ទីរឃុំឃាំងទួលស្លែង ។ ហ៊ឹម ហ៊ុយ បានសារភាពដោយចំហថា វៀតណាមដូចជាអ្នកទោសទាំងអស់នេះជាដើម ត្រូវបានធ្វើទារុណកម្មនិងសម្លាប់ចោលបន្ទាប់ពីសរសេរចម្លើយសារភាពរួច ។ ហ៊ឹម ហ៊ុយ មិនបានចាំឈ្មោះអ្នកទោសជនជាតិវៀតណាមណាម្នាក់ឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្ភាសន៍បន្ថែមជាមួយសន្តិសុខគុកក៏អាចផ្តល់ជាភ័ស្តុតាងបង្ហាញពីជោគវាសនារបស់អ្នកទោសមួយចំនួនដែរ ។ ជាងនេះទៅទៀត សន្តិសុខគុកទាំងនេះក៏អាចដឹងបន្ថែមនូវព័ត៌មានដែលទាក់ទិននឹងការធ្វើទារុណកម្ម និងការរំលោភបំពានលើអ្នកទោសវៀតណាមដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ។

ក្រៅពីបញ្ជីឈ្មោះសម្លាប់អ្នកទោសនៅទួលស្លែង ក៏មានភ័ស្តុតាងបង្ហាញអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើទាហាន និងជនស៊ីវិលវៀតណាមនៅតាមព្រំដែនផងដែរ ។ សារព័ត៌មានអន្តរជាតិបានថតរូបភាពនៃអំពើសាហាវយង់ឃ្នងដែលបានកើតឡើងនៅក្នុងភូមិវៀតណាម ។ ក៏ប៉ុន្តែ ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់ថាតុលាការមានដែនយុត្តាធិការកាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។

### ការទទួលខុសត្រូវរបស់ នួន ជា

#### ១) គោលការណ៍គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង

តាមគោលការណ៍ច្បាប់អន្តរជាតិ "គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង" មនុស្សម្នាក់មិនអាចទទួលខុសត្រូវចំពោះអំពើដែលមិនមែនជាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅពេលនោះឡើយ ។ ទោះបីជាគោលការណ៍គ្មានបទឧក្រិដ្ឋបើគ្មានច្បាប់ចែង កំណត់ការកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងដែនវិសាលភាពមួយចំនួនខ្លះ ផ្សេងៗទៀតយ៉ាងណាក៏ដោយ ក៏គោលការណ៍នេះនឹងមិនការពារមេដឹកនាំខ្មែរក្រហមដែលជាប់ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ ។ ទាំងប្រទេសកម្ពុជានិងប្រទេសវៀតណាម សុទ្ធតែចុះហត្ថលេខាចូលជាសមាជិកអនុសញ្ញាទីក្រុងហ្សឺណែវក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដូចនេះការប្រើប្រាស់ទាហាន ឬឧក្រិដ្ឋជនដោយខុសច្បាប់នៅក្នុងសម័យសង្គ្រាម ជាបទឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។

#### ២) ការទទួលខុសត្រូវដោយផ្ទាល់និងចំពោះការបង្គាប់បញ្ជា

មាត្រា២៩ នៃច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនសង្ស័យអាចទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្ម ប្រសិនបើជនសង្ស័យនោះ "មានផែនការញុះញង់ បញ្ជា ជួយជម្រុញ ឬប្រព្រឹត្ត" ឧក្រិដ្ឋកម្ម ។ ការទទួលខុសត្រូវបែបនេះ ត្រូវបានឲ្យឈ្មោះថា ជាការទទួលខុសត្រូវដោយផ្ទាល់ ឬជាបុគ្គលដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិ ។ ជាងនេះទៀត មាត្រា២៩ ចែងថាថ្នាក់លើទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ ប្រសិនបើថ្នាក់លើមានបញ្ជា និងគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់ ហើយថ្នាក់លើបានដឹង និងមានហេតុផលដឹងថាអ្នកនៅក្រោមបង្គាប់ ប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ ហើយមិនបានចាត់វិធានការចាំបាច់និងសមស្រប ដើម្បីដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋកម្មនេះ ។ ការទទួលខុសត្រូវបែបនេះ ដែលត្រូវបានចាត់ទុកថា ជាការទទួលខុសត្រូវរបស់ថ្នាក់លើ ឬចំពោះការបង្គាប់បញ្ជានោះ គឺត្រូវដាក់ទណ្ឌកម្មជនសង្ស័យថ្នាក់ខ្ពស់ដោយច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

##### ក) ការទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងប្រជាជនវៀតណាម

មានភ័ស្តុតាងជាក់ស្តែងតិចតួចបំផុតដែលអាចដាក់ឲ្យ នួន ជា ទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅលើប្រជាជនវៀតណាមនៅក្នុងគុកទួលស្លែង ។ គេពុំមានឃើញឈ្មោះ នួន ជា នៅលើទំព័រមុខនៃចម្លើយសារភាពណាមួយឡើយ និងពុំមានឯកសារណាមួយដែលនិយាយអំពីការសម្លាប់អ្នកទោសវៀតណាមត្រូវបានចម្លងជូន នួន ជា ដែរ ។ ទោះបីជាយ៉ាងណាក៏ដោយឈ្មោះ នួន ជា ត្រូវបានគេឃើញសរសេរ

នៅក្នុងទូរលេខដែលនិយាយថា ឈ្លើយសឹកវៀតណាមត្រូវបានបញ្ជូនមកកាន់គុកទួលស្លែង ។ ឯកសារនេះមានសារសំខាន់ក្នុងការដាក់ឲ្យ នួន ជា ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ។ ឌុច អតីតប្រធានគុកទួលស្លែង បាននិយាយប្រាប់អ្នកសារព័ត៌មានម្នាក់ឈ្មោះ នេត ថៃយ័រ ថា នួន ជា បានដឹងអ្នកទោសវៀតណាម និងបានបញ្ជាឲ្យសម្លាប់អ្នកទោសទាំងនោះជាមួយនឹងអ្នកទោសផ្សេងៗទៀត មុនពេលដែលខ្មែរក្រហមដួលរលំនៅក្នុងឆ្នាំ១៩៧៩ ។ ការចោទប្រកាន់របស់ ឌុច នឹងជាការចោទប្រកាន់យ៉ាងសំខាន់ក្នុងការដាក់បន្ទុកឲ្យ នួន ជា ទទួលខុសត្រូវដោយផ្ទាល់ចំពោះការសម្លាប់អ្នកទោសទាំងនោះដោយអនុសញ្ញាទីក្រុងហ្សឺណែវ ។ ក៏ប៉ុន្តែពុំមានឯកសារដែលត្រូវបានស្គាល់អាចបញ្ជាក់យ៉ាងច្បាស់អំពីកសិណរបស់ ឌុច បាននោះទេ ហើយគេនៅមិនដឹងនៅឡើយថាតើសាលាក្តីខ្មែរក្រហមនេះនឹងត្រូវការព័ត៌មានច្រើនប៉ុន្មានដើម្បីភ្ជាប់ជាមួយនឹងចម្លើយកសិណរបស់ ឌុច នោះ ។ ប្រវត្តិវិទូ ប៊ែន ឃៀរនិន បានបង្ហាញឯកសារមួយដែលមានចំណងជើងថា “សេចក្តីណែនាំពីមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា” ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ ដែលបានបញ្ជាឲ្យចាប់ជនជាតិវៀតណាមភាគតិចទាំងអស់ ឬអ្នកដែលមានទំនាក់ទំនងនឹងប្រជាជនវៀតណាម ។ ឌុច ពិតជាមិនមានអារម្មណ៍និយាយកុហកឡើយ ពីព្រោះ ឌុច បានសារភាពថា បានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏គួរខ្ពើមរអើមមកលើអ្នកទោស ។ ប្រសិនបើ ឌុច ផ្តល់ជាកសិណ ហើយកសិណរបស់ ឌុច អាចជឿទុកចិត្តបានទៀតនោះ វាទំនងជាអាចបង្ហាញថា នួន ជា អាចជាអ្នកទទួលខុសត្រូវដោយផ្ទាល់ចំពោះការស្លាប់អ្នកទោសជនជាតិវៀតណាម ។

## ១) ការទទួលខុសត្រូវចំពោះការបង្គាប់បញ្ជាប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាម

ប្រសិនបើតុលាការរកឃើញថា នួន ជា មិនបានទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកទោសវៀតណាមវិញនោះ ទំនងជានឹងអាចរកឃើញថា នួន ជា បានទទួលខុសត្រូវចំពោះការបង្គាប់បញ្ជាប្រព្រឹត្តអំពើទាំងនេះ ។ ក្នុងនាមជាសមាជិកម្នាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍ អំណាចតាមព្រឹត្តន័យរបស់ នួន ជា បានពង្រីកទៅដល់គ្រប់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមទាំងអស់ ដោយរាប់បញ្ចូលទាំង ឌុច និងយុទ្ធជនដទៃទៀតនៅគុកទួលស្លែង ។ នៅសវនាការ នួន ជា នឹងទំនងជាប្រកាសថាខ្លួនទទួលខុសត្រូវបានត្រឹមតែរដ្ឋសភាជាតិ មិនមែនទួលស្លែងទេ និងថាខ្លួនគ្មានអំណាចសម្រេចអ្វីទាំងអស់ ។ របាយការណ៍មួយចំនួនពី ឌុច និងយុទ្ធជនសួរចម្លើយផ្សេងៗទៀត ដែលត្រូវបានរាយការណ៍ជូន នួន ជា ក៏អាចជួយ នួន ជា មិនទទួលស្គាល់ការទទួលខុសត្រូវនេះ ។ ម្យ៉ាងទៀត មានភស្តុតាងសំខាន់ៗដែលបង្ហាញថា ទាហានវៀតណាមបានឃុំឃាំងនៅក្នុងគុកទួលស្លែង ។ ក្រៅពីទូរលេខដែលរាយការណ៍ជូន នួន ជា ថា អ្នកទោសវៀតណាមកំពុងតែជាប់ឃុំឃាំង ចម្លើយសារភាពរបស់អ្នកទោសទាំងនោះ ត្រូវបានផ្សព្វផ្សាយតាមវិទ្យុជាតិ“នៅគ្រប់ឃុំនិងតាមវាលស្រែទាំងអស់” ។ ជាក់ស្តែង មិនអាចបង្ហាញថា នួន ជា មិនបានដឹងថា អ្នកទោសវៀតណាមកំពុងឃុំខ្លួននិងកំពុងត្រូវបានធ្វើទារុណកម្មនៅក្នុងគុកទួលស្លែង ។ ជាងនេះទៅទៀត ទូរលេខពីភូមិភាគបូព៌ាបានរាយការណ៍ជូន នួន ជា ឲ្យដឹងជាមុនថា ឧក្រិដ្ឋកម្មសង្គ្រាមកំពុងតែកើតឡើង ។ ដោយសារតែ នួន ជា មិនបានបង្ការ ឬដាក់ទណ្ឌកម្មអ្នកនៅបង្គាប់របស់ខ្លួនចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ នួន ជា នឹងត្រូវទទួលខុសត្រូវចំពោះអំពើទាំងនោះដោយគោលការណ៍ទទួលខុសត្រូវចំពោះការបង្គាប់បញ្ជា ។

## សន្និដ្ឋាន

ឧក្រិដ្ឋកម្មដែលខ្មែរក្រហមបានប្រព្រឹត្តបានកើតឡើងអស់រយៈពេលជាងពីរទសវត្សរ៍ និងមានភស្តុតាងដែលត្រូវបានកំណត់ថាមានសុពលភាពសម្រាប់ការដាក់ទោសឧក្រិដ្ឋកម្មទាំងអស់នេះ ។ ក៏ប៉ុន្តែ ចម្លើយសារភាពរបស់អ្នកទោសវៀតណាមដែលរក្សាទុកនៅគុកទួលស្លែង មានសារសំខាន់យ៉ាងខ្លាំង ក្នុងការធ្វើពាក្យបណ្តឹងប្តឹង នួន ជា ចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មសង្គ្រាម និងអាចប្តឹង ឌុច បានផងដែរ ។ ឯកសារទាំងនេះ រួមជាមួយនឹងការទំនាក់ទំនងគ្នារបស់ខ្មែរក្រហម និងរឿងរ៉ាវដែលសរសេរដោយប្រវត្តិវិទូ ជួយបង្កើតឲ្យមានការទទួលខុសត្រូវរបស់ នួន ជា ចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ។ ក្រុមព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការវិភាគ និងពិនិត្យបន្ថែមឯកសារទាំងនេះនូវភាពស្របច្បាប់ដ៏មានសុក្កានុពលភាពនៅក្នុងសវនាការខាងមុខនេះ ។

**ខេត ហ៊ុល**

# ការបង្ហាញអំពីការរំលោភច្បាប់របស់ខ្មែរក្រហម ការប្រើប្រាស់និងការកំណត់ទៅលើភស្តុតាងដែលមាន

ភស្តុតាងក្នុងការកាត់ទោសរឿងព្រហ្មទណ្ឌផ្តល់ជាមូលដ្ឋានសម្រាប់ការកាត់សេចក្តី ឬសម្រាប់បង្ហាញថាគ្មានទោស ។ ជាព័ត៌មានដែលចៅក្រម ឬគណៈវិនិច្ឆ័យប្រើដើម្បីកំណត់ថាមាន ឬគ្មានបទល្មើស ដែលចុងចោទត្រូវបានចោទប្រកាន់ ។ នៅក្នុងសាលាក្តីខ្មែរក្រហម ភស្តុតាងនឹងក្លាយជាបណ្តុំព័ត៌មានមួយដែលចៅក្រមនឹងពិនិត្យដើម្បីកំណត់ថាតើអតីតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យណាខ្លះបានប្រព្រឹត្តបទឧក្រិដ្ឋ (មានបំណងពិរុទ្ធ) ដែលនឹងត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋមួយចំនួន ឬបទឧក្រិដ្ឋទាំងប្រាំបីដែលបានពិភាក្សានៅក្នុងជំពូកទី២ ។ ភស្តុតាងអាចមានច្រើនទម្រង់ដែលរួមមាន ឯកសាររូបថត វត្ថុអាចប៉ះពាល់បាន និងការឆ្លើយបំភ្លឺរបស់សាក្សី ។ រាល់ព្រឹត្តិការណ៍ទាំងឡាយនៅក្នុងពេលកាត់ទោសនឹងកំណត់ប្រភេទនៃភស្តុតាងសម្រាប់ការកាត់សេចក្តីនិងការការពារក្តី ហើយដំណើរការរបស់តុលាការខ្មែរក្រហមដែលនឹងមកដល់ក៏ដូច្នេះដែរ ។ រយៈពេលកន្លងផុតទៅតាំងពីរបប ប៉ុល ពត ការរំលោភបំពានរបស់ខ្មែរក្រហមក្នុងទ្រង់ទ្រាយធំ ការអភិវឌ្ឍន៍បច្ចេកវិទ្យានិងសេដ្ឋកិច្ចដែលមានកម្រិតរបស់កម្ពុជាក្នុងរយៈកាលនោះ និងសារជាតិអាក្រក់នៃរបបកម្ពុជាប្រជាធិបតេយ្យ រួមចំណែកដោយផ្អែកទៅលើប្រភេទនៃព័ត៌មានដែលនៅសេសសល់រហូតដល់សព្វថ្ងៃ ។ ទោះជាមានភស្តុតាងច្រើនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងណាក៏ដោយ ក៏ភស្តុតាងដែលអាចប្រើការបានសម្រាប់ប្រភេទឧក្រិដ្ឋកម្មជាក់លាក់ និងភស្តុតាងប្រឆាំងនឹងចុងចោទប្រហែលជាមិនមានច្រើនដូចដែលព្រះរាជអាជ្ញាត្រូវការនោះទេ ។ ដូច្នេះ បទឧក្រិដ្ឋមួយចំនួននឹងមានភាពងាយស្រួលក្នុងការបង្ហាញជាងប្រភេទបទឧក្រិដ្ឋផ្សេងៗទៀត ហើយវានឹងមានភាពងាយស្រួលក្នុងការកាត់ទោសចុងចោទមួយចំនួន ជាងចុងចោទដទៃទៀត ។

ប្រភេទភស្តុតាងដែលចេញមកពីប្រភពជាច្រើន នឹងអាចប្រើប្រាស់បានសម្រាប់ភាគីជម្លោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ភស្តុតាងភាគច្រើនមានទម្រង់ជាឯកសារ ប៉ុន្តែក៏មានភស្តុតាងជាឧបករណ៍ផ្សេងៗដូចជាឧបករណ៍ធ្វើទារុណកម្ម និងការឆ្លើយបំភ្លឺរបស់សាក្សីមួយចំនួនផងដែរ ។ ទោះជាយ៉ាងនេះក្តី ភស្តុតាងដែលអាចប្រើប្រាស់បានមិនមែនមានន័យថា នឹងត្រូវយកមកប្រើប្រាស់ទាំងអស់នោះទេ ។ ដូចតុលាការផ្សេងៗទៀតដែរ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើឯកសារ វត្ថុ និងចម្លើយកសិណសាក្សីណាខ្លះ នឹងត្រូវបានអនុញ្ញាតឲ្យប្រើនៅក្នុងរឿងក្តីនីមួយៗ ។ ដូចដែលបានពិភាក្សានៅក្នុងជំពូកទី៣ ភស្តុតាងមួយចំនួននឹងត្រូវបានចាត់ទុកថាមិនមានភាពគួរទុកចិត្តបាន មានភាពលម្អៀង ឬមិនអាចទទួលយកបានហេតុដូច្នេះភស្តុតាងទាំងនេះនឹងមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ទេ ។ ភស្តុតាងជាឯកសារភាគច្រើនបច្ចុប្បន្នត្រូវបានរក្សាទុកនៅក្នុងមជ្ឈមណ្ឌល ឯកសារកម្ពុជា ឬក្នុងបណ្ណសារដ្ឋានរបស់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ភស្តុតាងអាចប៉ះបានមាននៅរាយប៉ាយនៅទូទាំងប្រទេស ហើយសាក្សីដែលអាចផ្តល់ចម្លើយបានមាននៅទូទាំងប្រទេសកម្ពុជានិងនៅបរទេស ។ ការប្រមូលរាល់ព័ត៌មានទាំងអស់ដែលប្រើប្រាស់ជាភស្តុតាងគឺជាកិច្ចការដ៏លំបាកចម្បងមួយរបស់សហព្រះរាជអាជ្ញានិងក្រុមការពារក្តី ។

## ប្រភេទនៃវត្ថុតាងសក្តានុពល

អង្គជំនុំជម្រះវិសាមញ្ញមានព័ត៌មានជាច្រើនទម្រង់ ដែលអាចប្រើប្រាស់ជាភស្តុតាងបាន ។ អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ចាប់តាំងពីការបង្កើតគណៈកម្មការស្រាវជ្រាវឧក្រិដ្ឋកម្ម សាក្សីសំខាន់ៗជាច្រើនស្លាប់និងផ្លាស់ប្តូរទីកន្លែងជាបន្តបន្ទាប់ ។ ការស្វែងរកអ្នកដែលរត់គេចចេញពីប្រទេសក្នុងរយៈកាលដ៏ជ្រួលច្របល់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នឹងជួបនូវការលំបាកជាច្រើន ដោយសារតែគ្មានការកត់ត្រាឲ្យបានល្អនៅតាម

តំបន់ជនបទជាច្រើននិងការភៀសខ្លួនទៅរស់នៅបរទេស ។ សូម្បីតែសាក្សីដែលនៅរស់និងអាចរកឃើញ ប្រហែលជាភ្លេចព្រឹត្តិការណ៍សំខាន់ៗអស់ហើយ ។ អ្នកផ្សេងទៀតមិនហ៊ានចែករំលែកព័ត៌មានទាក់ទិននឹងខ្មែរក្រហម ដោយភ័យខ្លាចចំពោះការធ្វើទុកបុកម្នេញ ហើយមួយចំនួនទៀត ដែលទទួលរងនូវផលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរ មានការពិបាកក្នុងការធ្វើឲ្យធូរស្រាលចំពោះអំពើឃោរឃៅពីអតីតកាល ។ ដូច្នេះចម្លើយសាក្សីដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងតុលាការអន្តរជាតិផ្សេងៗទៀតប្រហែលជាមិនអាចក្លាយជាប្រភពភ័ស្តុតាងដ៏មានប្រសិទ្ធភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ។

ឯកសារគឺប្រហែលជាទម្រង់នៃភ័ស្តុតាងដែលអាចប្រើប្រាស់បានសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ ទោះបីជាមានឯកសាររាប់ពាន់ទំព័រក្តី ឯកសារទាំងនេះប្រហែលគ្រាន់តែជាផ្នែកមួយនៃឯកសារដែលមន្ត្រីនិងកម្មាភិបាលខ្មែរក្រហមបានបង្កើតឡើង ។ មិនមែនត្រឹមតែពេលវេលាទេដែលនាំឲ្យឯកសារមានការខូចខាត ឬការបំផ្លិចបំផ្លាញឯកសារមួយចំនួន ប៉ុន្តែថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យធ្វើការអាថ៌កំបាំងបំផុត និងបានបញ្ជាឲ្យដុតឯកសារចោលជាច្រើន នៅពេលកងទ័ពបះបោរកម្ពុជានិងកងកម្លាំងសម្ព័ន្ធមិត្តវៀតណាមបានវាយចូលទីក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ១៩៧៨ និងសប្តាហ៍ទីមួយនៃឆ្នាំ១៩៧៩ ។ ជាងនេះទៅទៀត អស្ថិរភាពនយោបាយនៅក្នុងប្រទេសបន្ទាប់ពីដួលរលំនៃរបបខ្មែរក្រហមបង្ហាញឲ្យឃើញថា ឯកសារដែលនៅសេសសល់មិនត្រូវបានរក្សាទុកនៅទីកន្លែងដើមទេ ។ ផ្ទុយទៅវិញ ឯកសារជាច្រើននៅរាយប៉ាយនៅទូទាំងប្រទេសនិងត្រូវបានបំផ្លាញ ។ ដោយសារតែការសម្ងាត់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងការខូចខាតនិងការបំផ្លិចបំផ្លាញឯកសារអស់រយៈពេលជាច្រើនឆ្នាំ ឱកាសដែលថានឹងមានឯកសារដែលអាចបញ្ជាក់អំពីទោសកំហុសគឺមានតិចតួចណាស់ ។

ឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងចែកចេញជាពីរប្រភេទ ដោយធ្វើការបែងចែកទៅតាមពេលវេលានិងប្រភព ។ ប្រភេទទីមួយគឺ ឯកសារដែលធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារទាំងនេះរួមមានឯកសារដែលសរសេរដោយមន្ត្រីនិងកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពរបស់អ្នកទោសនិងឯកសារផ្សេងៗទៀតមកពីប្រទេសក្រៅ ។ ប្រភេទទីពីរគឺឯកសារដែលធ្វើឡើងក្រោយការដួលរលំនៃរបបខ្មែរក្រហម ។ ឯកសារនៅក្នុងរយៈកាលនេះបានមកពីប្រភពជាច្រើនដែលរួមមាន ពាក្យបណ្តឹងផ្តល់ឲ្យដោយប្រជាជនកម្ពុជានិងវៀតណាម បទសម្ភាសន៍រវាងអ្នកស្រាវជ្រាវនិងអ្នកកាសែតជាមួយអ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ក៏ដូចជាការបង្ហាញពីទីតាំងរណ្តៅសាកសព សំណល់ឆ្អឹងលលាដ៍ក្បាល អតីតគុកខ្មែរក្រហមនិងបូជនីយដ្ឋាននានា ។

## ភ័ស្តុតាងពីរបបកម្ពុជាប្រជាធិបតេយ្យ

ឯកសារដែលធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនឹងជាប្រភពភ័ស្តុតាងសំខាន់បំផុតសម្រាប់សាលាក្តីខ្មែរក្រហម ។ សំបុត្រឆ្លើយឆ្លងរវាងសមាជិកបក្សកុម្មុយនីស្តកម្ពុជាពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩នៅសេសសល់នៅឡើយ ។ សំបុត្រឆ្លើយឆ្លងទាំងនេះរួមមានការទាក់ទងគ្នារវាងថ្នាក់លើនិងអ្នកនៅក្រោមបង្គាប់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ប្រភេទឯកសារនៅរបបកម្ពុជាប្រជាធិបតេយ្យក៏រួមមានទាំងការសរសេរចម្លើយសារភាពផង ។ ចម្លើយសារភាពភាគច្រើនត្រូវបានធ្វើឡើងនៅក្នុងគុកទួលស្លែង និងមួយចំនួនទៀតមានប្រភពមកពីគុកឬមន្ទីរឃុំឃាំងដទៃទៀត ។ ចម្លើយសារភាពខ្លះមានចំណារសរសេរដោយដៃនៅកែមទំព័ររបស់មន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ដូចជា កាំង ហ្គេចអៀវ ហៅ ឌុច ធ្វើការតាមដាន ។ កំណត់ហេតុអង្គប្រជុំរបស់គណៈកម្មាធិការយោធា និងគណៈកម្មាធិការនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យក៏នៅសេសសល់ដែរ ហើយក៏មានសេចក្តីប្រកាសជាសាធារណៈធ្វើឡើងដោយមេដឹកនាំជាន់ខ្ពស់ផងដែរ ។ ប្រវត្តិរូបអ្នកទោសដែលសរសេរឡើង នៅពេលត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ ឧបករណ៍ឃុំខ្លួនផ្សេងៗ ក៏ដូចជាប្រវត្តិរូបសមាជិកបក្សកុម្មុយនីស្តកម្ពុជាត្រូវបានរក្សាទុក ហើយអាចមានប្រយោជន៍សម្រាប់សាលាក្តី ។ ជាចុងក្រោយ សៀវភៅសរសេរនិងកំណត់ហេតុរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា កងទ័ព និងមន្ត្រីផ្សេងៗទៀត នៅសេសសល់ប្រហែលចំនួន

៥២០ ក្បាលត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ឯកសារសារព័ត៌មានដែលរួមមានច្បាប់ដើមនៃទស្សនាវដ្តីរបស់កម្ពុជាប្រជាធិបតេយ្យ គឺជាឯកសារមួយទៀតនៃភ័ស្តុតាង ។ បន្ថែមពីលើការបោះពុម្ពទស្សនាវដ្តីជាច្រើន បក្សកុម្មុយនីស្តកម្ពុជាដោយមានជំនួយពីទីប្រឹក្សាចិនបានបង្កើតខ្សែភាពយន្តនិងវីដេអូអប់រំមួយចំនួនទៀត ។ ខ្សែភាពយន្តឯកសារប្រហែល ៩៥ដុំនៅសេសសល់ ដែលបច្ចុប្បន្នត្រូវបានរក្សាទុកនៅប្រទេសបារាំង ។ ខ្សែភាពយន្ត៦ដុំផ្សេងទៀតត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលដែលមានទំនោរទៅរកអាល្បឺម៉ង់ខាងកើតមានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាចុងក្រោយ ក៏មានឯកសារបរទេសមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារទាំងនេះរួមមានរបាយការណ៍ដែលត្រូវបានចុះហត្ថលេខារវាងមន្ត្រីបក្សកុម្មុយនីស្តកម្ពុជាជាមួយមន្ត្រីនៃរដ្ឋាភិបាលចិន ឬវៀតណាមទាក់ទងនឹងការធ្វើពាណិជ្ជកម្មរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសទាំងនោះ ។

## ភ័ស្តុតាងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ឯកសារដែលធ្វើឡើងបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចមានប្រយោជន៍ក្នុងការកាត់សេចក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ទោះជាយ៉ាងនេះក្តី មេធាវីការពារក្តីអាចធ្វើការប្រឆាំងទៅនឹងឯកសារទាំងអស់នេះ ដោយចោទប្រកាន់ថាឯកសារទាំងអស់នេះមិនអាចជឿទុកចិត្តបានដោយសារភាពលម្អៀងខាងនយោបាយ ឬការចងចាំមិនច្បាស់លាស់របស់អ្នកនិពន្ធ ។ ពាក្យបណ្តឹងរបស់អ្នកដែលនៅរស់រានមានជីវិតគឺជាប្រភេទទីមួយនៃឯកសារដែលធ្វើឡើងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ។ ពាក្យបណ្តឹងទាំងនេះត្រូវបានសរសេរឡើងដើម្បីចងក្រងឯកសារស្តីពីការរំលោភបំពានក្នុងរបបខ្មែរក្រហម ដែលរួមបញ្ចូលទាំងប្រវត្តិរូបរបស់អ្នកធ្វើពាក្យបណ្តឹង និងជីវិតរស់នៅក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ។ មន្ត្រីរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាប្រមូលពាក្យបណ្តឹងបានជាងមួយលានច្បាប់ពីប្រជាជនកម្ពុជាក្នុងដើមទសវត្សរ៍ឆ្នាំ ១៩៨០ ។ ជាងនេះទៅទៀត ប្រជាជនវៀតណាមដែលបាត់បង់សមាជិកគ្រួសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានដាក់ពាក្យបណ្តឹងចំនួន២៩ច្បាប់ ។ ភាគច្រើននៃឯកសារទាំងនេះត្រូវបានប្រមូលនិងរក្សាទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ពាក្យបណ្តឹងផ្សេងទៀតដែលប្តឹងតាមរយៈអង្គការអន្តរជាតិនិងអង្គការសិទ្ធិមនុស្សក៏មានប្រយោជន៍សម្រាប់អង្គជំនុំជម្រះវិសាមញ្ញដែរ ។ ទោះជាយ៉ាងនេះក្តី ពាក្យបណ្តឹងទាំងនេះអាចត្រូវខាងចុងចោទចាត់ទុកថាមានភាពលម្អៀងសម្រាប់ហេតុផលមួយចំនួន ។ ពាក្យបណ្តឹងទាំងនេះសរសេរឡើងដោយភូតកុហក ហើយសរសេរឡើងជាច្រើនខែ (ទោះជាមិនមែនជាច្រើនឆ្នាំ) បន្ទាប់ពីអង្គហេតុបានកើតឡើង ។ សំខាន់ជាងនេះទៅទៀត ពាក្យបណ្តឹងទាំងនេះត្រូវបានធ្វើឡើងក្រោមការញុះញង់ពីមន្ត្រីសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅក្នុងស្ថានភាពជម្លោះនយោបាយនិងជម្លោះយោធាដ៏ក្តៅគគុក ។ ដោយសារពាក្យបណ្តឹងទាំងនេះត្រូវបានសរសេរឡើងជាផ្នែកមួយដើម្បីគាំទ្ររដ្ឋាភិបាលបន្តពីរបបខ្មែរក្រហម វាប្រហែលជាត្រូវបានមើលឃើញថាមានលក្ខណៈលម្អៀង ហើយមិនមានទម្ងន់សម្រាប់សាលាក្តីនោះទេ ។

ប្រភពឯកសារមួយទៀតគឺបានមកពីតុលាការប្រជាជនបដិវត្តន៍កម្ពុជាឆ្នាំ១៩៧៩ ដែលកាត់សេចក្តី "បន ប៉ុល ពត-អៀង សារី" ។ ឯកសារទាំងនេះរួមមានការថ្លែងរបស់សាក្សី របាយការណ៍របស់ក្រុមអ្នកស៊ើបអង្កេតបទព្រហ្មទណ្ឌនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសេចក្តីដកស្រង់ចេញពីឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា ។ ឯកសារទាំងអស់នេះត្រូវបានយកមកប្រើជាភ័ស្តុតាងក្នុងតុលាការឆ្នាំ១៩៧៩ ។ ឯកសារផ្សេងៗទៀតរួមមានដំណើររឿងរបស់តុលាការឆ្នាំ១៩៧៩ ដែលមានប្រភពពីបណ្តាញផ្សព្វផ្សាយព័ត៌មានបរទេស របាយ-ការណ៍ស្តីពីការកាត់សេចក្តី និងរបាយការណ៍ស្តីពីសាលក្រមសម្រេចក្តី ។ ទោះជាយ៉ាងនេះក្តី ដូចបានរៀបរាប់ពីដំពូកទីពរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានហៅចុងចោទថាជាជនមានទោសតាំងពីដើមទីមកម៉្លេះ ។ ជាលទ្ធផល មេធាវីការពារក្តី អាចធ្វើការចោទប្រកាន់ប្រឆាំងនឹងឯកសារទាំងអស់នេះ ជាពិសេសឯកសារដែលសរសេរឡើងដោយតុលាការដោយលើកហេតុផលថា ឯកសារទាំងនេះលម្អៀងនិងមិនអាច

ជឿទុកចិត្តបាន ។ ឯកសារទាំងនេះប្រហែលជានឹងមិនមានទម្ងន់សម្រាប់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ។

ប្រភេទទីបីនៃឯកសារក្រោយឆ្នាំ១៩៧៩គឺជាបទសម្ភាសន៍របស់អ្នកនៅរស់រានមានជីវិតពីរបបខ្មែរក្រហមជាមួយអ្នកស្រាវជ្រាវ អ្នកកាសែត និងបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សេចក្តីចម្លងនៃបទសម្ភាសន៍ដែលធ្វើឡើងជាមួយជនរងគ្រោះក៏ដូចជាធ្វើឡើងមួយកម្មាភិបាលជាន់ខ្ពស់និងកម្មាភិបាលថ្នាក់ក្រោមរបស់កម្ពុជាប្រជាធិបតេយ្យ អាចមានប្រយោជន៍សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ ទោះជាយ៉ាងនេះក្តី គួរកត់សម្គាល់ថា បទសម្ភាសន៍មិនស្ថិតនៅក្នុងទណ្ឌកម្មសម្រាប់សក្ខីភាពក្លែងក្លាយនោះទេ ។ បទសម្ភាសន៍ជាច្រើនធ្វើឡើងជាច្រើនឆ្នាំក្រោយអង្គហេតុ ហើយភាពអាចជឿទុកចិត្តបានប្រហែលជាអាចប៉ះពាល់ដោយសារតែការចងចាំមិនច្បាស់លាស់ ។

ប្រភេទចុងក្រោយនៃឯកសារក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមានរបាយការណ៍ស្តីពីការកំណត់ដែនទីរណ្តៅសាកសព សំណល់ឆ្អឹងលលាដ៍ក្បាល ព្រមទាំងគុកនិងឧបករណ៍ ឃុំឃាំងដទៃទៀតសេសសល់ពីរបបកម្ពុជាប្រជាធិប-តេយ្យ ។ ដោយមានជំនួយពីក្រុមអ្នកបច្ចេកទេសនិងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាកំណត់ទីតាំងភូមិសាស្ត្រ (GPS) មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដែនទីមួយដែលបានកំណត់ទីតាំងរណ្តៅសាកសពទូទាំងប្រទេសចំនួន១៩.៤៤០រណ្តៅ សំណល់ឆ្អឹងលលាដ៍ក្បាលជាច្រើន អតីតមន្ទីរសន្តិសុខចំនួន១៨៩ និងបូជនីយដ្ឋានប្រល័យពូជសាសន៍ចំនួន៧៧កន្លែង ។ ដែនទីនិងព័ត៌មានអំពីទីតាំងភស្តុតាងជាក់ស្តែងទាំងនេះនឹងជាវត្ថុតាងដ៏មានប្រយោជន៍សម្រាប់សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមក្នុងការបង្កើតឡើងនូវអង្គហេតុជាក់ស្តែង ដែលមិនអាចប្រមូលបានស្រួលពីឯកសារទាំងឡាយដែលបានរៀបរាប់ពីខាងដើម ។

## ដែនកំណត់នៃភស្តុតាងដែលមាន

ដើម្បីប្រើប្រាស់នៅក្នុងការកាត់សេចក្តីបង្ហាញពីធាតុផ្សំនៃបទឧក្រិដ្ឋមានន័យថា ដើម្បីអាចប្រើជាភស្តុតាងបានឯកសារមួយច្បាប់ឬវត្ថុមួយតម្រូវឲ្យមានការអនុញ្ញាតពីចៅក្រម ។ ដូចបានរៀបរាប់នៅក្នុងជំពូកទី៣ ក្នុងការសម្រេចថាតើឯកសារ ឬវត្ថុជាក់លាក់ណាមួយអាចត្រូវបានអនុញ្ញាតឲ្យប្រើជាភស្តុតាងបាន ចៅក្រមនឹងធ្វើការពិចារណាថា តើវាមានភាពទាក់ទងនិងសុពលភាពឬអត់ ។ នៅពេលឯកសារមួយឬវត្ថុតាងមួយត្រូវបានអនុញ្ញាត សាលាក្តីត្រូវតែធ្វើការសម្រេចចិត្តទៅលើភាពត្រឹមត្រូវនៃការបកស្រាយព័ត៌មានទាំងនេះ ។ ព្រះរាជអាជ្ញានិងមេធាវីចុងចោទនៃអង្គជំនុំជម្រះវិសាមញ្ញនឹងព្យាយាមធ្វើឲ្យចៅក្រមជឿជាក់ថាការបកស្រាយទាំងនោះត្រឹមត្រូវ ដើម្បីគាំទ្រការជជែកតវ៉ាសម្រាប់ក្រុមរៀងៗខ្លួន និងដើម្បីបង្ហាញថាមានទោសឬគ្មានទោស ។ បញ្ហាចំពោះការបកស្រាយជាពិសេសមួយដែលសាលាក្តីនឹងជួបប្រទះគឺ តម្រូវការក្នុងការបកស្រាយភាសាសម្ងាត់ដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងរបាយការណ៍សរសេរឬសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ ។ ខ្មែរក្រហមបានឲ្យនិយមន័យថ្មីទៅលើភាសាដែលមានស្រាប់ ហេតុដូច្នេះ ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែកំណត់ឲ្យបានច្បាស់លាស់អំពីអត្ថន័យនៃពាក្យទាំងនោះដើម្បីឲ្យឯកសារនិងចម្លើយសាក្សីមានអត្ថន័យច្បាស់លាស់អាចប្រើប្រាស់ជាភស្តុតាងបាន ។

ចម្លើយសារភាពក៏ជាបញ្ហាដ៏ពិបាកមួយសម្រាប់គ្រប់តុលាការទាំងអស់ ដោយសារតែចម្លើយសារភាពទទួលបានមកពីការប្រើទារុណកម្មមិនមានភាពអាចជឿទុកចិត្តបាន ។

## ការបកស្រាយភាសាសម្ងាត់

រាល់ឯកសារដែលត្រូវបានអនុញ្ញាតឲ្យប្រើជាភស្តុតាងដោយតុលាការណាមួយត្រូវតែទទួលការបកស្រាយពីតុលាការនោះដើម្បីកំណត់ពីតម្លៃនៃសុពលភាពរបស់ឯកសារ ក៏ដូចជាទម្ងន់នៃភស្តុតាងដែលត្រូវបានផ្តល់ឲ្យ ។ ឯកសារពីរបបខ្មែរក្រហមបង្ហាញចេញនូវបញ្ហាជាពិសេសទៅលើការបកស្រាយ ដោយសារតែការប្រើភាសាសម្ងាត់ដ៏ច្រើននៃរបបនេះ ។ ពាក្យមួយចំនួនត្រូវបានឲ្យនិយមន័យខុសគ្នាទាំងស្រុងទៅនឹងនិយមន័យដើម ធ្វើឲ្យអ្នកនៅខាងក្រៅមានការភ័ន្តច្រឡំចំពោះអត្ថន័យពិតរបស់ពាក្យប្រយោគ ឬអត្ថន័យរបស់ឯកសារទាំងមូល ។ បញ្ហានេះគឺកើតមានឡើងពិតប្រាកដចំពោះឯកសារដែលសរសេរដោយបក្សកុម្មុយនីស្តកម្ពុជា ជាងនេះទៅទៀត វាក៏កើតមានឡើងចំពោះ

ឯកសារដែលសរសេររាយការណ៍អំពីរបបនេះដែរ ។ ដូច្នេះ វាមានសារសំខាន់ខ្លាំងណាស់ក្នុងការបកស្រាយភាសានៅក្នុងឯកសារទាំងនោះដើម្បីឲ្យយល់ច្បាស់ ព្រោះថាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាគឺជាប្រភពភ័ស្តុតាងដ៏មានតម្លៃបំផុតសម្រាប់ប្រឆាំងនឹងចុងចោទដែលអាចនឹងត្រូវនាំយកមកកាត់ទោសនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ នៅពេលធ្វើការបកស្រាយរួចរាល់ឯកសារទាំងនេះដែលរួមមានរបាយការណ៍អំពីសកម្មភាពរបស់កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនអាចជួយក្នុងការស្វែងរកគោលនយោបាយរបស់បក្សខ្មែរសន្ទាក់នៃការបញ្ជានិងគោលបំណងរបស់ចុងចោទនីមួយៗ ។

ភាគច្រើននៃភាសាសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងទៅនឹងការសម្លាប់និងការធ្វើទារុណកម្ម ហើយក៏ប្រហែលជាមានការទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការធ្វើឲ្យមានការឈឺចាប់និងការដាក់ទណ្ឌកម្មទៀតផង ។ ឧទាហរណ៍ ការវិភាគដ៏ទូលំទូលាយរបស់អ្នកស្រាវជ្រាវអំពីពាក្យ“កម្ទេច”មានន័យស្មើនឹងពាក្យ“សម្លាប់” ។ ទោះជាយ៉ាងនេះក្តីពាក្យថា“សម្រាំង”និងពាក្យ“បោសសម្អាត” មានន័យមិនសូវច្បាស់លាស់ ។ សកម្មភាពដែលពណ៌នាដោយពាក្យទាំងនេះអាចរួមបញ្ចូលទាំងការសម្លាប់ ប៉ុន្តែពាក្យទាំងនេះក៏បានបង្ហាញពីសកម្មភាពមួយចំនួនផ្សេងទៀតដូចជាការធ្វើវិសុទ្ធកម្មទៅលើមន្ត្រីដែលមិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាពីមន្ទីរក្រសួងរបស់រដ្ឋាភិបាលក៏ដូចជាពីតំណែងនានា ប៉ុន្តែមិនមានន័យ“សម្លាប់”ទេ ។ ពាក្យ“ខ្មាំង” “ជនក្បត់” និង“សមាសភាពមិនល្អ”ក៏ត្រូវបានប្រើយ៉ាងច្រើននៅក្នុងឯកសារបក្សកុម្មុយនីស្តកម្ពុជា ។ យោងតាមអ្នកស្រាវជ្រាវមួយចំនួនពាក្យ“ខ្មាំង” សំដៅទៅលើអ្នកទាំងឡាយណាដែលត្រូវបានមើលឃើញថាជាគូបដិបក្ខនយោបាយ ដែលរួមមានទាំងប្រជាជនវៀតណាមទូទៅផង ។ “ជនក្បត់”សំដៅទៅលើខ្មាំងនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាក៏ដូចជាកងកម្លាំងរបស់ពួកចក្រពត្តិនិយម ។ ពាក្យ“សមាសភាពមិនល្អ”សំដៅលើសត្រូវផ្ទៃក្នុងបក្សប្រហាក់ប្រហែលនឹងពាក្យ“ជនក្បត់” ។ ការបកស្រាយពាក្យទាំងបីនេះមានសារសំខាន់ខ្លាំងណាស់ក្នុងការកសាងសំណុំរឿងអំពីឧក្រិដ្ឋ-កម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ប្រសិនបើពាក្យទាំងបីនេះត្រូវបានរកឃើញថាបានសំដៅទៅលើសមាជិកនៃក្រុមដែលត្រូវបានការពារ ហើយប្រសិនបើការប្រើប្រាស់ពាក្យទាំងនេះសំដៅទៅលើសកម្មភាពសម្លាប់រង្គាលប្រព្រឹត្តឡើងប្រឆាំងទៅនឹងសមាជិកនៃក្រុមទាំងមូល ព្រះរាជអាជ្ញានឹងប្រើប្រាស់ពាក្យទាំងនេះក្នុងការពង្រឹងសំណុំរឿងប្រឆាំងនឹងចុងចោទចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

បក្សកុម្មុយនីស្តកម្ពុជាក៏ប្រើភាសាសម្ងាត់ ដើម្បីលាក់បាំងអត្តសញ្ញាណមន្ត្រីនិងកម្មាភិបាលនៃរបបនេះ ។ ឧទាហរណ៍ ឯក-សារជាធម្មតាត្រូវបានចុះហត្ថលេខានិងផ្ញើទៅឈ្មោះការិយាល័យឬអង្គភាព ជាជាងផ្ញើទៅឈ្មោះបុគ្គលដែលជាមន្ត្រី ឬកម្មាភិបាល ។ ឧទាហរណ៍ មហាជនត្រូវបានសំដៅទៅ“អង្គការ” ជាជាងសំដៅទៅលើបុគ្គលដែលជាមន្ត្រីជាន់ខ្ពស់នៃរបបនេះ ឬទៅមន្ទីរស-២១ ជាជាងទៅ ឌុច ដែលជាអ្នកគ្រប់គ្រងមជ្ឈមណ្ឌលឃុំខ្លួននិងធ្វើទារុណកម្មនេះ ។ “មន្ទីរ៨៧០” (មន្ទីររបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា) គឺជាឈ្មោះសម្ងាត់មួយទៀតដែលត្រូវបានប្រើជាញឹកញាប់ ហើយពាក្យផ្សេងទៀតដូច“មន្ទីរ៥៦០”និង“មន្ទីរ៤០១” ក៏មាននៅក្នុងការសន្ទនាឆ្លើយឆ្លងគ្នាដែរ ។

ក្រុមមេធាវីការពារចុងចោទប្រហែលជាអះអាងថា ឈ្មោះសម្ងាត់ទាំងនេះមិនអាចធ្វើឲ្យកូនក្តីរបស់ខ្លួនទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនោះទេ ដោយសារតែមិនមានឈ្មោះចុងចោទទាំងនោះនៅក្នុងឯកសារដែលបង្ហាញថាអ្នកទាំងនេះបានដឹង ឬបញ្ជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ។ ជាងនេះទៅទៀត មេធាវីការពារក្តីអាចជំទាស់ថា តុលាការមិនអាចចោទប្រកាន់ថា បុគ្គលណាមួយបានដឹងថាមានបទឧក្រិដ្ឋដោយផ្អែកតែទៅលើសម្ព័ន្ធភាពរបស់បុគ្គលនោះនៅក្នុងក្រុមមួយបានទេ ។ ការបកស្រាយឈ្មោះការិយាល័យនិងវាក្យស័ព្ទដូចជាពាក្យ“អង្គការ” ដែលប្រការនេះបង្ហាញថាឈ្មោះទាំងនេះសំដៅទៅលើបុគ្គលឬក្រុមមន្ត្រីណាមួយច្បាស់លាស់ នឹងមានសារសំខាន់ខ្លាំងណាស់សម្រាប់លទ្ធភាពក្នុងការចោទប្រកាន់ ដើម្បីបង្ហាញថាមន្ត្រីជាន់ខ្ពស់បានដឹងឬផ្តល់សិទ្ធិឲ្យកម្មាភិបាលថ្នាក់ក្រោមប្រព្រឹត្តបទឧក្រិដ្ឋ ។

មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម (មិនកំណត់ចំពោះមេដឹកនាំ

ដែលនឹងត្រូវកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញ) បានបិទបាំងអត្តសញ្ញាណពិតប្រាកដរបស់ខ្លួនដោយប្រើឈ្មោះប្តូរជាច្រើន ហើយធ្វើការផ្លាស់ប្តូរឈ្មោះក្លែងក្លាយនោះជាញឹកញាប់ ។ បញ្ហានេះនឹងជាឧបសគ្គមួយទៀតសម្រាប់ព្រះរាជអាជ្ញា គឺប្រហាក់ប្រហែលទៅនឹងបញ្ហានៃឈ្មោះការិយាល័យសម្ងាត់ ។ ទោះជាយ៉ាងនេះក្តី ប្រសិនបើគំនិតយោបល់របស់អ្នកស្រាវជ្រាវត្រូវបានទទួលយកកិច្ចការរបស់ព្រះរាជអាជ្ញាទាក់ទងនឹងឈ្មោះក្លែងក្លាយនេះនឹងលែងជាបញ្ហាស្មុគស្មាញទៀតហើយ ។ មានការយល់ស្របគ្នាច្រើនក្នុងចំណោមអ្នកជំនាញការទៅលើអត្តសញ្ញាណរបស់បុគ្គលមួយចំនួនក្នុងជួរដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ។ ឧទាហរណ៍ ប៉ុល ពត ត្រូវបានស្គាល់ជាទូទៅថាជា សាឡុត ស និងជា“បងធំទី១” ។ គីម ត្រាង ត្រូវបានស្គាល់ថាជា “អៀង សារី” ឬ “វ៉ាន់” ។ ជាចុងក្រោយ នួន ជា និង “បងធំទី២” គឺជាឈ្មោះពីររបស់មនុស្សតែមួយ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានមធ្យោបាយច្រើនក្នុងការបកស្រាយពាក្យដែលបក្សកុម្មុយនីស្តកម្ពុជាបានប្រើ ក៏ប៉ុន្តែការបកប្រែភាសាឲ្យត្រូវគ្នាតែមួយប្រហែលជាមានការលំបាកក្នុងការបង្កើត ។ មន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនឹងជាប្រភពធនធានដ៏ល្អបំផុតក្នុងការបកស្រាយ ព័ត៌មានទាំងនេះ ប៉ុន្តែមេដឹកនាំដែលនឹងត្រូវអង្គជំនុំជម្រះវិសាមញ្ញធ្វើការកាត់ទោសមិនអាចត្រូវបានបង្ខំឲ្យឆ្លើយសារភាពនោះទេ ។ ប្រសិនបើចុងចោទម្នាក់ឬច្រើនមិនយល់ព្រមឬមិនត្រូវបានបញ្ចុះបញ្ចូលឲ្យឆ្លើយដោយស្ម័គ្រចិត្តនោះ ចម្លើយរបស់អ្នកទាំងនេះនឹងមិនអាចយកមកប្រើនៅក្នុងតុលាការបានទេ ។ អ្នកជំនាញការមួយចំនួនបានវិភាគភាសាសម្ងាត់ ដោយផ្អែកលើការសិក្សារបស់ខ្លួនទៅនឹងដើមកំណើតនៃពាក្យអត្ថបទសម្ភាសន៍ និងភ័ស្តុតាងឯកសារផ្សេងៗទៀត ។ មានកសិណសាក្សីរបស់អ្នកជំនាញការជាច្រើននាក់ដែលនឹងអាចជួយស្រាយបំភ្លឺអត្ថន័យនៃពាក្យទាំងនេះ ។ តុលាការប្រហែលជានឹងត្រូវស្វែងរកជំនួយបន្ថែមពីអត្ថបទសម្ភាសន៍និងឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជា ។

## ការអនុញ្ញាតឲ្យប្រើនិងការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំ

ប្រភពព័ត៌មានដ៏ធំមួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានិងខ្សែសង្វាក់នៃការបញ្ជា គឺជាបណ្តុំចម្លើយសារភាពរបស់កម្មាភិបាលខ្មែរក្រហម មន្ត្រីជាន់ខ្ពស់និងក្រុមគ្រួសារដែលត្រូវអ្នកសួរចម្លើយខ្មែរក្រហមបង្ខំឲ្យឆ្លើយ ។ សេចក្តីចម្លងនៃចម្លើយសារភាពទាំងនេះមិនត្រឹមតែបង្ហាញឲ្យឃើញពីគោលនយោបាយ និងរចនាសម្ព័ន្ធនៃការបញ្ជាប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយក្រុមខ្មែរក្រហមទៀតផង ។ ដូច្នេះ ចម្លើយសារភាពទាំងនេះគឺជាជំនួយដ៏សំខាន់របស់ក្រុមអ្នកស្រាវជ្រាវនិងព្រះរាជអាជ្ញាក្នុងការកសាងសំណុំរឿងប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ទោះជាយ៉ាងនេះក្តី នៅក្នុងករណីមួយចំនួន សេចក្តីចម្លងមួយចំនួនប្រហែលជាមិនអាចត្រូវអនុញ្ញាតឲ្យប្រើប្រាស់ ។

ក្នុងករណីមួយចំនួន ទោះបីជាចម្លើយសារភាពអាចត្រូវបានប្រើជាភ័ស្តុតាងក្តី វិធីសាស្ត្រនិងស្ថានភាពដែលប្រើដើម្បីចម្រាញ់យកចម្លើយសារភាព នឹងកំណត់ភាពអាចទទួលយកបានទម្ងន់នៃភ័ស្តុតាងនិងការប្រើប្រាស់ ។ ជាទូទៅ ច្បាប់អន្តរជាតិហាមប្រាមការប្រើប្រាស់ចម្លើយសារភាពដែលធ្វើឡើងក្រោមទារុណកម្មប្រឆាំងនឹងអ្នកសារភាព ។ ការប្រើប្រាស់ចម្លើយសារភាពបែបនេះ គឺបង្ហាញពីកំហុសផ្នែកក្រមសីលធម៌ធ្ងន់ធ្ងរ ប្រៀបបាននឹងការផ្តល់រង្វាន់ឲ្យអ្នកធ្វើទារុណកម្មដែលបានបង្កឲ្យមានការឈឺចាប់ក្នុងការទទួលបានព័ត៌មាន ។ ជាងនេះទៅទៀត ការពិតនៃចម្លើយសារភាពទទួលបានដោយការធ្វើទារុណកម្មមានចំណុចសង្ស័យខ្ពស់ដែលនាំឲ្យមានចម្ងល់ទាក់ទងនឹងតម្លៃនៃសុពលភាពរបស់ចម្លើយសារភាពប្រឆាំងនឹងអ្នកសារភាព និងអ្នកដទៃទៀតដែលជាប់ក្នុងចម្លើយសារភាព ។ ចំពោះហេតុផលទាំងនេះ មានអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងវិធានស្តីពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា បានហាមមិនឲ្យប្រើចម្លើយសារភាពបែបនេះប្រឆាំងនឹងអ្នកឆ្លើយសារភាព ។

ទោះជាយ៉ាងនេះក្តី អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបង្កើតឡើងនូវការលើកលែងមួយចំនួនចំពោះនីតិវិធីដែលហាម

ក្រោមការប្រើប្រាស់ចម្លើយសារភាពក្រោមការធ្វើទារុណកម្ម ។ ចម្លើយសារភាពបែបនេះអាចត្រូវបានប្រើសម្រាប់បង្ហាញការពិតដែលថា ទារុណកម្មនិងប្រហែលជាបទឧក្រិដ្ឋផ្សេងៗទៀតបានកើតឡើង ។ ប្រសិនបើរកឃើញការពិតដែលថាចម្លើយសារភាពទទួលបានដោយការធ្វើទារុណកម្មនោះ សេចក្តីចម្លងចម្លើយសារភាពអាចត្រូវបានអនុញ្ញាតឲ្យប្រើដើម្បីបង្ហាញថា ឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចជាការធ្វើទារុណកម្មបានកើតមានឡើង ។ ដូច្នេះ ការប្រើសេចក្តីចម្លងចម្លើយសារភាពពីរបបកម្ពុជាប្រជាធិបតេយ្យប្រឆាំងនឹងមន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជានឹងមិនបង្កឲ្យមានបញ្ហាដែលអាចកើតមានឡើង ប្រសិនបើចម្លើយសារភាពទាំងនោះត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នកសារភាព ។ ចម្លើយសារភាពត្រូវបានបក្សកុម្មុយនីស្តកម្ពុជាប្រើប្រាស់ជាផ្នែកមួយដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយដែលជាមូលដ្ឋានសម្រាប់តុលាការព្រហ្មទណ្ឌធ្វើការចោទប្រកាន់ ។ ជាក់ស្តែងក្នុងអំឡុងពេលវិសុទ្ធកម្មកម្មាភិបាលក្នុងជួរបក្សកុម្មុយនីស្តកម្ពុជានៅពេលរបបនេះមានការសង្ស័យថាខ្មាំងសត្រូវបានជ្រៀតចូលទៅក្នុងជួរបក្ស កម្មាភិបាលដែលត្រូវសង្ស័យថាជា"ជនក្បត់" ជាញឹកញាយត្រូវបានសួរចម្លើយដោយទារុណកម្ម ។ គោលបំណងមួយក្នុងការសួរចម្លើយគឺដើម្បីសម្រាំងយកព័ត៌មានអំពីអត្តសញ្ញាណជនក្បត់ដទៃទៀតនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ។ បន្ទាប់ពីទទួលបានបញ្ជីរាយនាមជនក្បត់ដទៃទៀត អ្នកសារភាពត្រូវបានសម្លាប់ចោល ។ ហេតុដូច្នេះ ចម្លើយសារភាពគឺជាចំណុចស្នូលនៃនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ។ សេចក្តីចម្លងចម្លើយសារភាពទាំងនោះអាចត្រូវបានអនុញ្ញាតឲ្យប្រើជាភ័ស្តុតាងអំពីគោលនយោបាយទាំងនោះ នៅក្នុងតុលាការប្រឆាំងនឹងមន្ត្រីជាន់ខ្ពស់ខ្មែរក្រហម ។ ជាងនេះទៅទៀត វាអាចមានប្រយោជន៍ដល់ក្រុមអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាដែលអាចនាំទៅដល់ការរកឃើញប្រភពព័ត៌មានសំខាន់ៗដែលអាចប្រើប្រាស់បានផ្សេងៗទៀត ។

**ការប្រើប្រាស់ភ័ស្តុតាងប្រកបដោយសក្តានុពល ៖ ការកសាងសំណុំរឿងប្រឆាំងនឹងបុគ្គលមួយចំនួន**

ទោះបីមានភ័ស្តុតាងជាច្រើនបង្ហាញអំពីការរំលោភបំពានរបស់ខ្មែរក្រហមក៏ដោយ ក៏កម្លាំងនៃភ័ស្តុតាងទាំងនោះប្រែប្រួលទៅតាមចុងចោទនិងប្រភេទឧក្រិដ្ឋកម្ម ។ ដើម្បីបង្ហាញថាតើសំណុំភ័ស្តុតាងដែលមានត្រូវបានប្រើដើម្បីកសាងសំណុំរឿងប្រឆាំងនឹងបុគ្គលមួយចំនួនដោយរបៀបណា និងដើម្បីចង្អុលបង្ហាញពីចំណុចខ្សោយនិងចំណុចខ្លាំងនៃភ័ស្តុតាងទាំងនោះ ផ្នែកនេះនឹងបង្ហាញអំពីភ័ស្តុតាងសក្តានុពលមួយចំនួនប្រឆាំងនឹងចុងចោទបីនាក់ ដែលអាចត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋផ្សេងៗដោយសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ឧទាហរណ៍ទាំងនេះបង្ហាញអំពីព័ត៌មានសំខាន់ៗដែលព្រះរាជអាជ្ញាអាចប្រើបាន ។ វាក៏បង្ហាញអំពីចំនួនកំណត់នៃភ័ស្តុតាងសក្តានុពលដែលមាននាពេលបច្ចុប្បន្ន ហើយប្រការនេះបង្ហាញឲ្យឃើញថា មេធាវីចុងចោទមានលទ្ធភាពទទួលជោគជ័យច្រើនក្នុងការបង្ហាញថាចុងចោទជាជនគ្មានទោស ។ អ្នកសង្កេតការណ៍ជាច្រើនបានធ្វើការប៉ាន់ស្មានថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងធ្វើការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា ៖ នួន ជា, អៀង សារី, ខៀវ សំផន, ស៊ូ មេត, មាស មុត និង ឌុច ។ មានតែ ឌុច ម្នាក់គត់ដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំង ។ មេដឹកនាំបីនាក់ផ្សេងទៀត (ប៉ុល ពត, តាម៉ុក និង កែ ពក) ដែលសកម្មភាពរបស់អ្នកទាំងនេះក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យមិនអាចគេចផុតពីការចាប់ខ្លួននោះ បានស្លាប់ក្នុងអំឡុងសតវត្សរ៍ចុងក្រោយនេះដោយគ្មានការជំនុំជម្រះទោសអ្វីទាំងអស់ ។

នួន ជា គឺជាអនុលេខាគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ។ ភ័ស្តុតាងសំខាន់ៗ មួយចំនួនបង្ហាញថា នួន ជា បានដើរតួនាទីសំខាន់ក្នុងការបង្កើតឡើងនិងអនុវត្តនយោបាយកាប់សម្លាប់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ជាចុងក្រោយ គាត់ទទួលខុសត្រូវចំពោះមន្ទីរស-២១ ដែលត្រូវបានស្គាល់ជាទូទៅថាគុកទួលស្លែង ។ អៀង សារី គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស ។ យោងតាមរបាយការណ៍មួយចំនួន អៀង សារី បានជំរុញជាសាធារណៈឲ្យមានការចាប់ខ្លួននិងការសម្លាប់អ្នកបម្រើការនៅក្នុងក្រសួងរបស់គាត់ក៏ដូចជាប្រជាជននៅទូទាំងប្រទេស ។ ខៀវ សំផន គឺជា

សមាជិកគណៈកម្មាធិការមជ្ឈិម និងជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជារបបប្រជាធិបតេយ្យ ។ អ្នកស្រាវជ្រាវមួយចំនួនបានចោទប្រកាន់ថា ខៀវ សំផន មិនត្រឹមតែបានដឹងអំពីនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការចាប់ខ្លួន ការធ្វើទារុណកម្ម និងសម្លាប់អ្នកដែលបក្សអះអាងថាជាក្មាំងរបស់ខ្មាំងប៉ុណ្ណោះទេ ថែមទាំងបានជួយអនុវត្តនយោបាយទាំងនេះក្នុងកម្រិតមួយទៀតផង ។

ស៊ូ មេត ជាមេបញ្ជាការកងពលរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយទទួលខុសត្រូវចំពោះការចាប់កងទ័ពនៅក្នុងកងពលនេះ ។ គាត់ត្រូវបានចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធជាមួយនឹងការចាប់បញ្ជូនកងទ័ពទាំងនោះមកសម្លាប់នៅមន្ទីរស-២១ ។ មាស មុត ជាមេបញ្ជាការកងពលរបស់ខ្មែរក្រហម ហើយត្រូវបានដឹងថាមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រហាក់ប្រហែលនឹង ស៊ូ មេត ដែរ ។ ឌុច ជាប្រធានមន្ទីរស-២១ ជាកន្លែងដែលអ្នកទោសរាប់ពាន់នាក់ត្រូវបានឃុំឃាំងនិងធ្វើទារុណកម្មមុនពេលយកទៅសម្លាប់ ។

ឧទាហរណ៍ខាងក្រោមបង្ហាញពីភស្តុតាងមួយចំនួនដែលមានសម្រាប់ការកាត់សេចក្តីបុគ្គលមួយចំនួនចំពោះឧក្រិដ្ឋកម្មផ្សេងៗ ។ តាមរយៈការបង្ហាញពីប្រភេទនិងទំហំនៃភស្តុតាងដែលមាន វាបានបង្ហាញឲ្យឃើញពីផលវិបាកដែលព្រះរាជអាជ្ញានឹងជួបប្រទះក្នុងការបង្ហាញពីបទឧក្រិដ្ឋមួយចំនួន ។ ឧទាហរណ៍ពាក្យបណ្តឹងប្រឆាំងនឹង ឌុច ចំពោះទារុណកម្មមិនត្រឹមតែមានប្រយោជន៍ដើម្បីបង្ហាញពីព្រំដែននៃភស្តុតាងដែលមានដើម្បីបញ្ជាក់ពីបទឧក្រិដ្ឋនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជាក់ពីផលវិបាកដែលព្រះរាជអាជ្ញានឹងជួបប្រទះចំពោះបទឧក្រិដ្ឋផ្សេងៗទៀត ។

ករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រឆាំងនឹង នួន ជា បង្ហាញពីករណីមួយចំនួនដែលថាមានភស្តុតាងសម្រាប់ចោទប្រកាន់ ប៉ុន្តែព្រះរាជអាជ្ញានៅតែជួបប្រទះផលវិបាកធ្ងន់ធ្ងរក្នុងការបង្ហាញពីករណីទាំងនោះ ។ ឧទាហរណ៍ទីបី ករណីបទឧក្រិដ្ឋប្រល័យពូជសាសន៍ប្រឆាំងនឹង អៀង សារី បង្ហាញពីភាពកម្រនៃភស្តុតាងដែលមានក្នុងការចោទប្រកាន់រឿងក្តីនេះ ។

បញ្ហាជាបឋមមួយដែលសាលាក្តីនឹងជួបប្រទះ គឺទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ថ្នាក់លើ ព្រោះដែនសមត្ថកិច្ចរបស់តុលាការគឺកាត់សេចក្តីតែអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ អតីតមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាទាំងនោះប្រហែលជាមិនធ្វើការកាប់សម្លាប់និងធ្វើទារុណកម្មដោយផ្ទាល់ដៃទេ ដូច្នេះដើម្បីកាត់ទោសអ្នកទាំងនោះចំពោះបទឧក្រិដ្ឋទាំងឡាយគឺពឹងផ្អែកទៅលើការបង្ហាញថា អ្នកទាំងនេះបានបញ្ជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់ ។

ដូចដែលបានពិភាក្សាក្នុងជំពូកទី២ បុគ្គលម្នាក់មានការទទួលខុសត្រូវជាបុគ្គលចំពោះបទឧក្រិដ្ឋ នៅពេលបុគ្គលនោះចូលរួមដោយចេតនាក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនោះ ។ ការចូលរួមនេះរួមមានបញ្ជាឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ជួយ និងញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ហើយនៅក្នុងករណីខ្លះធ្វើឡើងដោយចេតនា ឬរៀបចំឲ្យអ្នកផ្សេងទៀតប្រព្រឹត្តបទឧក្រិដ្ឋ ។ បុគ្គលម្នាក់មានការទទួលខុសត្រូវថ្នាក់លើចំពោះបទឧក្រិដ្ឋមួយ ប្រសិនបើបុគ្គលនោះបានដឹង ឬគួរតែបានដឹងពីសកម្មភាពឧក្រិដ្ឋ ប៉ុន្តែមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើអំពើឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមការបង្គាប់បញ្ជាឬក្រោមការគ្រប់គ្រងរបស់ខ្លួន ។

**ឧទាហរណ៍ទី១ : ការកាត់ទោស ឌុច ពីបទធ្វើទារុណកម្ម**

រឿងក្តីដែលស្រួលជាងគេសម្រាប់ព្រះរាជអាជ្ញាប្រហែលជាការចោទប្រកាន់ ឌុច អតីតប្រធានមន្ទីរសន្តិសុខគុកទួលស្លែងថាបានប្រព្រឹត្តបទឧក្រិដ្ឋធ្វើទារុណកម្ម ។ ដូចដែលបានរៀបរាប់នៅក្នុងជំពូកទី២ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកំណត់និយមន័យនៃការធ្វើទារុណកម្មដែលរួមមានធាតុបី : ១) ការធ្វើឡើងដោយចេតនាឲ្យជនរងគ្រោះទទួលរងការឈឺចាប់ធ្ងន់ធ្ងរដល់រូបរាងកាយនិងសតិបញ្ញា, ២) ការបង្កឲ្យឆ្លើយសារភាព និង ៣) ទាំងក្រោមទម្រង់នៃការដាក់ទណ្ឌកម្ម ឬការគំរាមកំហែង ។

ភស្តុតាងក្នុងការដាក់បន្ទុកថា ឌុច បានប្រព្រឹត្តអំពើទារុណកម្មមានច្រើន ។ ក្នុងឋានៈខ្លួនជាប្រធានសន្តិសុខនៃបក្សកុម្មុយ

នីស្តកម្ពុជា ឌុច គ្រប់គ្រងគុកនិងមជ្ឈមណ្ឌលធ្វើទារុណកម្មដែលត្រូវបានស្គាល់ថាជាមន្ទីរស-២១ឬគុកទួលស្លែង ។ ឌុច គឺជាបុគ្គលមួយរូបក្នុងចំណោមមន្ត្រីជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ។ ឌុច ប្រាកដណាស់ថាមានជាប់ពាក់ព័ន្ធច្រើនក្នុងអំពើទារុណកម្ម និងការកាប់សម្លាប់ដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១ ហើយគាត់បានទទួលបញ្ជាឲ្យអនុវត្តអំពើទាំងនេះនិងបានរៀបរាប់ការណ៍អំពីករណីដូចគ្នានេះទៅថ្នាក់លើរបស់គាត់ ។ ឌុច ត្រូវបានរកឃើញថាមានជាប់ពាក់ព័ន្ធនឹងការធ្វើទារុណកម្មប្រព្រឹត្តឡើងនៅមន្ទីរស-២១ មិនត្រឹមតែតាមរយៈឯកសារជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈចម្លើយសារភាពរបស់គាត់ក្រោយឆ្នាំ១៩៧៩ ។ ដោយសារតែមានភស្តុតាងច្រើនបែបនេះ ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋនេះមិនគួរជាកិច្ចការលំបាកសម្រាប់ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានោះទេ ។ ជាងនេះទៅទៀត ភស្តុតាងទាំងនេះអាចត្រូវបានប្រើប្រាស់ក្នុងការចោទប្រកាន់ថា ឌុច មានការទទួលខុសត្រូវដោយផ្ទាល់និងទទួលខុសត្រូវថ្នាក់លើចំពោះទារុណកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ ។ ភស្តុតាងទាំងនេះមិនត្រឹមតែបង្ហាញថា គាត់បានបញ្ជាឲ្យធ្វើទារុណកម្មប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងមិនបានដាក់ទោសឬបញ្ឈប់ការធ្វើទារុណកម្មដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់ ទោះបីជាទារុណកម្មទាំងនោះប្រព្រឹត្តឡើងក្រោមបញ្ជារបស់គាត់ ឬអត់ក៏ដោយ ។

ធាតុផ្សំទីមួយនៃអំពើទារុណកម្មតម្រូវឲ្យមានការបង្ហាញឲ្យឃើញថា មានការប៉ុនប៉ងធ្វើឲ្យមានការឈឺចាប់ធ្ងន់ធ្ងរលើរូបរាងកាយនិងសតិបញ្ញា ។ មានភស្តុតាងក្នុងការបង្ហាញថា ឌុច ទទួលខុសត្រូវដោយផ្ទាល់ចំពោះការធ្វើឲ្យមានការឈឺចាប់ដោយចេតនា ។ ឌុច ខ្លួនឯងបានផ្តល់ភស្តុតាងជាច្រើន ដូចដែលគាត់បានសារភាពអំពីបទឧក្រិដ្ឋជាច្រើន ហើយបានដាក់ការទទួលខុសត្រូវចំពោះអ្នកផ្សេងទៀត នៅក្នុងបទសម្ភាសន៍ជាមួយអ្នកកាសែត នេត ថៃយ័រ ។ ការជំរុញលើកទឹកចិត្តដល់ ឌុច ឲ្យសារភាពនៅក្នុងបទសម្ភាសន៍ទាំងនេះគឺការបួងសួងរបស់គាត់នៅក្នុងពិធីសាសនាគ្រិស្តនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ដែលជំរុញឲ្យគាត់ស្វែងរកការលើកលែងទោសចំពោះបាបកម្មទាំងឡាយដែលខ្លួនបានសាង ។ នៅក្នុងបទសម្ភាសន៍ទាំងនេះ ឌុច បានអះអាងថា នួន ជា និង សុន សេន ជាញឹកញាប់បានបញ្ជាឲ្យគាត់ធ្វើទារុណកម្មនិងសម្លាប់អ្នកទោសនៅមន្ទីរស-២១ ។ ឌុច ក៏បានសារភាពថាខ្លួនបានបញ្ជាឲ្យធ្វើទារុណកម្ម ហើយជួនកាលគាត់បានធ្វើសកម្មភាពទាំងនេះដោយផ្ទាល់ដៃទៀតផង ។ ឌុច បានពន្យល់ ថៃយ័រ ថាគាត់បានប្រើ“ចិត្តសាស្ត្រ”ធ្វើឲ្យអ្នកទោសជឿថា ខ្លួននឹងរួចរស់ជីវិតប្រសិនបើសារភាពការពិត ។ ឌុច និយាយថា ការរួមបញ្ចូលគ្នារវាងវិធីចិត្តសាស្ត្រនិងទារុណកម្មគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការចម្រាញ់យកព័ត៌មាន ។ ទោះបីជា ឌុច បានសារភាពយ៉ាងច្បាស់លាស់ចំពោះការជាប់ពាក់ព័ន្ធរបស់ខ្លួននៅក្នុងអំពើទារុណកម្មនៅមន្ទីរស-២១ក៏ដោយ ក៏គាត់មិនបានសារភាពបែបនេះនៅចំពោះមុខតុលាការទេ ។ ដូចដែលបានពិភាក្សានៅក្នុងជំពូកទី៣ ដើម្បីឲ្យចម្លើយសារភាពមួយមានទម្ងន់ ព្រះរាជអាជ្ញាអាចយកអត្ថបទសម្ភាសន៍ទាំងនោះធ្វើជាភស្តុតាង ឬអាចកោះហៅ ឌុច និង នេត ថៃយ័រ មកធ្វើជាសាក្សី ។ ភស្តុតាងដ៏ច្រើននិងគ្មានការបង្ខិតបង្ខំនៃការសារភាពដែល ឌុច ឆ្លើយប្រាប់ នេត ថៃយ័រ ធ្វើឲ្យភស្តុតាងនៃការឆ្លើយសារភាពដោយបង្ខំរបស់ ឌុច អាចប្រើប្រាស់បានសម្រាប់ព្រះរាជអាជ្ញា ។

ក្រៅពីការសារភាពអំពីការជាប់ពាក់ព័ន្ធរបស់ខ្លួននៅក្នុងរយៈកាលនោះ ឌុច បានចេញលិខិតបញ្ជាមួយចំនួនឲ្យកម្មាភិបាលក្រោមបង្គាប់របស់គាត់ឲ្យអនុវត្តការធ្វើទារុណកម្ម ។ ប្រសិនបើលិខិតសរសេរដោយដៃទាំងនោះមានលក្ខណៈស្របច្បាប់ ដូចដែលបានបង្ហាញនៅក្នុងជំពូកទី៣ ឯកសារទាំងនេះនឹងក្លាយជាក្រដាស់ដ៏មានប្រយោជន៍សម្រាប់ធ្វើជាភស្តុតាង ក្នុងការកសាងសំណុំរឿងពីអំពើទារុណកម្មប្រឆាំងនឹង ឌុច ។ ឧទាហរណ៍ ចំណារនៅលើចម្លើយសារភាពមួយនៅមន្ទីរស-២១ ឌុច បានសរសេរថា “បន្តធ្វើទារុណកម្ម” ហើយថែមទាំងចុះហត្ថលេខានៅលើចំណារនោះទៀត ។ ចំណារសរសេរដោយដៃរបស់ ឌុច មួយទៀតបានបញ្ជាឲ្យអ្នកនៅក្រោមបង្គាប់ “ប្រើវិធីក្តៅ ទោះជាវាស្លាប់ក៏មិនអីដែរ” ។ អ្នកស្រាវជ្រាវបានធ្វើការសន្និដ្ឋានថា “វិធីក្តៅ” សំដៅលើទារុណកម្ម ហើយ“វិធីត្រជាក់”សំដៅលើការសួរចម្លើយដោយគ្មានទារុណកម្ម ។ ការទទួលស្គាល់ថា វិធីសាស្ត្រមួយចំនួន

អាចនាំឲ្យអ្នកទោសស្លាប់ គឺបានបង្ហាញយ៉ាងច្បាស់ថាវិធីសាស្ត្រនេះបានធ្វើឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ទោះជាមិនស្លាប់ក៏ដោយ ។ អត្ថន័យនៃចំណារនេះក៏បានបង្ហាញអំពីបំណងប្រព្រឹត្ត ។ ប្រសិនបើឯកសារទាំងនេះមានលក្ខណៈស្របច្បាប់វានឹងក្លាយជាឧបសគ្គដ៏ធំសម្រាប់មេធាវីការពារក្ដី ។

ឌុច ក៏ត្រូវបានចោទប្រកាន់ផងដែរថា មានការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំចំពោះអំពើទារុណកម្មដែលប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់នៅមន្ទីរស-២១ ព្រោះគាត់បានដឹងអំពីសកម្មភាពទាំងនេះ ទោះបីជាគ្មានភ័ស្តុតាងបញ្ជាក់ថា គាត់បានបញ្ជាឲ្យធ្វើ និងមិនមានភ័ស្តុតាងបញ្ជាក់ថា គាត់បានដាក់ទណ្ឌកម្ម ឬបញ្ឈប់សកម្មភាពទាំងនោះក៏ដោយ ។ ដោយសារ ឌុច មើលការខុសត្រូវនៅមន្ទីរស-២១ ភ័ស្តុតាងដែលបញ្ជាក់ថា ទារុណកម្មត្រូវបានធ្វើឡើងជាញឹកញាប់មានសារសំខាន់ខ្លាំងណាស់ ក្នុងការប្ដឹងប្រឆាំងនឹងគាត់ ទោះជាភ័ស្តុតាងទាំងនោះមិនបានបញ្ជាក់ឲ្យបានច្បាស់ថាគាត់បានបញ្ជាឲ្យប្រព្រឹត្តក៏ដោយ ។ ភ័ស្តុតាងមួយចំនួនអាចត្រូវបានប្រើដើម្បីបញ្ជាក់ថា ឌុច បានដឹង ឬគួរតែដឹងថាអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្តទារុណកម្មលើអ្នកទោស ។ ឧទាហរណ៍ ប្រធានក្រុមសួរចម្លើយរបស់ ឌុច នៅមន្ទីរស-២១បានរក្សាទុកសៀវភៅកំណត់ហេតុផ្ទាល់ខ្លួន ដែលគាត់បានកត់ត្រាអំពីគោលការណ៍ក្នុងការធ្វើទារុណកម្មដូចជា «ធ្វើឲ្យវាឆ្លើយដោយប្រើការឃោសនា ឬធ្វើឲ្យវាឆ្លើយដោយប្រើទារុណកម្ម ប៉ុន្តែកុំឲ្យវាស្លាប់ ។ កុំធ្វើឲ្យពួកវាខ្សោយកម្លាំងពេកយើងមិនអាចសួរឲ្យវាឆ្លើយបានទេ» ។

សៀវភៅកត់ត្រាអំពីការសិក្សានៅមន្ទីរស-២១ ពីឆ្នាំ១៩៧៦មាននៅសេសសល់ សៀវភៅនេះបានដាក់ចេញនៅគោលការណ៍៧ចំណុចសម្រាប់ការសួរចម្លើយ ។ គោលការណ៍ទាំងនេះរួមមានធ្វើទារុណកម្មអ្នកទោស សួរចម្លើយ បង្ខិតបង្ខំអ្នកទោសដោយប្រើការឃោសនានយោបាយ ។ សំបុត្រមួយច្បាប់ទៀតដែលធ្វើឡើងដោយអ្នកសួរចម្លើយនៅឆ្នាំ១៩៧៦ ហើយផ្ញើទៅឲ្យ ឌុច សរសេរថា អង្គការបានណែនាំឲ្យធ្វើទារុណកម្មចំពោះអ្នកទោសម្នាក់ ហើយ«យើងបានចាប់ផ្ដើមធ្វើទារុណកម្មវាដោយវាយពី២០ទៅ៣០រំពាត់នៅព្រឹកនេះ ។ នៅពេលល្ងាចយើងបានធ្វើទារុណកម្មវាដោយវាយនឹងខ្សែភ្លើងពី២០ទៅ៣០ដង...វាបានឆ្លើយសារភាពដែលមានអត្ថន័យដូចចម្លើយសរសេរដែរ» ។ ការវាយនឹងខ្សែភ្លើងបានបង្ហាញឲ្យឃើញច្បាស់ថា ជនរងគ្រោះត្រូវបានធ្វើឲ្យឈឺចាប់លើរូបរាងកាយយ៉ាងធ្ងន់ធ្ងរ ។ អត្ថន័យនៅក្នុងរបាយការណ៍ដែលថាទារុណកម្មត្រូវបានធ្វើឡើងក្រោមការណែនាំរបស់អង្គការបានបញ្ជាក់ឲ្យឃើញច្បាស់ពីគោលបំណងក្នុងការបង្កឲ្យមានការឈឺចាប់ ។

ព្រះរាជអាជ្ញាអាចប្រើសេចក្ដីរាយការណ៍ទាំងនេះដើម្បីបង្ហាញថា ឌុច បានដឹងឬមានហេតុផលអាចដឹងពីអំពើទារុណកម្មដែលប្រព្រឹត្តឡើងដោយអ្នកដែលរាយការណ៍ឲ្យគាត់ ។ ឯកសារភ័ស្តុតាង ដែលបង្ហាញថា ឌុច មិនបានទប់ស្កាត់ការធ្វើទារុណកម្ម ឬដាក់ទោសការធ្វើទារុណកម្មដែលមានរៀបរាប់នៅក្នុងសំបុត្រ និងសៀវភៅកំណត់ហេតុអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញថា ឌុច មានការទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំចំពោះអំពើទារុណកម្មដែលបានរៀបរាប់ពីខាងដើម ។

ឯកសារយោងស្ដីអំពីចេតនាក្នុងការធ្វើឲ្យមានការឈឺចាប់អាចត្រូវបានបញ្ជាក់បន្ថែមនៅតុលាការដោយរបាយការណ៍ផែនទីរណ្ដៅសាកសពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានកំណត់ទីតាំង ឧបករណ៍ធ្វើទារុណកម្មដែលនៅសេសសល់នៅតាមអតីតមណ្ឌលឃុំឃាំងមួយចំនួន ។ ប្រសិនបើតុលាការទទួលស្គាល់ថាអាចជឿទុកចិត្តបានរបាយការណ៍និងឧបករណ៍ទាំងនោះអាចត្រូវបានប្រើប្រាស់ក្នុងការកសាងសំណុំរឿងប្រឆាំងនឹង ឌុច ។

ធាតុផ្សំទីពីរនិងទីបីនៃអំពើទារុណកម្មមានទំនាក់ទំនងគ្នាទៅវិញទៅមក ។ ដូច្នេះ ដើម្បីកសាងសំណុំរឿងស្ដីពីអំពើទារុណកម្មមានសារសំខាន់ណាស់ក្នុងការបង្កើតសំណុំរឿងអំពីធាតុផ្សំណាមួយ ប៉ុន្តែមិនមែនទាំងពីរនោះទេ ។ ធាតុផ្សំទីពីរតម្រូវឲ្យមានការបង្ហាញឲ្យឃើញការបង្កឲ្យមានការឈឺចាប់លើរូបរាងកាយនិងសតិបញ្ញាដែលជាធាតុផ្សំទីមួយត្រូវបានធ្វើឡើងដើម្បីចម្រាញ់យកចម្លើយសារភាព ។ ក្នុងការកសាងសំណុំរឿងប្រឆាំងនឹង ឌុច ឯកសារមួយដែលអាចជួយក្នុងស្វែងរកធាតុផ្សំទីពីរគឺចម្លើយសារភាពពីមន្ទីរស-២១ ដែលអ្នកសួរចម្លើយបាននិយាយថា ៖

យើងចុចវា(ជនរងគ្រោះ)ចំចំណុចដែលថាវាធ្លាប់រស់នៅ

ជាមួយជនក្បត់ ។ នៅពេលយើងបន្តបង្ខំវាឲ្យឆ្លើយចំណុចនេះ វាមិនព្រមនិយាយ ហើយយើងក៏ធ្វើទារុណកម្មខ្លះៗ ។ បន្ទាប់មក វាបានសារភាពថាវាជាជនក្បត់ ។ ខ្ញុំបានសួររកខ្សែរយៈក្បត់ ក៏ដូចជាផែនការ និងសកម្មភាពក្បត់ទាំងឡាយ ។ ដោយសារតែវាឆ្លើយមិនច្បាស់ត្រង់ចំណុចនេះ យើងបានបន្តធ្វើទារុណកម្មរហូតដល់វានិយាយចេញមក ។

អ្នកសួរចម្លើយបានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួននិងអ្នកដទៃទៀតប្រើទារុណកម្មក្នុងគោលបំណង បង្ខំយកចម្លើយពីជនរងគ្រោះ ដែលនេះជាធាតុផ្សំទីពីរនៃអំពើទារុណកម្ម ។ លិខិតដែលបានលើកឡើងខាងលើ ដែលប្រធានក្រុមសួរចម្លើយបានកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្លួន "បង្ខំឲ្យពួកវាឆ្លើយដោយប្រើការឃោសនាឬទារុណកម្ម ប៉ុន្តែកុំឲ្យវាស្លាប់ ។ កុំធ្វើឲ្យវាខ្សត់ខ្សោយកម្លាំងពេក យើងមិនអាចធ្វើឲ្យវាឆ្លើយបានទេ" ។ ចំណារទាំងនេះគឺមានប្រយោជន៍ខ្លាំងណាស់ក្នុងការបញ្ជាក់ថា គោលបំណងក្នុងការធ្វើឲ្យមានការឈឺចាប់លើរូបរាងកាយគឺដើម្បីបង្ខំយកចម្លើយសារភាព ។

បញ្ហាផ្នែកសីលធម៌និងផ្នែកច្បាប់ដែលបានពិភាក្សាខាងលើទាក់ទងទៅនឹងការប្រើប្រាស់ចម្លើយសារភាពដោយបង្ខំជាភ័ស្តុតាងស្ថិតក្នុងធាតុផ្សំទីពីរនៃអំពើទារុណកម្ម ។ ប៉ុន្តែ ដូចដែលបានពិភាក្សារួចមកហើយ ការប្រើប្រាស់សេចក្តីចម្លងទាំងនោះដើម្បីបង្ហាញថាទារុណកម្មពិតជាកើតមានឡើង ប្រហែលជាអាចទទួលយកបាននៅក្នុងតុលាការ ហើយសេចក្តីចម្លងទាំងនេះនឹងជួយក្នុងការបង្ហាញឲ្យឃើញធាតុផ្សំទីពីរ ដោយបានអះអាងបន្ថែមថា ចម្លើយសារភាពទទួលបានដោយការបង្កឲ្យមានការឈឺចាប់ ។ ធាតុផ្សំទីបីនៃឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មដែលអាចត្រូវបានបង្ហាញជំនួសឲ្យធាតុផ្សំទីពីរ តម្រូវថា ការធ្វើឲ្យមានការឈឺចាប់ត្រូវបានធ្វើឡើងក្នុងទម្រង់ជាការដាក់ទណ្ឌកម្ម ឬការបំភិតបំភ័យ ។ ឯកសារទាក់ទងនឹងការប្រើ"វិធីសាស្ត្រក្តៅ" ដែលរៀបរាប់ពីខាងលើក្នុងបរិបទនៃធាតុផ្សំទីមួយអាចប្រើដើម្បីបង្កើតធាតុផ្សំទីបីនៃអំពើទារុណកម្ម ។ ចំណារសរសេរដោយដៃគឺសំដៅទៅលើការប្រើប្រាស់"វិធីសាស្ត្រក្តៅ"ទៅលើអ្នកទោសដែលមិនព្រមសហការដែលបញ្ជាក់ថាវិធីសាស្ត្រធ្វើទារុណកម្មត្រូវបានប្រើដើម្បីធ្វើឲ្យអ្នកទោសសហការ ឬនិយាយម្យ៉ាងទៀតដើម្បីបំភិតបំភ័យអ្នកទោសឲ្យសហការ ។

ការឆ្លើយបំភ្លឺរបស់សាក្សីដើម្បីបង្ហាញធាតុផ្សំនីមួយៗនៃអំពើទារុណកម្មនឹងអាចត្រូវបានយកមកប្រើដើម្បីបញ្ជាក់បន្ថែមទៅលើភ័ស្តុតាងជាក្រដាស់ ។ កងសន្តិសុខនៅមន្ទីរស-២១មួយចំនួនដែលនៅរស់បាននិយាយជាសាធារណៈអំពីការប្រព្រឹត្តរបស់ខ្លួនទៅលើអ្នកទោសនៅក្នុងខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា "មន្ទីរស-២១ : ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម" ដែលជាស្នាដៃរបស់លោក រិទ្ធី ប៉ាន់ ។ អតីតអ្នកទោសនៅមន្ទីរស-២១ចំនួន៩នាក់បានរួចជីវិតពីគុកនេះ ហើយបាមចូលរួមសម្តែងនៅក្នុងខ្សែភាពយន្តនេះ ។ ទោះបីជាបទសម្ភាសន៍នៅក្នុងខ្សែភាពយន្តប្រហែលជាមិនត្រូវបានអនុញ្ញាតឲ្យប្រើនៅក្នុងតុលាការក៏ដោយ ក៏កងសន្តិសុខនិងជនរងគ្រោះទាំងនេះ ក៏ដូចជាអ្នកឯទៀត ក៏អាចត្រូវបានអញ្ជើញឲ្យទៅធ្វើកសិណសាក្សីនៅក្នុងតុលាការដែរ ។

**ឧទាហរណ៍ទី២ : ការកាត់សេចក្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

ឧទាហរណ៍នៃភ័ស្តុតាង ដែលអាចត្រូវបានយកមកប្រើប្រាស់ដើម្បីបង្ហាញពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បង្ហាញអំពីរឿងក្តីមធ្យមដែលនឹងអាចត្រូវបាននាំយកមកកាត់ទោសនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ដែលមានភ័ស្តុតាងសំខាន់ៗប្រឆាំងនឹងបុគ្គលមួយចំនួន ប៉ុន្តែវាមិនចាំបាច់ទេដែលថា ភ័ស្តុតាងទាំងនោះត្រូវតែមានច្រើនលើសលប់ឬច្បាស់លាស់មួយរយភាគរយ ។ ដើម្បីសង្ខេបខ្លឹមសារដែលបានពិភាក្សានៅក្នុងជំពូកទី២ អំពើមួយចំនួនដែលរួមមាន ការសម្លាប់ ការធ្វើឲ្យទៅជាទាសករ ការជម្លៀស ការចាប់ឃុំឃាំង ការធ្វើទារុណកម្ម ការចាប់រំលោភ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនឹងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើអំពើទាំងនោះជាផ្នែកមួយនៃការវាយប្រហារក្នុងទ្រង់ទ្រាយធំឬការវាយប្រហារដែលមានលក្ខណៈជាប្រព័ន្ធទៅលើជនស៊ីវិល ឬទៅលើក្រុមជាតិពន្ធ ក្រុមជាតិសាសន៍ ក្រុមជនជាតិ ឬក្រុមនយោបាយ ។

**(នៅមានត)** **ជូលា ហ្វ្រេមហ្វលស៍**

# យុវសិស្សគួរតែទទួលការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

ខ្ញុំជាក្មេងដែលកើតជំនាន់ក្រោយនៃការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យរយៈពេល៧ឆ្នាំ ។ ខ្ញុំកើតនៅសង្កាត់លេខ២ក្រុងភ្នំពេញ ។ ខ្ញុំជាក្មេងដែលធំដឹងក្តីដោយទទួលបានការថ្នាក់ថ្នមក្តីស្រឡាញ់ពីឪពុកម្តាយនិងមានសំណាងទទួលបានការអប់រំនៅសាលារៀន ។ ខ្ញុំចាំបានថា កាលពីខ្ញុំនៅក្មេងមានប្រយោគមួយដែលខ្ញុំឆ្ងល់គឺ «ថាតើខ្មែរក្រហមជានរណា?» ហើយតែងតែទន្ទឹមរង់ចាំចម្លើយពីចម្ងល់នោះ ។ ភាពជាក្មេងដែលទើបតែចម្រើនវ័យបានជាង៩ឆ្នាំ ខ្ញុំតែងតែចង់ដឹងចង់ឮនូវអ្វីដែលកើតឡើងនៅជុំវិញខ្លួនរបស់ខ្ញុំជារៀងរាល់ថ្ងៃ ។ ចម្ងល់របស់ខ្ញុំបានចាប់ផ្តើមមានឡើង នៅថ្ងៃដែលឪពុកម្តាយរបស់ខ្ញុំនាំខ្ញុំនិងបងប្អូនរបស់ខ្ញុំទៅលេងស្រុកកំណើតនារដូវខែបុណ្យចូលឆ្នាំខ្មែរ ដោយមានការជួបជុំបងប្អូនសាច់ញាតិជិតនិងឆ្ងាយផ្ទះរបស់លោកតា និងលោកយាយខ្ញុំ នៅភូមិអណ្តែងសាំង ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ។ ពេលជួបជុំគ្នាម្តងៗគាត់ម្នាក់ៗតែនិយាយលេងពីនេះពីនោះ បន្ទាប់ពីបែកគ្នាអស់រយៈកាល១ឆ្នាំដោយសារមមាញឹកនឹងការងារធ្វើស្រែចម្ការ ប្រូតកាត់ និងការងារជាមន្ត្រីរាជការរបស់គាត់ ។ នៅខណៈពេលនោះខ្ញុំក៏បានអង្គុយលេងនៅក្បែរគាត់ ហើយបានឮគាត់និយាយអំពីជីវិតរស់នៅរបស់គាត់ម្នាក់ៗកាលពីជំនាន់ខ្មែរក្រហមដោយមានអ្នកខ្លះរៀបរាប់ពីទុក្ខលំបាកវេទនា និងការបាត់បង់អាយុជីវិតបងប្អូនខុសៗគ្នានៅក្នុងរបបនោះ ។ ភាពជាក្មេងដែលកំពុងស្ថិតនៅក្នុងវ័យលូតលាស់ ខ្ញុំបានកត់ត្រានូវចម្ងល់ពាក្យថា «ខ្មែរក្រហម» ទុកនៅក្នុងខួរក្បាលរបស់ខ្ញុំ ។ ខ្ញុំតែងតែគិតជានិច្ចថាតើខ្មែរក្រហមជានរណា? ខ្មែរក្រហមមានរូបរាងពណ៌សម្បុរយ៉ាងដូចម្តេច? តើខ្មែរក្រហមជាខ្មែរដូចប្រជាជនខ្មែរដែរអត់? ចម្ងល់នេះចេះតែបន្តនៅជាប់ក្នុងខួរក្បាលរបស់ខ្ញុំជានិច្ច ជួនកាលខ្ញុំគិត ជួនកាលខ្ញុំបំភ្លេចពាក្យនោះទៅតាមភាពជាក្មេងវ័យរបស់ខ្ញុំ ។ ប៉ុន្តែពាក្យខ្មែរក្រហមនេះបានលេចចម្លើយបន្តិចម្តងៗទៅតាមការចម្រើនវ័យរបស់ខ្ញុំ តាមរយៈការដាស់តឿនក្រើនរំឭកជាញឹកញាប់ពីឪពុកម្តាយរបស់ខ្ញុំស្ទើរតែគ្រប់ពេលដែលខ្ញុំនិងបងៗរើសមុខម្ហូប មិនព្រមហូបសម្លណាដែលខ្លួនមិនចូលចិត្ត ។ គាត់តែងតែពោលពាក្យថា «កូនបានសម្លហូបប៉ុណ្ណឹងសំណាងហើយ កាលជំនាន់ពុកម៉ែនិងបងធំៗរបស់កូនដែលកើតនៅក្នុងសម័យខ្មែរក្រហម មិនបានអាហារហូបបែបហ្នឹងនោះទេ គឺមានតែបបររាវសុទ្ធតែទឹក ហូបមិនឆ្អែត ហើយមិនអាចអង្គុយហូបបាយដែលមានគុមានចានស្លាបព្រាល្អដូចនៅសម័យនេះទេ ។ មានពេលខ្លះហូបមិនឆ្អែត ក៏ដើរលួចបេះត្រួយល្ហុងនិងស្លឹកឈើមកហូបសុំដើម្បីតែមួយចំអែតពោះ ពី១ថ្ងៃទៅ១ថ្ងៃដើម្បីរស់» ។ រឿងរ៉ាវនិងប្រវត្តិតស៊ូរបស់គាត់ទាំងពីរកាលនៅជំនាន់ខ្មែរក្រហមបានលាតត្រដាងឲ្យខ្ញុំ និងបងស្រីបងប្រុសរបស់ខ្ញុំដែលជាក្មេងកើតមិនទាន់សម័យនោះបានយល់ដឹងពីទុក្ខវេទនារបស់ពួកគាត់ ។ ឪពុកម្តាយរបស់ខ្ញុំគឺជាកូនអ្នកស្រុកស្រែចម្ការ មានស្រុកកំណើតនៅភូមិអណ្តែងសាំង ឃុំជីខ្មា ស្រុកទ្រាំង ខេត្តតាកែវ ។ ក្រោយពីគាត់ទាំងពីររៀបការរួច ឪពុករបស់ខ្ញុំរៀនមិនទាន់ចប់បាក់ឌុបទេ ប៉ុន្តែគាត់ក៏បន្តរៀនរហូតដល់ចប់ ហើយបានដាក់ពាក្យប្រលងចូលបម្រើការងារនៅភ្នំពេញជាជាងអគ្គិសនីនៅអគ្គិសនីកម្ពុជាវត្តភ្នំ ។ ក្រោយមកគ្រួសារខ្ញុំដែលមានសមាជិក៥នាក់ គឺពុកម៉ែ បងប្រុស២នាក់និងបងស្រីខ្ញុំម្នាក់បានផ្លាស់មករស់នៅឯភ្នំពេញទាំងអស់គ្នានៅម្តុំសាលារៀនបឹងត្របែក ។ ជីវភាពគ្រួសាររបស់ខ្ញុំកាលនោះរស់នៅប្រកបដោយសុភមង្គល ឪពុកខ្ញុំបម្រើការងាររដ្ឋជាជាងអគ្គិសនី ចំណែកឯម្តាយខ្ញុំគាត់ជាមេផ្ទះផង និងឆ្លៀតពេលដាំដី ដាំបន្លែបង្កាបន្តិចបន្តួចនៅជុំវិញផ្ទះសម្រាប់លក់ដោះដុំនៅតាមផ្សារ ។ ជីវភាពដែលរស់នៅប្រកបដោយសេចក្តីសុខនិង


លឿង សុភ័ក្ត្រ ឆ្នាំ១៩៩១

សុភមង្គលរបស់គ្រួសារខ្ញុំត្រូវបានបាត់បង់ចាប់តាំងពីពេលដែលកងទ័ពខ្មែរក្រហមកាន់កាប់អំណាចទាំងស្រុងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ថ្ងៃនោះឪពុករបស់ខ្ញុំគាត់បានចេញទៅធ្វើការដូចថ្ងៃធម្មតា ព្រោះមិនដឹងពីហេតុការណ៍មុន ។ ម្តាយរបស់ខ្ញុំគាត់មានអារម្មណ៍មិនស្ងប់ គាត់ភ័យខ្លាចចំពោះស្នូរគ្រាប់កាំភ្លើង និងគ្រាប់ផ្លោងផ្ទុះនៅក្បែរផ្ទះ និងបារម្ភពីសុវត្ថិភាពរបស់ពុកដែលចេញពីផ្ទះបាត់ទៀត ។ មិនយូរប៉ុន្មាន ពុកក៏បានត្រឡប់មកផ្ទះវិញ ហើយក៏ត្រូវពួកទាហានខ្មែរក្រហមប្រាប់ថាឲ្យចាកចេញពីផ្ទះតែរយៈពេល៣ថ្ងៃប៉ុណ្ណោះដើម្បីបោសសម្អាតទីក្រុង ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅស្រុកកំណើតនៅខេត្តតាកែវ ។ ក្រុមគ្រួសាររបស់ខ្ញុំត្រូវបានចាត់ទុកជាប្រជាជនថ្មី«ពួក១៧» បើទោះបីជាគាត់មានស្រុកកំណើតនៅមូលដ្ឋានដែលគាត់ជម្លៀសទៅក៏ដោយ ។ ម៉ែបានយកបងៗរបស់ខ្ញុំទាំង៣នាក់ទៅផ្ញើនឹងផ្ទះយាយដែលជាប្រជាជនមូលដ្ឋាន ។ ចំណែកម៉ែនិងពុកត្រូវបំបែកឲ្យទៅធ្វើការនៅកន្លែងផ្សេងពីគ្នា ។ ពុកត្រូវបានចាត់តាំងឲ្យទៅធ្វើជាងធ្វើខ្ទះនិងឆ្នាំង ។ ដោយឡែកម៉ែត្រូវបញ្ជូនទៅធ្វើស្រែនៅឯងស្រែលើដែលនៅឆ្ងាយពីភូមិ ។ ក្រុមគ្រួសាររបស់ខ្ញុំនៅជំនាន់ខ្មែរក្រហមរស់នៅបែកគ្នាទាំងអស់ ហើយធ្វើការធ្ងន់ៗនិងទទួលបានរបបអាហារមិនគ្រប់គ្រាន់ គឺមានតែបបររាវកក្លុក ហើយមានពេលខ្លះដោយសារតែឃ្លានខ្លាំងពេក បងប្រុសទី២របស់ខ្ញុំដែលស្ថិតនៅក្នុងវ័យ៦-៧ឆ្នាំ ហូបកន្ទក់ដើម្បីបំពែតក្រពះ ។ ម៉ែមានបងប្អូនបង្កើត៤នាក់ គឺស្រី២ ប្រុស២ គាត់ជាកូនច្បងក្នុងគ្រួសារ ។ ម៉ែបានបាត់ប្អូនប្រុស២នាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យម្នាក់ឈ្មោះ លឿង សុខេន បាត់ខ្លួនពេលនៅភ្នំពេញនៅពេលដែលខ្មែរក្រហមចូលកាន់កាប់នៅទីក្រុងភ្នំពេញ គាត់ធ្វើការនៅរាជាយស្ម័យយានកម្ពុជា នៅភ្នំពេញ និងប្អូនម្នាក់ទៀតឈ្មោះ លឿង សុខន បាត់ខ្លួននៅពេលដែលទាហានខ្មែរក្រហមហៅទៅកាប់វល្លិ៍ធ្វើបង្គីនៅក្នុងព្រៃ ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ ម៉ែនៅសល់តែលោកតាលោកយាយនិងប្អូនស្រីពៅម្នាក់ប៉ុណ្ណោះ ។ សំណាងល្អក្រុមគ្រួសាររបស់ខ្ញុំមិនមានបាត់បង់ជីវិតសមាជិកណាមួយឡើយ ។

ចម្ងល់នៃពាក្យថាខ្មែរក្រហមនេះបានស្រាយបំភ្លឺបន្តិចម្តងៗតាមរយៈការរៀបរាប់អំពីប្រវត្តិនៃជីវិតពិតរបស់ពុកម៉ែខ្ញុំ និងតាមរយៈការអានសៀវភៅប្រវត្តិសាស្ត្រ និងឯកសារផ្សេងៗដែលបរិយាយអំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលមានតម្កល់នៅបណ្ណាល័យសិក្សានិងនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លើសពីនេះទៅទៀតខ្ញុំបានស្វែងយល់អំពីខ្មែរក្រហមនេះតាមរយៈការចុះទៅចែកឯកសារនិងជួបសម្ភាសជាមួយអ្នកភូមិដែលមានវ័យចំណាស់ៗដែលធ្លាប់ឆ្លងកាត់នូវបទពិសោធន៍ឈឺចាប់នៅសម័យខ្មែរក្រហម ។

ទោះជាយ៉ាងណាក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយដែលមិនបានឆ្លងកាត់របបនេះក៏ដូចជាយុវជនផ្សេងទៀតសំណូមពរឲ្យបញ្ចូលព្រឹត្តិការណ៍នៅសម័យខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាឲ្យបានលម្អិត ដើម្បីឲ្យអ្នកជំនាន់ក្រោយបានយល់ដឹងពីរបបនោះក្នុងគោលបំណងទប់ស្កាត់ និងអប់រំកុំឲ្យមានអំពើប្រល័យពូជ-សាសន៍កើតមានឡើងម្តងទៀតក្នុងប្រទេសកម្ពុជា ។ អ្វីដែលប្រជាពលរដ្ឋខ្មែរ ក៏ដូចជាឪពុកម្តាយរបស់ខ្ញុំ តែងតែទន្ទឹងរង់ចាំនោះគឺការបង្កើតឲ្យមានតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ដើម្បីនាំយកអ្នកទាំងនោះមកកាត់ទោសរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឪពុកម្តាយខ្ញុំសង្ឃឹមថាតុលាការនេះនឹងប្រព្រឹត្តយ៉ាងយុត្តិធម៌និងប្រកបដោយជោគជ័យ ។

**លឿង សុភ័ក្ត**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# លិខិតពីមិត្តអ្នកអាន

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកនាយកដែលបានចុះផ្សាយអត្ថបទរបស់នាងខ្ញុំនៅក្នុងទំព័រទស្សនាវដ្តី «ស្វែងរកការពិត» លេខ៨១ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានចំណងជើងថា «អ្នកដែលឃ្លាតឆ្ងាយ» ។

ក្រោយពេលនាងខ្ញុំបានឃើញជីវប្រវត្តិរបស់លោកឪពុក និងក្រុមគ្រួសារខ្ញុំចុះផ្សាយនៅលើទស្សនាវដ្តី នាងខ្ញុំត្រេកអរជាខ្លាំង អានហើយអានទៀត ដោយក្តីរីករាយលាយឡំនិងការឈឺចាប់នឹងអតីតកាលដែលជីវិតរស់នៅក្នុងរបបខ្មែរក្រហមគ្រប់គ្រងដោយ ប៉ុល ពត, អៀង សារី, ខៀវ សំផន បានផ្តាច់ជីវិតមនុស្សរាប់លាននាក់យ៉ាងព្រៃផ្សៃជាទីបំផុត ។

ក្នុងនាមនាងខ្ញុំជាអ្នកព្យាយាមអានទស្សនាវដ្តី«ស្វែងរកការពិត»ជារៀងរហូតមក នាងខ្ញុំសំណូមពរសុំឲ្យមជ្ឈមណ្ឌលជួយជម្រុញឲ្យតុលាការវិសាមញ្ញដែលសព្វថ្ងៃកំពុងធ្វើការស៊ើបអង្កេតរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមដែលបានកាប់សម្លាប់មនុស្សក្នុងអំឡុងពេលដែលពួកគេកាន់អំណាចនោះគឺជារឿងពិតៗ សូមលោកជួយជម្រុញឲ្យការស៊ើបអង្កេតនេះមានដំណើរការឆាប់រហ័សបំផុត ពីព្រោះប្រជាជនខ្មែរទាំងអស់ចង់ឃើញថ្ងៃចុងក្រោយនៃការសម្រេចរបស់តុលាការ ថាតើឧក្រិដ្ឋជនត្រូវទទួលទោសបែបណា! ហើយអ្នករងគ្រោះត្រូវទទួលយុត្តិធម៌ដែរឬទេ?

នាងខ្ញុំសូមជូនពរលោកនាយក និងសហការី សុំឲ្យដំណើរការបានជោគជ័យនិងប្រកបដោយសេចក្តីសុខជានិច្ចកាល ។

**កៀនស្វាយ ថ្ងៃទី២៥ ខែ១២ ឆ្នាំ២០០៦**

**ពុធ ធាវី**

# ដំណឹងសួររកបងស្រី និងបងថ្លៃ

នាងខ្ញុំ យូ សៀមអេង ភេទស្រី អាយុ៥៤ឆ្នាំ ពីមុនរស់នៅភូមិខ្សា ឃុំដា ស្រុកក្រចេះ ខេត្តក្រចេះ បច្ចុប្បន្នរស់នៅភូមិខាងជើងស៊ឹង ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ ឪពុកឈ្មោះ យូ ប៉េងស៊ា និងម្តាយឈ្មោះ វ៉ាន់ សាវុន សូមសួររកបងស្រីឈ្មោះ យូ សៀមចេង និងបងថ្លៃ ជឹង ហាំងវេង ។ មុនឆ្នាំ១៩៧៥ បងស្រីនិងបងថ្លៃរស់នៅទីក្រុងភ្នំពេញ អ្នកទាំងពីរត្រូវអង្គការជម្លៀសទៅខេត្តបាត់ដំបង ។ ក្រោយមកឮដំណឹងថាបងថ្លៃស្លាប់ នៅរស់តែបងស្រីនិងកូន ។ នៅឆ្នាំ១៩៧៩ បានឮដំណឹងថាបងស្រីរស់នៅទឹកថ្លា ក្រុងភ្នំពេញ ។ ប៉ុន្តែចាប់តាំងពីនោះមក នាងខ្ញុំពុំដែលបានទទួលដំណឹងពីគាត់ទៀតឡើយ ។

ដូច្នេះបើបងស្រី ឬបងប្អូនបានស្គាល់ឈ្មោះខាងលើនេះ សូមជួយទាក់ទងមកតាមអាសយដ្ឋានខាងលើកុំបីខាន ។ សូមអរគុណ ។

# ដំណឹងសួររកបងស្រី និងបងប្រុស

នាងខ្ញុំឈ្មោះ ឈុន រុំ អាយុ៥៣ឆ្នាំ រស់នៅភូមិមមាញ ឃុំរលួស ស្រុកប្រាសាទបាគង ខេត្តសៀមរាប មានបងប្អូន៥នាក់ ។ ឪពុកឈ្មោះ ឈុន ផម និងម្តាយឈ្មោះ ឃុន រឿន ។ នាងខ្ញុំសូមសួររក ៖ ១) បងស្រី ឈុន រ៉ែន និងប្តី (ជាប្អូនបង្កើតរបស់អ្នកចម្រៀងឈ្មោះ មាស សាម៉ែន) ជាអតីតទាហានអាម៉ារីនមុនឆ្នាំ១៩៧៥ អ្នកទាំងពីររស់នៅទីក្រុងភ្នំពេញ ហើយបាត់ដំណឹងតាំងពីពេលអង្គការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ២) បងប្រុស ឈុន រៀន ដែលបានចេញទៅបម្រើកងទ័ពរំដោះនៅឆ្នាំ១៩៧២ ហើយក៏បាត់ដំណឹងរហូត ។ មុនឡើងរថយន្តចាកចេញពីភូមិជាមួយយុទ្ធជនដទៃទៀត រៀនបានផ្ញើសំបុត្រមួយច្បាប់ប្រាប់ក្រុមគ្រួសារថាខ្លួនចាកចេញពីភូមិហើយ ហើយឲ្យក្រុមគ្រួសារទៅយកកង់របស់ខ្លួនពីកន្លែងហ្វឹកហាត់នៅជិតមន្ទីរឃុំ ។

ដូច្នេះបើបងប្រុសនិងបងស្រីបានឮឬបានអានសេចក្តីប្រកាសនេះសូមរកប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។



រូបថតក្រុមគ្រួសារ លឿង សូភ័ក្ត្រ ថតនៅឆ្នាំ១៩៨១

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 85, January 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.